9.	កាលណាវាគ្មានលុយវាចេះតែខ្ចីខ្ញុំ។	When he doesn't have money he always borrows from me.
10.	កាលណាវាមិនឃើញខ្ញុំវាចេះតែយំ។	When he doesn't see me he always cries.
11.	កាលណាវានឹកខ្ញុំវាចេះតែរកខ្ញុំ។	When he misses me he always looks for me.
12.	កាលណាខ្ញុំបាត់ដំណឹងខ្ញុំចេះតែព្រួយ។	When he doesn't get any news he always gets sad.
13.	កាលណាកូនសិស្សរៀនមិនកើតគេចេះតែថាគ្រូ។	When the students can't study they always blame the teacher.
14.	កាលណាកូនសិស្សរៀនមិនចាប់ គេចេះតែថាពិបាកណាស់។	When the students don't catch on they always say it's difficult.
15.	កាលណាកូនសិស្សខ្ជិលគេចេះតែថា	When the students are lazy they

គ្រូមិនល្អ ។	always say the teacher is not good.
16. កាលណាគេមិនទៅពេទ្យ គេចេះតែថាឈឺ ។	When he doesn't go to the doctor he always says he's sick.

Drill C. Substitution

1. យើងត្រូវតែប្រយ័ត្នកាលណាមូសខាំ ។	We have to be careful when a mosquito bites.
2. យើងត្រូវតែប្រយ័ត្នកាលណាបើកឡាន ។	We have to be careful when we drive the car.
3. យើងត្រូវតែប្រយ័ត្នកាលណាឆ្លងថ្នល់ ។	We have to be careful when we cross the street.
4. យើងត្រូវតែប្រយ័ត្នកាលណាកើតគ្រុនញាក់ ។	We have to be careful when we have a fever.
5. យើងត្រូវតែប្រយ័ត្នកាលណាជិះកង់ ។	We have to be careful when we ride a bicycle.
6. យើងត្រូវតែប្រយ័ត្នកាលណាជិះទូក ។	We have to be careful when we ride in a boat.
7. យើងត្រូវតែប្រយ័ត្នកាលណាក្អកច្រើន ។	We have to be careful when we cough a lot.
8. យើងត្រូវតែប្រយ័ត្នកាលណាមិនស្រួលខ្លួន ។	We have to be careful when we are not well.

Drill D. Response

MODEL: គ្រូ: លោកត្រូវការថ្នាំអ្វី? (អាស្ពីរីន ១ ដប)	Teacher: What kind of medicine do you need? (a bottle of aspirin)
សិស្ស: ខ្ញុំត្រូវការអាស្ពីរីន ១ ដប ។	Student: I need a bottle of aspirin.
1. គាត់ត្រូវការលុយប៉ុន្មាន? (បីពាន់)	គាត់ត្រូវការលុយបីពាន់ ។
2. គាត់ត្រូវការសៀវភៅណា? (គណិតវិទ្យា)	គាត់ត្រូវការសៀវភៅគណិតវិទ្យា ។
3. លោកត្រូវការយកឡានទៅណា? (ទៅរៀនភាសា)	ខ្ញុំត្រូវការយកឡានទៅរៀនភាសា ។
4. លោកត្រូវការទៅធ្វើអីនៅទីនោះ? (ជួបបងខ្ញុំ)	ខ្ញុំត្រូវការទៅជួបបងខ្ញុំនៅទីនោះ ។
5. លោកត្រូវការនៅទីនេះប៉ុន្មានថ្ងៃទៀត? (ពីរបីថ្ងៃ)	ខ្ញុំត្រូវការនៅទីនេះពីរបីថ្ងៃទៀត ។
6. គេត្រូវការធ្វើអីទៀតនៅក្រុងនោះ? (សង់មន្ទីរពេទ្យ ១ ទៀត)	គេត្រូវការសង់មន្ទីរពេទ្យមួយទៀតនៅក្រុងនោះ ។

7.	លោកត្រូវការផ្ញើអីទៅជាមួយខ្ញុំ? (សំបុត្រមួយនិងកញ្ចប់មួយ)	ខ្ញុំត្រូវការផ្ញើសំបុត្រ១និងកញ្ចប់១ទៅជាមួយលោក។

Drill E. Response

MODEL: គ្រូ: លោកត្រូវការទិញអី? (អាស្ពីរីនពីរដប) — Teacher: What do you need to buy? (two bottles of aspirin)

សិស្ស: ខ្ញុំត្រូវការទិញអាស្ពីរីន២ដប។ — Student: I need to buy two bottles of aspirin.

1.	លោកត្រូវការលក់អី? (សៀវភៅប្រវត្តិសាស្ត្រ)	ខ្ញុំត្រូវការលក់សៀវភៅប្រវត្តិសាស្ត្រ។
2.	លោកត្រូវការជួបអ្នកណា? (បងលោក)	ខ្ញុំត្រូវការជួបបងលោក។
3.	លោកត្រូវការសរសេរប៉ុន្មានសន្លឹកទៀត? (ពីរបី)	ខ្ញុំត្រូវការសរសេរពីរបីសន្លឹកទៀត។
4.	លោកត្រូវការទៅសៀមរាបប៉ុន្មានថ្ងៃ? (ពីរ)	ខ្ញុំត្រូវការទៅសៀមរាបពីរថ្ងៃ។
5.	លោកត្រូវការមើលអី? (សាលារៀន១)	ខ្ញុំត្រូវការមើលសាលារៀនមួយ។
6.	លោកត្រូវការរៀនប៉ុន្មានឆ្នាំទៀត។ (មួយ)	ខ្ញុំត្រូវការរៀន១ឆ្នាំទៀត។
7.	លោកត្រូវការយកអីទៅជាមួយ? (សៀវភៅខ្លួន)	ខ្ញុំត្រូវការយកសៀវភៅខ្លួនទៅជាមួយ។

Drill F. Expansion

1.	គេអាចទៅ។	They can go.
2.	គេអាចទៅមន្ទីរពេទ្យថ្មី។	They can go to the new hospital.
3.	គេអាចទៅមន្ទីរពេទ្យថ្មីរាជការ។	They can go to the new government hospital.
4.	គេអាចទៅមន្ទីរពេទ្យថ្មីរាជការនៅតាខ្មៅ។	They can go to the new government hospital in Takhmau.
5.	គេអាចទៅមន្ទីរពេទ្យថ្មីរាជការនៅតាខ្មៅបានដោយងាយ។	They can go to the new government hospital in Takhmau easily.

Drill G. Reduction

1.	គេអាចទៅមន្ទីរពេទ្យថ្មីរាជការនៅតាខ្មៅបានដោយងាយ ។	They can go to the new government hospital in Takhmau easily.
2.	គេអាចទៅមន្ទីរពេទ្យថ្មីរាជការនៅតាខ្មៅ ។	They can go to the new government hospital in Takhmau.
3.	គេអាចទៅមន្ទីរពេទ្យថ្មីរាជការ ។	They can go to the new government hospital.
4.	គេអាចទៅមន្ទីរពេទ្យថ្មី ។	They can go to the new hospital.
5.	គេអាចទៅ ។	They can go.

Drill H. Multiple Substitution

1.	បើខ្ញុំគ្រាន់តែឈឺបន្តិចបន្តួច ខ្ញុំមិនព្រួយទេ ។	If I'm only sick a little bit, I don't worry.
2.	បើគាត់គ្រាន់តែផ្ដាសាយបន្តិចបន្តួច គាត់មិនព្រួយទេ ។	If he's got a slight cold he doesn't worry.
3.	បើកូនគាត់គ្រាន់តែផ្ដាសាយបន្តិចបន្តួច គ្រូមិនព្រួយទេ ។	If his son has a slight cold the teacher doesn't worry.
4.	បើវាគ្រាន់តែខូចបន្តិចបន្តួច ខ្ញុំមិនព្រួយទេ ។	If it's broken a little bit I don't worry.
5.	បើគាត់គ្រាន់តែគ្រុនបន្តិចបន្តួច ខ្ញុំមិនព្រួយទេ ។	If he has a slight fever he doesn't worry.
6.	បើវាគ្រាន់តែលួចបន្តិចបន្តួច ខ្ញុំមិនព្រួយទេ ។	If he steals a little bit I don't worry.
7.	បើគេគ្រាន់តែខុសបន្តិចបន្តួច ខ្ញុំមិនព្រួយទេ ។	If they're slightly mistaken I don't worry.
8.	បើវាគ្រាន់តែបែកបន្តិចបន្តួច ខ្ញុំមិនព្រួយទេ ។	If it's broken a little bit I don't worry.

UNIT 53

BASIC DIALOGUE

1.	មានស្គាល់គ្រូពេទ្យណានៅក្រុងនេះទេ?	Sok	Do you know a doctor in this town?
2.	ស្គាល់ច្រើនណាស់ ប៉ុន្តែមិនមើលជំងឺដូចគ្នាទេ ។	Pon	I know a lot of them, but they don't all treat the same diseases.
3.	ចង់ទៅពេទ្យណាដែលពូកែខាងមើលច្រមុះ ។	Sok	I want to go to a doctor who specializes in treating noses.
4.	កើតឫស ដុំឬសាច់(អ្វី) ?	Pon	Do you have a tumor?
5.	ប្រហែលហើយ ព្រោះចេះតែឈឺច្រមុះ ។	Sok	Maybe, because my nose is always sore.
6.	បើអញ្ចឹងមិនបាច់ទៅរកឯណាឆ្ងាយទេ ។ ទៅជួបគ្រូពេទ្យខ្ញុំទៅ ។	Pon	In that case you won't have to look far. Go see my doctor.
7.	កើតជំងឺនេះដែរ ?	Sok	Did you have this trouble too?
8.	គ្រូពេទ្យខ្ញុំកំពុងតែមើលជំងឺខ្ញុំ សព្វថ្ងៃនេះ ។	Pon	My doctor is treating me these days (for that, also).
9.	គ្រូពេទ្យនោះមើលជំងឺនោះប៉ុន្មានខែហើយ ?	Sok	How many months has this doctor been treating your illness?

10.	ប្រហែលពីរបីខែប៉ុណ្ណោះទេ។	Pon	Oh, maybe two or three months, that's all.
11.	គ្រូពេទ្យឲ្យថ្នាំអ្វីខ្លះ?	Sok	What kind of medicine does he give?
12.	គាត់ចាក់ថ្នាំឲ្យមួយម្ជុល ហើយឲ្យថ្នាំខ្លះលេបរាល់ពីរអាទិត្យ។	Pon	He gives me a shot and some medicine every two weeks.
13.	១ថ្ងៃលេប ប៉ុន្មានគ្រាប់?	Sok	How many pills do you take a day?
14.	៦គ្រាប់១ថ្ងៃ ពីរគ្រាប់ម្ដង ក្រោយពេលបាយ។	Pon	Six pills a day. Two pills after each meal.
15.	ឥឡូវនេះគ្រាន់បើហើយឬនៅ?	Sok	Are you getting better now?
16.	ឥឡូវនេះ គ្រាន់បើច្រើនហើយ។ ប៉ុន្តែក្នុងពេលពីរបីអាទិត្យដំបូងខ្ញុំ អស់កម្លាំងណាស់។	Pon	I'm much better now. But during the first two or three weeks I was very tired.
17.	ម៉េចចឹង!	Sok	How come?
18.	មិនដឹងទេដែរ តែមុនដំបូងគ្រូពេទ្យ ចាក់ថ្នាំឲ្យខ្ញុំ ហើយឲ្យថ្នាំលេបច្រើន គ្រាប់។	Pon	I don't know, but at first the doctor gave me shots and he had me take a lot of pills.
19.	ហើយឲ្យសំរាកនៅផ្ទះ ។		And he had me stay and rest at home.
20.	ហាមមិនឲ្យធ្វើការធ្ងន់ទាំងអស់។		He forbade me to do any heavy work.

DRILLS

Drill A. Substitution

1.	លោកមានស្គាល់គ្រូពេទ្យច្រមុះណានៅជិតនេះទេ?	Do you know any nose doctor near here?
2.	លោកមានស្គាល់លោកសង្ឃណានៅជិតនេះទេ?	Do you know any monk near here?
3.	លោកមានស្គាល់អភិបាលខេត្តណានៅជិតនេះទេ?	Do you know any province chief near here?
4.	លោកមានស្គាល់អាវុកាណានៅជិតនេះទេ?	Do you know any lawyer near here?
5.	លោកមានស្គាល់ហាងបាយខ្មែរណានៅជិតនេះទេ?	Do you know any Cambodian restaurant near here?
6.	លោកមានស្គាល់ផ្ទះលក់គុយទាវណានៅជិតនេះទេ?	Do you know any noodle shop near here?
7.	លោកមានស្គាល់ផ្ទះធ្វើស្បែកជើងណានៅជិតនេះទេ?	Do you know any shoe shop near here?
8.	លោកមានស្គាល់ផ្ទះកាត់ដេរអាវណានៅជិតនេះទេ?	Do you know any tailor shop near near here?
9.	លោកមានស្គាល់ហាងជាងឡានណានៅជិតនេះទេ?	Do you know any car repair shop near here?
10.	លោកមានស្គាល់កន្លែងលក់សាំងណានៅជិតនេះទេ?	Do you know any gas station near here?
11.	លោកមានស្គាល់កន្លែងពិកនិកណានៅជិតនេះទេ?	Do you know any picnic spot near here?
12.	លោកមានស្គាល់រោងកុនណានៅជិតនេះទេ?	Do you know any movie house near here?
13.	លោកមានស្គាល់រោងល្ខោនណានៅជិតនេះទេ?	Do you know any theatre near here?
14.	លោកមានស្គាល់ឱសថស្ថានណានៅជិតនេះទេ?	Do you know any pharmacy near here?
15.	លោកមានស្គាល់ជាងដែកណានៅជិតនេះទេ?	Do you know any blacksmith near here?
16.	លោកមានស្គាល់សួនច្បារណានៅជិតនេះទេ?	Do you know any public gardens near here?

Drill B. Substitution

1.	ឥឡូវលោកកើតឫសដូងច្រមុះឬអី?	Do you have a nose tumor now?
2.	ឥឡូវលោកកើតអុតឬអី?	Do you have measles now?
3.	ឥឡូវលោកកើតរមាស់ឬអី?	Do you have itching now?
4.	ឥឡូវលោកលេបថ្នាំឬអី?	Are you taking medicine (pill) now?
5.	ឥឡូវលោកផឹកថ្នាំឬអី?	Are you taking medicine (liquid) now?
6.	ឥឡូវលោកទៅពេទ្យឬអី?	Are you going to the doctor now?
7.	ឥឡូវលោកទៅសម្រាន្តឬអី?	Are you going to bed now?
8.	ឥឡូវលោកស្រួលបួលហើយឬនៅ?	Are you better now?

Drill C. Response

MODEL: គ្រូ: ឥឡូវលោកកើតឫសដូងច្រមុះឬអី? (តឹងច្រមុះ)

សិស្ស: បាទទេ ខ្ញុំអត់កើតឫសដូងច្រមុះទេ ខ្ញុំគ្រាន់តែតឹងច្រមុះទេបាទ

Teacher: Do you have a nose tumor? (stuffy nose)

Student: No, I don't have a nose tumor, I only have a stuffy nose.

1.	ឥឡូវលោកកើតឫសដូងច្រមុះឬអី? (ក្តៅខ្លួន)	បាទទេ ខ្ញុំអត់កើតឫសដូងច្រមុះទេ ខ្ញុំគ្រាន់តែក្តៅខ្លួនទេ។
2.	ឥឡូវលោកកើតរមាស់ឬអី? ([illegible])	បាទទេ ខ្ញុំអត់កើតរមាស់ទេ ខ្ញុំគ្រាន់តែ[illegible]ទេ។
3.	ឥឡូវលោកលេបថ្នាំឬអី? ([illegible])	បាទទេ ខ្ញុំអត់លេបថ្នាំទេ ខ្ញុំគ្រាន់តែ[illegible]ទេ។
4.	ឥឡូវលោកផឹកថ្នាំឬអី? ([illegible])	បាទទេ ខ្ញុំអត់ផឹកថ្នាំទេ ខ្ញុំគ្រាន់តែ[illegible]ទេ។
5.	ឥឡូវលោកទៅពេទ្យឬអី? ([illegible])	បាទទេ ខ្ញុំអត់ទៅពេទ្យទេ ខ្ញុំគ្រាន់តែ[illegible]ទេ។
6.	ឥឡូវលោកទៅសម្រាន្តឬអី? ([illegible])	បាទទេ ខ្ញុំអត់ទៅសម្រាន្តទេ ខ្ញុំគ្រាន់តែ[illegible]ទេ។
7.	ឥឡូវលោកស្រួលបួលហើយឬនៅ? ([illegible])	បាទទេ ខ្ញុំអត់ទាន់ស្រួលបួលទេ [illegible]ទេ។

Drill D. Multiple Substitution

1.	មុនដំបូងគ្រូពេទ្យចាក់ថ្នាំឲ្យ រួចគាត់ឲ្យដេក ។	First of all, the doctor gave him a shot, and then had him lie down.
2.	បន្ទាប់មកគ្រូពេទ្យចាក់ថ្នាំឲ្យ រួចគាត់ឲ្យអង្គុយ ។	Next the doctor gave him a shot, and then had him sit down.
3.	ក្រោយមកគ្រូពេទ្យចាក់ថ្នាំឲ្យ រួចគាត់ឲ្យទៅផ្ទះ ។	Afterwards the doctor gave him a shot, and then had him go home.
4.	ម្សិលមិញគ្រូពេទ្យចាក់ថ្នាំឲ្យ រួចគាត់ឲ្យលេបអាស្ពីរីន ។	Yesterday the doctor gave him a shot, and then had him take aspirin.
5.	ថ្ងៃមុនគ្រូពេទ្យចាក់ថ្នាំឲ្យ រួចគាត់ឲ្យផឹកថ្នាំ ។	Previously the doctor gave him a shot, and then had him take medicine (liquid).
6.	ថ្ងៃស្អែកគ្រូពេទ្យចាក់ថ្នាំឲ្យ រួចគាត់ឲ្យផឹកថ្នាំ [illegible] ។	Tomorrow the doctor will give him a shot and then have him take medicine (liquid).
7.	ថ្ងៃនេះគ្រូពេទ្យចាក់ថ្នាំឲ្យ រួចគាត់ឲ្យលេបថ្នាំ ។	Today the doctor will give him a shot and then have him take medicine (pill).
8.	មុននេះគ្រូពេទ្យចាក់ថ្នាំឲ្យ រួចគាត់ឲ្យមកវិញ គាត់មួយអាទិត្យទៀត ។	Before this the doctor gave him a shot and then had him come back in a week.

Drill E. Response

MODEL:	គ្រូ: លោកស្គាល់គ្រូពេទ្យច្រមុះណាទេ? (ម្នាក់)	Teacher: Do you know any nose doctors? (one)
	សិស្ស: បាទ ខ្ញុំស្គាល់ម្នាក់នៅជិតនេះ ។	Student: Yes, I know one near here.

1.	លោកស្គាល់លោកសង្ឃណាទេ? (ពីរអង្គ)	បាទ ខ្ញុំស្គាល់ពីរអង្គនៅជិតនេះ ។
2.	លោកស្គាល់ទេវិកាណាទេ? (ពីរបីនាក់)	បាទ ខ្ញុំស្គាល់ពីរបីនាក់នៅជិតនេះ ។
3.	លោកស្គាល់ហាងបាយចិនណាទេ? (មួយឈ្មោះ បាសាក់)	បាទ ខ្ញុំស្គាល់មួយឈ្មោះ បាសាក់នៅជិតនេះ ។
4.	លោកស្គាល់ផ្ទះលក់គុយទាវណាទេ? (១ ល្អ ឈ្មោះ វត្តភ្នំ)	បាទ ខ្ញុំស្គាល់មួយល្អ ឈ្មោះ វត្តភ្នំនៅជិតនេះ ។
5.	លោកស្គាល់កន្លែងផ្ញើឡានណាទេ?	បាទ ខ្ញុំស្គាល់មួយនៅក្បែរវិស្គុលជួប

	(មួយនៅថ្នល់អង្គឌួង)	នៅជិតនេះ ។
6.	លោកស្គាល់ហាងម៉ាស៊ីណាទេ? (ច្រើន)	បាទ ខ្ញុំស្គាល់ហាងម៉ាស៊ីច្រើននៅជិតនេះ ។
7.	លោកស្គាល់រោងឯស្ទូនណាទេ? (មួយនៅក្បែរផ្សារស្នួន)	បាទ ខ្ញុំស្គាល់មួយនៅក្បែរផ្សារស្នួន នៅជិតនេះ ។
8.	លោកស្គាល់កន្លែងលក់សាំងណាទេ? (ពិស្ហលនៅកាច់ជ្រុង)	បាទ ខ្ញុំស្គាល់ពិស្ហលនៅកាច់ជ្រុងនៅជិតនេះ ។
9.	លោកស្គាល់កន្លែងផិតនិតណាទេ? (មួយ)	បាទ ខ្ញុំស្គាល់មួយ នៅជិតនេះ ។

Drill F. Transformation

MODEL: គ្រូ: រាល់ថ្ងៃគាត់ធ្វើការធ្ងន់ ។ — Teacher: Every day he works hard.

សិស្ស: រាល់ថ្ងៃគាត់មិនហ៊ានធ្វើការធ្ងន់ទេ ។ — Student: Every day he doesn't dare work hard.

1.	រាល់ថ្ងៃខ្ញុំបើកឡានច្រើន ។	រាល់ថ្ងៃខ្ញុំមិនហ៊ានបើកឡានច្រើនទេ ។
2.	រាល់ថ្ងៃ គាត់សំរាក យូរ ។	រាល់ថ្ងៃ គាត់មិនហ៊ានសំរាកយូរទេ ។
3.	រាល់ថ្ងៃវាទៅជួបនឹងគ្រូពេទ្យ ។	រាល់ថ្ងៃវាមិនហ៊ានទៅជួបនឹងគ្រូពេទ្យទេ ។
4.	រាល់ថ្ងៃគ្រូពេទ្យចាក់ថ្នាំឲ្យវា	រាល់ថ្ងៃគ្រូពេទ្យមិនហ៊ានចាក់ថ្នាំឲ្យវាទេ ។
5.	រាល់ថ្ងៃគាត់ត្រូវលេបអាស្ពីរីនមួយគ្រាប់ ។	រាល់ថ្ងៃគាត់មិនហ៊ានលេបអាស្ពីរីនមួយគ្រាប់ទេ ។
6.	រាល់ថ្ងៃវាដេក នៅក្រៅផ្ទះ ។	រាល់ថ្ងៃវាមិនហ៊ានដេកនៅក្រៅផ្ទះទេ ។
7.	រាល់ថ្ងៃវាត្រូវទៅជួបគ្រូវា ។	រាល់ថ្ងៃវាមិនហ៊ានទៅជួបគ្រូវាទេ ។
8.	រាល់ថ្ងៃក្មួយលោកសុនឈប់រៀនហើយ ។	រាល់ថ្ងៃក្មួយលោកសុនមិនហ៊ានឈប់រៀនទេ ។

Drill G. Expansion

1.	ខ្ញុំស្គាល់ ។	I know.
2.	ខ្ញុំស្គាល់មួយអង្គ ។	I know one.

3.	ខ្ញុំស្គាល់លោកសង្ឃមួយអង្គ។	I know one monk.
4.	ខ្ញុំស្គាល់លោកសង្ឃមួយអង្គនៅសាលាបាលី។	I know one monk at the Pali School.
5.	ខ្ញុំស្គាល់លោកសង្ឃមួយអង្គកំពុងរៀននៅសាលាបាលី។	I know one monk studying at the Pali School.
6.	ខ្ញុំស្គាល់លោកសង្ឃមួយអង្គកំពុងរៀនអង់គ្លេសនៅសាលាបាលី។	I know one monk studying English at the Pali School.

Jrill H. Reduction

1.	ខ្ញុំស្គាល់លោកសង្ឃមួយអង្គកំពុងរៀនភាសាអង់គ្លេសនៅសាលាបាលី។	I know one monk studying English at the Pali School.
2.	ខ្ញុំស្គាល់លោកសង្ឃមួយអង្គកំពុងរៀននៅសាលាបាលី។	I know one monk studying at the Pali School.
3.	ខ្ញុំស្គាល់លោកសង្ឃមួយអង្គនៅសាលាបាលី។	I know one monk at the Pali School.
4.	ខ្ញុំស្គាល់លោកសង្ឃមួយអង្គ។	I know one monk.
5.	ខ្ញុំស្គាល់មួយអង្គ។	I know one.
6.	ខ្ញុំស្គាល់។	I know.

Drill I. Response

MODEL: គ្រូ: លោកដឹងទេ ក្រុងនេះមានគ្រូពេទ្យប៉ុន្មាននាក់? (៦,៧)
សិស្ស: បាទ ខ្ញុំដឹងមិនប្រាកដទេ តែខ្ញុំស្មានប្រហែល ៦, ៧នាក់។

Teacher: Do you know how many doctors there are in this town? (6 or 7)

Student: I don't know for sure, but I think about 6 or 7.

1.	លោកដឹងទេបន្ទប់នេះមានកូនសិស្សប៉ុន្មាននាក់។ (៨)	បាទ ខ្ញុំដឹងមិនប្រាកដទេ តែខ្ញុំស្មានប្រហែល ៨នាក់។
2.	លោកដឹងទេ លោកត្រូវលេបថ្នាំនេះប៉ុន្មានគ្រាប់ក្នុងមួយថ្ងៃ។ (១គ្រាប់)	បាទ ខ្ញុំដឹងមិនប្រាកដទេ តែខ្ញុំស្មានប្រហែល១គ្រាប់១ថ្ងៃ។
3.	លោកដឹងទេ លោកគ្រូពេទ្យមកដាក់ថ្នាំឲ្យលោកម៉ោងប៉ុន្មាន។ (២ រសៀល)	បាទ ខ្ញុំដឹងមិនប្រាកដទេ តែខ្ញុំស្មានប្រហែលម៉ោងពីររសៀល។
4.	លោកដឹងទេ ហ្វាម៉ាស៊ីបើកម៉ោង	បាទ ខ្ញុំដឹងមិនប្រាកដទេ តែខ្ញុំស្មានប្រ

	ប៉ុន្មាន? (ម៉ោង៨,៣០ព្រឹក)	ហែលម៉ោង៨,៣០ព្រឹក។
5.	លោកដឹងទេ គាត់អញ្ជើញមកដល់ ថ្ងៃណា? (ស្អែក)	បាទ ខ្ញុំដឹងមិនច្បាស់ទេ តែខ្ញុំស្មានប្រ ហែលស្អែក។
6.	លោកដឹងទេ គាត់ឈឺអី? (ឈឺពោះ)	បាទ ខ្ញុំដឹងមិនច្បាស់ទេ តែខ្ញុំស្មាន ប្រហែលឈឺពោះ។
7.	លោកដឹងទេ គ្រូពេទ្យឲ្យលោកធ្វើ ការធ្ងន់បានទេ? (ខ្ញុំធ្វើបាន)	បាទ ខ្ញុំដឹងមិនច្បាស់ទេ តែខ្ញុំស្មានប្រ ហែលខ្ញុំធ្វើបាន។
8.	លោកដឹងទេ ថ្នាំនេះ១ម្ជុលថ្លៃ ប៉ុន្មាន? (ថ្លៃម្ភៃរៀល)	បាទ ខ្ញុំដឹងមិនច្បាស់ទេ តែខ្ញុំស្មាន ប្រហែលថ្លៃម្ភៃរៀល។

Drill J. Response

MODEL: គ្រូ: លោកដឹងទេ ក្រុងនេះមាន គ្រូពេទ្យប៉ុន្មាននាក់?

សិស្ស: បាទ ខ្ញុំមិនដឹងជាមាន ប៉ុន្មាននាក់ទេ។

Teacher: Do you know how many doctors there are in this town?

Student: I don't know how many there are.

1.	លោកដឹងទេ បន្ទប់នេះមានកូន សិស្សប៉ុន្មាននាក់?	បាទ ខ្ញុំមិនដឹងជាប៉ុន្មាននាក់ទេ។
2.	លោកដឹងទេ លោកត្រូវលេប ថ្នាំនេះប៉ុន្មានគ្រាប់ក្នុង១ថ្ងៃ?	បាទ ខ្ញុំមិនដឹងជាប៉ុន្មានគ្រាប់ទេ។
3.	លោកដឹងទេ លោកគ្រូពេទ្យមក ដាក់ថ្នាំឲ្យម៉ោងប៉ុន្មាន?	បាទ ខ្ញុំមិនដឹងជាម៉ោងប៉ុន្មានទេ។
4.	លោកដឹងទេ ហ្វាម៉ាស៊ីបើកម៉ោង ប៉ុន្មាន?	បាទ ខ្ញុំមិនដឹងជាម៉ោងប៉ុន្មានទេ។
5.	លោកដឹងទេ គាត់អញ្ជើញមក ដល់ម៉ោងប៉ុន្មាន?	បាទ ខ្ញុំមិនដឹងជាម៉ោងប៉ុន្មានទេ។
6.	លោកដឹងទេ គាត់ឈឺអី?	បាទ ខ្ញុំមិនដឹងជាគាត់ឈឺអីទេ។
7.	លោកដឹងទេ គ្រូពេទ្យឲ្យលោក ធ្វើការធ្ងន់បានទេ?	បាទ ខ្ញុំមិនដឹងជាបានឬមិនបានទេ។
8.	លោកដឹងទេ ថ្នាំនេះ១ម្ជុល ថ្លៃប៉ុន្មាន?	បាទ ខ្ញុំមិនដឹងជាថ្លៃប៉ុន្មានទេ។

UNIT 54

BASIC DIALOGUE

1.	គ្រូពេទ្យមានសុំឲ្យទៅដេកពេទ្យទេ?	Sok	Did the doctor ask you to go to the hospital?
2.	អឺ លោកមានប្រសាសន៍ថានៅក្នុងពេទ្យ មានគ្រឿងប្រដាប់ល្អ ។	Pon	Yes. He said that in the hospital they have good equipment.
3.	ហើយមានពេទ្យយ៉ាងប្រសប់សម្រាប់ថែទាំផង ។		And they also have skilled nurses to take care (of you).
4.	ប៉ុន្តែមិនស្មានថាឈឺធ្ងន់ទេ ដូច្នេះបានជាខ្ញុំមិនទៅពេទ្យ ។		But I didn't think I was seriously ill, therefore I didn't go to the hospital,
5.	ម៉េច បានជាដឹងកើតឫស្សដូង?	Sok	How did you know that you had a tumor?
6.	ខ្ញុំចេះតែតឹងច្រមុះក្នុងពេលបួនបីខែមុននេះ ។	Pon	My nose was stuffed up three or four months before.
7.	ហើយចេះតែអស់កម្លាំងមែនទេ?	Sok	And you were always tired, right?
8.	អឺ ហើយមិនបានទៅពេទ្យ ព្រោះស្មានថាជំងឺនោះស្រាល ។	Pon	Yes, and I didn't go to the hospital because I thought the illness was not serious.
9.	គួរទៅជួបនឹងគ្រូពេទ្យខ្ញុំភ្លាមទៅ កុំទុកយូរពេក ។	Sok	You should go see my doctor immediately. Don't put it off too long.

10.	ដឹងហើយ ។ ប៉ុន្តែ ឥឡូវនេះទើប ដកធ្មេញមួយហើយ ។	Pon	I know, but now I've just had a tooth pulled.
11.	ពេទ្យធ្មេញនោះពូកែទេ ?	Sok	Is your dentist good?
12.	អូ គ្រូពេទ្យនោះ ពូកែណាស់ ។	Pon	Oh, that dentist is very good.
13.	មានធ្មេញមួយឈឺ... ខ្ញុំចង់ឲ្យពេទ្យដកដែរ ។	Sok	I have a tooth that hurts. I want the dentist to pull it.
14.	ពេទ្យនោះ ពូកែ ខាងបិទធ្មេញ ដែរ ។	Pon	That doctor is very good at filling teeth.
15.	បើដូច្នេះ... ទៅជួបនឹង គ្រូពេទ្យខ្ញុំទៅ ហើយខ្ញុំទៅជួប នឹងពេទ្យបង ។	Sok	In that case, you go see my doctor, and I'll go see your dentist.

DRILLS

Drill A. Response

MODEL:		
គ្រូ:	គ្រូពេទ្យមានសុំឲ្យលោកអញ្ជើញទៅសំរាន្តពេទ្យទេ?	Teacher: Did the doctor ask you to go to the hospital?
សិស្ស:	បាទទេ គាត់ថាខ្ញុំមិនបាច់ទៅ ទន្ទួលតានដេកនៅពេទ្យទេ។	Student: No, he said I don't have to go to the hospital.

1.	គ្រូពេទ្យមានដាក់ថ្នាំឲ្យលោកទេ?	បាទ គាត់ថាមិនបាច់ដាក់ថ្នាំឲ្យខ្ញុំទេ។
2.	គ្រូពេទ្យឲ្យលោកសំរាកនៅផ្ទះទេ?	បាទ គាត់ថាមិនបាច់សំរាកនៅផ្ទះទេ។
3.	គ្រូពេទ្យឲ្យលោកទៅជួបគាត់ទៀតទេ?	បាទ គាត់ថាខ្ញុំមិនបាច់ទៅជួបគាត់ទៀតទេ។
4.	គ្រូពេទ្យមានឲ្យសំបុត្រទិញថ្នាំទេ?	បាទទេ គាត់ថាមិនបាច់យកសំបុត្រទិញថ្នាំទេ។
5.	គ្រូពេទ្យមានឲ្យថ្នាំយកទៅលេបទេ?	បាទទេ គាត់ថាមិនបាច់យកថ្នាំទៅលេបទេ។

Drill B. Response

MODEL:		
គ្រូ :	ដុកទ័រប្រាប់ឲ្យទៅពេទ្យ។	Teacher: The doctor said to go to the hospital.
សិស្ស:	ដុកទ័រប្រាប់ឲ្យទៅណា?	Student: Where did the doctor say to go?
គ្រូ:	ដុកទ័រប្រាប់ឲ្យទៅដេកពេទ្យ។	Teacher: The doctor said to go to the hospital.

1.	គ្រឿងប្រដាប់នៅក្នុងពេទ្យច្រើនហើយល្អ។	គ្រឿងប្រដាប់នៅក្នុងពេទ្យយ៉ាងម៉េច? គ្រឿងប្រដាប់នៅក្នុងពេទ្យច្រើនហើយល្អ។
2.	នៅក្នុងពេទ្យមានន្ទូបសម្រាប់វិជតាំ។	នៅក្នុងពេទ្យមានន្ទូបសម្រាប់ធ្វើអី? នៅក្នុងពេទ្យមានន្ទូបសម្រាបវិជតាំ។
3.	គាត់មិនស្មានថាគាត់ឈឺធ្ងន់។	គាត់ស្មានយ៉ាងម៉េច? គាត់មិនស្មានថាគាត់ឈឺធ្ងន់។
4.	លោកប៉ុនមិននៅផ្ទះទេថ្ងៃនេះ។	លោកប៉ុននៅផ្ទះទេថ្ងៃនេះ? លោកប៉ុនមិននៅផ្ទះទេថ្ងៃនេះ។
5.	គាត់ទៅពេទ្យពីព្រឹកមិញ។	គាត់ទៅពេទ្យពីអង្កាល់? គាត់ទៅពេទ្យពីព្រឹកមិញ។
6.	គាត់ចេះរិតតឹងច្រើនម្លេះ។	គាត់ចេះរិតយ៉ាងម៉េច?

7. វាត្រូវដកធ្មេញមួយថ្ងៃនេះ ។

8. គេកើតឫសដូងច្រមុះ ។

គាត់ចេះតែហៀរច្រមុះ ។
វាត្រូវធ្វើអ្វីថ្ងៃនេះ?
វាត្រូវដកធ្មេញមួយថ្ងៃនេះ ។
គេកើតអី?
គេកើតឫសដូងច្រមុះ ។

Drill C. Substitution

1. គ្រូពេទ្យថា ខ្ញុំមិនបាច់ឈប់រៀនទេ ។	The doctor said that I don't have to miss school.
2. គ្រូខ្ញុំថា ខ្ញុំមិនបាច់ឈប់រៀនទេ ។	My teacher said that I don't have to miss school.
3. បងខ្ញុំថា ខ្ញុំមិនបាច់ឈប់រៀនទេ ។	My older brother said that I don't have to miss school.
4. គាត់ថាខ្ញុំមិនបាច់ឈប់រៀនទេ ។	He said that I don't have to miss school.
5. កូនសិស្សទាំងអស់ថាខ្ញុំមិនបាច់ឈប់រៀនទេ ។	All the students said that I don't have to miss school.
6. គេយល់ថាខ្ញុំមិនបាច់ឈប់រៀនទេ ។	They understand that I don't have to miss school.
7. គេគិតថាខ្ញុំមិនបាច់ឈប់រៀនទេ ។	They think that I don't have to miss school.
8. គាត់ពន្យល់ខ្ញុំថាខ្ញុំមិនបាច់ឈប់រៀនទេ ។	They explained to me that I don't have to miss school.
9. វានិយាយថាខ្ញុំមិនបាច់ឈប់រៀនទេ ។	He says to me that I don't have to miss school.
10. ខ្ញុំផ្តាសាយតែគេថាខ្ញុំមិនបាច់ឈប់រៀនទេ ។	I have a cold but they say that I don't have to miss school.
11. ខ្ញុំដើរមិនបានតែគេថាខ្ញុំមិនបាច់ឈប់រៀនទេ ។	I can't walk, but they say that I don't have to miss school.

Drill D. Multiple Substitution

1.	លោកគួរទៅជួបគ្រូពេទ្យភ្លាមទៅ កុំចាំយូរពេក។	You should go see the doctor immediately; don't wait too long.
2.	លោកគួរទៅជួបគ្រូពេទ្យធ្មេញភ្លាមទៅ កុំពុកយូរពេក។	You should go see the dentist immediately; don't delay too long.
3.	លោកគួរទៅជួបលោកគ្រូភ្លាមទៅកុំនៅយូរពេក។	You should go see the teacher immediately; don't stay too long.
4.	លោកគួរទៅជួបបងខ្ញុំភ្លាមទៅ កុំចាំយូរពេក។	You should go see my older brother immediately; don't wait too long.
5.	លោកគួរទៅជួបអ្នកលក់ភ្លាមទៅ កុំនៅយូរពេក។	You should go see the salesman immediately; don't stay too long.
6.	លោកទៅជួបពូភ្លាមទៅ កុំចាំយូរពេក។	You should go see my uncle immediately; don't wait too long.

Drill E. Multiple Substitution

1.	ខ្ញុំដឹងហើយប៉ុន្តែ ឥឡូវខ្ញុំឈឺធ្មេញ។	I know it already, but now I have a toothache.
2.	ខ្ញុំស្តាប់បានហើយប៉ុន្តែឥឡូវខ្ញុំធ្វើមិនបាន។	I heard it already, but now I can not do it.
3.	ខ្ញុំយល់ហើយ ប៉ុន្តែឥឡូវខ្ញុំភ្លេច។	I understood it already, but now I have forgotten.
4.	ខ្ញុំឃើញហើយប៉ុន្តែ ឥឡូវខ្ញុំមិនបានយកមក។	I saw it already, but now I can't bring it.
5.	ខ្ញុំស្គាល់ហើយ ប៉ុន្តែ ខ្ញុំមិនដឹងវាទៅណា។	I know (him) already, but now I don't know where he went.
6.	ខ្ញុំចេះហើយ ប៉ុន្តែ ខ្ញុំគ្មានពេលធ្វើ។	I know how already, but now I don't have the time to do it.
7.	ខ្ញុំទៅម្តងហើយ ប៉ុន្តែ ខ្ញុំភ្លេចកន្លែង។	I went once already, but now I forget the place.
8.	ខ្ញុំទិញម្តងហើយប៉ុន្តែខ្ញុំចង់ទិញទៀត។	I bought some once already, but now I want to buy some more.
9.	ខ្ញុំជួបហើយប៉ុន្តែខ្ញុំចង់សួរគាត់។	I met him already, but now I want to ask him (something).
10.	ខ្ញុំមានហើយប៉ុន្តែខ្ញុំចង់បានទៀត។	I have it already, but now I want to have some more.

Drill F. Response

MODEL:	គ្រូៈ ធ្មេញខ្ញុំចេះតែឈឺ ។ (គ្រូពេទ្យ)	Teacher: My teeth keep aching. (doctor)
	សិស្សៈ លោកមានស្គាល់គ្រូពេទ្យណាពូកែទេ?	Student: Do you know a good doctor?
1.	កូនខ្ញុំចេះតែក្អក ។ (ថ្នាំក្អក)	លោកមានស្គាល់ថ្នាំក្អកណាពូកែទេ?
2.	ឡានខ្ញុំចេះតែខូច ។ (ជាង)	លោកមានស្គាល់ជាងណាពូកែទេ?
3.	លោកស្មិតធ្វើការចេះតែមិនកើត ។ (អ្នកណា)	លោកមានស្គាល់អ្នកណាពូកែទេ?
4.	វាប្រឡងចេះតែធ្លាក់ ។ (កូនសិស្ស)	លោកមានស្គាល់កូនសិស្សណាពូកែទេ?
5.	ខ្ញុំចេះតែចង់រៀនបើកឡាន ។ (គ្រូបង្រៀនបើកឡាន)	លោកមានស្គាល់គ្រូបង្រៀនបើកឡានណាពូកែទេ?
6.	ខ្ញុំចេះតែចង់រៀនសរសេរ ។ (អ្នកបង្ហាត់)	លោកមានស្គាល់អ្នកបង្ហាត់ណាពូកែទេ?

Drill G. Response

MODEL:	គ្រូៈ លោកមានស្គាល់គ្រូពេទ្យណាពូកែទេ?	Teacher: Do you know any good doctors?
	សិស្សៈ ខ្ញុំស្គាល់គ្រូពេទ្យម្នាក់ដែរ លោកអាចទៅជួបគាត់បាន ។	Student: I know one; you can go see him.
1.	លោកមានស្គាល់ជាងធ្វើឡានណាពូកែទេ?	ខ្ញុំស្គាល់ជាងធ្វើឡានម្នាក់ដែរ លោកអាចទៅជួបគាត់បាន ។
2.	លោកមានស្គាល់កូនសិស្សណាពូកែទេ?	ខ្ញុំស្គាល់កូនសិស្សម្នាក់ដែរ លោកអាចទៅជួបវាបាន ។
3.	លោកមានស្គាល់គ្រូបង្រៀនណាពូកែទេ?	ខ្ញុំស្គាល់គ្រូបង្រៀនម្នាក់ដែរ លោកអាចទៅជួបគាត់បាន ។
4.	លោកមានស្គាល់អ្នកបង្ហាត់សិស្សណាពូកែទេ?	ខ្ញុំស្គាល់អ្នកបង្ហាត់សិស្សម្នាក់ដែរ លោកអាចទៅជួបគាត់បាន ។
5.	លោកមានស្គាល់អ្នកបកប្រែណាពូកែទេ?	ខ្ញុំស្គាល់អ្នកបកប្រែម្នាក់ដែរ លោកអាចទៅជួបគាត់បាន ។

6.	លោកមានស្គាល់គ្រូពេទ្យណាម្នាក់ទេ?	ខ្ញុំស្គាល់គ្រូពេទ្យម្នាក់ដែរ លោកអាចទៅជួបគាត់បាន។

Drill H. Expansion

1.	ខ្ញុំឃើញលោក។	I see you.
2.	ខ្ញុំឃើញលោកគ្រូ។	I see the teacher.
3.	ខ្ញុំឃើញលោកគ្រូពេទ្យ។	I see the doctor.
4.	ខ្ញុំឃើញលោកគ្រូពេទ្យធ្មេញ។	I see the dentist.
5.	ខ្ញុំឃើញលោកគ្រូពេទ្យធ្មេញម្សិលមិញ។	I saw the dentist yesterday.
6.	ខ្ញុំឃើញលោកគ្រូពេទ្យធ្មេញ ម្សិលមិញនៅមុខសាលា។	I saw the dentist yesterday in front of the hall.
7.	ខ្ញុំឃើញលោកគ្រូពេទ្យធ្មេញម្សិលមិញនៅមុខសាលារៀន។	I saw the dentist yesterday in front of the school.
8.	ខ្ញុំឃើញលោកគ្រូពេទ្យធ្មេញ ម្សិលមិញ កំពុងដើរនៅមុខសាលារៀន។	I saw the dentist yesterday walking in front of the school.
9.	ខ្ញុំឃើញលោកគ្រូពេទ្យធ្មេញ ម្សិលមិញ កំពុងដើរជាមួយគ្រូបង្រៀន នៅមុខសាលារៀន។	I saw the dentist yesterday walking in front of the school with the teacher.
10.	ខ្ញុំឃើញលោកគ្រូពេទ្យធ្មេញ ម្សិលមិញ កំពុងដើរជាមួយគ្រូបង្រៀនម្នាក់ នៅមុខសាលារៀន។	I saw the dentist yesterday walking in front of the school with a teacher.

Drill I. Reduction

1.	ខ្ញុំឃើញលោកគ្រូពេទ្យធ្មេញម្សិលមិញ កំពុងដើរជាមួយគ្រូបង្រៀនម្នាក់ នៅមុខសាលារៀន។	I saw the dentist yesterday walking in front of the school with a teacher.
2.	ខ្ញុំឃើញលោកគ្រូពេទ្យធ្មេញ ម្សិលមិញ កំពុងដើរជាមួយគ្រូបង្រៀន នៅមុខសាលារៀន។	I saw the dentist yesterday walking in front of the school with the teacher.
3.	ខ្ញុំឃើញលោកគ្រូពេទ្យធ្មេញ ម្សិលមិញ កំពុងដើរនៅមុខសាលារៀន។	I saw the dentist yesterday walking in front of the school.
4.	ខ្ញុំឃើញលោកគ្រូពេទ្យធ្មេញ ម្សិញ	I saw the dentist yesterday in front

	នៅមុខសាលារៀន ។	of the school.
5.	ខ្ញុំឃើញលោកគ្រូពេទ្យធ្មេញ ម្សិលមិញ នៅមុខសាលា ។	I saw the dentist yesterday in front of the hall.
6.	ខ្ញុំឃើញលោកគ្រូពេទ្យធ្មេញ ម្សិលមិញ ។	I saw the dentist yesterday.
7.	ខ្ញុំឃើញលោកគ្រូពេទ្យធ្មេញ ។	I saw the dentist.
8.	ខ្ញុំឃើញលោកគ្រូពេទ្យ ។	I saw the doctor.
9.	ខ្ញុំឃើញលោកគ្រូ ។	I saw the teacher.
10.	ខ្ញុំឃើញលោក ។	I saw you.

UNIT 55

NARRATION

1. មានមិត្តសំឡាញ់ពីរនាក់ ម្នាក់ឈ្មោះប៉ុន ម្នាក់ទៀតឈ្មោះសុខ ។
2. ប៉ុននឹងសុខ ជាអ្នកជំងឺ ។
3. តែឥឡូវ អ្នកទាំងពីរនាក់បានស្រួលបន្តិចហើយ ។
4. ថ្ងៃប៉ុនចូលធ្វើការ សុខសួរគាត់ថា: បានស្រួលហើយឬនៅ?
5. ប៉ុនប្រាប់សុខថា: គ្រាន់តែឈឺពោះទេ ឥឡូវជាហើយ ។
6. ប៉ុនបានទៅជួបគ្រូពេទ្យ ហើយគ្រូពេទ្យឲ្យថ្នាំខ្លះមកលេប ហើយនឹងឲ្យសម្រាក ។
7. ថ្នាំនោះគ្រាប់ធំៗពណ៌លឿងដែលប៉ុនត្រូវលេប ១ថ្ងៃ ៣ គ្រាប់ ១គ្រាប់ភាល់ពេលបាយ ។
8. សុខថា: ថ្នាំនេះប្រហែលដូចថ្នាំគាត់លេបពីខែមុននេះ ។
9. ប៉ុនក៏នៅចាំដែរ ថាសុខឈឺយូរណាស់កាលហ្នឹង ។
10. គាត់ផ្ដាសាយខ្លាំងណាស់ លេបថ្នាំអីក៏មិនត្រូវ ហើយឈឺនៅតែលើគ្រែអស់ពីរអាទិត្យ ។
11. ក្រោយមក គ្រូពេទ្យក៏ចាក់ថ្នាំឲ្យគាត់ ហើយគាត់ក៏បានស្រួលរហូតមក ។

1. There were two friends, one named Pon, the other named Sok.
2. Pon and Sok were sick.
3. But now both of them are feeling a little better.
4. The day Pon went back to work, Sok asked him: How are you feeling?
5. Pon told him he just had a stomach-ache; he feels fine now.
6. Pon went to see his doctor and the doctor gave him some pills to take and told him to rest.
7. That medicine is large yellow pills which Pon must take three times a day, one pill at each meal.
8. Sok said that these pills look like the ones he was taking last month.
9. Mr. Pon remembers also that Mr. Sok was sick for quite a long time then.
10. He had a very bad cold - no matter what pills he took, it didn't help, and so he was sick in bed for two weeks.
11. Finally, the doctor gave him some shots and he recovered.

1. លោកប៉ុនឈឺច្រមុះហើយសួរលោកថាតើគាត់ស្គាល់គ្រូពេទ្យណាពូកែខាងច្រមុះទេ។
2. លោកសុខស្គាល់គ្រូពេទ្យច្រើន តែគេមិនមើលជំងឺដូចគ្នាទេ។
3. គាត់ប្រាប់លោកប៉ុនថាបើគាត់គិតថាគាត់កើតឫស ដូងគាត់ទៅជួបនឹងគ្រូពេទ្យម្នាក់ដែលគាត់ស្គាល់។
4. គ្រូពេទ្យនោះកំពុងថែទាំជំងឺគាត់សព្វថ្ងៃ។
5. លោកគ្រូពេទ្យចាប់មើលជំងឺលោកសុខ បានប្រហែលពីរបីខែហើយ។
6. គាត់ចាក់ថ្នាំ១ម្ជុល ហើយឲ្យថ្នាំលោកសុខយកទៅលេប គាត់ទៅពេទ្យពីរអាទិត្យម្ដង។
7. ក្នុងមួយថ្ងៃគាត់ត្រូវលេប៦គ្រាប់ ពីរគ្រាប់ម្ដងក្រោយពេលបាយ។
8. ប៉ុន សួរថាៈ ឥឡូវគ្រាន់បើឬនៅ?
9. លោកសុខថាគាត់គ្រាន់បើច្រើនហើយ ប៉ុន្តែពីរបីអាទិត្យដំបូង គាត់អស់កំឡាំងណាស់។
10. ពេលនោះគ្រូពេទ្យចាក់ថ្នាំឲ្យ គាត់ ឲ្យលេបថ្នាំច្រើនគ្រាប់ ហាមមិនឲ្យធ្វើការធ្ងន់ ហើយឲ្យនៅសំរាកឯផ្ទះ។

1. Mr. Pon has some pain in his nose and he asks Mr. Sok if he knows any good nose doctor.
2. Mr. Sok knows a lot of doctors, but they don't treat the same kinds of diseases.
3. He tells Mr. Pon that if he thinks he has a growth in his nose he can go to see a doctor that he knows.
4. That doctor is treating Mr. Sok's illness at present.
5. The doctor began treating Mr. Sok's illness about two or three months ago.
6. Every two weeks he gives him a shot and gives him some medicine to take along.
7. He has to take six pills every day - two pills after each meal.
8. (later) Mr. Pon asks if Mr. Sok is better now.
9. Mr. Sok says that he feels much better now, but the first two or three weeks he felt very tired.
10. At that time the doctor gave him some shots, many pills to take, forbade him to do any heavy work, and ordered him to rest at home.

1. គ្រូពេទ្យលោកសុខចង់ឲ្យគាត់ទៅដេកពេទ្យទិនិរ ។
2. នៅមន្ទីរពេទ្យមានគ្រឿងប្រដាប់ល្អ ហើយមានពេទ្យយ៉ាងប្រសប់សម្រាប់ថែទាំផង ។
3. ប៉ុន្តែលោកសុខគិតថាគាត់មិនឈឺធ្ងន់ទេ ហើយគាត់សុំគ្រូពេទ្យសម្រាកនៅផ្ទះ ។
4. លោកប៉ុនសួរលោកសុខថា: ម៉េចបានជាដឹងថាកើតឫសដូង?
5. លោកសុខថា: ចេះតែតឹងច្រមុះ តែមិនបានទៅពេទ្យ ។
6. គាត់ប្រាប់លោកប៉ុនថា: គួរទៅជួបនឹងគ្រូពេទ្យភ្លាមទៅ កុំទុកយូរពេក ។
7. លោកសុខចង់ទៅភ្លាមដែរ តែគាត់ទើបនឹងដកធ្មេញមួយរួច ។
8. ឮដូច្នោះលោកប៉ុនសួរលោកសុខថាតើគាត់អាចទៅជួបគ្រូពេទ្យធ្មេញនោះបានទេ ធ្មេញគាត់មួយឈឺដែរ ។
9. លោកសុខថាគ្រូពេទ្យធ្មេញនោះពូកែណាស់ គាត់ប្រសប់ប៉ះធ្មេញយ៉ាងល្អ ។
10. អញ្ចឹងទៅជួបគ្រូពេទ្យខ្ញុំទៅ ហើយខ្ញុំទៅជួបគ្រូពេទ្យឯង ។

1. Mr. Sok's doctor wants him to stay in the hospital.
2. At the hospital there is good equipment and trained medical technicians to look after (him).
3. But Mr. Sok didn't think he was very ill and he asked his doctor to (let him) rest at home.
4. Mr. Pon asked Mr. Sok how he knew that he had a growth in his nose.
5. Mr. Sok said that he constantly had difficulty in breathing, but he didn't go to the doctor.
6. He told Mr. Pon: 'You should go to see my doctor right away; don't put it off too long.'
7. Mr. Sok wants to go to see the doctor right away but he says that he has just had a tooth pulled.
8. Hearing this Mr. Pon asks Mr. Sok: 'Can I go to see this dentist too? I have a toothache also.'
9. Mr. Sok says: 'This dentist is very good. He's very good at filling teeth too.'
10. 'You go to see my doctor, and I'll go see yours.'

UNIT 56

BASIC DIALOGUE

Sok

1. នៅស្រុកនេះពិបាករកជួលក្មេងបម្រើ ណាស់ទេ? — Is it hard to find a servant in this town?

Pon

2. មិនពិបាកទេ បើលោកមានមិត្តសំឡាញ់ខ្មែរ។ — It's not hard if you have a Cambodian friend.

3. លោកសុំឲ្យគេជួយរកទៅបានហើយ។ — Ask him to help you find one.

Sok

4. សុំលោកជួយរកឲ្យខ្ញុំផងបានទេ? — Can you help me find one?

Pon

5. លោកចង់បានក្មេងធ្វើបាយ ឬក្មេងបោះសំអាតផ្ទះ។ — Do you want a servant to cook or to clean the house?

Sok

6. ខ្ញុំចង់បានក្មេងប្រុសម្នាក់ចេះរៀបចំផ្ទះ ហើយនឹងធ្វើបាយបន្តិចបន្តួច។ — I want a man servant who knows how to take care of the house and to cook a little bit.

Pon

7. បើអញ្ចឹងមិនអីទេ ចាំខ្ញុំនាំក្មេងម្នាក់មកជួបលោក។ — In that case, it's no problem; wait and I'll bring one to meet you.

- - - - - - - - - - - -

Sok

8. ឯងឈ្មោះអី? ស្រុកទេសនៅឯណា? — What's your name? Where is your native village?

Kim

9. ខ្ញុំឈ្មោះគឹម ស្រុកកំណើតខ្ញុំ — My name is Kim; my birthplace is in Takeo Province.

នៅខេត្តតាកែវ។

Sok

10. ឯ អាយុប៉ុន្មានឆ្នាំហើយ? How old are you?

Kim

11. បាទ ពីរខែទៀត ខ្ញុំអាយុ ១៨ឆ្នាំហើយ។ In two months I'll be eighteen.

DRILLS

Drill A. Response

MODEL:	គ្រូ: នៅនេះពិបាករកជួលតាក់ស៊ីទេ?	**Teacher:** Is it hard to get a taxi here?
	សិស្ស: ទេ មិនពិបាកទេ មានតាក់ស៊ីច្រើនតែ ថ្លៃបន្តិច ។	**Student:** No, it's not hard; there are a lot of taxis, but they're a little expensive.

1.	នៅនេះពិបាករកជួលឡានទេ?	ទេ មិនពិបាកទេ មានឡានច្រើន តែថ្លៃបន្តិច ។
2.	នៅនេះពិបាករកជួលរ៉ឺម៉កទេ?	ទេ មិនពិបាកទេ មានរ៉ឺម៉កច្រើន តែថ្លៃបន្តិច ។
3.	នៅនេះពិបាករកជួលរទេះសេះទេ?	ទេ មិនពិបាកទេ មានរទេះសេះច្រើន តែថ្លៃបន្តិច ។
4.	នៅនេះពិបាករកជួលអ្នកធ្វើបាយទេ?	ទេ មិនពិបាកទេ មានអ្នកធ្វើបាយច្រើន តែថ្លៃបន្តិច ។
5.	នៅនេះពិបាករកអ្នកថែសួនច្បារទេ?	ទេ មិនពិបាកទេ មានអ្នកថែសួនច្បារច្រើន តែថ្លៃបន្តិច ។
6.	នៅនេះពិបាករកជួលទូកជិះលេងទេ?	ទេ មិនពិបាកទេ មានទូកជិះលេងច្រើន តែថ្លៃបន្តិច ។
7.	នៅនេះពិបាករកជួលផ្ទះទេ?	ទេ មិនពិបាកទេ មានផ្ទះច្រើន តែថ្លៃបន្តិច ។
8.	នៅនេះពិបាករកបន្ទប់នៅទេ?	ទេ មិនពិបាកទេ មានបន្ទប់នៅច្រើន តែថ្លៃបន្តិច ។

Drill B. Response

MODEL:	គ្រូ: ខ្ញុំចង់រកក្មេងម្នាក់ជួយរៀប ផ្ទះនឹងធ្វើបាយ ។	**Teacher:** I want to get a young person to help prepare the food and to keep house.
	សិស្ស: មិនអីទេ អ៊ីចឹង ខ្ញុំ ជួយរក អាទិត្យក្រោយ ខ្ញុំមកជួបទៀត ។	**Student:** O K, (in that case) let me help you look. Next week I'll come see you again.

1.	ខ្ញុំចង់ទិញអាវពីរបីសម្រាប់ទៅវត្ត។	មិនអីទេ ចាំខ្ញុំជួយទិញ អាទិត្យក្រោយខ្ញុំមកជួបលោកទៀត។
2.	ខ្ញុំចង់ធ្វើបាយទទួលពួកម៉ាកថ្ងៃសៅរ៍ក្រោយ។	មិនអីទេ ចាំខ្ញុំជួយធ្វើ អាទិត្យក្រោយខ្ញុំមកជួបទៀត។
3.	កូនខ្ញុំចង់រៀនបើកឡាន។	មិនអីទេ ចាំខ្ញុំជួយបង្រៀន អាទិត្យក្រោយខ្ញុំមកជួបទៀត។
4.	វាចង់លាងឡានដឹងថ្ងៃសុក្រ។	មិនអីទេ ចាំខ្ញុំជួយលាង អាទិត្យក្រោយខ្ញុំមកជួបទៀត។
5.	ក្មេងនេះមិនទាន់ចេះធ្វើបាយទេ។	មិនអីទេ ចាំខ្ញុំជួយធ្វើ អាទិត្យក្រោយខ្ញុំមកជួបទៀត។
6.	ខ្ញុំចង់ឲ្យវារៀនអ៊ុតខោអាវ។	មិនអីទេ ចាំខ្ញុំជួយបង្រៀន អាទិត្យក្រោយខ្ញុំមកជួបទៀត។

Drill C. Response

MODEL: គ្រូ: សុខ ឯងធ្វើបាយហើយឬនៅ? — **Teacher:** Have you prepared the meal yet?

សិស្ស: បាទ ខ្ញុំធ្វើហើយ ហើយចាំឲ្យតែដល់ម៉ោងទេ។ — **Student:** Yes, I've prepared it, and am waiting for it to be time (to eat).

1.	ហ៊ួន ឯងរៀនមេរៀនទីពីរហើយឬនៅ?	បាទ ខ្ញុំរៀនហើយៗ ចាំតែដល់ម៉ោងទេ។
2.	សាម ឯងរៀបចំបន្ទប់ហើយឬនៅ?	បាទ ខ្ញុំរៀបចំហើយៗ ចាំតែដល់ម៉ោងទេ។
3.	សុខ ឯងមើលសៀវភៅនោះចប់ហើយឬនៅ?	បាទ ខ្ញុំមើលចប់ហើយៗ ចាំ(ឲ្យ)តែដល់ម៉ោងទេ។
4.	និន ឯងស្លៀកពាក់ហើយឬនៅ?	បាទ ខ្ញុំស្លៀកពាក់ហើយៗ ចាំ(ឲ្យ)តែដល់ម៉ោងទេ។
5.	កូនសិស្សរៀបចំហើយឬនៅ?	បាទ គេរៀបចំហើយៗ ចាំ(ឲ្យ)តែដល់ម៉ោងទេ។
6.	គាត់បោះដុំហើយឬនៅ?	បាទ គាត់បោះហើយៗ ចាំតែដល់ម៉ោងទេ។
7.	តឹម ឯងដុតទឹកហើយឬនៅ?	បាទ ខ្ញុំដុតហើយៗ ចាំតែ ដល់ម៉ោងទេ។

Drill D. Substitution

1.	ខ្ញុំចេះដាំបាយបានខ្លះ នឹងរៀបចំផ្ទះ។	I know how to cook rice and take care of the house.
2.	ខ្ញុំចេះធ្វើម្ហូបបានខ្លះ នឹងរៀបចំផ្ទះ។	I know how to cook and take care of the house.
3.	ខ្ញុំចេះមើលក្មេង នឹងរៀបចំផ្ទះ	I know how to look after children and take care of the house.
4.	ខ្ញុំចេះទៅផ្សារ នឹងរៀបចំផ្ទះ។	I know how to go marketing and take care of the house.
5.	ខ្ញុំចេះបើកឡាន នឹងរៀបចំផ្ទះ។	I know how to drive and take care of the house.
6.	ខ្ញុំចេះបំរើភ្ញៀវ នឹងរៀបចំផ្ទះ។	I know how to serve guests and take care of the house.

Drill E. Double Substitution

1.	ឯងមានស្គាល់អ្នកណាគេអាចជួយបានទេ?	Did you know anyone who could help?
2.	ឯងមានដឹងអ្នកណាគេអាចធ្វើបានទេ?	Did you know anyone who could do (it)?
3.	ឯងឃើញអ្នកណាគេអាចទៅបានទេ?	Did you see anyone who could go?
4.	ឯងមានឲ្យអ្នកណាគេអាចទៅមើលបានទេ?	Did you allow anyone to go see (it)?
5.	ឯងមានប្រាប់អ្នកណាគេអាចចាំយើងបានទេ?	Did you tell anyone to wait for us?
6.	ឯងមានហៅអ្នកណាគេអាចមកជួបយើងបានទេ?	Did you call anyone to come meet us?
7.	ឯងមានរកអ្នកណាគេអាចពន្យល់យើងបានទេ?	Did you look for anyone who could explain (it to) us?
8.	ឯងមានឮអ្នកណាគេអាចចេញបានទេ?	Did you hear about anyone who could leave?

9.	ឯងមាននាំអ្នកណាគេអាចទៅជួបបានទេ?	Did you take anyone to go meet (someone)?
10.	ឯងមានចង់ឲ្យអ្នកណាគេអាចទៅយកបានទេ?	Did you want anyone to go get (it)?

Drill F. Double Substitution

1.	បាទ ខ្ញុំស្គាល់ដែរ តែគេជួយមិនបាន ។	Yes I knew (someone), but he couldn't help.
2.	បាទ ខ្ញុំដឹងដែរ តែគេធ្វើមិនបាន ។	Yes I knew (someone), but he couldn't do (it).
3.	បាទ ខ្ញុំឃើញដែរ តែគេទៅមិនបាន ។	Yes I saw (someone), but he couldn't go.
4.	បាទ ខ្ញុំឲ្យដែរ តែគេទៅមើលមិនបាន ។	Yes I allowed (someone), but he couldn't go see (it).
5.	បាទ ខ្ញុំប្រាប់ដែរ តែគេចាំយើងមិនបាន ។	Yes I told (someone), but he couldn't wait.
6.	បាទ ខ្ញុំហៅដែរ តែគេមកជួបមិនបាន ។	Yes I called (someone), but he couldn't come meet (us).
7.	បាទ ខ្ញុំរកដែរ តែគេពន្យល់មិនបាន ។	Yes I looked for (someone), but he couldn't explain (it to) us.
8.	បាទ ខ្ញុំឮដែរ តែគេចេញមិនបាន ។	Yes I heard about (someone), but he couldn't leave.
9.	បាទ ខ្ញុំនាំដែរ តែគេទៅជួបមិនបាន ។	Yes I took (someone), but he couldn't meet (them).

Drill G. Expansion

1.	ខ្ញុំចង់បានក្មេងម្នាក់ ។	I want to get a young servant.
2.	ខ្ញុំចង់បានក្មេងប្រុសម្នាក់ ។	I want to get a young man servant.
3.	ខ្ញុំចង់បានក្មេងប្រុសម្នាក់នៅជាមួយខ្ញុំ ។	I want to get a young man servant to live with me.
4.	ខ្ញុំចង់បានក្មេងប្រុសម្នាក់នៅជាមួយខ្ញុំរៀបចំផ្ទះ ។	I want to get a young man servant to live with me to help keep the house in order.

5. ខ្ញុំចង់បានក្មេងប្រុសម្នាក់នៅជាមួយខ្ញុំរៀបចំផ្ទះនិងធ្វើបាយ។
I want to get a young man servant to live with me to help keep the house in order and to cook.

6. ខ្ញុំចង់បានក្មេងប្រុសម្នាក់នៅជាមួយខ្ញុំរៀបចំផ្ទះនិងធ្វើបាយបន្តិចបន្តួច។
I want to get a young man servant to live with me to help keep the house in order and to cook a little bit.

Drill H. Reduction

1. បើខ្ញុំមានក្មេងម្នាក់នៅមើលកូន ប្រពន្ធខ្ញុំអាចទៅធ្វើការបាន។
If I had a young servant to live in and look after the children, my wife could go to work.

2. បើខ្ញុំមានក្មេងម្នាក់នៅមើលកូន ខ្ញុំអាចទៅធ្វើការបាន។
If I had a young servant to live in and look after the children, I could go to work.

3. បើខ្ញុំមានក្មេងម្នាក់នៅមើលកូន ខ្ញុំអាចទៅបាន។
If I had a young servant to live in and look after the children, I could go.

4. ខ្ញុំមានក្មេងម្នាក់នៅមើលកូន ខ្ញុំអាចទៅបាន។
I have a young servant to live in and look after the children, and I can go.

5. ខ្ញុំមានក្មេងម្នាក់នៅមើលកូន។
I have a young servant to live in and look after the children.

6. ខ្ញុំមានក្មេងម្នាក់។
I have a young servant.

Drill I. Substitution

1. ពីរខែទៀត ខ្ញុំអាយុ ដប់ប្រាំបីឆ្នាំ។
In two more months I will be 18 years old.

2. បួនខែទៀតខ្ញុំអាយុ ដប់ប្រាំបីឆ្នាំ។
In four more months I will be 18 years old.

3. បួនខែទៀតខ្ញុំអាយុ ម្ភៃមួយឆ្នាំ។
In four more months I will be 21 years old.

4. បីខែទៀតខ្ញុំអាយុ ម្ភៃមួយឆ្នាំ។
In three more months I will be 21 years old.

5. បីខែទៀត កូនខ្ញុំចូលរៀន។
In three more months my children will enter school.

6. មួយខែទៀតកូនខ្ញុំចូលរៀន។
In one more month my children will enter school.

7. មួយខែទៀតកូនខ្ញុំ រៀនចប់។
In one more month my children will finish school.

8. ពីរខែទៀតកូនខ្ញុំរៀនចប់។
In two more months my children will finish school.

9. ពីរខែទៀត ខ្ញុំអាយុ ដប់ប្រាំបីឆ្នាំ ។

Drill J. Transformation

MODEL:	គ្រូ: ខ្ញុំអាយុ ដប់ប្រាំពីរឆ្នាំ ដប់ខែ ។	**Teacher:** I am 17 years ten months old.
	សិស្ស: ពីរខែទៀត ខ្ញុំអាយុ ដប់ប្រាំបីឆ្នាំ ។	**Student:** In two months more, I will be 18 years old.

1.	ខ្ញុំអាយុម្ភៃឆ្នាំប្រាំបីខែ ។	បួនខែទៀត ខ្ញុំអាយុម្ភៃមួយឆ្នាំ ។
2.	ខ្ញុំអាយុដប់បួនឆ្នាំ ប្រាំមួយខែ ។	ប្រាំមួយខែទៀត ខ្ញុំអាយុ ១៥ ឆ្នាំ ។
3.	ខ្ញុំអាយុ ១៧ ឆ្នាំ ៩ ខែ ។	បីខែទៀត ខ្ញុំអាយុ ១៨ ឆ្នាំ ។
4.	ខ្ញុំអាយុ ១៥ ឆ្នាំ ១១ ខែ ។	មួយខែទៀត ខ្ញុំអាយុ ១៦ ឆ្នាំ ។
5.	ខ្ញុំអាយុ ២២ ឆ្នាំ ៧ ខែ ។	ប្រាំខែទៀត ខ្ញុំអាយុ ២៣ ឆ្នាំ ។

UNIT 57

BASIC DIALOGUE

		Sok	
1.	ឪពុកម្ដាយបងគាត់នៅរស់ទាំងសងទេឬអី?		Are your parents both living now?
		Kim	
2.	បាទ ឪពុកខ្ញុំគាត់ស្លាប់ហើយ នៅតែម្ដាយខ្ញុំទេ។		My father's dead; now there's just my mother.
		Sok	
3.	បងមានបងប្អូនប៉ុន្មាននាក់?		How many brothers and sisters do you have?
		Kim	
4.	ខ្ញុំមានបងស្រីម្នាក់គាត់មានប្ដីហើយ។		I have one older sister who's married already.
5.	ហើយនៅជាមួយម្ដាយខ្ញុំសព្វថ្ងៃនេះ។		And she lives with my mother at present.
		Sok	
6.	បងថ្លៃបងរកស៊ីធ្វើការអី?		What does your brother-in-law do for a living?
		Kim	
7.	បាទ គាត់ធ្វើស្រែជួយម្ដាយខ្ញុំ ពីព្រោះគាត់ចាស់ណាស់ហើយ។		He farms to help my mother because she is old.
		Sok	
8.	បងមកនៅក្រុងនេះប៉ុន្មានខែហើយ?		How many months have you been in this city?
		Kim	
9.	ខ្ញុំនៅនេះ ទើបតែនឹងបាន មួយខែទេ។		I've been in this city just one month.
		Sok	
10.	បងធ្លាប់នៅជាមួយអ្នកណាទេ?		Did you used to work for somebody?

Kim

11. ខ្ញុំធ្លាប់នៅបំរើលោកអភិបាលស្រុកម្នាក់នៅតាកែវបានប្រហែលមួយឆ្នាំដែរ ។

I used to work as a servant for the chief of a srok in Takeo for about a year.

DRILLS

Drill A. Substitution

1.	ឯងមានបងប្អូននៅទីក្រុងនេះទេ?	Do you have brothers and sisters in this city?
2.	ឯងមានស្គាល់អ្នកណានៅទីក្រុងនេះទេ?	Do you know anyone in this city?
3.	ឯងមានពួកម៉ាកនៅទីក្រុងនេះទេ?	Do you have friends in this city?
4.	ឯងមានផ្ទះនៅទីក្រុងនេះទេ?	Do you have a house in this city?
5.	ឯងមានគេមកទទួលនៅទីក្រុងនេះទេ?	Do you have anyone to come get you in this city?
6.	ឯងមានឃើញអ្វីប្លែកនៅទីក្រុងនេះទេ?	Have you seen anything interesting (strange)in this city?
7.	ឯងមានទិញអីនៅទីក្រុងនេះទេ?	Have you bought anything in this city?
8.	ឯងមានការណ៍នៅទីក្រុងនេះទេ?	Have you any business in this city?
9.	ឯងមានជួបអាកុមារនៅទីក្រុងនេះទេ?	Have you met Koma in this city?

Drill B. Substitution

1.	ខ្ញុំមានបងប្រុសតែម្នាក់ទេ ហើយ ឥឡូវ គាត់មានប្រពន្ធហើយ។	I have only one older brother, and he has a wife already.
2.	ខ្ញុំមានបងស្រីតែម្នាក់ទេ ហើយ ឥឡូវ គាត់មានប្ដីហើយ។	I have only one older sister, and she has a husband already.
3.	ខ្ញុំមានប្អូនប្រុសតែម្នាក់ទេ ហើយ ឥឡូវ វាមានប្រពន្ធហើយ។	I have only one younger brother, and he has a wife already.
4.	ខ្ញុំមានបងថ្លៃតែម្នាក់ទេ ហើយ ឥឡូវ គាត់មានកូនហើយ។	I have only one brother-in-law, and he has children already.
5.	ខ្ញុំមានពូតែម្នាក់ទេ ហើយ ឥឡូវ គាត់មានប្រពន្ធហើយ។	I have only one younger uncle, and he has a wife already.

6.	ខ្ញុំមានមីងតែម្នាក់ទេ ហើយឥឡូវ គាត់មានប្តីហើយ ។	I have only one older aunt, and she has a husband already.
7.	ខ្ញុំមានកូនស្រីតែម្នាក់ទេ ហើយឥឡូវ វាមានកូនហើយ ។	I have only one daughter, and she has children already.
8.	ខ្ញុំមានប្អូនតែម្នាក់ទេ ហើយឥឡូវ វាមានការងារហើយ ។	I have only one younger sibling, and he has a job already.

Drill C. Response

MODEL:

គ្រូ៖	អ្នកណានៅជាមួយបងលោកសព្វថ្ងៃនេះ? (ប្អូនថ្លៃតូច)	Teacher:	Who is living with your older brother these days?
សិស្ស៖	បាទ ឥឡូវនេះគ្មានអ្នកណានៅជាមួយគាត់ទេ ក្រៅពីប្អូនថ្លៃតូចម្នាក់ ។	Student:	Now he doesn't have anyone living with him except a younger brother (sister)-in-law.

1.	នរណានៅជាមួយពូលោកសព្វថ្ងៃនេះ? (ក្មេងតូច)	បាទ ឥឡូវគាត់គ្មានអ្នកណានៅជាមួយគាត់ទេ ក្រៅពីក្មេងតូចម្នាក់ ។
2.	នរណានៅជាមួយឪពុកម្តាយលោកសព្វថ្ងៃនេះ? (បងស្រីខ្ញុំ)	បាទ ឥឡូវគាត់គ្មានអ្នកណានៅជាមួយគាត់ទេ ក្រៅពីបងស្រីខ្ញុំម្នាក់ ។
3.	អ្នកណានៅជាមួយគាត់សព្វថ្ងៃនេះ? (ក្មួយគាត់)	បាទ ឥឡូវគាត់គ្មានអ្នកណានៅជាមួយគាត់ទេ ក្រៅពីក្មួយគាត់ម្នាក់ ។
4.	អ្នកណានៅជាមួយលោកគ្រូសព្វថ្ងៃនេះ? (ពួកម៉ាកគាត់)	បាទ ឥឡូវគាត់គ្មានអ្នកណានៅជាមួយគាត់ទេ ក្រៅពីពួកម៉ាកគាត់ម្នាក់ ។
5.	អ្នកណានៅជាមួយតាចាស់សព្វថ្ងៃនេះ? (ចៅតូចគាត់)	បាទ ឥឡូវគាត់គ្មានអ្នកណានៅជាមួយគាត់ទេ ក្រៅពីចៅតូចគាត់ម្នាក់ ។
6.	អ្នកណានៅជាមួយគាត់សព្វថ្ងៃនេះ? (ប្អូនស្រីតូច)	បាទ ឥឡូវគាត់គ្មានអ្នកណានៅជាមួយគាត់ទេ ក្រៅពីប្អូនស្រីម្នាក់តូច ។
7.	អ្នកណានៅជាមួយម្តាយក្មេកលោកសព្វថ្ងៃនេះ? (ប្រពន្ធខ្ញុំនិងកូនតូច)	បាទ ឥឡូវគាត់គ្មានអ្នកណានៅជាមួយគាត់ទេ ក្រៅពីប្រពន្ធខ្ញុំនិងកូនតូចម្នាក់ ។
8.	អ្នកណានៅជាមួយនាងសម៉ិយសព្វថ្ងៃនេះ? (ម្តាយគាត់និងក្មេងប្រុស)	បាទឥឡូវគាត់គ្មានអ្នកណានៅជាមួយទេ ក្រៅពីម្តាយគាត់និងក្មេងប្រុសម្នាក់ ។

9. អ្នកណានៅជាមួយលោកស្មិតសព្វថ្ងៃនេះ? (កូនគាត់ពីរនាក់និងអ្នកធ្វើបាយ)	បាទ ឥឡូវ គាត់គ្មានអ្នកណានៅជាមួយគាត់ទេ ក្រៅពីកូនគាត់ពីរនាក់និងអ្នកធ្វើបាយម្នាក់។

Drill D. Response

MODEL:	គ្រូ: លោកជួបនឹងនាងសំណាងហើយឬនៅ?	Teacher: Have you met Miss Samnang yet or not?
	សិស្ស: បាទ ខ្ញុំមិនទាន់បានជួបទេ ខ្ញុំទើបតែមកដល់។	Student: I didn't have a chance to meet her yet; I just arrived.

1. លោកបានទទួលសៀវភៅរឿងហើយនៅ?	បាទ ខ្ញុំមិនទាន់ទទួលទេ ខ្ញុំទើបតែមកដល់។
2. លោកទៅឃើញផ្សារថ្មីហើយឬនៅ?	បាទ ខ្ញុំមិនទាន់ទៅឃើញទេ ខ្ញុំទើបតែមកដល់។
3. លោកយកសំបុត្រខ្ញុំទៅឲ្យអ្នកគ្រូហើយនៅ?	បាទ ខ្ញុំមិនទាន់យកទៅទេ ខ្ញុំទើបតែមកដល់។
4. លោកឃើញគាត់មកដល់ហើយនៅ?	បាទ ខ្ញុំមិនទាន់ឃើញទេ ខ្ញុំទើបតែមកដល់។
5. ឯងទៅផ្សារហើយនៅ?	បាទ ខ្ញុំមិនទាន់ទៅទេ ខ្ញុំទើបតែមកដល់។
6. ឯងទិញកាហ្វេបានហើយឬនៅ?	បាទ ខ្ញុំមិនទាន់ទិញបានទេ ខ្ញុំទើបតែមកដល់។
7. ឯងទៅទិញសំបុត្រឡានហើយនៅ?	បាទ ខ្ញុំមិនទាន់ទៅទិញទេ ខ្ញុំទើបតែមកដល់។
8. ប៉ុន ឯងរៀបបាយហើយនៅ?	បាទ មិនទាន់រៀបទេ ខ្ញុំទើបតែមកដល់។

Drill E. Response

MODEL:	គ្រូ: លោកធ្លាប់ប្រើម៉ាស៊ីននេះទេ?	Teacher: Have you ever used this machine?
	សិស្ស: ខ្ញុំធ្លាប់ប្រើវាដែរ តែប្រហែលភ្លេចហើយឥឡូវ។	Student: I have used it, but I've probably forgotten how by now.

1.	លោកធ្លាប់ជិះឡាននេះទេ?	ខ្ញុំដែលជិះដែរ តែប្រហែលភ្លេចហើយឥឡូវ។
2.	លោកធ្លាប់ឃើញគេរៀបយ៉ាងម៉េចទេ?	ខ្ញុំដែលឃើញដែរ តែប្រហែលភ្លេចហើយឥឡូវ។
3.	លោកធ្លាប់ឃើញគេដាំបាយយ៉ាងម៉េចទេ?	ខ្ញុំដែលឃើញដែរ តែប្រហែលភ្លេចហើយឥឡូវ។
4.	លោកធ្លាប់សរសេរសំបុត្រសុំធ្វើការទេ?	ខ្ញុំដែលសរសេរដែរ តែប្រហែលភ្លេចហើយឥឡូវ។
5.	លោកស្រីធ្លាប់បើកឡានទេ?	ខ្ញុំដែលបើកដែរ តែប្រហែលភ្លេចហើយឥឡូវ។
6.	ឯងធ្លាប់ស្គាល់ផ្លូវទៅផ្សារថ្មីទេ?	ខ្ញុំដែលស្គាល់ដែរ តែប្រហែលភ្លេចហើយឥឡូវ។
7.	ឯងធ្លាប់ឮគេនិយាយពីស្រុកខ្មែរទេ?	ខ្ញុំដែលឮដែរ តែប្រហែលភ្លេចហើយឥឡូវ។

Drill F. Questioning

MODEL: គ្រូ: ខ្ញុំធ្លាប់ប្រើម៉ាស៊ីននឹងដែរ។ — **Teacher:** I used to use this machine.

សិស្ស: លោកដែលប្រើម៉ាស៊ីននឹងទេ? — **Student:** Have you ever used this machine?

1.	ខ្ញុំធ្លាប់ជិះឡាននឹងដែរ។	លោកដែលជិះឡាននឹងទេ?
2.	ខ្ញុំធ្លាប់ដាំបាយដែរ។	លោកដែលដាំបាយទេ?
3.	ខ្ញុំធ្លាប់បើកឡានដែរ។	លោកដែលបើកឡានទេ?
4.	វាមិនដែលឃើញផ្សារថ្មីទេ។	វាដែលឃើញផ្សារថ្មីទេ?
5.	គាត់ធ្លាប់សរសេរសំបុត្រទៅផ្ទះដែរ។	គាត់ដែលសរសេរសំបុត្រទៅផ្ទះទេ?
6.	ខ្ញុំធ្លាប់បើកឡានតាមផ្លូវនោះដែរ។	លោកដែលបើកឡានតាមផ្លូវនោះទេ?
7.	ខ្ញុំធ្លាប់ជិះយន្តហោះដែរ។	លោកដែលជិះយន្តហោះទេ?
8.	ខ្ញុំធ្លាប់សរសេរសៀវភៅរឿងដែរ។	លោកដែលសរសេរសៀវភៅរឿងទេ?

Drill G. Transformation

MODEL: គ្រូៈ ខ្ញុំមិនទាន់ជួបនាងសំណាងទេ។ — Teacher: I haven't met Miss Samnang yet.

សិស្សៈ ខ្ញុំក៏មិនទាន់ជួបដែរ ខ្ញុំទើបនឹងមកដល់។ — Student: I haven't met her yet. I just arrived.

1.	ខ្ញុំមិនទាន់បានទទួលសៀវភៅទេ។	ខ្ញុំក៏មិនទាន់បានទទួលដែរ ខ្ញុំទើបនឹងមកដល់។
2.	វាមិនទាន់យកសំបុត្រទៅជូនលោកគ្រូទេ។	វាក៏មិនទាន់យកសំបុត្រទៅជូនដែរ វាទើបនឹងមកដល់។
3.	ខ្ញុំមិនទាន់ឃើញគាត់ចូលមកទេ។	ខ្ញុំក៏មិនទាន់ឃើញគាត់ចូលមកដែរ ខ្ញុំទើបនឹងមកដល់។
4.	គាត់មិនទាន់ទៅផ្សារទេ។	គាត់ក៏មិនទាន់ទៅដែរ គាត់ទើបនឹងមកដល់។
5.	ខ្ញុំមិនទាន់ទៅយកខ្សានទេ។	ខ្ញុំក៏មិនទាន់ទៅដែរ ខ្ញុំទើបនឹងមកដល់។
6.	ប្អូនគាត់មិនទាន់បានលុយទេ។	ប្អូនគាត់ក៏មិនទាន់បានដែរ គាត់ទើបនឹងមកដល់។
7.	ខ្ញុំមិនទាន់ដឹងគេនិយាយអីទេ។	ខ្ញុំក៏មិនទាន់ដឹងដែរ ខ្ញុំទើបនឹងមកដល់។

Drill H. Transformation

MODEL: គ្រូៈ គាត់មានប្អូនថ្លៃតូចម្នាក់។ (ក្មេង) — Teacher: She has a younger brother-in law. (young servant)

សិស្សៈ ក្រៅពីនោះមានក្មេងម្នាក់នៅជាមួយគាត់។ — Student: Besides this she has a young servant living with her.

1.	លោកមានឪពុកម្ដាយ។ (ក្មួយ)	ក្រៅពីនោះមានក្មួយម្នាក់នៅជាមួយគាត់។
2.	បងខ្ញុំនៅជាមួយប្រពន្ធគាត់។ (ប្អូនថ្លៃ)	ក្រៅពីនោះគាត់មានប្អូនថ្លៃម្នាក់នៅជាមួយគាត់។
3.	លោកស្រីគមានកូនតូចម្នាក់។ (បងថ្លៃ)	ក្រៅពីនោះគាត់មានបងថ្លៃម្នាក់នៅជាមួយគាត់។

4.	ខ្ញុំនៅជាមួយពូខ្ញុំ។ (ក្មេងតូច)	ក្រៅពីនោះមានក្មេងតូចម្នាក់នៅជាមួយគាត់។
5.	គាត់មានពួកម៉ាកពីរនាក់ធ្វើការជាមួយគ្នា។ (កូនសិស្ស)	ក្រៅពីនោះមានកូនសិស្សនៅជាមួយគាត់។
6.	លោកគ្រូខ្ញុំមានបងប្រុសពីរនាក់ទើបនឹងមកដល់។ (ពួកម៉ាក)	ក្រៅពីនោះមានពួកម៉ាកម្នាក់នៅជាមួយគាត់។

Drill I. Substitution

1.	ខ្ញុំនៅក្រុងនេះទើបតែបាន១ខែទេ។	I have lived in this town just one month.
2.	ខ្ញុំនៅផ្ទះនេះទើបតែបាន១ខែទេ	I have lived in this house just one month.
3.	ខ្ញុំនៅផ្ទះនេះទើបតែបាន១ឆ្នាំទេ។	I have lived in this house just one year.
4.	ខ្ញុំនៅបំរើគាត់ទើបតែបានប្រហែល១ឆ្នាំទេ។	I have served him just one year.
5.	ខ្ញុំនៅបំរើគាត់បានប្រហែល១ឆ្នាំហើយ។	I have served him about one year.
6.	ខ្ញុំនៅបំរើគាត់បានប្រហែល១ខែហើយ។	I have served him about one month.
7.	ខ្ញុំនៅផ្ទះនេះបានប្រហែល១ខែហើយ។	I have lived in this house about one month.
8.	ខ្ញុំនៅក្រុងនេះបានប្រហែល១ខែហើយ។	I have lived in this city about one month.
9.	ខ្ញុំនៅក្រុងនេះទើបនឹងបាន១ខែទេ។	I have lived in this city just one month.

Drill J. Response

MODEL:

គ្រូ:	ឯងនៅក្រុងនេះប៉ុន្មានខែហើយ? (ទើប១ខែ)	Teacher:	How many months ago did you come to live in this city? (just one month)
សិស្ស:	ខ្ញុំនៅក្រុងនេះទើបតែនឹងបាន១ខែទេ។	Student:	I have lived in this city just one month.

1.	ឯងនៅទីនេះប៉ុន្មានឆ្នាំហើយ? (ជិត ១ ឆ្នាំ)	ខ្ញុំនៅទីនេះជិតជិតនឹងបាន ១ ឆ្នាំហើយ។
2.	ឯងមកនៅប៉ារីគាត់ប៉ុន្មានឆ្នាំហើយ? (ប្រហែល ១ ឆ្នាំ)	ខ្ញុំមកនៅប៉ារីគាត់ប្រហែល ១ ឆ្នាំហើយ។
3.	ឯងមកនៅក្រុងនេះប៉ុន្មានខែហើយ? (ប្រហែល ៣ ខែ)	ខ្ញុំមកនៅក្រុងនេះប្រហែល ៣ ខែហើយ។
4.	ឯងមកនៅទីនេះប៉ុន្មានខែហើយ? (ប្រហែល ៦ ខែ)	ខ្ញុំមកនៅទីនេះប្រហែល ៦ ខែហើយ។
5.	ឯងមកនៅប៉ារីគាត់ប៉ុន្មានខែហើយ? (ជិត ១ ខែ)	ខ្ញុំមកនៅប៉ារីគាត់ជិតជិតនឹងបាន ១ ខែទេ។

UNIT 58

BASIC DIALOGUE

1.	ឯងធ្វើការអីបានខ្លះ?	Sok	What kind of work can you do?
2.	ខ្ញុំធ្វើការក្នុងផ្ទះបានខ្លះ។	Kim	I can do work around the house.
3.	ប៉ុន្តែខ្ញុំមិនប្រសប់ធ្វើបាយទេ។		But I'm not very good at cooking.
4.	ខ្ញុំអាចបោសសំអាតផ្ទះ បោកអ៊ុតខោអាវបាន។		I can clean the house and wash and iron clothes.
5.	ឯងចេះបំរើភ្ញៀវទេ?	Sok	Do you know how to serve guests?
6.	ខ្ញុំដឹងអំពីរបៀបបំរើបាយ និងភេសជ្ជៈខ្លះ។	Kim	I know something about serving food and drinks.
7.	ចុះឯងចេះបើកឡានដែរទេ?	Sok	Do you also know how to drive a car?
8.	បាទ ខ្ញុំចូលចិត្តបើកឡានណាស់ ទោះបីខ្ញុំបើកយូរណាស់ហើយក៏ដោយ។	Kim	Yes, I like to drive a car very much even though I have been driving for a long time.
9.	ចេះប៉ុណ្ណឹងបានហើយ ក្រៅពីនេះ ប្រហែលខ្ញុំត្រូវការប្រើឯងទៅផ្សារយូរៗម្ដង។	Sok	It's good that you know all that; besides these things, maybe I'll need to send you to the market once in a while.
10.	បាទ ខ្ញុំមិនគិតទេ បើមានការអីខ្ញុំធ្វើកើត ខ្ញុំចេះតែធ្វើហើយ។	Kim	I don't mind; if there's something I can do, I'll always do it.
11.	អញ្ចឹងល្អណាស់។ ខ្ញុំចូលចិត្ត	Sok	That's very good. I like someone

	អ្នកណាពិបាលមិនប្រកាន់ខ្លួនសញ្ចឹង ។	who doesn't mind.
	Kim	
12.	ខ្ញុំគ្រាន់តែសុំ បើខ្ញុំខុសឆ្គងបន្តិចបន្តួច សុំលោកកុំប្រកាន់ ។	I only ask that if I make a mistake, please forgive me.
	Sok	
13.	មិនអីទេ កុំព្រួយ ។	O.K., don't worry.
	Kim	
14.	ខ្ញុំសុំអរគុណលោកច្រើនណាស់ ។	Thank you very much.

DRILLS

Drill A. Substitution

1.	ខ្ញុំធ្វើម្ហូបបានខ្លះដែរ តែមិនសូវប្រសប់ទេ ។	I can prepare food some, but I'm not very good at it.
2.	ខ្ញុំអ៊ុតខោអាវបានខ្លះដែរ តែមិនសូវប្រសប់ទេ ។	I can iron clothes some, but I'm not very good at it.
3.	ខ្ញុំបំរើភ្ញៀវបានខ្លះដែរ តែមិនសូវប្រសប់ទេ ។	I can serve guests some, but I'm not very good at it.
4.	ខ្ញុំចេះលាយស្រាបានខ្លះដែរ តែមិនសូវប្រសប់ទេ ។	I know how to mix drinks some, but I'm not very good at it.
5.	ខ្ញុំចេះបើកឡានបានខ្លះដែរ តែមិនសូវប្រសប់ទេ ។	I know how to drive some, but I'm not very good at it.
6.	ខ្ញុំចេះរៀបចំផ្ទះបានខ្លះដែរ តែមិនសូវប្រសប់ទេ ។	I know how to take care of the house some, but I'm not very good at it.
7.	ខ្ញុំចេះបោកខោអាវបានខ្លះដែរ តែមិនសូវប្រសប់ទេ ។	I know how to do the laundry some, but I'm not very good at it.
8.	ខ្ញុំចេះទិញម្ហូបបានខ្លះដែរ តែមិនសូវប្រសប់ទេ ។	I know how to buy food some, but I'm not very good at it.
9.	ខ្ញុំចេះទទួលភ្ញៀវបានខ្លះដែរ តែមិនសូវប្រសប់ទេ ។	I know how to receive guests some, but I'm not very good at it.

Drill B. Transformation

MODEL:	គ្រូ: ខ្ញុំមិនសូវប្រសប់ធ្វើម្ហូបទេ ។	Teacher: I'm not very good at preparing food.
	សិស្ស: ខ្ញុំធ្វើម្ហូបបានខ្លះដែរតែមិនសូវប្រសប់ទេ ។	Student: I can prepare food some, but I'm not very good at it.
1.	ខ្ញុំមិនសូវប្រសប់អ៊ុតខោអាវទេ ។	ខ្ញុំអ៊ុតខោអាវបានខ្លះដែរតែមិនសូវប្រសប់ទេ ។
2.	ខ្ញុំមិនសូវប្រសប់បំរើភ្ញៀវទេ ។	ខ្ញុំបំរើភ្ញៀវបានខ្លះដែរតែមិនសូវប្រសប់ទេ ។
3.	ខ្ញុំមិនសូវប្រសប់លាយស្រាទេ ។	ខ្ញុំលាយស្រាបានខ្លះដែរតែមិនសូវ

		ប្រសប់ទេ។
4.	ខ្ញុំមិនសូវប្រសប់បើកឡានទេ។	ខ្ញុំបើកឡានបានខ្លះដែរ តែមិនសូវប្រសប់ទេ។
5.	ខ្ញុំមិនសូវប្រសប់រៀបចំផ្ទះទេ។	ខ្ញុំរៀបចំផ្ទះបានខ្លះដែរ តែមិនសូវប្រសប់ទេ។
6.	ខ្ញុំមិនសូវប្រសប់បោកខោអាវទេ។	ខ្ញុំបោកខោអាវបានខ្លះដែរ តែមិនសូវប្រសប់ទេ។
7.	ខ្ញុំមិនសូវប្រសប់ទិញម្ហូបទេ។	ខ្ញុំទិញម្ហូបបានខ្លះដែរ តែមិនសូវប្រសប់ទេ។
8.	ខ្ញុំមិនសូវប្រសប់ទទួលភ្ញៀវទេ។	ខ្ញុំអាចទទួលភ្ញៀវបានខ្លះដែរ តែមិនសូវប្រសប់ទេ។
9.	ខ្ញុំមិនសូវប្រសប់និយាយអង់គ្លេសទេ។	ខ្ញុំនិយាយអង់គ្លេសបានខ្លះដែរ តែមិនសូវប្រសប់ទេ។

Drill C. Substitution

1.	ប៉ុន ល្ងាចហ្នឹង ខ្ញុំចង់ឲ្យប៉ុនឯងទៅទិញសម្លម្ជូរមកញ៉ាំ។	Pon, this evening I want you to go buy some Somloo Məuu to bring back to eat.
2.	ប៉ុន ល្ងាចហ្នឹង ខ្ញុំចង់ឲ្យប៉ុនឯងទៅទិញក្រូចបាត់ដំបងមកញ៉ាំ។	Pon, this evening I want you to go buy some Battambang oranges to bring back to eat.
3.	ប៉ុនល្ងាចហ្នឹង ខ្ញុំចង់ឲ្យប៉ុនឯងទៅទិញឪឡឹកមកញ៉ាំ។	Pon, this evening I want you to go buy some watermelons to bring back to eat.
4.	ប៉ុនល្ងាចហ្នឹង ខ្ញុំចង់ឲ្យប៉ុនឯងទៅទិញមៀនកំប៉ុងមកញ៉ាំ។	Pon, this evening I want you to go buy some canned lychees to bring back to eat.
5.	ប៉ុនល្ងាចហ្នឹងខ្ញុំចង់ឲ្យប៉ុនឯងទៅទិញត្រីងៀតមកញ៉ាំ។	Pon, this evening I want you to go buy some dried fish to bring back to eat.
6.	ប៉ុនល្ងាចហ្នឹងខ្ញុំចង់ឲ្យប៉ុនឯងទៅទិញនំបុ័ងមកញ៉ាំ។	Pon, this evening I want you to go buy some bread to bring back to eat.
7.	ប៉ុនល្ងាចហ្នឹងខ្ញុំចង់ឲ្យប៉ុនឯងទៅទិញក្តាមមកញ៉ាំ។	Pon, this evening I want you to go buy some crabs to bring back to eat.
8.	ប៉ុនល្ងាចហ្នឹងខ្ញុំចង់ឲ្យប៉ុនឯងទៅទិញបង្កងមកញ៉ាំ។	Pon, this evening I want you to go buy some lobster to bring back to eat.
9.	ប៉ុនល្ងាចហ្នឹងខ្ញុំចង់ឲ្យប៉ុនឯងទៅទិញ	Pon, this evening I want you to go

ពោតមកញ៉ាំ។ — buy some corn to bring back to eat.

10. ប៉ុនល្ងាចហ្នឹងខ្ញុំចង់ឲ្យប៉ុនឯងទៅទិញ សាច់ជ្រូកខ្វៃមកញ៉ាំ។ — Pon, this evening I want you to go buy some roast pork to bring back to eat.

Drill D. Response

MODEL:

គ្រូៈ ខ្ញុំចង់រកមនុស្សម្នាក់ចេះ
បោកអ៊ុតខោអាវផង។

Teacher: I'm looking for someone who knows how to wash and iron too.

សិស្សៈ មិនអីទេ បូរ៉ាប្រសប់អ៊ុត
ខោអាវណាស់ កាលវានៅ
ជាមួយខ្ញុំ។

Student: O.K., Bora was very good at washing and ironing when he was with me.

1.	ខ្ញុំចង់រកមនុស្សម្នាក់ចេះបើកឡាន ផង។	មិនអីទេ បូរ៉ាប្រសប់បើកឡានណាស់ កាលវានៅជាមួយខ្ញុំ។
2.	ខ្ញុំចង់រកមនុស្សម្នាក់ចេះធ្វើម្ហូបផង។	មិនអីទេ បូរ៉ាប្រសប់ធ្វើម្ហូបណាស់ កាលវានៅជាមួយខ្ញុំ។
3.	គាត់ចង់រកមនុស្សម្នាក់ចេះមើលកូន ផង។	មិនអីទេ បូរ៉ាប្រសប់មើលកូនណាស់ កាលវានៅជាមួយខ្ញុំ។
4.	គាត់ចង់រកមនុស្សចេះបំរើភ្ញៀវ ផង។	មិនអីទេ បូរ៉ាប្រសប់បំរើភ្ញៀវណាស់ កាលវានៅជាមួយខ្ញុំ។
5.	លោកចង់រកមនុស្សចេះលាយស្រា ផង។	មិនអីទេ បូរ៉ាប្រសប់លាយស្រាណាស់ កាលនៅជាមួយខ្ញុំ។
6.	ខ្ញុំចង់រកមនុស្សវាយដាក់ទីលឡូម្នាក់ ផង។	មិនអីទេ បូរ៉ាប្រសប់វាយដាក់ទីលឡូ ណាស់ កាលវានៅជាមួយខ្ញុំ។
7.	គាត់ចង់រកមនុស្សចេះនាំកូនក្មេង ដើរលេងផង។	មិនអីទេ បូរ៉ាប្រសប់នាំក្មេងដើរលេង ណាស់កាលវានៅជាមួយខ្ញុំ។
8.	វាចង់រកមនុស្សចេះប្រើម៉ាស៊ីនIBM (អាយប៊ីអិម) ផង។	មិនអីទេបូរ៉ាប្រសប់ប្រើណាស់ កាលវានៅជាមួយខ្ញុំ។

Drill E. Multiple Substitution

1. ខ្ញុំចូលចិត្តធ្វើបាយណាស់ថ្វីបើខ្ញុំ មិនសូវពូកែក៏ដោយ។ — I like to cook even though I'm not very good at it.

2. ខ្ញុំចូលចិត្តទទួលទានបន្លែណាស់ថ្វីបើ — I like to eat vegetables even though

ខ្ញុំមិនគាន់ដឹងរបៀបលោកធ្វើ ។ — I don't know how you prepare them.

3. ខ្ញុំចូលចិត្តមកតាមផ្លូវនេះ ថ្វីបើខ្ញុំត្រូវវៀងបន្តិច ។ — I like to come along this street even though I have to go out of my way a little.

4. ខ្ញុំចូលចិត្តទៅវត្តខ្មែរ ថ្វីបើខ្ញុំមិនកាន់ព្រះពុទ្ធសាសនា ។ — I like to go to Cambodian wats even though I'm not a Buddhist.

5. ខ្ញុំចូលចិត្តញ៉ាំគុយទៀវ ថ្វីបើខ្ញុំធ្លាប់ញ៉ាំហើយ ។ — I like to eat kuy-tiav even though I've eaten it already.

6. ខ្ញុំចូលចិត្តទៅលេងអង្គរវត្ត ថ្វីបើខ្ញុំធ្លាប់ឃើញហើយ ។ — I like to visit Angkor Wat even though I've already seen it.

7. ខ្ញុំចូលចិត្តកាហ្វេ ថ្វីបើខ្ញុំដឹងថាមិនឆ្ងាញ់ ។ — I like coffee even though I know it does not taste good.

8. ខ្ញុំចូលចិត្តស្តាប់លោកនិយាយខ្មែរ ថ្វីបើខ្ញុំមិនគាន់ស្តាប់បានច្រើន ។ — I like to listen to you speak Cambodian even though I still don't understand much.

9. ខ្ញុំចូលចិត្តដើរលេង ថ្វីបើខ្ញុំគ្មានលុយ ។ — I like to go out for a good time even though I don't have money.

10. ខ្ញុំចូលចិត្តរៀនខ្មែរ ថ្វីបើខ្ញុំមិនគាន់ទៅស្រុកខ្មែរ ។ — I like to study Cambodian even though I still haven't gone to Cambodia.

11. ខ្ញុំចូលចិត្តមើលកាសែត ថ្វីបើខ្ញុំឮដំណឹងតាមវិទ្យុហើយ ។ — I like to read the newspaper even though I listened to the news on the radio.

12. ខ្ញុំចូលចិត្តធ្វើដំណើរតាមកប៉ាល់ ថ្វីបើខ្ញុំមិនដែលជិះយន្តហោះ ។ — I like to travel by ship even though I have never ridden in a plane.

Drill F. Transformation

MODEL:

គ្រូ៖ ខ្ញុំចូលចិត្តធ្វើបាយណាស់ ថ្វីបើខ្ញុំមិនសូវពូកែក៏ដោយ ។

Teacher: I like to cook very much, even though I'm not very good at it.

សិស្ស៖ ខ្ញុំមិនសូវពូកែទេ ប៉ុន្តែខ្ញុំចូលចិត្តធ្វើបាយណាស់ដែរ ។

Student: I'm not very good at it, but I like to cook very much.

1. ខ្ញុំចូលចិត្តទទួលទានបន្លែណាស់ ថ្វីបើខ្ញុំមិនគាន់ដឹងរបៀបលោកធ្វើក៏ដោយ ។ — ខ្ញុំមិនគាន់ដឹងរបៀបលោកធ្វើទេ ប៉ុន្តែខ្ញុំចូលចិត្តទទួលទានណាស់ដែរ ។

2. ខ្ញុំចូលចិត្តមកតាមផ្លូវនេះណាស់ ថ្វីបើខ្ញុំត្រូវវៀងបន្តិចក៏ដោយ ។ — ខ្ញុំត្រូវវៀងបន្តិច ប៉ុន្តែខ្ញុំចូលចិត្តមកតាមផ្លូវនេះណាស់ដែរ ។

3.	ខ្ញុំចូលចិត្តទៅវត្តខ្មែរណាស់ ថ្វីបើខ្ញុំមិនកាន់សាសនាព្រះពុទ្ធក៏ដោយ។	ខ្ញុំមិនកាន់ព្រះពុទ្ធសាសនាទេ ប៉ុន្តែខ្ញុំចូលចិត្តទៅវត្តខ្មែរណាស់ដែរ។
4.	ខ្ញុំចូលចិត្តញ៉ាំគុយទាវណាស់ ថ្វីបើខ្ញុំធ្លាប់ញ៉ាំក៏ដោយ។	ខ្ញុំធ្លាប់ញ៉ាំហើយ ប៉ុន្តែខ្ញុំចូលចិត្តញ៉ាំគុយទាវណាស់ដែរ
5.	ខ្ញុំចូលចិត្តទៅលេងអង្គរវត្តណាស់ ថ្វីបើខ្ញុំ ធ្លាប់ឃើញហើយក៏ដោយ។	ខ្ញុំធ្លាប់ឃើញហើយ ប៉ុន្តែ ខ្ញុំចូលចិត្តទៅលេងអង្គរវត្តណាស់ដែរ។
6.	ខ្ញុំចូលចិត្តកាហ្វេណាស់ ថ្វីបើខ្ញុំដឹងថាវិត ឆ្ងាញ់ក៏ដោយ។	ខ្ញុំដឹងថាវិតឆ្ងាញ់ ប៉ុន្តែខ្ញុំចូលចិត្តកាហ្វេណាស់ដែរ។
7.	ខ្ញុំចូលចិត្តស្ដាប់លោកនិយាយខ្មែរណាស់ ថ្វីបើខ្ញុំមិនទាន់ស្ដាប់បានច្រើនក៏ដោយ។	ខ្ញុំមិនទាន់ស្ដាប់បានច្រើន ប៉ុន្តែខ្ញុំចូលចិត្តស្ដាប់លោកនិយាយខ្មែរណាស់ដែរ។
8.	ខ្ញុំចូលចិត្តដើរលេងណាស់ ថ្វីបើខ្ញុំគ្មានលុយក៏ដោយ។	ខ្ញុំគ្មានលុយ ប៉ុន្តែខ្ញុំចូលចិត្តដើរលេងណាស់ដែរ។
9.	ខ្ញុំចូលចិត្តរៀនខ្មែរណាស់ ថ្វីបើខ្ញុំ មិនទាន់ត្រូវទៅស្រុកខ្មែរក៏ដោយ។	ខ្ញុំមិនទាន់ត្រូវទៅស្រុកខ្មែរទេ ប៉ុន្តែខ្ញុំចូលចិត្តរៀនខ្មែរណាស់ដែរ។
10.	ខ្ញុំចូលចិត្តមើលកាសែតណាស់ ថ្វីបើខ្ញុំឮ ដំណឹងតាមវិទ្យុហើយក៏ដោយ។	ខ្ញុំឮដំណឹងតាមវិទ្យុហើយ ប៉ុន្តែខ្ញុំចូលចិត្តមើលកាសែតណាស់ដែរ។
	ខ្ញុំចូលចិត្តធ្វើដំណើរតាមកប៉ាល់ណាស់ ថ្វីបើខ្ញុំមិនដែលជិះយន្តហោះក៏ដោយ។	ខ្ញុំមិនដែលជិះកប៉ាល់ហោះទេ ប៉ុន្តែខ្ញុំចូលចិត្តជិះកប៉ាល់ណាស់ដែរ។

Drill G. Response

MODEL:	គ្រូ៖ ពូសុំទៅទិញកាសែតកម្ពុជាឲ្យខ្ញុំ១ភ្លេតបានទេ? សិស្ស៖ បាទ មានអី លោកត្រូវការកាសែតហ្នឹងឥឡូវឬ?	Teacher: Uncle, please buy the newspaper Kampuchia for me. Student: All right. Do you need the newspaper now?
1.	ពូ សុំទៅយកអាវឲ្យខ្ញុំមួយភ្លេតបានទេ?	បាទ មានអី លោកត្រូវការអាវហ្នឹងឥឡូវឬ?
2.	ពូសុំទៅទិញស្រា១ដបឲ្យខ្ញុំ១ភ្លេតបានទេ?	បាទមានអី លោកត្រូវការស្រាហ្នឹងឥឡូវឬ?
3.	ពូសុំទៅហៅស៊ីក្លូ១ឲ្យខ្ញុំ១ភ្លេតបានទេ?	បាទមានអី លោកត្រូវការស៊ីក្លូ ឥឡូវឬ?
4.	បងសុំទៅទិញនំបុ័ង១ឲ្យខ្ញុំ១ភ្លេត	បាទមានអី លោកត្រូវការនំបុ័ងឥឡូវ

	បានទេ?	ឬ?
5.	បងសុំទៅទិញទឹកមប្រី ឲ្យខ្ញុំ១ភ្លែតបានទេ?	បាទ មានអី លោកត្រូវការទឹកមប្រី ឥឡូវឬ?
6.	បងសុំ ទៅអញ្ជើញលោកស្មិតឲ្យខ្ញុំ១ភ្លែតបានទេ?	បាទ មានអី លោកត្រូវការលោកស្មិត ឥឡូវឬ?

Drill H. Transformation

MODEL: គ្រូ: ប៉ុន សុំទៅទិញកាសែតកម្ពុជាឲ្យខ្ញុំ១ភ្លែតបានទេ?
សិស្ស: ខ្ញុំត្រូវការប្រើប៉ុនទៅទិញកាសែតកម្ពុជា។

Teacher: Pon, please go buy the newspaper Kampuchia for me.

Student: I need to send Pon to go buy the newspaper Kampuchia.

1.	ដឹម សុំទៅយកអាវឲ្យខ្ញុំ១ភ្លែតបានទេ?	ខ្ញុំត្រូវការប្រើដឹមទៅយកអាវ។
2.	ប៉ុន សុំទិញស្រាឲ្យខ្ញុំ១ដបបានទេ?	ខ្ញុំត្រូវការប្រើ ប៉ុនទៅទិញស្រា១ដប។
3.	ប៉ុនសុំទៅហៅស៊ីក្លូ១ ឲ្យខ្ញុំបានទេ?	ខ្ញុំត្រូវការប្រើប៉ុនទៅហៅស៊ីក្លូ១ ។
4.	បង សុំទៅទិញនំប៉័ងមួយទៀតឲ្យខ្ញុំបានទេ?	ខ្ញុំត្រូវការប្រើ បងទៅទិញនំប៉័ង១ទៀត។
5.	ឯងទៅផ្សារឲ្យខ្ញុំយូរៗម្ដងបានទេ ?	ខ្ញុំត្រូវការ ឯងទៅផ្សារយូរៗម្ដង។
6.	បង សុំទៅអញ្ជើញលោកស្មិតឲ្យខ្ញុំបានទេ?	ខ្ញុំត្រូវការប្រើបង ទៅអញ្ជើញលោកស្មិត។

Drill I. Response

MODEL: គ្រូ: ឯងចេះបំរើបាយនិងភេសជ្ជៈ បានទេ?
សិស្ស: ខ្ញុំដឹងរបៀបបំរើបាយនិងភេសជ្ជៈ ខ្លះ។

Teacher: Do you know how to serve food and drinks to guests?

Student: I know something about serving food and drinks to guests.

1.	ឯងចេះធ្វើការក្នុងផ្ទះបានទេ?	ខ្ញុំដឹងរបៀបធ្វើការក្នុងផ្ទះខ្លះ។
2.	ឯងអាចបោសសំអាតផ្ទះបានទេ ?	ខ្ញុំដឹងរបៀបបោសសំអាតផ្ទះខ្លះ។
3.	ឯងអាចបោកអ៊ុតខោអាវបានទេ?	ខ្ញុំដឹងរបៀបបោកអ៊ុតខោអាវខ្លះ។
4.	ឯងអាចធ្វើបាយបានល្អទេ?	ខ្ញុំដឹងរបៀបធ្វើបាយខ្លះ។
5.	ឯងចេះលាយស្រា បានទេ ?	ខ្ញុំដឹងរបៀបលាយស្រាខ្លះ ។

6.	ឯងអាចទៅផ្សារបានទេ?	ខ្ញុំនឹងរៀនទៅផ្សារខ្លះ។
7.	ឯងចេះរៀបជំនុំបានទេ?	ខ្ញុំនឹងរៀនរៀបជំនុំខ្លះ។

Drill J. Substitution

1.	បើមានការអ្វីខ្ញុំធ្វើកើត ខ្ញុំចេះតែធ្វើ។	If there's anything I'm able to do, I'll do it.
2.	បើមានការអ្វីខ្ញុំអាចធ្វើបាន ខ្ញុំចេះតែធ្វើ។	If there's anything I can do, I'll do it.
3.	បើមានការអ្វីខ្ញុំអាចជួយបាន ខ្ញុំចេះតែធ្វើ។	If there's anything I (can do) to help, I'll do it.
4.	បើមានការអ្វីខ្ញុំអាចជួយបាន ខ្ញុំចេះតែជួយ។	If there's anything I (can do) to help, I'll help.
5.	បើមានអ្នកណាខ្ញុំអាចជួយបាន ខ្ញុំចេះតែជួយ។	If there's anybody I can help I'll help.
6.	បើមានអ្នកណាសុំឲ្យខ្ញុំជួយ ខ្ញុំចេះតែជួយ។	If there's anybody who asks me to help, I'll help.
7.	បើមានអ្នកណាចង់ប្រើខ្ញុំធ្វើអ្វី ខ្ញុំចេះតែជួយ។	If there's anybody who wants to send me to do something, I'll help.
8.	បើមានអ្នកណាចង់ប្រើខ្ញុំធ្វើអ្វី ខ្ញុំចេះតែធ្វើ។	If there's anybody who wants to send me to do something, I'll do it.
9.	បើមានការអ្វី ខ្ញុំធ្វើកើត ខ្ញុំចេះតែធ្វើ។	If there's anything I can do, I'll do it.

UNIT 59

BASIC DIALOGUE

1.	ឈ្នួលបងគិតមួយខែប៉ុន្មាន?	Sok	How much do you want a month?
2.	បាទ ស្រេចតែលើលោកទេ។	Kim	That's up to you alone.
3.	ខ្ញុំគិតឲ្យ១ខែប្រាំរយ ហើយ បងញុំាំបាយនៅនេះចុះ បានទេ?	Sok	I plan to give you 500 a month, and you'll eat here with me. Is that all right?
4.	បើលោកមានបន្ទប់ណាទំនេរ ខ្ញុំសុំនៅផង ពីព្រោះខ្ញុំគ្មានកន្លែងណានៅទេ។	Kim	If you have an empty room, I'd like to stay (there) too, because I haven't got any place to stay.
5.	មានបន្ទប់តូចមួយនៅខាងក្រោយ បងអាចនៅបាន។	Sok	I have a small room in back. You can stay there.
6.	ខ្ញុំអរគុណណាស់លោក។	Kim	Thank you very much.
7.	បងចូលមកនៅថ្ងៃណាបាន?	Sok	What day can you come and start?
8.	បាទ ថ្ងៃណាក៏បានដែរ។ ខ្ញុំគ្មានអីវ៉ាន់អីច្រើនទេ។	Kim	Any day. I don't have many things.
9.	អញ្ចឹងមកស្អែកទៅ។	Sok	In that case come tomorrow.
10.	បាទ ។	Kim	O.K.
11.	មកម៉ោងប្រាំបីព្រឹកទៅ។ ខ្ញុំនឹងប្រគល់សោឲ្យមុននឹងខ្ញុំទៅធ្វើការ។	Sok	Come at 8:00 A.M., I'll give you the keys before I go to work.

DRILLS

Drill A. Substitution

1.	ខ្ញុំគ្មានអីវ៉ាន់អីច្រើនទេ។	I don't have many things.
2.	ខ្ញុំគ្មានការអីធ្ងន់ទេ។	I don't have any heavy work.
3.	ខ្ញុំគ្មានបន្ទប់ណាទំនេរទេ។	I don't have any free rooms.
4.	ខ្ញុំគ្មានភ្ញៀវមកច្រើនទេ។	I don't have a lot of guests coming.
5.	ខ្ញុំគ្មានអីវ៉ាន់អីធ្ងន់ទេ។	I don't have any heavy things.
6.	ខ្ញុំគ្មានបន្ទប់ណាតូចទេ។	I don't have any small rooms.
7.	ខ្ញុំគ្មានឡានអីទំនេរទេ។	I don't have any free cars.
8.	ខ្ញុំគ្មានកន្លែងណានៅទេ។	I don't have any place to stay.
9.	ខ្ញុំគ្មានអីវ៉ាន់អីច្រើនទេ។	I don't have many things.

Drill B. Response

MODEL:

គ្រូៈ ហេតុអីបានជាលោករកបន្ទប់ទំនេរ? (គ្មានកន្លែងនៅ)	Teacher: Why are you looking for a free room? (have no place to stay)
សិស្សៈ ខ្ញុំរកបន្ទប់ទំនេរព្រោះខ្ញុំគ្មានកន្លែងនៅ។	Student: I'm looking for a free room because I have no place to stay.

1.	ហេតុអីបានជាលោកមិនជិះស៊ីក្លូទៅ? (គ្មានអីវ៉ាន់ច្រើន)	ខ្ញុំមិនជិះស៊ីក្លូទៅ ពីព្រោះខ្ញុំគ្មានអីវ៉ាន់ច្រើន។
2.	ហេតុអីបានជាលោកធ្វើតែម្នាក់ឯង? (គ្មានការធ្ងន់)	ខ្ញុំធ្វើតែម្នាក់ឯង ពីព្រោះខ្ញុំគ្មានការធ្ងន់។
3.	ហេតុអីបានជាលោកឲ្យគេនៅបន្ទប់ធំ? (គ្មានបន្ទប់តូច)	ខ្ញុំឲ្យគេនៅបន្ទប់ធំ ពីព្រោះខ្ញុំគ្មានបន្ទប់តូច។
4.	ហេតុអីបានជាលោកជិះស៊ីក្លូទៅ? (គ្មានឡានទំនេរ)	ខ្ញុំជិះស៊ីក្លូទៅ ពីព្រោះគ្មានឡានទំនេរ។
5.	ហេតុអីបានជាលោកធ្វើជប់លៀងនៅផ្ទះ? (គ្មានភ្ញៀវមកច្រើន)	ខ្ញុំធ្វើជប់លៀងនៅផ្ទះ ពីព្រោះគ្មានភ្ញៀវមកច្រើន។

Drill C. Variable Substitution

1.	បើលោកមានបន្ទប់ណាទំនេរ ខ្ញុំសុំនៅផង។	If you have a free room, let me stay there too.
2.	បើលោកមានកន្លែងណានៅ ខ្ញុំសុំនៅផង។	If you have a place to stay, let me stay there too.
3.	បើលោកមានកន្លែងណាទៅ ខ្ញុំសុំទៅជាមួយលោកផង។	If you have any place to go, let me go with you too.
4.	បើលោកមានឡានអីទំនេរ ខ្ញុំសុំទៅជាមួយលោកផង។	If you have free car (space), let me go with you too.
5.	បើលោកមានឡានអីទំនេរ ខ្ញុំសុំជួយជញ្ជូនអីវ៉ាន់លោកផង។	If you have free car (space), let me help you move your things.
6.	បើលោកមានអីវ៉ាន់អីធ្ងន់ ខ្ញុំសុំជួយជញ្ជូនអីវ៉ាន់លោកផង។	If you have anything heavy, let me help you move your things.
7.	បើលោកមានអីវ៉ាន់អីធ្ងន់ ខ្ញុំទៅជួយរៀបចំផ្ទះលោកដែរ។	If you have anything heavy, let me help you arrange your house.
8.	បើលោកមានភ្ញៀវមកច្រើន ខ្ញុំទៅជួយរៀបចំផ្ទះលោកដែរ។	If you have a lot of guests, let me help you arrange your house.

Drill D. Response

MODEL:	គ្រូ: លោកគិតឲ្យប្រាក់ខែខ្ញុំប៉ុន្មានទៅ? (៥០០, ញ៉ាំបាយជាមួយខ្ញុំ)	Teacher: How much salary do you plan to give me? (500, eat with me)
	សិស្ស: ខ្ញុំគិតឲ្យឯង៥០០ ហើយញ៉ាំបាយជាមួយខ្ញុំផង។	Student: I plan to give you 500 a month, and you'll eat with me.
1.	លោកគិតឲ្យប្រាក់ខែខ្ញុំប៉ុន្មានទៅ? (៤០០, នៅបន្ទប់ទំនេរខ្ញុំ)	ខ្ញុំគិតឲ្យឯង៤០០ ហើយឯងនៅបន្ទប់ទំនេរខ្ញុំផង។
2.	លោកគិតឲ្យប្រាក់ខែខ្ញុំប៉ុន្មានទៅ? (៣៥០, គ្រួសារឯងញ៉ាំបាយជា១ខ្ញុំ)	ខ្ញុំគិតឲ្យឯង៣៥០ ហើយគ្រួសារឯងញ៉ាំបាយជាមួយខ្ញុំផង។
3.	លោកគិតឲ្យប្រាក់ខែខ្ញុំប៉ុន្មានទៅ? (៥៥០, បើឯងមិនញ៉ាំបាយជា១ខ្ញុំ)	ខ្ញុំគិតឲ្យឯង៥៥០ បើឯងមិនញ៉ាំបាយជាមួយខ្ញុំ។

4.	លោកគិតឲ្យប្រាក់ខែខ្ញុំប៉ុន្មានទៅ? (៦០០ បើឯងនៅផ្ទះឯង)	ខ្ញុំគិតឲ្យឯង១ខែ ៦០០ ចុះ បើឯងនៅផ្ទះឯង។
5.	លោកគិតឲ្យប្រាក់ខែខ្ញុំប៉ុន្មានទៅ? (៧៥០ បើប្រពន្ធឯងធ្វើការនៅផ្ទះ)	ខ្ញុំគិតឲ្យឯង១ខែ ៧៥០ ចុះ បើប្រពន្ធធ្វើការនៅផ្ទះ។
6.	លោកគិតឲ្យប្រាក់ខែខ្ញុំប៉ុន្មានទៅ? (៥៥០ ឯងទៅក្រៅក្រុងជាមួយខ្ញុំ)	ខ្ញុំគិតឲ្យឯង១ខែ ៥៥០ ចុះ ហើយឯងទៅក្រៅក្រុងជាមួយខ្ញុំ។

Drill E. Transformation

MODEL: គ្រូ: ខ្ញុំមានអីវ៉ាន់ច្រើនណាស់។ (អី) — Teacher: I have a lot of things.

សិស្ស: ខ្ញុំគ្មានអីវ៉ាន់អីច្រើនទេ។ — Student: I don't have a lot of things.

1.	ខ្ញុំមានការពិបាកណាស់។ (អី)	ខ្ញុំគ្មានការអីពិបាកទេ។
2.	ខ្ញុំមានបន្ទប់មួយទំនេរ ។ (ណា)	ខ្ញុំគ្មានបន្ទប់ណាទំនេរទេ។
3.	ខ្ញុំមានភ្ញៀវមកច្រើនណាស់។ (អី)	ខ្ញុំគ្មានភ្ញៀវអីមកច្រើនទេ។
4.	ខ្ញុំមានអីវ៉ាន់ធ្ងន់ណាស់។ (អី)	ខ្ញុំគ្មានអីវ៉ាន់អីធ្ងន់ទេ។
5.	គាត់មានបន្ទប់១តូច។ (ណា)	គាត់គ្មានបន្ទប់ណាតូចទេ។
6.	វាមានកន្លែងនៅហើយ។ (ណា)	វាគ្មានកន្លែងណានៅទេ។

Drill F. Transformation

MODEL: គ្រូ: ខ្ញុំគ្មានអីវ៉ាន់អីច្រើនទេ។ (ណាស់) — Teacher: I don't have a lot of things.

សិស្ស: ខ្ញុំមានអីវ៉ាន់ច្រើនណាស់។ — Student: I have a lot of things.

1.	ខ្ញុំគ្មានកន្លែងណានៅទេ។ (ហើយ)	ខ្ញុំមានកន្លែងនៅហើយ។
2.	ខ្ញុំគ្មានបន្ទប់ណាតូចទេ។ (មួយ)	ខ្ញុំមានបន្ទប់មួយតូច។
3.	ខ្ញុំគ្មានអីវ៉ាន់អីធ្ងន់ទេ។ (ណាស់)	ខ្ញុំមានអីវ៉ាន់ធ្ងន់ណាស់។
4.	ខ្ញុំគ្មានភ្ញៀវអីមកច្រើនទេ។ (ណាស់)	ខ្ញុំមានភ្ញៀវមកច្រើនណាស់។
5.	ខ្ញុំគ្មានបន្ទប់ណាទំនេរទេ។ (មួយ)	ខ្ញុំមានបន្ទប់១ទំនេរ។
6.	ខ្ញុំគ្មានការអីពិបាកទេ។ (ណាស់)	ខ្ញុំមានការពិបាកណាស់។

Drill G. Substitution

1.	ឯងចូលមកនៅថ្ងៃណាបាន?	What day can you come to stay?
2.	ឯងចូលមកធ្វើការថ្ងៃណាបាន?	What day can you come to work?
3.	ឯងចូលមកធ្វើការម៉ោងប៉ុន្មានបាន?	What time can you come to work?
4.	ឯងចូលមករៀនម៉ោងប៉ុន្មានបាន?	What time can you come to study?
5.	ឯងចូលមករៀនខែណាបាន?	What month can you come to study?
6.	ឯងចូលមកធ្វើការខែណាបាន?	What month can you come to work?
7.	ឯងចូលមកនៅខែណាបាន?	What month can you come to stay?
8.	ឯងចូលមកនៅថ្ងៃណាបាន?	What day can you come to stay?

Drill H. Response

MODEL:	គ្រូ: ឯចូលមកនៅថ្ងៃណាបាន? (គ្មានឥវ៉ាន់ច្រើនទេ)	Teacher: What day can you move in? (don't have many things)
	សិស្ស: ថ្ងៃណាក៏បានដែរ ខ្ញុំគ្មានឥវ៉ាន់ច្រើនទេ។	Student: Any day is all right. I don't have many things.
1.	ឯងចូលមកធ្វើការថ្ងៃណាបាន? (គ្មានរបស់អីច្រើនទេ)	ថ្ងៃណាក៏បានដែរ ខ្ញុំគ្មានរបស់អីច្រើនទេ។
2.	ឯងចូលមកធ្វើការម៉ោងប៉ុន្មានបាន? (គ្មានការអីទៀតទេ)	ម៉ោងប៉ុន្មានក៏បានដែរ ខ្ញុំគ្មានការអីទៀតទេ។
3.	ឯងចូលរៀនម៉ោងប៉ុន្មានបាន? (គ្មានរបស់អីច្រើនទេ)	ម៉ោងប៉ុន្មានក៏បានដែរ ខ្ញុំគ្មានរបស់អីទៀតទេ។
4.	ឯងចូលមករៀនខែណាបាន? (គ្មានបញ្ហាអីធ្ងន់ទេ)	ខែណាក៏បានដែរ ខ្ញុំគ្មានបញ្ហាអីធ្ងន់ទេ។
5.	ឯងចូលមកធ្វើការខែណាបាន? (គ្មានឈើអីធ្ងន់ទេ)	ខែណាក៏បានដែរ ខ្ញុំគ្មានឈើអីធ្ងន់ទេ។
6.	ឯងចូលមកនៅខែណាបាន? (គ្មានអីវ៉ាន់ច្រើនទេ)	ខែណាក៏បានដែរ ខ្ញុំគ្មានអីវ៉ាន់ច្រើនទេ។

Drill I. Expansion

1.	កុំប្រកាន់។	Don't be offended.
2.	សុំលោក កុំប្រកាន់។	Please don't be offended.
3.	ខ្ញុំគ្រាន់តែសួរមើល សុំលោកកុំប្រកាន់។	I only ask, please don't be offended.
4.	ខ្ញុំគ្រាន់តែសួរមើល បើខ្ញុំខុសឆ្គង សុំលោកកុំប្រកាន់។	I only ask, if I do something wrong, please don't be offended.
5.	ខ្ញុំគ្រាន់តែសួរមើល បើខ្ញុំខុសឆ្គងបន្តិចបន្តួច សុំលោកកុំប្រកាន់។	I only ask, if I do something a little bit wrong, please don't be offended.

Drill J. Reduction

1.	ខ្ញុំគ្រាន់តែសួរមើល បើខ្ញុំខុសឆ្គងបន្តិចបន្តួច សុំលោកកុំប្រកាន់។	I only ask, if I do something a little bit wrong, please don't be offended.
2.	ខ្ញុំសួរមើល បើខ្ញុំខុសឆ្គងបន្តិចបន្តួច សុំលោកកុំប្រកាន់។	I ask, if I do something a little bit wrong, please don't be offended.
3.	ខ្ញុំសួរមើល ខុសឆ្គងបន្តិចបន្តួច សុំលោកកុំប្រកាន់។	I ask (if I) do something wrong, please don't be offended
4.	ខ្ញុំសួរមើល ខុសឆ្គងបន្តិចបន្តួច កុំប្រកាន់។	I ask (if I) do something wrong, don't be offended.
5.	ខុសឆ្គងបន្តិចបន្តួច កុំប្រកាន់។	(If I) do something wrong, don't be offended.
6.	កុំប្រកាន់។	Don't be offended.

UNIT 60

NARRATION

1. គេសួរគ្នាអំពីរបៀបរកមនុស្សមកជួយធ្វើការផ្សេងៗនៅផ្ទះ។
2. មិត្តសំឡាញ់ម្នាក់សួរទៅពួកម៉ាកគេថា៖ នៅស្រុកនេះពិបាករកជួលក្មេងបំរើទេ?
3. ពួកម៉ាកគេប្រាប់ថាមិនពិបាកទេ បើអ្នកចង់រកជួលក្មេងមានមិនសំឡាញ់ខ្មែរ។
4. គេអាចសុំឲ្យមិត្តសំឡាញ់នោះជួយរកបាន។
5. តែគេត្រូវដឹងថាគេចង់ជួលក្មេងមកជួយធ្វើបាយ ឬមកបោសសំអាតផ្ទះ។
6. អ្នកចង់បានក្មេងនេះត្រូវការអ្នកចេះធ្វើបាយផង ហើយរៀបចំផ្ទះផង។
7. គាត់សុំឲ្យមិត្តសំឡាញ់ខ្មែរគាត់ជួយរកឲ្យ។
8. មិត្តសំឡាញ់គាត់បាននាំក្មេងម្នាក់មកជួបនឹងគាត់។
9. ក្មេងនោះឈ្មោះគិម ស្រុកកំណើតនៅខេត្តតាកែវ។
10. ពីរខែទៀតវាមានអាយុ ១៨ ឆ្នាំ។

1. They're talking about the way to find a person to come help do the various tasks in the house.
2. One friend asks his friend, "Is it difficult to hire a servant in this country?"
3. His friend says, "It's not difficult if the person who wants to hire the servant has a Cambodian friend."
4. "He can ask his friend to help look."
5. "But he has to know if he wants to hire a servant to come cook or come clean the house."
6. The person who wants to have a servant needs a person who knows how to cook and clean up the house.
7. He asks his Cambodian friend to help look for him.
8. His friend brought a servant to meet him.
9. The servant's name is Kim; his native village is Takeo Province.
10. In two more months he will be 18.

- - - - - - - - - - - - - -

1. គិមមានតែម្ដាយនៅគង់ទេ ឪពុកវាស្លាប់ហើយ។
2. គិមមានបងស្រីម្នាក់មានប្ដីហើយ។
3. បងថ្លៃវានឹងបងស្រីវា នៅជាមួយម្ដាយវា ។
4. អ្នកចង់បានគិមមកនៅជួយធ្វើ គាត់សួរវាថា៖ បងថ្លៃឯងរកស៊ីធ្វើការអី?

5. គិមឆ្លើយថា៖ គាត់ធ្វើស្រែជួយម្ដាយខ្ញុំ ព្រោះគាត់ចាស់ណាស់ហើយ។
6. គេសួរគិមទៀតថាតើវាមកនៅក្រុងនេះបានប៉ុន្មានខែហើយ។
7. គិមថាវាទើបនឹងមកនៅបានមួយខែទេ។
8. មុនមកនេះវាធ្វើការនៅខេត្តតាកែវ។
9. គិមធ្លាប់បំរើលោកអភិបាលស្រុកម្នាក់នៅតាកែវ។
10. វាធ្វើការនៅនោះបានប្រហែលមួយឆ្នាំដែរ។

1. Kim has only his mother now; his father died a long time ago.
2. Kim has an older sister who is married.
3. Kim's brother-in-law and his older sister live with Kim's mother.
4. The person who wants to have Kim help with the work asks Kim, "What does your brother-in-law do to earn a living?"
5. Kim answers, "He grows rice to help my mother because she is very old."
6. He asks Kim further, how many months he has lived in the city.
7. Kim says he just came to live (here) a month ago.
8. Before coming here he worked in Takeo Province.
9. Kim used to be a servant for the chief of a srok in Takeo.
10. He worked there for about a year.

1. គិមថាវាមិនប្រសប់ធ្វើបាយទេ។
2. កាលវានៅជាមួយលោកអភិបាលស្រុក វាជាអ្នកបោសសំអាតនិងបោកអ៊ុតខោអាវ។
3. អ្នកចង់ជួលគិមសួរវាថាតើវាចេះបំរើភ្ញៀវបានឬទេ។
4. គិមចេះរៀបបំរើបាយនិងភេសជ្ជៈជូនភ្ញៀវ។
5. គេចង់ឲ្យគិមបើកឡានផង។
6. គិមថាវាចូលចិត្តបើកឡានណាស់ ថ្វីបើវាចេះបើកឡានយូរហើយក៏ដោយ។
7. អ្នកចង់ជួលគិមគិតថាចេះប៉ុណ្ណឹងបានហើយ តែប្រហែលគេត្រូវការប្រើវាទៅផ្សារ
យូរៗម្ដង។
8. គិមថាវាមិនប្រកាន់ខ្លួនទេ បើមានការធ្វើបាន វាចេះតែធ្វើ។
9. តែវាសូមថាបើធ្វើខុសឆ្គងបន្តិចបន្តួច សុំឲ្យអ្នកដែលវានៅជាមួយកុំប្រកាន់។
10. អ្នកជួលគិមថា៖ មិនអីទេ កុំព្រួយ។

1. Kim says he's not very good at cooking.
2. When he was with the chief of the srok he was the housekeeper and did the laundry.
3. The person who wants to hire Kim asks him if he knows how to serve guests.
4. Kim knows how to serve food and drinks to guests.

5. He wants Kim to drive the car too.
6. Kim says that he likes to drive very much, even though he has known how to drive for a long time.
7. The person who wants to hire Kim thinks that if he knows that much, it'll do, but maybe they'll need to send Kim to market from time to time.
8. Kim says he doesn't mind; if there's any work he can do, he'll always do it.
9. But Kim asks that if he makes a little mistake, the person he lives with won't be offended.
10. The person who wants to hire Kim, says "Never mind, don't worry."

- - - - - - - - - - - - - - -

1. រួចមកគេគិតអំពីប្រាក់ខែ នឹងរឿងមកធ្វើការ ។
2. គេសួរគិមថា: ចង់បានប្រាក់ខែប៉ុន្មាន?
3. គិមមិនសម្រេចទេ វាថា: ស្រេចតែលើលោកទេ ។
4. លោកនោះក៏គិតថានឹងឲ្យគិម ១ខែ ៥០០ ហើយឲ្យគិមញ៉ាំបាយជាមួយគាត់ផង ។
5. គិមទទួលប្រាក់ខែនេះ តែវាសុំបន្ទប់ទំនេរមួយនៅ ពីព្រោះវាគ្មានកន្លែងឯណានៅទេ ។
6. លោកនោះមានបន្ទប់ទំនេរនៅខាងក្រោយផ្ទះ ហើយប្រាប់គិមឲ្យមករៀបចំនៅ ។
7. គិមត្រេកអរណាស់ ហើយជំរាបលោកនោះថា: លោកចង់ឲ្យខ្ញុំមកនៅថ្ងៃណាក៏បាន ដែរ ។
8. គិមគ្មានអីវ៉ាន់ច្រើនទេ ។
9. លោកនោះចង់ឲ្យគិមមកនៅស្អែក ម៉ោង ៩ព្រឹក ។
10. ពេលនោះលោកនឹងប្រគល់សោឲ្យគិមមុន គាត់ចេញទៅធ្វើការ ។

1. Then they discuss salary and the work.
2. He asks Kim how much salary he wants.
3. Kim isn't decided; he says, "It depends on you."
4. The man thinks that he will give Kim five hundred a month and will have Kim eat with him.
5. Kim accepts this salary but he asks for a spare room to live in because he has no place stay.
6. The man has a spare room behind the house and tells Kim to fix it up.
7. Kim is very happy, and tells the man, "Whatever day you want me to come to stay is all right."
8. Kim doesn't have many possessions.
9. The man wants Kim to come tomorrow, at nine in the morning.
10. At that time the man will give the key to Kim before he goes off to work.

UNIT 61

BASIC DIALOGUE

1.	ស្អែកយើងគិតទៅណា ?	Pon	Where are we planning on going tomorrow?
2.	ស្អែកយើងនឹងធ្វើដំណើរទៅ ក្រុងកំពង់ចាម ។	Sok	Tomorrow we'll take a trip to Kompong Cham.
3.	កំពង់ចាមជាក្រុងយ៉ាងម៉េច ប្រាប់ខ្ញុំបន្តិចបានទេ ?	Pon	What's Kompong Cham like? Can you tell me a little bit?
4.	កំពង់ចាមជាក្រុងដ៏ស្អាតហើយ ទំនើបមួយ ដែលស្ថិតនៅតាម បណ្ដោយច្រាំង ទន្លេមេគង្គ ។	Sok	Kompong Cham is a very clean and modern city which is located on the banks of the Mekong.
5.	មានកប៉ាល់ច្រើនទេ ពីភ្នំពេញ ទៅកំពង់ចាម ?	Pon	Are there a lot of boats from Phnom Penh to Kompong Cham?
6.	មានកប៉ាល់ច្រើនណាស់ដែរ ពី ភ្នំពេញទៅកំពង់ ចាមហើយពី កំពង់ចាម មកភ្នំពេញវិញ ។	Sok	Yes, there are a lot of boats from Phnom Penh going to Kompong Cham and coming back from Kompong Cham to Phnom Penh.
7.	ពីនេះទៅនោះកប៉ាល់រត់ ប៉ុន្មានម៉ោងបានដល់ ?	Pon	How many hours does the boat take from Phnom Penh to Kompong Cham?
8.	អូ ខ្ញុំគិតស្មានប្រហែលដប់ ម៉ោងឬជាង ។ តាមផ្លូវ កប៉ាល់ ឈប់ច្រើនណាស់ ។	Sok	Oh, I think about twelve hours or more. The boat stops at a lot of places along the way.
9.	យើងត្រូវទិញសំបុត្រទុកមុន ឬ?	Pon	Do we have to buy the tickets in advance?

Sok

10. មិនបាច់ទេ។ កាលណាកប៉ាល់
ចេញទៅទើបគេលក់សំបុត្រ។

It's not necessary. They don't sell the tickets until the boat leaves.

Pon

11. គេយកថ្លៃប៉ុន្មានពីភ្នំពេញ
ទៅកំពង់ចាម?

How much does the boat charge from Phnom Penh to Kompong Cham?

Sok

12. មិនថ្លៃប៉ុន្មានទេ ប្រហែលម្ភៃ
ប្រាំរៀល ប៉ុណ្ណោះ។

It's not very expensive, maybe twenty-five riels; that's all.

Pon

13. យើងគិតឡើងកប៉ាល់ម៉ោង
ប៉ុន្មាន?

What time should we get on the boat?

Sok

14. ម៉ោង៤ព្រឹក។ យើងទៅកប៉ាល់
នោះដើម្បីឲ្យវាត្រជាក់បន្តិច។
យើងត្រូវទៅដល់កប៉ាល់ម៉ោង៣
ឬយ៉ាងយឺតណាស់ម៉ោង ៣,៣០។
កប៉ាល់មិនចាំយើងទេ វិតកាលណា
ដល់ម៉ោង គេចេញភ្លាម។
អញ្ចឹងយើងត្រូវទៅដល់នោះ
មុនម៉ោង។

Four in the morning. We're going on that boat so it'll be a little cool. We have to get to the docks at three or, at the latest, three-thirty. The boat won't wait for us; when the time comes to leave, it leaves immediately. In that case we have to get there ahead of time.

DRILLS

Drill A. Substitution

1.	កំពង់ចាមជាក្រុងមួយដ៏ស្អាតហើយទំនើប ។	Kompong Cham is a city that is beautiful and modern.
2.	កំពង់ចាមជាក្រុងមួយដ៏ធំហើយសំខាន់ ។	Kompong Cham is a city that is large and important.
3.	ភ្នំពេញជាក្រុងមួយដ៏ធំហើយសំខាន់ ។	Phnom Penh is a city that is large and important.
4.	ភ្នំពេញជាក្រុងមួយដែលស្ថិតនៅតាមទន្លេមេគង្គ ។	Phnom Penh is a city that is located on the Mekong.
5.	ស្ទឹងត្រែងជាក្រុងមួយដែលស្ថិតនៅតាមទន្លេមេគង្គ ។	Stung Treng is a city that is located on the Mekong.
6.	ស្ទឹងត្រែងជាក្រុងមួយដែលខ្ញុំស្គាល់យូរណាស់មកហើយ ។	Stung Treng is a city that I've known for a long time.
7.	កំពង់ចាមជាក្រុងមួយដែលខ្ញុំស្គាល់យូរណាស់មកហើយ ។	Kompong Cham is a city that I've known for a long time.
8.	កំពង់ចាមជាក្រុងមួយដ៏ស្អាតហើយទំនើប ។	Kompong Cham is a city that is beautiful and modern.

Drill B. Response

MODEL:

គ្រូ:	កំពង់ចាមជាទីក្រុងយ៉ាងម៉េច? (ស្អាតហើយទំនើប)	Teacher: What kind of a city is Kompong Cham? (beautiful and modern)
សិស្ស:	កំពង់ចាមជាក្រុងមួយដ៏ស្អាតហើយទំនើប ។	Student: Kompong Cham is a city that is beautiful and modern.

1.	ភ្នំពេញជាក្រុងយ៉ាងម៉េច? (ធំហើយសំខាន់)	ភ្នំពេញជាក្រុងមួយដ៏ធំហើយសំខាន់ ។
2.	សៀមរាបជាក្រុងយ៉ាងម៉េច? (ចាស់ហើយសំខាន់)	សៀមរាបជាក្រុងមួយដ៏ចាស់ហើយសំខាន់ ។
3.	កំពង់សោមជាក្រុងយ៉ាងម៉េច? (ល្អមើលហើយទំនើប)	កំពង់សោមជាក្រុងមួយដ៏ល្អមើលហើយទំនើប ។
4.	ភូមិតាខ្មៅជាភូមិយ៉ាងម៉េច?	ភូមិតាខ្មៅជាភូមិមួយដ៏តូចហើយ

	(តូចហើយស្អាត)	ស្អាត។
5.	លីសេស៊ីសុវត្ថិជាសាលារៀនយ៉ាងម៉េច? (ទំនើបហើយល្អ)	លីសេស៊ីសុវត្ថិជាសាលារៀនមួយដ៏ទំនើបហើយល្អ។
6.	អូតែលរ៉ូយ៉ាល់ជាអូតែលយ៉ាងម៉េច? (ធំហើយទំនើប)	អូតែលរ៉ូយ៉ាល់ជាអូតែលមួយដ៏ធំហើយទំនើប។

Drill C. Transformation

MODEL: ក្រុង : ក្រុងកំពង់ចាមឋិតនៅតាមបណ្ដោយទន្លេមេគង្គ។

Teacher: The city of Kompong Cham is located along the banks of the Mekong.

សិស្ស: ក្រុងកំពង់ចាមជាក្រុងមួយដែលឋិតនៅតាមបណ្ដោយច្រាំងទន្លេមេគង្គ។

Student: Kompong Cham is a city that is located along the banks of the Mekong.

1.	ក្រុងកំពង់សោមឋិតនៅមាត់សមុទ្រជិតឈូងសមុទ្រសៀម។	ក្រុងកំពង់សោមជាក្រុងមួយដែលឋិតនៅមាត់សមុទ្រជិតឈូងសមុទ្រសៀម។
2.	ខ្ញុំស្គាល់ក្រុងស្វាយរៀងយូរណាស់មកហើយ។	ស្វាយរៀងជាក្រុងមួយដែលខ្ញុំស្គាល់យូរណាស់មកហើយ។
3.	ខ្ញុំតែងតែទៅលេងក្រុងសៀមរាបយ៉ាងតិចណាស់១ឆ្នាំម្ដង។	សៀមរាបជាទីក្រុងមួយដែលខ្ញុំតែងតែទៅលេងយ៉ាងតិចណាស់១ឆ្នាំម្ដង។
4.	ក្រុងបាត់ដំបងនៅជិតទន្លេសាប។	ក្រុងបាត់ដំបងជាក្រុងមួយដែលឋិតនៅជិតទន្លេសាប។
5.	ក្រុងកំពង់ឆ្នាំងឋិតនៅតាមបណ្ដោយច្រាំងទន្លេសាប។	ក្រុងកំពង់ឆ្នាំងជាក្រុងមួយដែលឋិតនៅតាមបណ្ដោយច្រាំងទន្លេសាប។
6.	គេទើបសង់ក្រុងកំពង់សោមបាន១០ឆ្នាំហើយ។	ក្រុងកំពង់សោមជាក្រុងមួយដែលទើបនឹងសង់ហើយ។

Drill D. Substitution

1.	ពីភ្នំពេញទៅកំពង់ចាមកប៉ាល់ដើរប៉ុន្មានម៉ោង?	How many hours does it take the boat to go from Phnom Penh to Kompong Cham?

2.	ពីកំពង់ចាមទៅភ្នំពេញ កប៉ាល់រត់ប៉ុន្មានម៉ោង?	How many hours does it take the boat to go from Kompong Cham to Phnom Penh?
3.	ពីកំពង់ចាមទៅភ្នំពេញកប៉ាល់ឈប់ប៉ុន្មានកន្លែង?	How many places does the boat stop from Kompong Cham to Phnom Penh?
4.	ពីកំពង់ចាមទៅភ្នំពេញ កប៉ាល់យកថ្លៃប៉ុន្មាន?	How much does the boat charge from Kompong Cham to Phnom Penh?
5.	ពីភ្នំពេញទៅកំពង់ចាមកប៉ាល់យកថ្លៃប៉ុន្មាន?	How much does the boat charge from Phnom Penh to Kompong Cham?
6.	ពីភ្នំពេញទៅកំពង់ចាមមានកប៉ាល់ច្រើនទេ?	Are there many boats from Phnom Penh to Kompong Cham?
7.	ពីភ្នំពេញទៅកំពង់ចាមកប៉ាល់ឈប់ប៉ុន្មានកន្លែង?	How many places does the boat stop from Phnom Penh to Kompong Cham?
8.	ពីភ្នំពេញទៅកំពង់ចាមកប៉ាល់រត់ប៉ុន្មានម៉ោង?	How many hours does it take the boat to go from Phnom Penh to Kompong Cham?

Drill E. Response

MODEL: គ្រូ: ពីភ្នំពេញទៅកំពង់ចាម កប៉ាល់រត់ប៉ុន្មានម៉ោង? (ប្រហែល ១០ម៉ោងឬជាង)

Teacher: How many hours does it take the boat to go from Phnom Penh to Kompong Cham? (maybe 10 hours or more)

សិស្ស: កប៉ាល់រត់ប្រហែលដប់ម៉ោងឬជាង ។

Student: The boat takes maybe 10 hours or more.

1.	ពីកំពង់ចាមទៅភ្នំពេញកប៉ាល់រត់ប៉ុន្មានម៉ោង? (ប្រហែល៨ម៉ោង)	កប៉ាល់រត់ប្រហែល៨ម៉ោង ។
2.	ពីកំពង់ចាមទៅភ្នំពេញ កប៉ាល់ឈប់ប៉ុន្មានកន្លែង? (ប្រហែល៤កន្លែងឬជាង)	កប៉ាល់ឈប់ប្រហែល៤កន្លែងឬជាង ។
3.	ពីភ្នំពេញទៅកំពង់ចាមកប៉ាល់យកថ្លៃប៉ុន្មាន? (ប្រហែល២៤រៀលប៉ុណ្ណោះ)	កប៉ាល់យកប្រហែល២៤រៀលប៉ុណ្ណោះ ។
4.	ពីភ្នំពេញទៅកំពង់ចាមមានកប៉ាល់ប៉ុន្មានមួយឆ្នាំ? (ប្រហែល១០ឬជាង)	មានកប៉ាល់ប្រហែល ១០ ឬជាង ។
5.	ពីភ្នំពេញទៅកំពង់ចាមកប៉ាល់យកថ្លៃប៉ុន្មាន? (ប្រហែលម្ភៃរៀលជាង)	កប៉ាល់យកប្រហែលម្ភៃរៀលជាង ។

Drill F. Substitution

1.	កាលណាដល់ពេលចេញ កប៉ាល់ចេញភ្លាម។	When it comes time to go, the boat leaves immediately.
2.	កាលណាដល់ពេលចេញ កប៉ាល់មិនចាំយើងទេ។	When it comes time to go, the boat won't wait for us.
3.	កាលណាដល់ម៉ោងបួនព្រឹក កប៉ាល់មិនចាំយើងទេ។	When it gets to be 4:00 in the morning, the boat won't wait for us.
4.	កាលណាដល់ម៉ោង៤ ព្រឹក យើងត្រូវទៅដល់ផែកប៉ាល់។	When it gets to be 4:00 in the morning, we have to get to the dock.
5.	យ៉ាងយឺតណាស់ ម៉ោងបីកន្លះ យើងត្រូវទៅដល់ផែកប៉ាល់។	When it gets to be 3:30 at the latest, we have to get to the dock.
6.	យ៉ាងយឺតណាស់ ម៉ោងបីកន្លះ កប៉ាល់ចេញពីផែ។	When it gets to be 3:30 at the latest, the boat leaves the dock.
7.	កាលណាដល់ពេលចេញ កប៉ាល់ចេញពីផែ។	When it comes time to go, the boat leaves the dock.
8.	កាលណាដល់ពេលចេញ គេទើបលក់សំបុត្រ។	When it comes time to go, only then do they sell tickets.
9.	កាលណាដល់ពេលចេញ កប៉ាល់ចេញភ្លាម។	When it comes time to go, the boat leaves immediately.

Drill G. Response

MODEL:

គ្រូ ៖ យើងត្រូវទៅដល់ផែកប៉ាល់ម៉ោងប៉ុន្មាន?
(បី បីកន្លះ)

Teacher: At what time do we have to arrive at the dock? (three, three thirty)

សិស្ស៖ យើងត្រូវទៅដល់ផែកប៉ាល់ម៉ោងបី ឬយ៉ាងយឺតណាស់ម៉ោងបីកន្លះ។

Student: We have to arrive at the dock at three o'clock, or at the latest, 3:30.

1.	យើងចាប់រៀនម៉ោងប៉ុន្មាន? (ម៉ោង៩ ម៉ោង៩,១៥នាទី)	យើងចាប់រៀនម៉ោង៩ ឬយ៉ាងយឺតណាស់ម៉ោង៩ និង១៥នាទី។
2.	ដល់ម៉ោងប៉ុន្មានទើបគេលក់? (ម៉ោង៧ ម៉ោង៨)	ដល់ម៉ោង៧ ឬយ៉ាងយឺតណាស់ម៉ោង៨ទើបគេលក់។
3.	កប៉ាល់ចេញម៉ោងប៉ុន្មាន?	កប៉ាល់ចេញម៉ោង៤ ឬយ៉ាងយឺត

	(ម៉ោង៤ ម៉ោងបួនកន្លះ)	ណាស់ម៉ោងបួនកន្លះ ។
4.	យើងត្រូវចេញពីផ្ទះម៉ោងប៉ុន្មាន? (ម៉ោងប្រាំកន្លះ ម៉ោង៦)	យើងត្រូវចេញពីផ្ទះម៉ោងប្រាំកន្លះ ឬយ៉ាងយឺតណាស់ម៉ោង៦ ។
5.	គេបើកទ្វាររោងកុនស៊ីណេលុចម៉ោងប៉ុន្មាន? (ម៉ោង១២ ម៉ោង១២និង១៥នាទី)	គេបើកទ្វារម៉ោង១២ ឬយ៉ាងយឺតណាស់ម៉ោង១២និង១៥នាទី ។

Drill H. Response

MODEL: គ្រូ: យើងទៅដល់ផែកប៉ាល់ម៉ោងប៉ុន្មាន? (បីកន្លះ បី)

Teacher: At what time do we have to arrive at the dock? (three thirty, three)

សិស្ស: តាមខ្ញុំស្មាន យើងទៅដល់ផែកប៉ាល់ម៉ោងបីកន្លះឬយ៉ាងឆាប់ណាស់ម៉ោងបី។

Student: I think we will get to the dock at maybe three thirty, or at the earliest 3 o'clock.

1.	គេនឹងចាប់រៀនម៉ោងប៉ុន្មាន? (៩,១៥ ៩)	តាមខ្ញុំស្មាន គេចាប់រៀនម៉ោង៩និង១៥នាទី ឬយ៉ាងឆាប់ណាស់ម៉ោង៩ ។
2.	ដល់ម៉ោងប៉ុន្មានទើបគេលក់សំបុត្រ? (៨ ៧)	តាមខ្ញុំស្មាន ដល់ម៉ោង៨ ឬយ៉ាងឆាប់ណាស់ម៉ោង៧ទើបគេលក់សំបុត្រ។
3.	កប៉ាល់ចេញទៅម៉ោងប៉ុន្មាន? (៤,៣០ ៤)	តាមខ្ញុំស្មាន កប៉ាល់ចេញម៉ោង៤,៣០ ឬយ៉ាងឆាប់ណាស់ម៉ោង៤ ។
4.	យើងនឹងចេញពីផ្ទះម៉ោងប៉ុន្មាន? (៦ ៥,៣០)	តាមខ្ញុំស្មាន យើងចេញម៉ោង៦ ឬយ៉ាងឆាប់ណាស់ម៉ោង៥,៣០ ។
5.	គេនឹងបើកទ្វាររោងកុនស៊ីណេលុចម៉ោងប៉ុន្មាន? (១២,១៥ ១២)	តាមខ្ញុំស្មាន រោងកុនបើកទ្វារម៉ោង១២,១៥ ឬយ៉ាងឆាប់ណាស់ម៉ោង១២។

Drill I. Substitution

1.	ពីភ្នំពេញទៅកំពង់ចាមមានកប៉ាល់យ៉ាងតិចណាស់ដប់ ។	From Phnom Penh to Kompong Cham there are at least 10 boats.
2.	ពីភ្នំពេញទៅកំពង់ចាមកប៉ាល់ឈប់យ៉ាងតិចណាស់ ៥ កន្លែង ។	From Phnom Penh to Kompong Cham, the boat stops at at least five places.
3.	ពីកំពង់ចាមទៅភ្នំពេញកប៉ាល់ឈប់យ៉ាងតិចណាស់៥កន្លែង ។	From Kompong Cham to Phnom Penh, the boat stops at at least five places.

4.	ពីកំពង់ចាមទៅភ្នំពេញគេយកថ្លៃ យ៉ាងតិចណាស់ម្ភៃរៀល ។	From Kompong Cham to Phnom Penh, they charge at least 20 riels.
5.	ពីកំពង់ចាមទៅភ្នំពេញ កប៉ាល់រត់ យ៉ាងឆាប់ណាស់៨ម៉ោង ។	From Kompong Cham to Phnom Penh the boat takes 8 hours at the fastest.
6.	ពីកំពង់ចាមទៅភ្នំពេញ កប៉ាល់រត់ យ៉ាងយឺតណាស់១០ម៉ោង ។	From Kompong Cham to Phnom Penh, the boat takes 10 hours at the slowest.
7.	ពីភ្នំពេញទៅកំពង់ចាមកប៉ាល់រត់ យ៉ាងយឺតណាស់ ១០ម៉ោង ។	From Phnom Penh to Kampong Cham, the boat takes 10 hours at the slowest.
8.	ពី ភ្នំពេញទៅកំពង់ចាម មានកប៉ាល់ យ៉ាងតិចណាស់ ១០ ។	From Phnom Penh to Kompong Cham there are at least 10 boats.

Drill J. Transformation

MODEL:	គ្រូ: មានកប៉ាល់ដប់ឬជាង ។	Teacher:	There are 10 boats or more.
	សិស្ស: មានកប៉ាល់យ៉ាងតិចណាស់ ១០ ។	Student:	There are at least 10 boats.

MODEL:	គ្រូ: មានកប៉ាល់ ១០ ប៉ុណ្ណោះ ។	Teacher:	There are only 10 boats.
	សិស្ស: មានកប៉ាល់យ៉ាងច្រើនណាស់ ១០ ។	Student:	At the most, there are 10 boats.

កប៉ាល់ឈប់ប្រាំកន្លែងឬជាង ។	កប៉ាល់ឈប់យ៉ាងតិចណាស់ប្រាំកន្លែង ។
កប៉ាល់ឈប់៤កន្លែងប៉ុណ្ណោះ ។	កប៉ាល់ឈប់យ៉ាងច្រើនណាស់៤កន្លែង ។
កប៉ាល់រត់១០ម៉ោងឬជាង ។	កប៉ាល់រត់យ៉ាងតិចណាស់ ១០ម៉ោង ។
កប៉ាល់រត់៨ម៉ោងប៉ុណ្ណោះ ។	កប៉ាល់រត់យ៉ាងច្រើនណាស់ ៨ ម៉ោង ។
គេយកថ្លៃម្ភៃរៀលឬជាង ។	គេយក យ៉ាងតិចណាស់ម្ភៃរៀល ។
គេយកថ្លៃ២៥រៀលប៉ុណ្ណោះ ។	គេយកយ៉ាងច្រើនណាស់២៥រៀល ។
ដល់ម៉ោង៧ទើបគេលក់សំបុត្រ ។	គេលក់សំបុត្រយ៉ាងឆាប់ណាស់ម៉ោង៧ ។
ដល់ម៉ោង៧,៣០ទើបគេលក់សំបុត្រ ។	គេលក់សំបុត្រយ៉ាងយឺតណាស់ម៉ោង ៧,៣០ ។

UNIT 62

BASIC DIALOGUE

1.	ជិតដល់ពេលចេញហើយ ។ គេនាំគ្នាឡើងលើកប៉ាល់ហើយ ។	Sok	It's almost time to leave. They are going aboard the boat.
2.	ពួកមនុស្សឯណោះគេកំពុងធ្វើអី ?	Pon	What are the people over there doing?
3.	អ្នកខ្លះទិញអីវ៉ាន់យកទៅលក់ ។ ខ្លះទៀតទិញម្ហូបចំណីយកទៅឲ្យកូនចៅគេ ដែលរង់ចាំនៅផ្ទះ ។	Sok	Some are buying food to take to their children who are waiting for them at home.
4.	អីហ្នឹង ? ខ្ញុំឮសូរស៊ីផ្លេ ។	Pon	What is that? I heard a whistle blow.
5.	បាទ កប៉ាល់គេស៊ីផ្លេឲ្យ សញ្ញា ។ ដល់ពេលចេញហើយ ។	Sok	The boat blows the whistle as a signal. It's time to leave.
6.	អ្នកបើកកប៉ាល់នោះធ្វើអី ?	Pon	What are those boatmen doing?
7.	គេកំពុងដោះស្រាយពួរ ស្រាយច្រវាក់ ។ អ្នកអង្គុយនៅនោះគឺអ្នកដំណើរ ។ គេអង្គុយស្ងៀម បន្តិចទៀតគេលក់សំបុត្រកប៉ាល់ហើយ ។	Sok	They are untying ropes and chains. And those quiet people sitting are passengers. In a while, someone will come to sell them tickets.
8.	អ្នកជិះចេញថ្លៃស្មើគ្នាទាំងអស់ឬ ?	Pon	Do all the passengers pay the same price?
9.	ទេ គេចេញថ្លៃតាមចម្ងាយ ។	Sok	No. They pay (on the boat) according to the distance.

10.	សង្ខាងទន្លេគ្មានអីទេ។ ងងឹតណាស់។ តែយូរៗឃើញភ្លើងព្រិលៗតាមមាត់ទន្លេ។	Pon	There is nothing on either side of the river. It's very dark, but once in a while there are dim lights along the edges of the river.
11.	ភ្លើងទូកអ្នកនេសាទត្រី។	Sok	They are fishermen's lights.
12.	នៅលើមេឃ ឃើញផ្កាយមួយភ្លឺជាងគេ។ ផ្កាយអីហ្នឹង ដឹងទេ?	Pon	In the sky I see a star. It's brighter than the others. What's its name? Do you know?
13.	គេហៅជាផ្កាយព្រឹក។ នៅខាងមុខ ឃើញពណ៌ក្រហមស្រាលៗទេ?	Sok	That's called the "morning star". Do you see a light red color ahead of us?
14.	ជិតភ្លឺហើយ ណាស់ ។	Pon	Yes, I do. It's almost light already.

DRILLS

Drill A. Substitution

1.	អ្នកខ្លះទិញអីវ៉ាន់យកទៅលក់។	Some people buy things to take to sell.
2.	អ្នកខ្លះទិញអីវ៉ាន់យកទៅផ្ញើកូនចៅ។	Some people buy things to take to their children.
3.	អ្នកខ្លះទិញនំប៉័ងយកទៅផ្ញើកូនចៅ។	Some people buy bread to take to their children.
4.	អ្នកខ្លះទៀតទិញនំប៉័ងយកទៅផ្ញើកូនចៅ។	Some others buy bread to take to their children.
5.	អ្នកខ្លះទៀតទិញផ្លែឈើយកទៅផ្ញើកូនចៅ។	Some others buy fruit to take to their children.
6.	អ្នកខ្លះទៀតទិញផ្លែឈើយកទៅជូនឪពុកម្ដាយ។	Some others buy fruit to take to their parents.
7.	អ្នកខ្លះទិញផ្លែឈើយកទៅជូនឪពុកម្ដាយ។	Some people buy fruit to take to their parents.
8.	អ្នកខ្លះទិញអីវ៉ាន់យកទៅជូនឪពុកម្ដាយ។	Some people buy things to take to their parents.
9.	អ្នកខ្លះទិញអីវ៉ាន់យកទៅលក់។	Some people buy things to take to sell.

Drill B. Response

MODEL:	គ្រូៈ ហេតុបានជាកប៉ាល់ទាញស៊ីផ្លេ? (ដល់ពេលចេញហើយ)	Teacher: Why is the boat blowing the whistle? (it's time to leave)
	សិស្សៈ កប៉ាល់ទាញស៊ីផ្លេឲ្យសញ្ញា ដល់ពេលចេញហើយ។	Student: The boat blows the whistle as a signal that it's time to leave.

1.	ហេតុបានជាកប៉ាល់ទាញស៊ីផ្លេ? (ថាដល់ពេលចេញ)	កប៉ាល់ទាញស៊ីផ្លេឲ្យសញ្ញា ថាដល់ពេលចេញ។
2.	ហេតុបានជាឡានឈ្នួលទាញស៊ីផ្លេ? (ថាដល់ពេលចេញ)	ឡានឈ្នួលទាញស៊ីផ្លេឲ្យសញ្ញា ថាដល់ពេលចេញ។
3.	ហេតុបានជាគ្រូបង្រៀនលើកដៃ?	គ្រូបង្រៀនលើកដៃឲ្យសញ្ញា កូនសិស្ស

	(កូនសិស្ស អង្គុយស្ងៀម)	អង្គុយស្ងៀម។
4.	ម៉េចបានជាអ្នកជិះលើកដៃ? (គេចង់ចុះពីឡាន)	អ្នកជិះលើកដៃឲ្យសញ្ញា គេចង់ចុះពីឡាន។
5.	ម៉េចបានជាកប៉ាល់ទាញស៊ីផ្លេ? (ដល់ពេលឡើងលើកប៉ាល់ហើយ)	កប៉ាល់ទាញស៊ីផ្លេឲ្យសញ្ញា ដល់ពេលឡើងលើកប៉ាល់ហើយ។

Drill C. Transformation

MODEL:	គ្រូ: អ្នកដើរកប៉ាល់ស្រាយពួរ ស្រាយច្រវាក់។ ឯអ្នកដំណើរអង្គុយស្ងៀម។	Teacher:	The workers on the boat untie the ropes and untie the chains. As for the passengers, they sit quietly.
	សិស្ស: នៅពេលដែលអ្នកដំណើរអង្គុយស្ងៀម អ្នកដើរកប៉ាល់ស្រាយពួរស្រាយច្រវាក់។	Student:	At the time the passengers are sitting quietly, the workers on the boat untie the ropes and untie the chains.

1.	អ្នកដើរកប៉ាល់ដើរលក់សំបុត្រឲ្យអ្នកជិះ។ ឯអ្នកជិះគេឡើងលើកប៉ាល់។	នៅពេលដែលអ្នកជិះឡើងលើកប៉ាល់ អ្នកដើរកប៉ាល់លក់សំបុត្រឲ្យអ្នកជិះ។
2.	អ្នកជិះទិញផ្លែឈើនឹងនំចាប់ឲ្យកូនចៅ។ ឯកូនចៅមើលតែផ្លូវនៅឯផ្ទះ។	នៅពេលដែលកូនចៅមើលផ្លូវនៅឯផ្ទះ អ្នកជិះទិញផ្លែឈើនឹងនំចាប់។
3.	អ្នកដំណើរឡើងលើកប៉ាល់។ ឯអ្នកដើរកប៉ាល់អង្គុយស្ងៀម។	នៅពេលដែលអ្នកដើរកប៉ាល់អង្គុយស្ងៀម អ្នកដំណើរឡើងលើកប៉ាល់។
4.	គ្រូបង្រៀនមើលមេរៀនថ្មី។ ឯកូនសិស្សអង្គុយស្ងៀមស្តាប់។	នៅពេលកូនសិស្សអង្គុយស្ងៀមស្តាប់ គ្រូបង្រៀនមើលមេរៀនថ្មី។
5.	អ្នកដើរកប៉ាល់ស្រាយពួរ ស្រាយច្រវាក់។ ឯអ្នកលក់អីវ៉ាន់ចុះពីកប៉ាល់។	នៅពេលអ្នកលក់អីវ៉ាន់ចុះពីកប៉ាល់ អ្នកដើរកប៉ាល់ស្រាយពួរ ស្រាយច្រវាក់។

Drill D. Substitution

1.	មួយសន្ទុះទៀត គេនឹងដើរលក់សំបុត្រឲ្យអ្នកជិះ។	In another moment the workers will go about selling tickets to the passengers.
2.	មួយសន្ទុះទៀត គេនឹងឈប់លក់សំបុត្រឲ្យអ្នកជិះ។	In another moment the workers will finish selling tickets to the passengers.
3.	ឥឡូវ គេនឹងឈប់លក់សំបុត្រឲ្យ	Now the workers will finish selling

	អ្នកជិះ។	tickets to the passengers.
4.	ឥឡូវ គេនឹងឈប់លក់សំបុត្រឲ្យអ្នកដំណើរ។	Now the workers will finish selling tickets to the travellers.
5.	ឥឡូវ គេនឹងទាញស៊ីហ្វ្លេ ឲ្យអ្នកដំណើរដឹង។	Now the workers will blow the whistle to let the travellers know.
6.	មួយសន្ទុះទៀត គេនឹងទាញស៊ីហ្វ្លេឲ្យអ្នកដំណើរដឹង។	In another moment the workers will blow the whistle to let the travellers know.
7.	មួយសន្ទុះទៀតគេនឹងទាញស៊ីហ្វ្លេឲ្យអ្នកជិះដឹង។	In another moment the workers will blow the whistle to let the passengers know.
8.	មួយសន្ទុះទៀត គេនឹងដើរលក់សំបុត្រឲ្យអ្នកជិះ។	In another moment the workers will go about selling tickets to the passengers.

Drill E. Substitution

1.	អ្នកជិះចេញថ្លៃស្មើគ្នាទាំងអស់ឬ?	Do the passengers all pay the same fare?
2.	អ្នកជិះធ្វើដំណើរចម្ងាយស្មើគ្នាទាំងអស់ឬ?	Do the passengers all travel the same distance?
3.	កប៉ាល់រត់ចម្ងាយស្មើគ្នាទាំងអស់ឬ?	Do the boats all travel the same distance?
4.	កប៉ាល់រត់ល្បឿនស្មើគ្នាទាំងអស់ឬ?	Do the boats all travel the same speed?
5.	ទូកនេសាទត្រីល្បឿនស្មើគ្នាទាំងអស់ឬ?	Do the fishing boats all travel the same speed?
6.	ទូកនេសាទត្រីធំប៉ុណគ្នាទាំងអស់ឬ?	Are all fishing boats the same size?
7.	ទូកនេសាទត្រីថ្លៃស្មើគ្នាទាំងអស់ឬ?	Do all fishing boats cost the same?
8.	អ្នកជិះចេញថ្លៃស្មើគ្នាទាំងអស់ឬ?	Do all the passengers pay the same fare?

Drill F. Expansion

1.	តាមចម្ងាយ។	According to distance.
2.	បាទទេ តាមចម្ងាយ។	No, according to distance.
3.	បាទទេ គេយកតាមចម្ងាយ។	No, they charge a fare according to distance.
4.	បាទទេ គេយកតាមតម្លៃចម្ងាយ។	No, they charge a fare which they charge according to distance.
5.	បាទទេ គេចេញតាមតម្លៃចម្ងាយ គេយក។	No, they pay a fare according to what they charge by distance.
6.	បាទទេ គេចេញថ្លៃតាមតម្លៃចម្ងាយ គេយក។	No, they pay a fare according to the fare which they charge by distance.

Drill G. Reduction

1.	បាទទេ គេចេញថ្លៃតាមតម្លៃ ចម្ងាយគេយក។	No, they pay a fare according to the fare which they charge by distance.
2.	បាទទេ គេចេញតាមតម្លៃចម្ងាយ គេយក។	No, they pay a fare according to what they charge by distance.
3.	បាទទេ គេយកតាមតម្លៃចម្ងាយ។	No, they charge a fare which they charge according to distance.
4.	បាទទេ គេយកតាមចម្ងាយ។	No, they charge a fare according to distance.
5.	បាទទេ តាមចម្ងាយ។	No, according to distance.
6.	តាមចម្ងាយ។	According to distance.

Drill H. Substitution

1.	មើលទៅសងខាងទន្លេ គ្មានឃើញអីទេ។	If you look at both sides of the river, you won't see anything.
2.	មើលទៅសងខាងទន្លេ ឃើញដើមឈើច្រើនណាស់។	If you look at both sides of the river, you will see many trees.
3.	មើលទៅខាងកើត ឃើញដើមឈើច្រើនណាស់។	If you look to the east of the river, you will see many trees.
4.	មើលទៅខាងកើត ឃើញជណ៍	If you look to the east of the

ក្រហមព្រាលៗ ។ — river, you will see a light red color.

5. មើលទៅលើមេឃ ឃើញពណ៌ក្រហមព្រាលៗ ។ — If you look in the sky, you will see a light red color.

6. មើលទៅលើមេឃ ឃើញ ផ្កាយមួយភ្លឺជាងគេ ។ — If you look in the sky, you will see the brightest star.

7. មើលទៅទិសដែលកប៉ាល់បើកទៅ ឃើញផ្កាយមួយភ្លឺជាងគេ ។ — If you look in the direction the boat's going, you will see the brightest star.

8. មើលទៅទិសដែលកប៉ាល់បើកទៅ ឃើញភ្លើងឆ្លិងៗ ។ — If you look in the direction the boat's going, you will see a dim floating light.

9. មើលទៅតាមមាត់ទន្លេ ឃើញភ្លើងឆ្លិងៗ ។ — If you look along the shore, you will see a dim floating light.

10. មើលទៅតាមមាត់ទន្លេ ឃើញភ្លើងទូកអ្នកនេសាទត្រី ។ — If you look along the shore, you will see lights in fishing boats.

11. មើលទៅសង្ខាងទន្លេ ឃើញភ្លើងទូកអ្នកនេសាទត្រី ។ — If you look at both sides of the river, you will see lights in fishing boats.

12. មើលទៅសង្ខាងទន្លេ គ្មានឃើញអីទេ ។ — If you look at both sides of the river, you won't see anything.

Drill I. Transformation

MODEL: គ្រូ: បើខ្ញុំឃើញពណ៌ក្រហមព្រាលៗនោះ ខ្ញុំដឹងថាជិតភ្លឺហើយ ។ — Teacher: If I see the light red color, I know it's near dawn already.

សិស្ស: ពណ៌ក្រហមព្រាលៗនោះ បញ្ជាក់ឲ្យដឹងថាជិតភ្លឺហើយ ។ — Student: The light red color indicates that it's close to dawn already.

1. បើខ្ញុំឃើញផ្កាយព្រឹក ខ្ញុំដឹងថាជិតភ្លឺហើយ ។ — ផ្កាយព្រឹកបញ្ជាក់ឲ្យដឹងថាជិតភ្លឺហើយ ។

2. បើខ្ញុំឃើញភ្លើងឆ្លិងៗនោះ ខ្ញុំដឹងថាទូកអ្នកនេសាទត្រីនៅតាមមាត់ទន្លេ ។ — ភ្លើងឆ្លិងៗនោះបញ្ជាក់ឲ្យដឹងថាទូកអ្នកនេសាទត្រីនៅតាមមាត់ទន្លេ ។

3. បើខ្ញុំឃើញពួរនឹងប្រហាក់ស្រាយអស់ហើយ ខ្ញុំដឹងថាជិតដល់ពេលកប៉ាល់ចេញ ។ — ពួរនឹងប្រហាកស្រាយអស់ហើយ បញ្ជាក់ឲ្យដឹងថាជិតដល់ពេលកប៉ាល់ចេញ ។

4.	បើខ្ញុំឮស្នូរស៊ីផ្លេ ខ្ញុំដឹងថាជិតដល់ពេលកប៉ាល់ចេញ។	ឮស្នូរស៊ីផ្លេ បញ្ជាក់ឲ្យដឹងថាជិតដល់ពេលកប៉ាល់ចេញ។
5.	បើខ្ញុំឮស្នូរស៊ីផ្លេ ខ្ញុំដឹងថាកប៉ាល់មកដល់វិញហើយ។	ឮស្នូរស៊ីផ្លេ បញ្ជាក់ឲ្យដឹងថាកប៉ាល់មកដល់វិញហើយ។
6.	បើខ្ញុំឃើញសៀវភៅលឿងៗនោះ ខ្ញុំដឹងថាគេកំពុងរៀនមើលអក្សរខ្មែរ។	សៀវភៅលឿងៗនោះ បញ្ជាក់ឲ្យដឹងថាគេកំពុងរៀនមើលអក្សរខ្មែរ។

Drill J. Transformation

MODEL: គ្រូ: ពណ៌ក្រហមស្រាលៗនោះ បញ្ជាក់ឲ្យដឹងថាជិតភ្លឺហើយ។ (បើខ្ញុំឃើញ)

Teacher: The light red color indicates that it's close to dawn already.

សិស្ស: បើខ្ញុំឃើញពណ៌ក្រហមស្រាលៗនោះ ខ្ញុំដឹងថាជិតភ្លឺហើយ។

Student: If I see the light red color, I know it's near dawn already.

1.	ផ្កាយព្រឹកបញ្ជាក់ឲ្យដឹងថាជិតភ្លឺហើយ។ (បើខ្ញុំឃើញ)	បើខ្ញុំឃើញផ្កាយព្រឹក ខ្ញុំដឹងថាជិតភ្លឺហើយ។
2.	ភ្លើងឆ្លុងៗនោះបញ្ជាក់ឲ្យដឹងថាទូកអ្នកនេសាទត្រីនៅតាមមាត់ទន្លេ។	បើខ្ញុំឃើញភ្លើងឆ្លុងៗនោះ ខ្ញុំដឹងថាទូកអ្នកនេសាទត្រីនៅតាមមាត់ទន្លេ។
3.	ពួរនិងច្រវាក់ស្រាយអស់ហើយ បញ្ជាក់ឲ្យដឹងថាជិតដល់ពេលកប៉ាល់ចេញ។	បើខ្ញុំឃើញពួរនិងច្រវាក់ស្រាយអស់ហើយ ខ្ញុំដឹងថាជិតដល់ពេលកប៉ាល់ចេញ។
4.	ឮស្នូរស៊ីផ្លេ បញ្ជាក់ឲ្យដឹងថាជិតដល់ពេលកប៉ាល់ចេញហើយ។	បើខ្ញុំឮស្នូរស៊ីផ្លេ ខ្ញុំដឹងថាជិតដល់ពេលកប៉ាល់ចេញហើយ។
5.	ឮស្នូរស៊ីផ្លេ បញ្ជាក់ឲ្យដឹងថាកប៉ាល់មកដល់ហើយ។	បើខ្ញុំឮស្នូរស៊ីផ្លេ ខ្ញុំដឹងថាកប៉ាល់មកដល់ហើយ។
6.	សៀវភៅលឿងបញ្ជាក់ឲ្យដឹងថាគេកំពុងរៀនមើលអក្សរខ្មែរ។	បើខ្ញុំឃើញសៀវភៅលឿង ខ្ញុំដឹងថាគេកំពុងរៀនអក្សរខ្មែរ។

UNIT 63

BASIC DIALOGUE

1.	Pon	ស៊ីហ្វ្លេអីហ្នឹង?	What's that whistle?
2.	Sok	កប៉ាល់ទាញស៊ីហ្វ្លេប្រាប់អ្នកដំណើរ ជិតដល់កន្លែងចុះ ត្រូវរៀបចំខ្លួន។	The boat blows the whistle to tell the travellers that it's about to arrive at a stop, and that they must get ready.
3.	Pon	ដល់កំពង់ចាមហើយ? ឆាប់ណាស់។	We've arrived in Kompong Cham already. That's very fast.
4.	Sok	មិនមែនកំពង់ចាមទេ។ នេះជាកន្លែងចុះមួយតូច មិនទាន់ដល់កំពង់ចាមទេ។ កប៉ាល់ចូលផែហើយ។	It's not Kompong Cham. This is a small stop; we haven't arrived in Kompong Cham yet. Look, the boat is coming into the docks.
5.	Pon	គេលក់អីខ្លះនៅលើផែ?	What are they selling on the dock?
6.	Sok	គេលក់នំ ម្ហូប ហើយនិងផ្លែឈើផង។ កប៉ាល់ចេញពីផែមួយទៅផែមួយទៀត។	Oh, they're selling cakes, food, and fruit too. The boat leaves one dock and goes to another.
7.	Pon	គេមានលក់ម្ហូបរាល់តែផែឬអី?	Do they sell food on every dock?
8.	Sok	មាន ហើយមានមនុស្សចុះឡើងតែរាល់ផែផង។	They do. And there are people getting off and on at each dock.
9.	Pon	ពេលព្រឹក តាមបណ្ដោយមាត់ទន្លេនេះល្អណាស់។	I find the landscape along the river in the morning very pretty.
10.	Sok	ផ្ទះអ្នកស្រុកសុទ្ធតែមានដើមឈើជុំវិញ មានស្វាយ ក្រូច ជាដើម។	Yes, the houses of the peasants are all surrounded by trees. Mango and orange, for example.

11.	ថ្ងៃក្ដៅបន្តិចៗហើយ។	Pon	Now the sun is getting hotter little by little.
12.	ម៉ោងជិតមួយហើយ។ជិតដល់កំពង់ចាមហើយ។ កប៉ាល់ចូលតែផែទន្លេបិទមួយទៀតទេ។	Sok	It's almost one o'clock. We're getting close to Kompong Cham. The boat still only has to go to the docks at Tonle Bat.
13.	មើលពីទន្លេបិទទៅឃើញកំពង់ចាមទេ?	Pon	If you look from Tonle Bat do you see Kompong Cham?
14.	ឃើញច្បាស់ហើយ ល្អណាស់ផង។ កប៉ាល់ឆ្លងទៅត្រើយខាងជើង ចូលចតផែក្រុងកំពង់ចាម ប្រហែលសាមសិបនាទីទៀតបានយើងទៅដល់។	Sok	Yes, you can see clearly, and it's pretty too. The boat will cross to the north bank and enter and stop at the dock of Kompong Cham in about thirty minutes more; then we will have arrived.
15.	សប្បាយណាស់ ធ្វើដំណើរនេះ ហើយមានប្រយោជន៍ផង។	Pon	This is a very pleasant trip, and it's interesting too.

DRILLS

Drill A. Substitution

1.	កប៉ាល់ទាញស៊ីហ្វ្លេប្រាប់អ្នកដំណើរ ជិតដល់កន្លែងចុះ។	The boat blows its whistle to tell the travellers they are about to arrive at a landing.
2.	កប៉ាល់ទាញស៊ីហ្វ្លេឲ្យសញ្ញាអ្នកដំណើរ ជិតដល់កន្លែងចុះ។	The boat blows its whistle as a signal to the travellers they are about to arrive at a landing.
3.	កប៉ាល់ទាញស៊ីហ្វ្លេឲ្យសញ្ញាអ្នកដំណើរ ត្រូវរៀបចំខ្លួន។	The boat blows its whistle as a signal to the travellers to get ready.
4.	ឡានឈ្នួលទាញស៊ីហ្វ្លេឲ្យសញ្ញាអ្នកដំណើរ ត្រូវរៀបចំខ្លួន។	The bus blows its horn as a signal to the travellers to get ready.
5.	ឡានឈ្នួលទាញស៊ីហ្វ្លេប្រាប់អ្នកដំណើរ ត្រូវរៀបចំខ្លួន។	The bus blows its horn to tell the travellers to get ready.
6.	ឡានឈ្នួលទាញស៊ីហ្វ្លេប្រាប់អ្នកដំណើរ ជិតដល់ពេលចេញហើយ។	The bus blows its horn to tell the travellers it's about time to leave.
7.	ឡានឈ្នួលទាញស៊ីហ្វ្លេប្រាប់អ្នកជិះ ជិតដល់ពេលចេញហើយ។	The bus blows its horn to tell the passengers it's about time to leave.
8.	កប៉ាល់ទាញស៊ីហ្វ្លេប្រាប់អ្នកជិះជិត ដល់ពេលចេញហើយ។	The boat blows its whistle to tell the passengers it's about time to leave.
9.	កប៉ាល់ទាញស៊ីហ្វ្លេប្រាប់អ្នកជិះជិតដល់ កន្លែងចុះ។	The boat blows its whistle to tell the passengers they are about to arrive at a landing.
10.	កប៉ាល់ទាញស៊ីហ្វ្លេប្រាប់អ្នកដំណើរ ជិតដល់កន្លែងចុះ។	The boat blows its whistle to tell the travellers they are about to arrive at a landing.

Drill B. Response

MODEL:	គ្រូ: ដល់កំពង់ចាមហើយ? (កន្លែងចុះមួយតូច)	Teacher: We've arrived in Kampong Cham. (small landing)
	សិស្ស: នេះជាកន្លែងចុះមួយតូច មិនទាន់ដល់កំពង់ចាមទេ។	Student: This is a little landing; we haven't arrived in Kampong Cham yet.
1.	ដល់ភ្នំពេញហើយ? (ចំណតយន្តហោះសៀមរាប)	នេះជាចំណតយន្តហោះសៀមរាប មិនទាន់ដល់ភ្នំពេញទេ។

2. ដល់បាត់ដំបងហើយ? (ភូមិមួយតូច)	នេះជាភូមិមួយតូច មិនទាន់ដល់បាត់ដំបងទេ។
3. ដល់កំពង់សោមហើយ? (កោះមួយតូច)	នេះជាកោះមួយតូច មិនទាន់ដល់កំពង់សោមទេ។
4. ដល់ភ្នំពេញហើយ? (ផែកប៉ាល់មួយតូច)	នេះជាផែកប៉ាល់មួយតូច មិនទាន់ដល់ភ្នំពេញទេ។
5 ដល់កំពង់ឆ្នាំងហើយ? (កន្លែងឈប់ឡានមួយ)	នេះជាកន្លែងឈប់ឡានមួយ មិនទាន់ដល់កំពង់ឆ្នាំងទេ។

Drill C. Double Substitution

1. កប៉ាល់ចេញពីផែមួយ ចូលផែមួយទៀត។	The boat leaves one dock (and) goes to another dock.
2. ឡានឈ្នួលចេញពីកន្លែងឈប់មួយ ចូលកន្លែងឈប់មួយទៀត។	The bus leaves one stop (and) goes to another stop.
3. កប៉ាល់ហោះចេញពីវាលយន្តហោះមួយ ចូលវាលយន្តហោះមួយទៀត។	The plane leaves one airport (and) goes to another airport.
4. រទេះភ្លើងចេញពីស្ថានីយមួយ ចូលស្ថានីយមួយទៀត។	The train leaves one station (and) goes to another station.
5. កូនសិស្សចេញពីបន្ទប់រៀនមួយ ចូលបន្ទប់រៀនមួយទៀត។	The students leave one room (and) go to another room.
6. អ្នកលក់ម្ហូបចេញពីហាងមួយ ចូលហាងមួយទៀត។	The food vendors leave one shop (and) go to another shop.
7. កម្មករចេញពីឃ្លាំងមួយ ចូលឃ្លាំងមួយទៀត។	The workers leave one warehouse (and) go to another warehouse.
8. កប៉ាល់ចេញពីផែមួយ ចូលផែមួយទៀត។	The boat leaves one dock (and) goes to another dock.

Drill D. Response

MODEL:	គ្រូ : តើមានឈប់ចតនៅគ្រប់ផែទាំងអស់ទេ? (មនុស្សចុះឡើង)	Teacher: Do they stop off at every dock? (people get off and on)
	សិស្ស: បាទមាន ហើយមានមនុស្សចុះឡើងនៅគ្រប់ផែទាំងអស់ផង។	Student: Yes. And there are people getting off and on at every dock.

1.	មានមនុស្សចុះឡើងពាស់ពេញស្ថានីយឬទេ? (លក់ផ្លែឈើ)	បាទមាន ហើយមានមនុស្សលក់ផ្លែឈើពាស់ពេញស្ថានីយដែរ។
2.	គេមានលក់សំបុត្រពាស់ពេញកន្លែងចុះឬទេ? (ផែនទីស្រុកនោះ)	បាទមាន ហើយមានផែនទីស្រុកនោះពាស់ពេញកន្លែងចុះដែរ។
3.	គេមានបន្ទប់សម្រាកពាស់ពេញវាលយន្តហោះឬទេ? (ភោជនីយដ្ឋានល្អៗ)	បាទមាន ហើយមានភោជនីយដ្ឋានល្អៗពាស់ពេញវាលយន្តហោះដែរ។
4.	គេមានភោជនីយដ្ឋានពាស់ពេញកន្លែងចុះឬទេ? (ហាងលក់ឥវ៉ាន់)	បាទមាន ហើយមានហាងលក់ឥវ៉ាន់ពាស់ពេញកន្លែងចុះដែរ។
5.	គេលក់ឥវ៉ាន់ពាស់ពេញផែឬទេ? (មនុស្សចុះឡើង)	បាទមាន ហើយមានមនុស្សចុះឡើងពាស់ពេញផែដែរ។

Drill E. Substitution

1.	ផ្ទះអ្នកស្រុកសុទ្ធតែព័ទ្ធជុំវិញដោយដើមឈើ។	The houses of peasants are all surrounded by trees.
2.	ផ្ទះអ្នកស្រុកសុទ្ធតែព័ទ្ធជុំវិញដោយកំពែង។	The houses of peasants are all surrounded by walls.
3.	ផ្ទះអ្នករដ្ឋការសុទ្ធតែព័ទ្ធជុំវិញដោយកំពែង។	The houses of government officials are all surrounded by walls.
4.	ផ្ទះអ្នករដ្ឋការសុទ្ធតែព័ទ្ធជុំវិញដោយទាហាន។	The houses of government officials are all surrounded by soldiers.
5.	ភូមិតូចៗសុទ្ធតែព័ទ្ធជុំវិញដោយទាហាន។	Small villages are all surrounded by soldiers.
6.	ភូមិតូចៗសុទ្ធតែព័ទ្ធជុំវិញដោយសួនច្បារ។	Small villages are all surrounded by gardens.
7.	វត្តនឹងវិហារសុទ្ធតែព័ទ្ធជុំវិញដោយសួនច្បារ។	Wats and temples are all surrounded by gardens.
8.	វត្តនឹងវិហារសុទ្ធតែព័ទ្ធជុំវិញដោយដើមឈើ។	Wats and temples are all surrounded by trees.
9.	ផ្ទះអ្នកស្រុកសុទ្ធតែព័ទ្ធជុំវិញដោយដើមឈើ។	The houses of peasants are all surrounded by trees.

Drill F. Equivalence drill

MODEL:	គ្រូ: មានដើមឈើនៅជុំវិញផ្ទះអ្នកស្រុកគ្រប់ផ្ទះ។	Teacher:	There are trees around all the houses of the peasants.
	សិស្ស: ផ្ទះអ្នកស្រុកសុទ្ធតែព័ទ្ធជុំវិញដោយដើមឈើ។	Student:	The houses of the peasants are all surrounded by trees.

1.	មានកំពែងនៅជុំវិញអ្នកធ្វើការ។	ផ្ទះអ្នកធ្វើការសុទ្ធតែព័ទ្ធដោយកំពែង។
2.	មានទាហាននៅជុំវិញភូមិតូចៗគ្រប់ភូមិ។	ភូមិតូចៗគ្រប់ភូមិសុទ្ធតែព័ទ្ធជុំវិញដោយទាហាន។
3.	មានសួនច្បារនៅជុំវិញវត្តនិងវិហារទាំងអស់។	វត្តនិងវិហារសុទ្ធតែព័ទ្ធដោយសួនច្បារជុំវិញ។
4.	មានកំពែងនៅជុំវិញភូមិតូចៗគ្រប់ភូមិ។	ភូមិតូចៗសុទ្ធតែព័ទ្ធជុំវិញដោយកំពែង។
5.	មានទាហាននៅជុំវិញផ្ទះអ្នកធ្វើការគ្រប់ផ្ទះ។	ផ្ទះអ្នកធ្វើការសុទ្ធតែព័ទ្ធជុំវិញដោយទាហាន។

Drill G. Substitution

1.	កប៉ាល់នៅតែចូលផែទន្លេបិទមួយ ទៀតទេ។	The boat still will enter only one more dock.
2.	កប៉ាល់នៅចូលតែ កន្លែងចុះមួយទៀតទេ។	The boat still will enter only one more stop (landing).
3.	ឡានឈ្នួលនៅតែចូលកន្លែងចុះមួយទៀតទេ។	The bus still will enter only one more stop.
4.	ឡានឈ្នួលនៅចូលតែ ភូមិតូចមួយទៀតទេ។	The bus still will enter only one more small village.
5.	រទេះភ្លើងនៅចូលតែភូមិតូចមួយទៀតទេ។	The train still will enter only one more small village.
6.	រទេះភ្លើងនៅចូលតែ ស្ថានីយកំពង់ឆ្នាំងមួយទៀតទេ។	The train still will enter only Kompong Chang station.
7.	ឡានឈ្នួលនៅចូលតែស្ថានីយកំពង់ឆ្នាំងមួយទៀតទេ។	The bus still will enter only Kompong Chang station.
8.	ឡានឈ្នួលនៅចូលតែផែទន្លេបិទ១ ទៀតទេ។	The bus still will enter only Tonle Bat dock.
9.	កប៉ាល់នៅចូលតែផែទន្លេបិទ១ទៀតទេ។	The boat still will enter only Tonle Bat dock.

Drill H. Transformation

MODEL:	គ្រូ: កប៉ាល់នៅចូលតែផែទន្លេបិទមួយទៀតទេ។	Teacher:	The ship will enter only one more dock, at Tonle Bat.
	សិស្ស: ក្រៅពីផែទន្លេបិទ កប៉ាល់មិនចូលផែណាទៀតទេ។	Student:	Besides the Tonle Bat dock, the ship won't go to any other dock.

1.	ឡានឈ្នួលចូលតែកន្លែងចុះព្រែកក្ដាមមួយទៀតទេ។	ក្រៅពីកន្លែងចុះព្រែកក្ដាម ឡានឈ្នួលមិនចូលកន្លែងចុះណាទៀតទេ។
2.	រទេះភ្លើងចូលតែស្ថានីយកំពង់ឆ្នាំងមួយទៀតទេ។	ក្រៅពីស្ថានីយកំពង់ ឆ្នាំងរទេះភ្លើងមិនចូលស្ថានីយណាទៀតទេ។
3.	យន្តហោះចុះតែវាលកប៉ាល់ហោះសៀមរាបមួយទៀតទេ។	ក្រៅពីវាលកប៉ាល់ហោះសៀមរាប យន្តហោះមិនចុះវាលណាទៀតទេ។
4.	ឡានចូលតែភូមិតាខ្មៅមួយទៀតទេ។	ក្រៅពីភូមិតាខ្មៅ ឡានមិនចូលភូមិណាទៀតទេ។
5.	កប៉ាលចូលផែព្រែកក្ដាមមួយទៀតទេ។	ក្រៅពីផែព្រែកក្ដាម កប៉ាល់មិនចូលផែណាទៀតទេ។

Drill I. Response

MODEL:	គ្រូ: នេះជាដំណើរយ៉ាងម៉េច? (មួយសប្បាយ មានប្រយោជន៍)	Teacher:	What kind of trip is this? (happy, interesting)
	សិស្ស: នេះជាដំណើរមួយយ៉ាងសប្បាយហើយមានប្រយោជន៍ផង។	Student:	This is a very happy trip, and interesting also.

1.	ទេសភាពពេលព្រឹកតាមបណ្ដោយទន្លេនេះ លោកឃើញយ៉ាងម៉េច? (សប្បាយ ល្អមើល)	ខ្ញុំឃើញទេសភាពយ៉ាងសប្បាយហើយល្អមើលផង។
2.	មើលពីទន្លេបិទលោកឃើញក្រុងកំពង់ចាមទេ? (ច្បាស់ល្អណាស់)	ខ្ញុំឃើញក្រុងកំពង់ចាមយ៉ាងច្បាស់ហើយល្អណាស់ដែរ។
3.	កំពង់ចាមជាក្រុងយ៉ាងម៉េច? (១ស្អាត ទំនើប)	កំពង់ចាមជាក្រុងមួយស្អាតហើយទំនើបផង។
4.	អាកាសពេលព្រឹកតាមទន្លេនេះលោកឃើញយ៉ាងម៉េច? (ស្ងៀម ត្រជាក់)	ខ្ញុំឃើញអាកាសពេលព្រឹកយ៉ាងស្ងៀមហើយត្រជាក់ផង។

Drill J. Substitution

1.	ឥឡូវព្រះអាទិត្យបញ្ចេញកម្ដៅបន្តិចម្ដងៗ រាល់នាទី។	Now the sun is warming up little by little every minute.
2.	ឥឡូវព្រះអាទិត្យបញ្ចេញពន្លឺបន្តិចម្ដងៗរាល់នាទី។	Now the sun is getting bright little by little every minute.
3.	ឥឡូវព្រះអាទិត្យបញ្ចេញពន្លឺបន្តិចម្ដងៗ រាល់ខណៈ។	Now the sun is getting bright little by little every moment.
4.	ឥឡូវចង្កៀងបញ្ចេញពន្លឺបន្តិចម្ដងៗរាល់ខណៈ។	Now the lamp is getting bright little by little every moment.
5.	ឥឡូវចង្កៀងបញ្ចេញកំដៅបន្តិចម្ដងៗរាល់ ខណៈ។	Now the lamp is warming up little by little every moment.
6.	ឥឡូវចង្កៀងបញ្ចេញកំដៅបន្តិចម្ដងៗរាល់នាទី។	Now the lamp is warming up little by little every minute.
7.	ឥឡូវព្រះអាទិត្យបញ្ចេញកំដៅបន្តិចម្ដងៗរាល់នាទី។	Now the sun is warming up little by little every minute.

UNIT 64

BASIC DIALOGUE

1.	ម៉េចបានជាហាងការិយាល័យទាំងអស់បិទទ្វារថ្ងៃនេះ?	Pon	How come all the stores and offices are closed today?
2.	ថ្ងៃភ្ជុំបិណ្ឌ មិនដឹងទេ?	Sok	Today is Bon Phcum, didn't you know?
3.	ខ្ញុំគិតថាភ្ជុំបិណ្ឌដល់ខែក្រោយទេ។ គេធ្វើបុណ្យយ៉ាងម៉េចខ្លះ?	Pon	I thought Bon Phcum was last month. How do they celebrate it?
4.	នៅថ្ងៃភ្ជុំ មនុស្សប្រុសស្រី ចាស់ក្មេង នាំគ្នាទៅវត្ត។	Sok	On Phcum day, the people, men and women, young and old, go to the wat.
5.	គេធ្វើបុណ្យឧទ្ទិសកុសលដល់មនុស្សដែលស្លាប់ទៅហើយ។		They have a memorial service for the dead.
6.	បុណ្យនេះគេធ្វើប៉ុន្មានថ្ងៃ?	Pon	How many days do they celebrate this holiday?
7.	ភ្ជុំតែមួយថ្ងៃទេ គឺនៅថ្ងៃដប់ប្រាំរោចខែភទ្របទ។	Sok	Phcum is just one day, that is, the fifteenth day of the waning moon of the month of Phutebot.
8.	បុណ្យសំខាន់ជាងបុណ្យចូលឆ្នាំឬអី?	Pon	Is Phcum more important than New Year's?
9.	បុណ្យទាំងពីរនេះសំខាន់ដូចគ្នា។	Sok	Both holidays are equally important.
10.	បុណ្យចូលឆ្នាំខ្មែរជាមួយគ្នានឹងចូលឆ្នាំចិន ឬក៏នៅថ្ងៃទីមួយខែមករា?	Pon	Does Cambodian New Year's coincide with Chinese New Year's, or is it January 1st?
11.	បុណ្យចូលឆ្នាំខ្មែរមិនមែនជាមួយនឹងចូលឆ្នាំចិន ឬក៏នៅថ្ងៃទីមួយខែមករាទេ។	Sok	Cambodian New Year's does not coincide with Chinese New Year's, and it isn't on January 1st.

12.	គឺនៅថ្ងៃទី១៣មេសា។	It's the 13th of April.
	Pon	
13.	រាល់ឆ្នាំមានបុណ្យសំខាន់ៗខ្លះទៀតដែលខ្មែរធ្វើ?	Every year are there other holidays that the Cambodians celebrate?
	Sok	
14.	មានបុណ្យឯទៀតដែរ ដូចជាបុណ្យកឋិន បុណ្យអុំទូក បុណ្យតាំងតុ ជាដើម។	Yes, there are other holidays, like Kathin, the Water Festival, and Tang Tok for example.
	Pon	
15.	ចុះថ្ងៃបុណ្យឯទៀតដែលមិនមែនរាល់ឆ្នាំមានដែរឬ?	How about holidays that don't occur every year. Do they have them?
	Sok	
16.	មាន ដូចជាបុណ្យរាជាភិសេក, ការបុណ្យបូជាសព ហើយឱកាសពិសេសខ្លះដែលគេតែងតែឈប់ធ្វើការ។	Yes, for example the coronation, marriage, cremations, and special occasions when they usually take off from work.
	Pon	
17.	កាលណាប្រមុខរដ្ឋពីប្រទេសមកទស្សនាប្រទេសកម្ពុជា គេតែងតែឈប់ធ្វើការឬអី?	When chiefs of state from other countries come to visit Cambodia, do they usually take off from work?
	Sok	
18.	តាមធម្មតាគេឈប់ធ្វើការដើម្បីទៅទទួលភ្ញៀវកិត្តិយស របស់ប្រទេស។	Yes, usually they take off in order to greet the honored guests of the country.
	Pon	
19.	កាលណាប្រមុខរដ្ឋនៃប្រទេសកម្ពុជាទៅប្រទេសក្រៅ ឬត្រឡប់មកវិញ ខ្ញុំឃើញមនុស្សច្រើនតាមផ្លូវ។	When the Chief of State of Cambodia goes abroad, or returns, I see a lot of people along the street.
20.	ឱកាសនោះថ្ងៃឈប់ដែរឬអី?	Is that occasion also a holiday?
	Sok	
21.	បាទ ឱកាសនោះគេឈប់ធ្វើការដើម្បីជូនដំណើរ ឬទៅទទួលស្វាគមន៍ប្រមុខរដ្ឋដែលបានមកដល់ប្រទេសវិញ។	Yes, on that occasion they take off from work also in order to accompany or greet the chief of state who has returned to the country.

DRILLS

Drill A. Response

MODEL: គ្រូៈ ហេតុអ្វីបានជាគេឈប់ធ្វើការ? (ទៅទទួលភ្ញៀវកិត្តិយស)
Teacher: Why did they stop work? (to greet the honored guests)

សិស្សៈ គេឈប់ធ្វើការដើម្បីនឹងទៅទទួលភ្ញៀវកិត្តិយស។
Student: They stopped work in order to greet the honored guests.

1.	ហេតុអ្វីបានជាគេធ្វើបុណ្យភ្ជុំបិណ្ឌ? (ធ្វើបុណ្យឧទ្ទិសកុសលដល់មនុស្សដែលស្លាប់ទៅហើយ)	គេធ្វើបុណ្យភ្ជុំបិណ្ឌដើម្បីនឹងធ្វើបុណ្យឧទ្ទិសកុសលដល់មនុស្សដែលសាប់ទៅហើយ។
2.	ហេតុអ្វីបានជាគេឈប់ធ្វើការ? (ទៅទទួលស្វាគំភ្ញៀវកិត្តិយស)	គេឈប់ធ្វើការដើម្បីនឹងទៅទទួលស្វាគំភ្ញៀវកិត្តិយស។
3.	ហេតុអ្វីបានជាគេនាំគ្នាទៅវាលយន្តហោះ? (ទៅទទួលស្វាគំភ្ញៀវកិត្តិយស)	គេនាំគ្នាទៅវាលយន្តហោះដើម្បីនឹងទៅទទួលស្វាគំភ្ញៀវកិត្តិយស។
4.	ហេតុអ្វីបានជាគេ ឈប់ ធ្វើការ? (ទៅបុណ្យខ្មោច)	គេ ឈប់ ធ្វើការដើម្បីទៅបុណ្យខ្មោច។
5.	ហេតុអ្វីបានជាគេឈប់រៀន? (ជូនដំណើរភ្ញៀវកិត្តិយស)	គេឈប់រៀនដើម្បីនឹងជូនដំណើរភ្ញៀវកិត្តិយស។

Drill B. Response

MODEL: គ្រូៈ បុណ្យភ្ជុំសំខាន់ជាងបុណ្យចូលឆ្នាំឬអ្វី? (ដូចគ្នា)
Teacher: Is Phcum Ben more important than New Years? (the same)

សិស្សៈ បុណ្យទាំងពីរសំខាន់ដូចគ្នា។
Student: Both these holidays are of the same importance.

1.	បុណ្យចូលឆ្នាំខ្មែរសំខាន់ជាងចូលឆ្នាំចិនឬអ្វី? (ដូចគ្នា)	បុណ្យទាំងពីរសំខាន់ដូចគ្នា។
2.	បុណ្យចូលឆ្នាំខ្មែរគេធ្វើយូរជាងបុណ្យភ្ជុំបិណ្ឌឬអ្វី? (ស្មើគ្នា)	បុណ្យទាំងពីរគេធ្វើយូរស្មើគ្នា។
3.	ទន្លេបាសាក់វែងជាងទន្លេសាបឬអ្វី? (ប្រវែងគ្នា)	ទន្លេទាំងពីរប្រវែងគ្នា។
4.	កប៉ាល់នោះធ្ងន់ជាងកប៉ាល់នេះឬអ្វី?	កប៉ាល់ទាំងពីរធ្ងន់ស្មើគ្នា។

	(ស្មើគ្នា)	
5.	ការិយាល័យលោកធំជាងការិយាល័យខ្ញុំឬអី? (ប៉ុណគ្នា)	ការិយាល័យទាំងពីរប៉ុនគ្នា។
6.	ផ្លូវពីភ្នំពេញទៅសៀមរាបឆ្ងាយជាងពីភ្នំពេញទៅបាត់ដំបងឬអី? (ប្រហែលគ្នា)	ផ្លូវទាំងពីរប្រហែលគ្នា។
7.	ទន្លេមេគង្គធំជាងទន្លេបាសាក់ឬអី? (ប៉ុណគ្នា)	ទន្លេទាំងពីរប៉ុណគ្នា។
8.	បុណ្យភ្ជុំបិណ្ឌសប្បាយជាងបុណ្យចូលឆ្នាំឬអី? (ដូចគ្នា)	បុណ្យទាំងពីរសប្បាយដូចគ្នា។

Drill C. Response

MODEL:	គ្រូ: បុណ្យចូលឆ្នាំខ្មែរជាមួយចូលឆ្នាំចិន ឬក៏នៅថ្ងៃទី១ ខែមករា?	Teacher: Does Cambodian New Year fall on Chinese New Year, or is it on the first of January?
	សិស្ស: បុណ្យចូលឆ្នាំខ្មែរមិនមែនជាមួយចូលឆ្នាំចិនទេ ឬក៏នៅថ្ងៃទី១ ខែមករាដែរ។	Student: Cambodian New Year doesn't fall on Chinese New Year, nor is it on the first of January.

1.	បុណ្យចូលឆ្នាំបារាំងជាមួយគ្នាចូលឆ្នាំចិន ឬក៏នៅថ្ងៃទី១៣ ខែមេសា?	បុណ្យចូលឆ្នាំបារាំងមិនមែនជាមួយចូលឆ្នាំចិនទេ ឬក៏នៅថ្ងៃទី១៣ មេសាដែរ។
2.	បុណ្យភ្ជុំបិណ្ឌជាមួយគ្នាចូលឆ្នាំខ្មែរ ឬក៏នៅថ្ងៃដប់រោចខែភទ្របទ។	បុណ្យភ្ជុំបិណ្ឌមិនមែនជាមួយចូលឆ្នាំខ្មែរទេ ឬក៏នៅថ្ងៃ១០រោចខែភទ្របទដែរ។
3.	បុណ្យកឋិនជាមួយបុណ្យអុំទូក ឬក៏ជាមួយបុណ្យតាំងតុ។	បុណ្យកឋិនមិនមែនជាមួយបុណ្យអុំទូកទេ ឬក៏ជាមួយបុណ្យតាំងតុដែរ។
4.	រាជាភិសេកជាមួយគ្នាបូជាសព ឬក៏ជាមួយការរៃងសរស្តេច?	រាជាភិសេកមិនមែនជាមួយបូជាសពទេ ឬក៏ជាមួយការរៃងសរស្តេចដែរ។
5.	បុណ្យណូអែលជាមួយគ្នាបុណ្យចូលឆ្នាំខ្មែរ ឬក៏នៅខែក្រោយ?	បុណ្យណូអែលមិនមែនជាមួយគ្នាបុណ្យចូលឆ្នាំទេ ឬក៏នៅខែក្រោយដែរ។

Drill D. Transformation

MODEL:	គ្រូ: កាលប្រមុខរដ្ឋមកដល់ប្រទេសវិញ គេទៅទទួលស្វាគំ។	Teacher:	When the head of state returns to the country, they go out to greet him.
	សិស្ស: គេទៅទទួលស្វាគំប្រមុខរដ្ឋដែលបានមកដល់ប្រទេសវិញ។	Student:	They go out to greet the head of state who has returned to the country.

1.	កាលណាប្រមុខរដ្ឋទៅប្រទេសក្រៅ គេទៅជូនដំណើរ។	គេទៅជូនដំណើរប្រមុខរដ្ឋដែលទៅប្រទេសក្រៅ។
2.	កាលណាប្រមុខរដ្ឋពីប្រទេសឯទៀតមកដល់ប្រទេសកម្ពុជា គេទៅទទួលស្វាគំ។	គេទៅទទួលស្វាគំប្រមុខរដ្ឋពីប្រទេសឯទៀតមកដល់ប្រទេសកម្ពុជា។
3.	កាលណាប្រមុខរដ្ឋពីប្រទេសឯទៀតត្រឡប់ទៅវិញ គេទៅជូនដំណើរ។	គេទៅជូនដំណើរប្រមុខរដ្ឋពីប្រទេសឯទៀតដែលត្រឡប់ទៅវិញ។
4.	កាលណាភ្ញៀវកិត្តិយស មកដល់វាលយន្តហោះ គេរិតឯរិតទៅទទួល។	គេរិតឯរិតទៅទទួលភ្ញៀវកិត្តិយសមកដល់វាលយន្តហោះ។
5.	កាលណាភ្ញៀវកិត្តិយសទៅប្រទេសគេវិញ គេរិតឯរិតទៅ ជូនដំណើរ។	គេរិតឯរិតទៅជូនដំណើរភ្ញៀវកិត្តិយសទៅប្រទេសវិញ។

Drill E. Expansion

1.	ខ្ញុំឃើញមនុស្សច្រើន។	I see many people.
2.	ខ្ញុំឃើញមនុស្សច្រើន តាមផ្លូវ។	I see many people along the street.
3.	កាលណាប្រមុខរដ្ឋទៅប្រទេសក្រៅ ខ្ញុំឃើញមនុស្សច្រើនតាមផ្លូវ។	When the head of state goes abroad, I see many people along the street.
4.	កាលណាប្រមុខរដ្ឋទៅប្រទេសក្រៅ ឬត្រឡប់មកវិញ ខ្ញុំឃើញមនុស្សច្រើនតាមផ្លូវ។	When the head of state goes abroad or returns, I see many people along the street.
5.	កាលណាប្រមុខរដ្ឋនៃប្រទេសកម្ពុជា ទៅប្រទេសក្រៅឬត្រឡប់មកវិញ ខ្ញុំឃើញមនុស្សច្រើនតាមផ្លូវ។	When the head of state of Cambodia goes abroad or returns, I see many people along the street.

Drill F. Reduction

1.	កាលណាប្រមុខរដ្ឋនៃប្រទេសកម្ពុជាទៅប្រទេសក្រៅឬត្រឡប់មកវិញខ្ញុំឃើញមនុស្សច្រើនតាមផ្លូវ។	When the head of state of Cambodia goes abroad or returns, I see many people along the street.
2.	កាលណាប្រមុខរដ្ឋទៅប្រទេសក្រៅឬត្រឡប់មកវិញ ខ្ញុំឃើញមនុស្សច្រើនតាមផ្លូវ។	When the head of state goes abroad or returns, I see many people along the street.
3.	កាលណាប្រមុខរដ្ឋទៅប្រទេសក្រៅខ្ញុំឃើញមនុស្សច្រើនតាមផ្លូវ។	When the head of state goes abroad, I see many people along the street.
4.	ខ្ញុំឃើញមនុស្សច្រើនតាមផ្លូវ។	I see many people along the street.
5.	ខ្ញុំឃើញមនុស្សច្រើន។	I see many people.

UNIT 65

NARRATION

1. គេគិតនាំគ្នាធ្វើដំណើរទៅក្រុងកំពង់ចាម ។
2. ប៉ុនមិនទាន់បានឃើញ កំពង់ចាមទេ។
3. គេសួរទៅសុខអំពីសភាពក្រុងនោះ។
4. សុខថាកំពង់ចាមជាក្រុងស្អាតហើយទំនើបមួយដែលនៅតាមបណ្ដោយច្រាំងទន្លេមេគង្គ ។
5. ប៉ុននឹងសុខ ចង់ទៅកំពង់ចាមតាមកប៉ាល់ដែលទៅមកជាច្រើនរាល់ថ្ងៃ ។
6. ធ្វើដំណើរតាមកប៉ាល់ យឺតបន្តិច ព្រោះគេឈប់ច្រើនកន្លែង។
7. អ្នកដំណើរមិនបាច់ទិញសំបុត្រទុកមុនទេ។ កាលណាកប៉ាល់ចេញទើបគេលក់សំបុត្រ។
8. សំបុត្រ ពីភ្នំពេញទៅកំពង់ចាម មិនថ្លៃប៉ុន្មានទេ ប្រហែលម្ភៃប្រាំរៀលប៉ុណ្ណោះ។
9. គេចង់ទៅតាមកប៉ាល់ដែលចេញពីព្រឹក ដើម្បីឲ្យត្រជាក់បន្តិច។
10. ដូច្នេះគេត្រូវទៅដល់ផែកប៉ាល់ឲ្យបានមួយម៉ោងឬកន្លះម៉ោងមុនពេលកប៉ាល់ចេញ ។

1. They are thinking about making a trip to Kompong Cham.
2. Pon hasn't yet had the chance to see Kompong Cham.
3. He asks Sok about the overall appearance of the city.
4. Sok says Kompong Cham is a clean and modern city which is on the banks of the Mekong.
5. Pon and Sok want to go to Kompong Cham by boat, of which there are many going and coming each day. (going round trip)
6. Travelling on boats is a little slow because they stop at many places.
7. Travellers cannot buy tickets in advance. Only when the boat leaves can they buy tickets.
8. The ticket from Pnhom Penh to Kompong Cham is not very expensive, maybe only 25 riels.
9. They want to go by the boat that leaves in the morning so that it will be a little cooler.
10. Therefore they have to arrive at the boat dock an hour or a half hour before the boat leaves.

1. ឥឡូវគេមកដល់ផែកប៉ាល់ហើយ។ គេនាំគ្នាឡើងលើកប៉ាល់៕
2. ប៉ុនឃើញអ្នកដំណើរច្រើន៕ ខ្លះឡើងមកលើកប៉ាល់មានអីវ៉ាន់នៅដៃ៕ ខ្លះទៀតកំពុងទិញរបស់ផ្សេងៗ ៕
3. សុខប្រាប់ប៉ុនថាអ្នកខ្លះទិញអីវ៉ាន់ច្រើនទៅលក់ អ្នកខ្លះទៀតទិញម្ហូបចំណីយកទៅផ្ញើកូនចៅនៅឯផ្ទះ៕
4. បន្តិចមកគេឮសូរស៊ីហ្វ្លេ៕
5. សុខនិយាយថាកប៉ាល់ទាញស៊ីហ្វ្លេឲ្យសញ្ញាថាដល់ម៉ោងចេញហើយ៕
6. អ្នកដើរកប៉ាល់កំពុងរិតស្រាយពួរ ច្រវាក់កប៉ាល់ ឯអ្នកដំណើរអង្គុយស្ងៀមចាំអ្នកលក់សំបុត្រ៕
7. គេលក់សំបុត្រ តម្លៃតាមចម្ងាយ៕
8. មើលពីកប៉ាល់ទៅសង្ខាងទន្លេ គ្មានឃើញអ្វីទេ ងងឹតណាស់៕
9. យូរៗឃើញភ្លើងទូកអ្នកនេសាទភ្លិងៗ នៅតាមមាត់ទន្លេ៕
10. មួយសន្ទុះមក គេឃើញពណ៌ក្រហមព្រាលៗនៅទិសខាងកើត -ជាសញ្ញាថា ភ្លឺហើយ-៕

1. Now they have arrived at the dock, and they go on the boat together.
2. Pon sees many travellers. Some are going on the boat with things in their hands; others are buying various things.
3. Sok tells Pon that some people buy things to sell; others buy food to take to the children at home.
4. A little later they hear the sound of the whistle.
5. Sok says that the boat blows the whistle as a signal that it is time for the boat to leave.
6. The boatmen are untying the ropes and the chains; as for the travellers, they sit quietly waiting for the ticket seller.
7. They sell tickets according to the distance.
8. If you look from the ship on both sides of the river, you don't see anything - it's very dark.
9. From time to time they see the flickering lights of the fishing boats along the bank.
10. After a moment they see a reddish color in the east - it's a sign that it's dawn.

1. ប៉ុនឮស៊ីហ្វ្លេកប៉ាល់ម្ដងទៀត ហើយស្មានថាដល់កំពង់ចាមហើយ។
2. សុខនិយាយថា នេះជាសញ្ញាប្រាប់អ្នកដំណើរថាជិតដល់កន្លែងចុះហើយ។ ហើយត្រូវរៀបចំខ្លួន។
3. កន្លែងចុះនេះមិនមែនកំពង់ចាមទេ ជាកន្លែងចុះមួយតូចនៅតាមផ្លូវ។
4. ឥឡូវកប៉ាល់រៀបចូលផែហើយ។
5. នៅលើផែគេលក់នំ និងម្ហូប ហើយនិងផ្លែឈើផ្សេងៗ។
6. កប៉ាល់ចេញពីផែមួយចូលផែមួយទៀត ហើយនៅគ្រប់ផែមានមនុស្សចុះឡើងជានិច្ច។
7. ទេសភាពពេលព្រឹកតាមបណ្ដោយនោះ ល្អណាស់។
8. គេឃើញផ្ទះអ្នកស្រុកនៅកប់ក្រោម ម្លប់ដើមឈើជាច្រើន ដូចជាស្វាយ ក្រូចចេក ជាដើម។
9. ថ្ងៃកាន់តែក្ដៅបន្តិចម្ដងៗ ព្រោះរសៀលហើយ។
10. កប៉ាល់បានមកជិតដល់កំពង់ចាមហើយ ហើយប៉ុនអាចឃើញទីក្រុងនេះច្បាស់ពីចម្ងាយ។
11. នេះជាដំណើរមួយយ៉ាងសប្បាយ ហើយមានប្រយោជន៍ចំពោះប៉ុន។

1. Pon hears the whistle of the boat again, and he thinks that they have arrived in Kompong Cham already.

2. Sok says that this is a signal to tell the travellers that they are about to arrive at a landing, and that they must get their things in order.

3. This landing is not Kompong Cham; it's a small landing along the way.

4. Now the ship is preparing to enter the dock.

5. On the dock they sell cakes, food and various fruits.

6. The boat leaves one dock and enters another; and at each dock there are always people getting off and on.

7. The landscape in the morning along the river is very pretty.

8. They see houses of the country people hidden in the shade of many trees: mango, citrus, and banana for example.

9. The sun is getting hotter and little by little because it's afternoon already.

10. The boat has arrived near Kompong Cham, and Pon can see the city clearly from the distance.

11. This is a very pleasant trip for Pon, and interesting, too.

1. ប៉ុនឃើញហាងនិងការិយាល័យទាំងអស់បិទទ្វារ តែមិនដឹងជាមានបុណ្យអ្វី។
2. សុខក៏ប្រាប់ថាថ្ងៃនេះគឺជាថ្ងៃភ្ជុំបិណ្ឌ។
3. ប៉ុនស្មានថាភ្ជុំបិណ្ឌដល់ទៅខែក្រោយ ហើយក៏សួរសុខថា:
4. នៅថ្ងៃបុណ្យនេះ គេនាំគ្នាទៅវត្ត ធ្វើបុណ្យឧទ្ទិសកុសលដល់មនុស្សដែលស្លាប់។
5. គេធ្វើបុណ្យតែមួយថ្ងៃទេ គឺនៅថ្ងៃ១៥រោចខែភទ្របទ។
6. សុខប្រាប់ប៉ុនថាបុណ្យភ្ជុំបិណ្ឌនេះនិងបុណ្យចូលឆ្នាំសំខាន់ដូចគ្នា។
7. តែបុណ្យចូលឆ្នាំខ្មែរមិនមែនជាមួយគ្នានឹងចូលឆ្នាំចិន ឬក៏នៅថ្ងៃទី១ខែមករាទេ គឺនៅថ្ងៃទី១៣មេសា។
8. ខ្មែរធ្វើបុណ្យខ្លះទៀតដូចជាបុណ្យកឋិន បុណ្យអុំទូក និងបុណ្យតាំងតុជាដើម។
9. បុណ្យខ្លះទៀតមិនមែនមានរាល់ឆ្នាំទេ មានឱកាសពិសេសដែលគេធ្វើ គេឈប់ធ្វើការ ដូចជាពិធីរាជាភិសេក ការ បូជាសព និងពេលប្រមុខរដ្ឋបរទេសមកទស្សនាប្រទេសកម្ពុជា។
10. អ្នករាជការនិងកូនសិស្សខ្លះអាចឈប់ពីរបីម៉ោង ដើម្បីទៅទទួលភ្ញៀវកិត្តិយសរបស់ប្រទេស។

1. Pon sees that all the stores and offices are closed, but he doesn't know what holiday it is.
2. Sok says: Today is Phcum Ben.
3. Pon thought that Phcum Ben was last month and asks Sok:
4. "On this holiday do they go to the wat to have memorial services for the dead?"
5. "They celebrate this holiday only one day, that is, every 15th day of the waning moon of the month of Phutebot."
6. Sok tells Pon that the Phcum Ben and New Year are equally important.
7. But the Cambodian New Year does not coincide with Chinese New Year nor is it on the first of January. It is on the 13th of April.
8. Cambodians celebrate other holidays such as Kathin, the Water Festival, and Tang Tok, for example.
9. Some other holidays do not occur every year; they are special occasions when people must stop work, such as the coronation, weddings, cremations, and the times when foreign chiefs of state come to visit Cambodia.
10. Government officials and some students can stop work for two or three hours in order to go greet the honored guests of the country.

UNIT 66

BASIC DIALOGUE

	Layman	
1.	ថ្វាយបង្គំព្រះតេជព្រះគុណ។ ព្រះតេព្រះគុណសុខសប្បាយជាទេ?	Hello. How are you?
	Monk	
2.	ចំរើនពរ អាត្មា សុខសប្បាយ ជាទេ។	I'm well.
	Layman	
3.	ព្រះតេជព្រះគុណនិមន្តទៅ ណាហ្នឹង?	Where are you going?
	Monk	
4.	អាត្មាទៅសាលា។	I'm going to school.
	Layman	
5.	សាលាព្រះតេជព្រះគុណនៅ ឯណា?	Where is your school?
	Monk	
6.	សាលាអាត្មានៅជិតវាំង សាលា ពុទ្ធិកវិទ្យាល័យ សុរាមរិទ្ធ។	My school is near the palace. It's called the Suramarit Buddhist Institute.
	Layman	
7.	ព្រះតេជព្រះគុណរៀនប៉ុន្មាន ឆ្នាំហើយ?	How many years have you studied already?
	Monk	
8.	អាត្មារៀនពីរឆ្នាំហើយ។ ឆ្នាំ នេះអាត្មារៀននៅថ្នាក់ទីបី។	I've studied two years. This year I'm in the third class.
	Layman	
9.	តេជគុណរៀនប៉ុន្មានម៉ោង១ថ្ងៃ?	How many hours a day do you study?
	Monk	
10.	អាត្មារៀន៥ម៉ោង១ថ្ងៃ។ ព្រឹក ពីរម៉ោង ល្ងាច៣ម៉ោង។	I study five hours a day: two hours in the morning, three in the afternoon.

(BASIC DIALOGUE
in lay language)

	Pon	
1.	ជំរាបសួរលោក ។ លោកសុខសប្បាយជាទេ?	Hello. How are you?
	Sok	
2.	បាទ ខ្ញុំសុខសប្បាយជាទេ ។	I'm well.
	Pon	
3.	លោកអញ្ជើញទៅណាហ្នឹង?	Where are you going?
	Sok	
4.	បាទ ខ្ញុំទៅសាលា ។	I'm going to school.
	Pon	
5.	សាលាលោកនៅឯណា?	Where is your school?
	Sok	
6.	សាលាខ្ញុំនៅជិតវាំង សាលាពុទ្ធិកវិទ្យាល័យសុរាមរិទ្ធ ។	My school is near the palace. It's called the Suramarit Buddhist Institute.
	Pon	
7.	លោករៀនប៉ុន្មានឆ្នាំហើយ?	How many years have you studied already?
	Sok	
8.	ខ្ញុំរៀនពីរឆ្នាំហើយ ។ ឆ្នាំនេះខ្ញុំរៀននៅថ្នាក់ទី៣ ។	I've studied two years. This year I'm in the third class.
	Pon	
9.	លោករៀនប៉ុន្មាន ១ ថ្ងៃ ។	How many hours a day do you study?
	Sok	
10.	បាទ ខ្ញុំរៀន៥ម៉ោង ១ ថ្ងៃ ។ ព្រឹក ២ម៉ោង ល្ងាច ៣ម៉ោង ។	I study five hours a day: two hours in the morning, three in the afternoon.

DRILLS

Drill A. Transformation

MODEL:	គ្រូ: ជំរាបសួរលោក ។ (ខ្ញុំបង្គំ)	**Teacher:** Hello, sir. (Hello)
	សិស្ស: ខ្ញុំបង្គំព្រះតេជព្រះគុណ ។	**Student:** Hello, monk.
1.	លោកសុខសប្បាយជាទេ? (ព្រះតេជព្រះគុណ)	ព្រះតេជព្រះគុណសុខសប្បាយជាទេ?
2.	លោកអញ្ជើញទៅណាហ្នឹង? (ព្រះតេជព្រះគុណនិមន្ត)	ព្រះតេជព្រះគុណនិមន្តទៅណាហ្នឹង?
3.	សាលារៀនលោកនៅឯណា? (ព្រះតេជព្រះគុណ)	សាលារៀនព្រះតេជព្រះគុណនៅឯណា?
4.	លោករៀនប៉ុន្មានឆ្នាំហើយ? (ព្រះតេជព្រះគុណ)	ព្រះតេជព្រះគុណរៀនប៉ុន្មានឆ្នាំហើយ?
5.	លោករៀនប៉ុន្មានម៉ោង១ថ្ងៃ? (ព្រះតេជព្រះគុណ)	ព្រះតេជព្រះគុណរៀនប៉ុន្មានម៉ោង១ថ្ងៃ ។

Drill B. Transformation

MODEL:	គ្រូ: បាទ ខ្ញុំសុខសប្បាយជាទេ ។ (ចំរើនពរ អាត្មា)	**Teacher:** Yes, I'm well. (Yes, I)
	សិស្ស: ចំរើនពរ អាត្មាសុខសប្បាយជាទេ ។	**Student:** Yes, I'm well.
1.	បាទ ខ្ញុំទៅសាលា ។ (ចំរើនពរ អាត្មា)	ចំរើនពរ អាត្មាទៅសាលា ។
2.	សាលាខ្ញុំនៅជិតវាំង ។ (អាត្មា)	សាលាអាត្មានៅជិតវាំង ។
3.	សាលាខ្ញុំឈ្មោះពុទ្ធកវិទ្យាល័យព្រះសុរាមរិទ្ធ ។ (អាត្មា)	សាលាអាត្មាឈ្មោះពុទ្ធកវិទ្យាល័យព្រះសុរាមរិទ្ធ ។
4.	ខ្ញុំរៀនពីរឆ្នាំហើយ ។ (អាត្មា)	អាត្មារៀនពីរឆ្នាំហើយ ។
5.	ឆ្នាំនេះខ្ញុំរៀននៅថ្នាក់ទី៣ ។ (អាត្មា)	ឆ្នាំនេះអាត្មារៀននៅថ្នាក់ទី៣ ។
6.	បាទ ខ្ញុំរៀន១ថ្ងៃ៤ម៉ោង ។(ចំរើនពរ អាត្មា)	ចំរើនពរ អាត្មារៀន១ថ្ងៃ៤ម៉ោង ។

Drill C. Transformation

MODEL: គ្រូ: ថ្វាយបង្គំព្រះតេជព្រះគុណ។ — Teacher: Hello.
សិស្ស: ជំរាបសួរលោក។ — Student: Hello.

1.	ព្រះតេជព្រះគុណសុខសប្បាយជាទេ?	លោកសុខសប្បាយជាទេ?
2.	ព្រះតេជព្រះគុណនិមន្តទៅណាហ្នឹង?	លោកអញ្ជើញទៅណាហ្នឹង?
3.	សាលាព្រះតេជព្រះគុណនៅឯណា?	សាលាលោកនៅឯណា?
4.	ព្រះតេជព្រះគុណរៀនប៉ុន្មានឆ្នាំហើយ?	លោករៀនប៉ុន្មានឆ្នាំហើយ?
5.	ព្រះតេជព្រះគុណរៀនប៉ុន្មានម៉ោងមួយថ្ងៃ?	លោករៀនប៉ុន្មានម៉ោងមួយថ្ងៃ?

Drill D. Transformation

MODEL: គ្រូ: ចំរើនពរ អាត្មាសុខសប្បាយជាទេ! — Teacher: I'm well.
សិស្ស: បាទ ខ្ញុំសុខសប្បាយជាទេ! — Student: I'm well.

1.	ចំរើនពរ អាត្មាទៅសាលា។	បាទ ខ្ញុំទៅសាលា។
2.	សាលារៀនអាត្មានៅជិតវាំង។	សាលារៀនខ្ញុំនៅជិតវាំង។
3.	សាលាអាត្មាឈ្មោះពុទ្ធិកវិទ្យាល័យព្រះសុរាមរិទ្ធ។	សាលាខ្ញុំឈ្មោះពុទ្ធិកវិទ្យាល័យព្រះសុរាមរិទ្ធ។
4.	អាត្មារៀនពីរឆ្នាំហើយ។	ខ្ញុំរៀនពីរឆ្នាំហើយ។
5.	ឆ្នាំនេះអាត្មារៀននៅថ្នាក់ទី៣។	ឆ្នាំនេះខ្ញុំរៀននៅថ្នាក់ទី៣។
6.	ចំរើនពរ អាត្មារៀនមួយថ្ងៃប្រាំម៉ោង។	បាទ ខ្ញុំរៀន១ថ្ងៃ៥ម៉ោង។

Drill E. Response (answer as a monk)

MODEL: គ្រូ: ព្រះតេជព្រះគុណរៀនប៉ុន្មានឆ្នាំហើយ? (ពីរ) — Teacher: How many years have you studied? (two)
សិស្ស: ចំរើនពរ អាត្មារៀនពីរឆ្នាំហើយ។ — Student: I've studied two years already.

1.	ព្រះតេជព្រះគុណសុខសប្បាយជាទេ? (សុខសប្បាយ)	ចំរើនពរ អាត្មាសុខសប្បាយជាទេ។
2.	ព្រះតេជគុណនិមន្តទៅណា? (សាលា)	ចំរើនពរ អាត្មាទៅសាលា។

3.	សាលាព្រះតេជគុណនៅឯណា?(ជិតវាំង)	ចំរើនពរ សាលាអាត្មានៅជិតវាំង។
4.	សាលាព្រះតេជគុណឈ្មោះអ្វី? (ពុទ្ធិកវិទ្យាល័យព្រះសុរាមរិទ្ធ)	ចំរើនពរ សាលាអាត្មាឈ្មោះពុទ្ធិកវិទ្យាល័យព្រះសុរាមរិទ្ធ។
5.	ឆ្នាំនេះព្រះតេជគុណរៀននៅថ្នាក់ណា? (ទី៣)	ចំរើនពរ អាត្មារៀននៅថ្នាក់ទី៣។
6.	ព្រះតេជគុណរៀន១ថ្ងៃប៉ុន្មានម៉ោង? (ប្រាំ)	ចំរើនពរ អាត្មារៀន១ថ្ងៃ៥ម៉ោង។

Drill F. Questioning

MODEL:	គ្រូ: ចំរើនពរ អាត្មារៀនពីរឆ្នាំហើយ។ (ប៉ុន្មានឆ្នាំ)	Teacher: I've studied two years already. (how many?)
	សិស្ស: ព្រះតេជគុណរៀនប៉ុន្មានឆ្នាំហើយ?	Student: How many years have you studied?
1.	ចំរើនពរ អាត្មាសុខសប្បាយជាទេ។ (សុខសប្បាយ)	ព្រះតេជគុណសុខសប្បាយជាទេ?
2.	ចំរើនពរ អាត្មាទៅសាលា។ (ទៅណា)	ព្រះតេជគុណនិមន្តទៅណា?
3.	ចំរើនពរ សាលាអាត្មានៅជិតវាំង។ (នៅឯណា)	សាលាព្រះតេជគុណនៅឯណា?
4.	ចំរើនពរ សាលាអាត្មាឈ្មោះពុទ្ធិកវិទ្យាល័យព្រះសុរាមរិទ្ធ។ (ឈ្មោះអ្វី)	សាលាព្រះតេជគុណឈ្មោះអ្វី?
5.	ចំរើនពរ អាត្មារៀននៅថ្នាក់ទី៣។ (ទីប៉ុន្មាន)	ព្រះតេជគុណរៀននៅថ្នាក់ទីប៉ុន្មាន?
6.	ចំរើនពរ អាត្មារៀន១ថ្ងៃ៥ម៉ោង។ (ប៉ុន្មានម៉ោង)	ព្រះតេជគុណរៀន១ថ្ងៃប៉ុន្មានម៉ោង?

Drill G. Substitution

1.	ព្រះតេជគុណនិមន្តទៅណាហ្នឹង?	Where are you (a monk) going?
2.	ព្រះតេជគុណនិមន្តទៅសាលាឬ?	Are you going to school?
3.	ព្រះតេជគុណនិមន្តមកផ្ទះខ្ញុំករុណាឬ?	Are you going to my house?
4.	លោកអញ្ជើញមកផ្ទះខ្ញុំឬ?	Are you (a layman) going to my house?
5.	លោកអញ្ជើញទៅសាលាឬ?	Are you going to school?

6.	លោកអញ្ជើញទៅណាណឹង?	Where are you going?
7.	លោកស្រីអញ្ជើញទៅណាណឹង?	Where are you (a woman) going?
8.	ព្រះតេជព្រះគុណនិមន្តទៅណាណឹង?	Where are you (a monk) going?

Drill H. Substitution

1.	ខ្ញុំករុណាសុខសប្បាយដូចធម្មតា។	I (a monk) am well as usual.
2.	ប្រពន្ធខ្ញុំសុខសប្បាយដូចធម្មតា។	My wife is well as usual.
3.	ប្រពន្ធខ្ញុំសុខសប្បាយជាទេ។	My wife is well.
4.	អាត្មាសុខសប្បាយជាទេ។	I (a monk) am well.
5.	អាត្មាសុខសប្បាយដូចធម្មតា។	I am well as usual.
6.	ឪពុកខ្ញុំករុណាសុខសប្បាយដូចធម្មតា។	My father is well as usual.
7.	ឪពុកខ្ញុំករុណាសុខសប្បាយជាទេ។	My father is well.
8.	ខ្ញុំករុណាសុខសប្បាយជាទេ។	I (a monk) am well.
9.	ខ្ញុំករុណាសុខសប្បាយដូចធម្មតា។	I (a monk) am well as usual.

UNIT 67

BASIC DIALOGUE

	Layman	
1.	គេបង្រៀនអ្វីខ្លះនៅសាលានោះ?	What subjects do they teach there?
	Monk	
2.	គេបង្រៀនវិជ្ជាគ្រប់មុខ ដូចនៅវិទ្យាល័យឯទៀតដែរ។ ហើយនៅសាលានោះគេបង្រៀនភាសាបាលី និងសំស្ក្រឹត ហើយនិងសាសនាដែរ។	They teach all subjects, as in other lycées, and in that school they teach Pali and Sanskrit and religion too.
	Layman	
3.	គេបង្រៀនភាសាបរទេស ដូចជាបារាំង អង់គ្លេស ដែរ?	Do they also teach foreign languages like French and English?
	Monk	
4.	បាទ សព្វថ្ងៃ គេបង្រៀនភាសាបារាំង និងអង់គ្លេសដែរ។	Yes, these days they teach English and French.
	Layman	
5.	លោកនិយាយភាសាអង់គ្លេសបានមែនទេ?	You can speak English, can't you?
	Monk	
6.	បាទ ខ្ញុំនិយាយបានខ្លះ ប៉ុន្តែខ្ញុំមិនសូវចេះពាក្យច្រើនទេ។	I can speak some, but I don't know too many words.
	Layman	
7.	លោកនៅវត្តណា?	In which wat do you live?
	Monk	
8.	បាទ ខ្ញុំនៅវត្តឧណ្ណាលោម។	I live in Wat Unalom.
	Layman	
9.	នៅវត្តនោះមានព្រះសង្ឃច្រើនមែនទេ?	There are a lot of monks in that wat, aren't there?
	Monk	
10.	បាទ មានច្រើន ប៉ុន្តែខ្ញុំដឹងមិនប្រាកដទេ។	There are a lot, but I don't know how many for sure.

Layman

11.	ព្រះសង្ឃទាំងអស់សុទ្ធតែ និមន្តទៅរៀននៅពុទ្ធិកវិទ្យាល័យ ?	Do all the monks go to study at the Buddhist Institute only?

Monk

12.	បាទទេ នៅវត្តនោះមានសាលា ពុទ្ធិកបឋមសិក្សាមួយ។ ព្រះសង្ឃខ្លះ រៀននៅសាលានោះ ហើយខ្លះទៀតទៅ រៀននៅពុទ្ធិកវិទ្យាល័យ។	No, in that wat there is a Buddhist elementary school; some monks study in that school, some others go to study at the Buddhist Institute.

(BASIC DIALOGUE

in lay language)

		Pon	
1.	គេបង្រៀនវិជ្ជាអ្វីខ្លះនៅសាលានោះ?		What subjects do they teach there?
		Sok	
2.	គេបង្រៀនវិជ្ជាគ្រប់មុខ ដូចនៅវិទ្យាល័យឯទៀតដែរ។ ហើយសាលានោះគេបង្រៀនភាសាបាលី និងសំស្ក្រឹត ហើយនិងសាសនាដែរ។		They teach all subjects, as in other lycées, and in that school they teach Pali and Sanskrit and religion too.
		Pon	
3.	គេបង្រៀនភាសាបរទេសដូចជាបារាំង អង់គ្លេសដែរ?		Do they also teach foreign languages like French and English?
		Sok	
4.	ចាំរើនពរ សព្វថ្ងៃគេបង្រៀនភាសាអង់គ្លេសនិងបារាំងដែរ។		Yes, these days they teach English and French.
		Pon	
5.	ព្រះតេជគុណមានពុទ្ធដីកាអង់គ្លេសបានទេ តានព្រះ?		You can speak English, can't you?
		Sok	
6.	ចាំរើនពរ អាត្មានិយាយបានខ្លះ ប៉ុន្តែអាត្មាមិនសូវចេះពាក្យច្រើនទេ។		I can speak some, but I don't know too many words.
		Pon	
7.	ព្រះតេជព្រះគុណគង់នៅវត្តណា?		In which wat do you live?
		Sok	
8.	ចាំរើនពរ អាត្មានៅវត្តឧណ្ណាលោម។		I live in Wat Unalom.
		Pon	
9.	នៅវត្តនោះមានព្រះសង្ឃច្រើនអង្គទេ តានព្រះ?		There are a lot of monks in that wat, aren't there?

Sok

10. ចំរើនពរ មានច្រើន ប៉ុន្តែអាត្មា មិនដឹងប្រាកដទេ។

There are a lot, but I don't know how many for sure.

Pon

11. ព្រះសង្ឃទាំងអស់សុទ្ធតែនិមន្ត ទៅរៀននៅពុទ្ធកវិទ្យាល័យឬ ក្រាបទូល?

Do all the monks go to study at the Buddhist Institute only?

Sok

12. ចំរើនពរទេ នៅវត្តនោះមាន សាលាពុទ្ធកបឋមសិក្សាមួយ។ ព្រះសង្ឃខ្លះរៀននៅសាលានោះ ហើយ អង្គខ្លះទៀតទៅរៀននៅ ពុទ្ធកវិទ្យាល័យ។

No, in that wat there is a Buddhist elementary school; some monks study in that school, some others go to study at the Buddhist Institute.

DRILLS

Drill A. Substitution

1.	គេបង្រៀនវិជ្ជាគ្រប់មុខនៅវិទ្យាល័យនោះ។	They study all subjects in that lycée.
2.	គេបង្រៀនភាសាបាលីនិងសំស្ក្រឹត នៅវិទ្យាល័យនោះ។	They study Pali and Sanskrit in that lycée.
3.	គេបង្រៀនភាសាបាលីនិងសំស្ក្រឹត នៅសាលារៀននោះ។	They study Pali and Sanskrit in that school.
4.	គេបង្រៀនភាសាបារាំងអង់គ្លេសនៅសាលារៀននោះ។	They study French and English in that school.
5.	ព្រះសង្ឃរៀន ភាសាបារាំងនិងអង់គ្លេស នៅសាលារៀននោះ។	The monks study French and English in that school.
6.	ព្រះសង្ឃរៀនភាសាបារាំងនិងអង់គ្លេស នៅវិទ្យាល័យនោះ។	The monks study French and English in that lycée.
7.	ព្រះសង្ឃរៀនវិជ្ជាគ្រប់មុខនៅវិទ្យាល័យនោះ។	The monks study all subjects in that lycée.
8.	គេបង្រៀនវិជ្ជាគ្រប់មុខ នៅវិទ្យាល័យនោះ	They teach all subjects in that lycée.

Drill B. Substitution

1.	ព្រះតេជព្រះគុណមានពុទ្ធដីកាភាសាអង់គ្លេស បានខ្លះ ទានព្រោស?	The monks can speak some English can't they?
2.	ព្រះតេជព្រះគុ មាន ពុទ្ធដីកាភាសាបរទេស ទានព្រោស?	The monks can speak some foreign languages,can't they?
3.	ព្រះសង្ឃគ្រប់អង្គមានពុទ្ធដីកា ភាសាបរទេសបានខ្លះ ទានព្រោះ?	All the monks can speak some foreign languages, can't they?
4.	ព្រះសង្ឃគ្រប់អង្គមានពុទ្ធដីកាភាសាបាលី បានខ្លះ ទានព្រោស?	All the monks can speak some Pali, can't they?
5.	ព្រះសង្ឃគ្រប់អង្គអានភាសាបាលីបានខ្លះ	All the monks can read some Pali,

	ទានទេប្រាស?	can't they?
6.	ព្រះសង្ឃគ្រប់អង្គ អាន ភាសាសំស្ក្រឹត បានខ្លះ ទានទេប្រាស?	All the monks can read some Sanskrit, can't they?
7.	ព្រះតេជព្រះគុណ អាន ភាសាសំស្ក្រឹត បានខ្លះ ទានទេប្រាស?	The monks can read some Sanskrit, can't they?
8.	ព្រះតេជព្រះគុណ អាន ភាសា អង់គ្លេស បានខ្លះ ទានទេប្រាស?	The monks can read some English, can't they?
9.	ព្រះតេជព្រះគុណ មានពុទ្ធដីកា ភាសា អង់គ្លេសបានខ្លះ ទានទេប្រាស?	The monks can speak some English, can't they?

Drill C. Substitution

1.	ព្រះតេជព្រះគុណគង់នៅវត្ត ឧណ្ណាលោម ទានទេប្រាស?	The monks (you) live in the Unnalom Pagoda, don't you?
2.	ព្រះសង្ឃគ្រប់អង្គសុទ្ធតែ គង់នៅវត្ត ឧណ្ណាលោម ទានទេប្រាស?	All the monks live in the Unnalom Pagoda, don't they?
3.	ព្រះសង្ឃគ្រប់អង្គសុទ្ធតែនិមន្តបំពេញ វិជ្ជា នៅវត្តឧណ្ណាលោម ទានទេប្រាស?	All the monks only go to study in the Unnalom Pagoda, don't they?
4.	ព្រះសង្ឃគ្រប់អង្គសុទ្ធតែនិមន្តបំពេញ វិជ្ជានៅពុទ្ធិកវិទ្យាល័យ ទានទេប្រាស?	All the monks only go to study in the Buddhist Institute, don't they?
5.	ព្រះសង្ឃ អង្គខ្លះ និមន្តបំពេញវិជ្ជា នៅ ពុទ្ធិកវិទ្យាល័យ ទានទេប្រាស?	Some monks only go to study in the Buddhist Institute, don't they?
6.	ព្រះសង្ឃអង្គខ្លះនិមន្តបំពេញវិជ្ជា នៅ ពុទ្ធិកបឋមសិក្សា ទានទេប្រាស?	Some monks only go to study in the Buddhist elementary school, don't they?
7.	ព្រះសង្ឃ អង្គខ្លះ គង់នៅវត្តឧណ្ណាលោម ទានទេប្រាស?	Some monks live in Unnalom Pagoda, don't they?
8.	ព្រះតេជព្រះគុណគង់នៅវត្តឧណ្ណាលោម ទានទេប្រាស?	The monks (you) live in Unnalom Pagoda, don't you?

Drill D. Response

MODEL:	គ្រូ: ព្រះតេជព្រះគុណរៀនភាសាអី នៅសាលានោះ(អង់គ្លេសនឹងបារាំង)	**Teacher:** What languages do you study at that school? (English and French)
	សិស្ស: ចំរើនពរ អាត្មារៀនភាសាអង់គ្លេស នឹងបារាំង ឯកន្លែងនោះ។	**Student:** I study English and French at that school.
1.	ព្រះតេជព្រះគុណ អានភាសាបរទេស បានខ្លះភានប្រាស? (បាលីនឹងសំស្ក្រឹត)	ចំរើនពរ អាត្មា អានភាសាបាលីនឹង សំស្ក្រឹតបានខ្លះ។
2.	ព្រះតេជព្រះគុណ គង់នៅវត្តណា? (ឧណ្ណាលោម)	ចំរើនពរ អាត្មានៅវត្តឧណ្ណាលោម។
3.	នៅវត្តនោះមានព្រះសង្ឃប៉ុន្មានអង្គ? (មួយរយអង្គប្រហែល)	ចំរើនពរ នៅវត្តនោះមានព្រះសង្ឃ មួយរយប្រហែល។
4.	ព្រះសង្ឃស្ទើរតែនិមន្តទៅរៀននៅ ពុទ្ធិកវិទ្យាល័យឬ? (ទេ ខ្លះរៀននៅសាលាបឋមសិក្សា)	ចំរើនពរ ទេ ព្រះសង្ឃអង្គខ្លះរៀន នៅសាលាបឋមសិក្សា។
5.	គេបង្រៀនវិជ្ជាគ្រប់មុខនៅសាលានោះ មែនទេ? (បាទ ដូចនៅវិទ្យាល័យឯទៀត ដែរ)	បាទ គេបង្រៀនវិជ្ជាគ្រប់មុខដូចនៅវិទ្យា ល័យឯទៀតដែរ។

Drill E. Transformation

MODEL:	គ្រូ: លោកនិយាយភាសាអង់គ្លេស បានទេ?	**Teacher:** You can speak English, can't you?
	សិស្ស: ព្រះតេជព្រះគុណមានពុទ្ធ ដីកាភាសាអង់គ្លេសបានទេ?	**Student:** You can speak English, can't you? (monk's language)
1.	លោកនៅវត្តណា?	ព្រះតេជព្រះគុណគង់នៅវត្តណា?
2.	លោកទៅរៀនសាលាណា?	ព្រះតេជព្រះគុណនិមន្តទៅរៀនសាលាណា?
3.	ជំរាបសួរលោក លោកសុខសប្បាយ ជាទេ?	ថ្វាយបង្គំព្រះតេជគុណ ព្រះតេជគុណ សុខសប្បាយជាទេ?
4.	លោកនៅវត្តឧណ្ណាលោមប៉ុន្មានឆ្នាំហើយ?	ព្រះតេជគុណគង់នៅវត្តឧណ្ណាលោមប៉ុន្មាន ឆ្នាំហើយ?
5.	លោកមកដល់ភ្នំពេញពីថ្ងៃណា?	ព្រះតេជគុណនិមន្តមកដល់ភ្នំពេញ ពីថ្ងៃ ណា?

Drill F. Response

MODEL:	គ្រូ: ព្រះសង្ឃគ្រប់អង្គសុទ្ធតែរៀននៅពុទ្ធិកវិទ្យាល័យ ឬអី? (សាលានោះ សាលាបឋមសិក្សា)	Teacher: Do all the monks only study at the Buddhist Institute? (that school, Buddhist elementary school)
	សិស្ស: ចំរើនពរ ព្រះសង្ឃខ្លះរៀននៅសាលានោះ ហើយអង្គខ្លះទៀតរៀននៅសាលាបឋមសិក្សា។	Student: No, some monks study in that school, and others study in the Buddhist elementary school.
1.	ព្រះសង្ឃគ្រប់អង្គសុទ្ធតែគង់នៅវត្តឧណ្ណាលោម ឬអី? (វត្តនោះ វត្តមួយនៅជិតវាំង)	ចំរើនពរ ព្រះសង្ឃខ្លះគង់នៅវត្តនោះ ហើយ អង្គខ្លះទៀត គង់នៅវត្តមួយជិតវាំង។
2.	កូនសិស្សទាំងអស់សុទ្ធតែរៀនភាសាបារាំង ឬអី? (ភាសាបារាំង ភាសាអង់គ្លេស)	ចំរើនពរ សិស្សខ្លះរៀនភាសាបារាំង ខ្លះទៀតរៀន ភាសាអង់គ្លេស។
3.	កូនសិស្សទាំងអស់សុទ្ធតែរស់នៅសាលារៀន ឬអី? (សាលារៀន ផ្ទះ)	ចំរើនពរ សិស្សខ្លះរស់នៅសាលារៀន ខ្លះទៀតនៅផ្ទះ។
4.	គ្រូទាំងអស់សុទ្ធតែបង្រៀនភាសាសំស្ក្រឹត ឬទេ? (ភាសានោះ ភាសាបាលី)	ចំរើនពរ គ្រូខ្លះបង្រៀនភាសាសំស្ក្រឹត ខ្លះទៀត ភាសានោះ។
5.	គ្រូទាំងអស់សុទ្ធតែជាអ្នករាជការ ឬអី? (អ្នករាជការ ព្រះសង្ឃ)	ចំរើនពរ គ្រូខ្លះជាអ្នករាជការ ខ្លះទៀតជាព្រះសង្ឃ។

Drill G. Response

MODEL:	គ្រូ: លោកតែងតែបង្រៀនភាសាបរទេស ឬអី? (សាលាបរទេស វិជ្ជាឯទៀត)	Teacher: Do you always teach foreign languages? (foreign languages, other subjects)
	សិស្ស: ជួនកាលខ្ញុំបង្រៀនភាសាបរទេស ជួនកាលខ្ញុំបង្រៀនវិជ្ជាឯទៀត។	Student: Sometimes I teach foreign languages; sometimes I teach other subjects.
1.	ព្រះតេជព្រះគុណតែងតែរៀនភាសាបរទេស ឬអី? (ភាសាបរទេស វិជ្ជាឯទៀត)	ជួនកាលអាត្មារៀនភាសាបរទេស ជួនកាល អាត្មារៀនវិជ្ជាឯទៀត។

2.	ព្រះសង្ឃតែងតែគង់នៅវត្តឬអី? (នៅវត្ត និមន្តទៅទេសនា)	ជួនកាលព្រះសង្ឃគង់នៅវត្ត ជួនកាលព្រះសង្ឃនិមន្តទៅទេសនា។
3.	កូនសិស្សតែងតែរៀននៅក្នុងសាលារៀនឬអី? (នៅក្នុងសាលា នៅផ្ទះ)	ជួនកាលកូនសិស្សរៀននៅក្នុងសាលា ជួនកាលកូនសិស្សរៀននៅផ្ទះ។
4.	ព្រះតេជព្រះគុណតែងតែនិមន្តទៅរៀនឬអី? (រៀន មិនរៀន)	ជួនកាលអាត្មារៀន ជួនកាលអាត្មាមិនរៀន។
5.	អ្នករាជការតែងតែឈប់ធ្វើការនៅពេលបុណ្យឬអី? (ឈប់ធ្វើការ មិនឈប់)	ជួនកាលអ្នករាជការឈប់ធ្វើការ ជួនកាលមិនឈប់។

Drill H. Transformation

MODEL:	គ្រូ:	កូនសិស្សរៀនភាសាខ្មែររាល់ឆ្នាំ។	**Teacher:** The students study Cambodian every year.
	សិស្ស:	កូនសិស្សតែងតែរៀនភាសាខ្មែររាល់ឆ្នាំ។	**Student:** The students always study Cambodian every year.
	គ្រូ:	កូនសិស្សទាំងអស់រៀនភាសាខ្មែរ។	**Teacher:** All the students study Cambodian.
	សិស្ស	កូនសិស្សទាំងអស់សុទ្ធតែរៀនភាសាខ្មែរ។	**Student:** All the students study only Cambodian.

1.	អាត្មារៀននៅវិទ្យាល័យរាល់ថ្ងៃ។ ព្រះសង្ឃទាំងអស់រៀននៅវិទ្យាល័យ។	អាត្មាតែងតែរៀននៅវិទ្យាល័យរាល់ថ្ងៃ។ ព្រះសង្ឃទាំងអស់សុទ្ធតែរៀននៅវិទ្យាល័យ។
2.	យើងនាំគ្នាទៅវត្តរាល់ថ្ងៃអាទិត្យ។	យើងតែងតែនាំគ្នាទៅវត្តរាល់ថ្ងៃអាទិត្យ។
3.	ខ្ញុំរៀនភាសាអង់គ្លេសរាល់ឆ្នាំ។	ខ្ញុំតែងតែរៀនភាសាអង់គ្លេសរាល់ឆ្នាំ។
4.	លោកទាំងអស់គ្នាត្រូវរៀនភាសា	លោកទាំងអស់គ្នាសុទ្ធតែត្រូវរៀនភាសា
5.	បរទេសមួយ។	បរទេសមួយ។

UNIT 68

BASIC DIALOGUE

Layman

1. ព្រះសង្ឃឆាន់ប៉ុន្មានដងមួយថ្ងៃ?

How many times do you eat in a day?

Monk

2. ចំរើនពរ ព្រះសង្ឃឆាន់តែពីរ
ពេលទេ ក្នុងមួយ គឺពេលព្រឹក និង
ពេលមុនថ្ងៃត្រង់។ ព្រះសង្ឃគ្មាន
ចង្ហាន់ពេលល្ងាចទេ។

Monks only eat two times a day: that is, in the morning and before noon. Monks don't have any food in the afternoon.

Layman

3. បើលោកមិនឆាន់ពេលល្ងាចទេ
លោកមិនអស់កម្លាំងទេឬអី?

If you don't eat in the afternoon, aren't you tired?

Monk

4. ចំរើនពរ មិនរាល់ថ្ងៃទេ ហើយបើ
លោកអស់កម្លាំង លោកអាចឆាន់
ភេសជ្ជៈ ដូចជាតែ កាហ្វេ ទឹកក្រូច
ជាដើម បាន។

Not every day. If you are tired you can drink a beverage like tea, coffee, or orange juice, for example.

Layman

5. នៅវត្តនីមួយៗ មានលោកគ្រូ
ចៅអធិការ។ កុដិលោកចៅអធិការ
នៅខាងក្រោយវិហារ។ លោកគ្រូចៅ
អធិការគង់នៅឬទេ?

In every wat there is a chief monk's house behind the temple. Is he in?

Monk

6. ព្រះតេជព្រះគុណចាំនឹងលោកគ្រូ
អាចារ្យ និមន្តទៅសូត្រមន្តនៅផ្ទះគេ
ខាងកើតវត្ត។ ភិក្ខុ សាមណេរ ឯទៀត
និមន្តទៅសូត្រធម៌ក្នុងវិហារ។ ស្អែក
ព្រឹកគេនិមន្តលោកទៅដាក់បាត។ លោកទាំង
អស់និមន្តទៅបិណ្ឌបាតនៅទីនោះ។ គេ
ប្រគេនចង្ហាន់លោកឲ្យលោកយកទៅ
ឆាន់ឯវត្ត។

The chief monk and his deputy are praying at someone's house east of the wat. The monks and novices are praying in the temple. Tomorrow morning the people have invited the monks to come to beg alms. All the monks go to ask alms there. They offer them food to take to eat in the wat.

Layman

7.	ខ្ញុំករុណាសូមថ្វាយបង្គំលាព្រះតេជគុណសិនហើយ ។	I would like to say goodbye.

DRILLS

Drill A. Substitution

1.	ព្រះសង្ឃឆាន់ប៉ុន្មានដង១ថ្ងៃ?	How many times a day do the monks eat?
2.	ព្រះសង្ឃនិមន្តបិណ្ឌបាតប៉ុន្មានដង១ថ្ងៃ?	How many times a day do the monks beg alms?
3.	ព្រះសង្ឃនិមន្តចូលវិហារប៉ុន្មានដង១ថ្ងៃ?	How many times a day do the monks enter the temple?
4.	ព្រះសង្ឃនិមន្តទៅសូត្រធម៌ប៉ុន្មានដង១ថ្ងៃ?	How many times a day do the monks go pray?
5.	ព្រះសង្ឃនិមន្តទៅរៀនបាលីប៉ុន្មានដង១ថ្ងៃ?	How many times a day do the monks study Pali?
6.	ព្រះសង្ឃនិមន្តទៅរៀនសំស្ក្រឹតប៉ុន្មានដង១ថ្ងៃ?	How many times a day do the monks study Sanskrit?
7.	ព្រះសង្ឃនិមន្តទៅសាលារៀនប៉ុន្មានដង១ថ្ងៃ?	How many times a day do the monks go to school?
8.	ព្រះសង្ឃនិមន្តទៅកុដិលោកគ្រូចៅអធិការ ប៉ុន្មានដង១ថ្ងៃ?	How many times a day do the monks visit the chief monk's quarters?

Drill B. Double Substitution

1.	នៅវត្តនីមួយៗមានលោកគ្រូចៅអធិការ។	In each wat there is a chief monk.
2.	នៅវត្តនីមួយៗមានលោកសង្ឃពីរបីអង្គ។	In each hut there are two or three monks.
3.	នៅវិហារនីមួយៗមានព្រះពុទ្ធរូបច្រើនអង្គ។	In each temple there are many images of Buddha.
4.	នៅភូមិនីមួយៗមានលោកសង្ឃនិមន្តទៅបិណ្ឌបាត។	In each village there are monks seeking alms.
5.	នៅក្រោយវិហារ មានកុដិលោកគ្រូចៅអធិការ។	Behind the temple is the chief monk's house.
6.	នៅវត្តមានអាចារ្យសម្រាប់វត្ត។	At the wat there is a teacher for the wat.
7.	នៅក្នុងវត្តមានសាលាបឋមសិក្សា។	Inside the wat, there is an elementary school.

8.	នៅថ្នាក់រៀនមានព្រះសង្ឃខ្លះចេះនិ យាយ អង់គ្លេស ។	In the class there are several monks who know how to speak English.

Drill C. Double Substitution

1.	បើលោកមិនឆាន់ល្ងាចទេ លោកមិន អស់កម្លាំងទេឬអី?	If they don't eat in the evening aren't they tired?
2.	បើលោកមិននិមន្តទៅរៀនទេ លោក មិនអាចប្រឡងបាន ។	If they don't go study, can't they take the exam?
3.	បើលោកមិនចេះបាលីទេ លោកមិនពិបាក រៀនធម៌ទេឬអី?	If they don't know Pali, isn't it hard to learn prayers?
4.	បើលោកមិននិមន្តទៅបិណ្ឌបាតទេ លោក មិនឲ្យគេទៅយកម្ហូបទេឬអី?	If they don't go begging, don't they have someone go get food?
5.	បើលោកមិននិមន្តទៅទេសនាទេ លោក មិនបានជួបគេទេឬអី?	If they don't go preach, can't they meet them?
6.	បើលោកមិនរៀនធម៌ទេ លោកមិន ចេះសូត្រធម៌ទេឬអី?	If they don't study to pray, don't they know how to pray?
7.	បើលោកមិនដែលទេសនាទេ លោកមិន ស្មានថាពិបាកទេឬអី?	If they have never preached, don't they think it's hard?

Drill D. Response

MODEL:	គ្រូ: លោកសង្ឃអាចឆាន់ចង្ហាន់ បានប៉ុន្មានដង១ថ្ងៃ? (តែពីរដងទេ)	Teacher:	How many times a day can a monk eat? (only two times)
	សិស្ស: លោកសង្ឃអាចឆាន់ចង្ហាន់ បានតែពីរដងទេ១ថ្ងៃ ។	Student:	A monk can eat only two times a day.

1.	ព្រះសង្ឃអាចឆាន់បាននៅពេល ណាខ្លះ? (ពេលព្រឹកនិងមុនថ្ងៃត្រង់ទេ)	ព្រះសង្ឃអាចឆាន់បាននៅពេលព្រឹក និងមុនថ្ងៃត្រង់ទេ ។
2.	តាមធម្មតាព្រះសង្ឃនិមន្តទៅបិណ្ឌ បាតប៉ុន្មានដង១ថ្ងៃ? (តែពីរដងទេ)	តាមធម្មតាព្រះសង្ឃនិមន្តទៅបិណ្ឌបាត តែពីរដងទេ១ថ្ងៃ ។
3.	តាមធម្មតាគេនាំគ្នាទៅប្រគេនចង្ហាន់ លោកប៉ុន្មានដង១ថ្ងៃ? (តែ២ដងទេ)	តាមធម្មតាគេនាំគ្នាទៅប្រគេនចង្ហាន់ លោកតែ២ដងទេ១ថ្ងៃ ។

4.	តាមធម្មតាព្រះសង្ឃមិននិមន្តទៅបិណ្ឌបាតប៉ុន្មានដង១ខែ? (តែ៤ ដងទេ)	តាមធម្មតាព្រះសង្ឃមិននិមន្តទៅបិណ្ឌបាតតែ៤ ដងទេ១ខែ។
5.	តាមធម្មតាព្រះសង្ឃនិមន្តចូលវិហារប៉ុន្មានដង១ថ្ងៃ? (ប៉ុន្មានដងក៏បានដែរ)	តាមធម្មតាព្រះសង្ឃនិមន្តចូលវិហារប៉ុន្មានដងក៏បានដែរ។
6.	តាមធម្មតាគេប្រគេនចង្ហាន់លោកប៉ុន្មានដង១ថ្ងៃ? (តែ១ដងទេ)	តាមធម្មតាគេប្រគេនចង្ហាន់លោកតែម្ដងទេ។

Drill E. Response

MODEL: គ្រូ: លោកដឹងទេ លោកគ្រូចៅអធិការគង់នៅកុដិណា? (ក្រោយវិហារ)

Teacher: Do you know in which house the chief monk lives? (behind the temple)

សិស្ស: បាទ លោកគ្រូចៅអធិការគង់នៅកុដិក្រោយវិហារ។

Student: Yes, the chief monk lives in a house behind the temple.

1.	លោកដឹងទេលោកគ្រូចៅអធិការនិមន្តទៅណា? (សូត្រមន្ត)	បាទ លោកគ្រូចៅអធិការនិមន្តទៅសូត្រមន្ត។
2.	លោកដឹងទេ លោកតាអាចារ្យអញ្ជើញទៅណា? (ជាមួយលោកគ្រូចៅអធិការ)	បាទ លោកតាអាចារ្យអញ្ជើញទៅជាមួយលោកគ្រូចៅអធិការ។
3.	លោកដឹងទេ លោកសង្ឃគង់នៅវត្តច្រើននិមន្តទៅបិណ្ឌបាតនៅភូមិណា? (ភូមិ សា)	បាទ លោកសង្ឃគង់នៅវត្តនេះច្រើននិមន្តទៅបិណ្ឌបាតនៅភូមិស្វា។
4.	លោកដឹងទេ គ្រូបង្រៀនថ្មីនោះមកពីខេត្តណា? (តាកែវ)	បាទ គ្រូបង្រៀននោះមកពីខេត្តតាកែវ។
5.	លោកដឹងទេ ព្រះសង្ឃគង់នៅវត្តនេះនិមន្តទៅរៀនសាលាណា? (ពុទ្ធិកវិទ្យាល័យ)	បាទ ព្រះសង្ឃគង់នៅវត្តនេះ និមន្តទៅរៀននៅសាលាពុទ្ធិកវិទ្យាល័យ។
6.	លោកដឹងទេ ឡាននេះទៅឈប់នៅឯណា? (ផ្សារថ្មី)	បាទ ឡាននេះនៅឈប់នៅផ្សារថ្មី។

Drill F. Transformation

MODEL: គ្រូ : នៅក្រោយវិហារ តែងតែ
មានកុដិលោកគ្រូចៅ
អធិការ។

Teacher: Behind the temple there is always the hut of the chief monk.

សិស្ស: កុដិលោកគ្រូចៅអធិការ
តែងតែនៅក្រោយវិហារ។

Student: The hut of the chief monk is always behind the temple.

1. នៅក្នុងពុទ្ធិកវិទ្យាល័យច្រើនមានព្រះសង្ឃនិមន្តមកពីវត្តនានា។	ព្រះសង្ឃនិមន្តមកពីវត្តនានា ច្រើនគង់នៅពុទ្ធិកវិទ្យាល័យ។
2. នៅតាមថ្នល់មិនសូវមានមនុស្សទេ។	មិនសូវមានមនុស្សទេនៅតាមថ្នល់។
3. នៅវត្តនេះច្រើនមានភិក្ខុសាមណេរនិមន្តមកសំណាក់និងរៀនបាលី។	ភិក្ខុសាមណេរច្រើននិមន្តមកសំណាក់និងរៀនបាលីនៅវត្តនេះ។
4. នៅតាមផ្លូវជុំវិញផ្សារថ្មីមានឡាននិងស៊ីក្លូទៅមកមិនឈប់ឈរទេ។	មានឡាននិងស៊ីក្លូទៅមកមិនឈប់ឈរទេ នៅតាមផ្លូវជុំវិញផ្សារថ្មី។
5. នៅក្នុងវិហារគេមិនត្រូវពាក់មួកឬស្បែកជើងទេ។	គេមិនត្រូវពាក់មួកឬស្បែកជើងទេនៅក្នុងវិហារ។
6. នៅក្នុងភូមិនោះប្រហែលមានផ្ទះលក់បាយមួយពីរ។	ប្រហែលមានផ្ទះលក់បាយមួយពីរនៅក្នុងភូមិនោះ។

Drill G. Transformation

MODEL: គ្រូ: ខ្ញុំករុណាខានមកលេងនឹង
ព្រះតេជព្រះគុណយូរ
ណាស់ហើយ ព្រោះខ្ញុំករុណា
មិនដែលបានទំនេរសោះ។

Teacher: I have missed coming to visit you for a long time because I have never had any free time at all.

សិស្ស: គាត់មិនបានមកលេងព្រះ
តេជគុណទេ ព្រោះគាត់
មិនទំនេរទេ។

Student: He didn't come visit the monk because he wasn't free.

1. វាខានទៅសាលាយូរហើយព្រោះវាចេះតែមិនស្រួលខ្លួនសោះ។	គាត់មិនបានទៅសាលារៀនទេ ព្រោះគាត់មិនស្រួលខ្លួន។
2. វាខានឲ្យដំណឹងយូរហើយព្រោះ វាមិនដែលមានពេលសោះ។	គាត់មិនដែលឲ្យដំណឹងព្រោះ គាត់គ្មានពេល។

3. ខ្ញុំបានជួបគាត់យូរហើយព្រោះខ្ញុំមិនទំនេរ ទៅលេងផ្ទះថ្មីគាត់នោះ។	គាត់មិនបានជួបទារក ព្រោះគាត់មិនទំនេរ ទៅផ្ទះថ្មីទារកនោះ។
4. ខ្ញុំបានទៅធ្វើការបានមួយអាទិត្យហើយ ព្រោះខ្ញុំត្រូវទៅជួបឧបជ្ឈាយ៍ខ្ញុំ។	គាត់មិនបានទៅធ្វើការបាន១ អាទិត្យហើយ ព្រោះគាត់ត្រូវទៅជួបឧបជ្ឈាយ៍គាត់។
5. លោកបានទៅបាញ់សត្វជិត១ឆ្នាំ ហើយព្រោះលោក ឈឺជើង។	គាត់មិនទៅបាញ់សត្វជិត១ឆ្នាំហើយ ព្រោះគាត់ឈឺជើង។
6. លោកបាននិមន្តមកបិណ្ឌបាត១ខែ ហើយ ព្រោះលោកកំពុងរវល់សង់វិហារ។	លោកមិននិមន្តមកបិណ្ឌបាត១ខែ ហើយ ព្រោះលោករវល់សង់វិហារ។

Drill H. Expansion

1. លោកគ្រូនិមន្តទៅសាលារៀន។	The teacher (monk) goes to the school.
2. លោកគ្រូចៅអធិការនិមន្តទៅសាលារៀន។	The chief monk goes to the school.
3. លោកគ្រូចៅអធិការនិងព្រះសង្ឃពីរអង្គនិមន្តទៅសាលារៀន។	The chief monk and two monks go to the school.
4. លោកគ្រូចៅអធិការនិងព្រះសង្ឃពីរអង្គនិមន្តទៅសាលារៀននៅមុខវាំង។	The chief monk and two monks go to the school in front of the palace.
5. លោកគ្រូចៅអធិការនិងព្រះសង្ឃពីរអង្គនិមន្តទៅសាលារៀន នៅមុខវាំង ឈ្មោះ ពុទ្ធិកវិទ្យាល័យ។	The chief monk and two monks go to the school in front of the palace called the Buddhist Institute.

Drill I. Reduction

1. លោកគ្រូចៅអធិការនិងព្រះសង្ឃពីរអង្គនិមន្តទៅសាលារៀន នៅមុខវាំង ឈ្មោះពុទ្ធិកវិទ្យាល័យ។	The chief monk and two monks go to the school in front of the palace called the Buddhist Institute.
2. លោកគ្រូចៅអធិការ និងព្រះសង្ឃពីរអង្គនិមន្តទៅសាលារៀននៅមុខវាំង។	The chief monk and two monks go to the school in front of the palace.
3. លោកគ្រូចៅអធិការនិងព្រះសង្ឃពីរអង្គនិមន្តទៅសាលារៀន។	The chief monk and two monks go to the school.

4. លោកគ្រូចៅអធិការនិមន្តទៅសាលារៀន ។
The chief monk goes to the school.

5. លោកគ្រូនិមន្តទៅសាលារៀន ។
The teacher (monk) goes to the school.

Drill J. Expansion

1. លោកមិននិមន្តមកបិណ្ឌបាតទេ ។
He didn't come to beg alms.

2. ម្សិលមិញលោកមិននិមន្តមកបិណ្ឌបាតទេ ។
He didn't come to beg alms yesterday.

3. ម្សិលមិញលោកបីអង្គនោះមិននិមន្តមកបិណ្ឌបាតទេ ។
The three monks didn't come to beg alms yesterday.

4. ម្សិលមិញលោកបីអង្គនោះមិននិមន្តមកបិណ្ឌបាតផ្ទះខ្ញុំទេ ។
The three monks didn't come to beg alms at my house yesterday.

Drill K. Reduction

1. ម្សិលមិញលោកបីអង្គនោះមិននិមន្តមកបិណ្ឌបាតផ្ទះខ្ញុំទេ ។
The three monks didn't come to beg alms at my house yesterday.

2. ម្សិលមិញលោកបីអង្គនោះមិននិមន្តមកបិណ្ឌបាតទេ ។
The three monks didn't come to beg alms yesterday.

3. ម្សិលមិញលោកមិននិមន្តមកបិណ្ឌបាតទេ ។
He didn't come to beg alms yesterday.

4. លោកមិននិមន្តមកបិណ្ឌបាតទេ ។
He didn't come to beg alms.

UNIT 69

BASIC DIALOGUE

	John	
1.	នៅប្រទេសកម្ពុជា ក្រៅពីចិន យួន នឹងជនជាតិ អឺរ៉ុប មានជនជាតិ ណាទៀត?	In Cambodia, besides Chinese, Vietnamese, and Europeans, what other nationalities are there?
	Sok	
2.	បាទ មានក្លិង្គ លាវ នឹងចាម។	There are Indians, Lao, and Chams.
	John	
3.	អូ ខ្ញុំភ្លេច ខ្ញុំឃើញក្លិង្គលក់ កំណាត់នៅផ្សារធំថ្មី។ ចុះលាវនឹង ចាម គេច្រើនរកស៊ីអី?	Oh, I forgot. I saw an Indian selling cloth at the New Market. As for the Lao and the Chams, how do they earn a living for the most part?
	Sok	
៤ 4.	បាទ លាវមិនសូវមានច្រើនទេ គេច្រើនតែមករៀន។ ឯចាមវិញ នៅស្រុកខ្មែរយូរមកហើយ។	There aren't many Lao. They mostly come to study. As for the Chams, they have lived in Cambodia for a long time.
	John	
5.	ចាមមកនៅស្រុកខ្មែរពីអង្កាល់?	How long (since when) have the Chams lived in Cambodia?
	Sok	
៦ 6.	តាមប្រវត្តិសាស្ត្រ ក្រោយ ប្រទេសចំប៉ា ទទួលបរាជ័យ ក្នុង ការវាយរាត ត្បាត ពីប្រទេស អាណាម មក។ ចាមជាច្រើនរត់ចេញ ពីប្រទេសកំណើតខ្លួន ទៅនៅប្រទេស ជិតខាង មានប្រទេស កម្ពុជា និង ឥណ្ឌូណេស៊ីជាដើម។	According to history, after Champa was defeated in the invasion from Annam, many Chams fled from their homeland to go live in neighboring countries, for example Cambodia and Indonesia.
	John	
7.	ម៉េចបានជាគេមិននៅជាមួយ យួន?	How come they didn't stay with the Vietnamese?

Sok

8. អូ យួន ធ្វើបាបគេណាស់ ឲ្យគេនៅជាមួយម៉េចបាន?

The Vietnamese mistreated them badly. How could they live with them?

John

9. ឥឡូវនៅស្រុកខ្មែរមានចាមប៉ុន្មាននាក់?

Now how many Chams are there in Cambodia?

Sok

10. បាទ មានជាងដប់ម៉ឺននាក់។

There are more than one hundred thousand.

John

11. គេច្រើននៅខេត្តណាខ្លះ?

In what provinces do most of them live?

Sok

12. បាទ គេច្រើននៅខេត្តកំពង់ចាម និងជ្រោយចង្វារជិតភ្នំពេញ?

For the most part they live in Kompong Cham province and in Chrui Changvar near Phnom Penh.

John

13. ចាម រកស៊ីធ្វើការអ្វី?

How do the Chams earn a living?

Sok

14. បាទ គេច្រើនតែធ្វើការនេសាទ ធ្វើចំការ ឬជាឈ្មួញគោ។

For the most part they fish, grow crops, and are cattle traders.

John

15. តាមខ្ញុំស្មាន ចាមទាំងនោះមានការរស់នៅនិងទំនៀមទម្លាប់មិនខុសពីខ្មែរប៉ុន្មានទេ។

I think that all those Chams have a life and customs which are not very different from the Cambodians.

Sok

16. បាទ មិនជាខុសច្រើនទេ តែគេអាចដឹងថាចាមបាន ព្រោះចាមស្លៀកសារុងហើយពាក់កាតិប ឬឈ្នួតក្បាល។ ចាមនិយាយខ្មែរច្បាស់គួរសំដែរ តែគេនៅប្រើភាសាចាមក្នុងការទាក់ទងក្នុងគ្រួសារគេ។

Not very different, but people can know (who is) a Cham, because the Chams wear a sarong and a cap or a turban. The Chams speak Cambodian well, but they still use Cham in their family dealings (relations).

DRILLS

Drill A. Substitution

1.	នៅភ្នំពេញមានជនជាតិអ្វីខ្លះ?	In Phnom Penh what kinds of nationality are there?
2.	នៅវ៉ាស៊ីនតោន មានជនជាតិអ្វីខ្លះ?	In Washington what kinds of nationality are there?
3.	នៅកាណាដា មានជនជាតិអ្វីខ្លះ?	In Canada what kinds of nationality are there?
4.	នៅសង់ហ្វ្រាង់ស៊ីស្កោ មានជនជាតិអ្វីខ្លះ?	In San Francisco what kinds of nationality are there?
5.	នៅសង់ហ្វ្រាង់ស៊ីស្កោមានផ្ទះរបៀបណាខ្លះ?	In San Francisco what kinds of house are there?
6.	នៅសង់ហ្វ្រាង់ស៊ីស្កោមានផ្លូវរបៀបណាខ្លះ?	In San Francisco what kinds of street are there?
7.	នៅសង់ហ្វ្រាង់ស៊ីស្កោមានផ្សាររបៀបណាខ្លះ?	In San Francisco what kinds of market are there?
8.	នៅសង់ហ្វ្រាង់ស៊ីស្កោមានវត្តរបៀបណាខ្លះ។	In San Francisco what kinds of wat are there?

Drill B. Double Substitution

1.	ក្រៅពីខ្មែរ គេឃើញមានក្លិង្គនិងចិន។	Besides Cambodians, they see that there are Indians and Chinese.
2.	ក្រៅពីយួន គេឃើញមានជប៉ុននិងឡាវ។	Besides Vietnamese, they see that there are Japanese and Lao.
3.	ក្រៅពីអាមេរិកាំង ឃើញមានយួននិងកូរ៉េ។	Besides Americans, they see that there are Vietnamese and Koreans.
4.	ក្រៅពីបារាំង គេឃើញមានខ្មែរនិងរុស្ស៊ី។	Besides French, they see that there are Cambodians and Russians.
5.	ក្រៅពីឡាន គេឃើញមានស៊ីក្លូនិងកង់។	Besides cars, they see that there are cyclos and bicycles.
6.	ក្រៅពីព្រះសង្ឃ គេឃើញមានអ្នករាជការ និងទាហាន។	Besides monks, they see that there are government workers and soldiers.
7.	ក្រៅពីនិស្សិតខ្មែរគេឃើញមាននិស្សិតបរទេស និងអ្នកកាសែត។	Besides Cambodian students, they see that there are foreign students and journalists.
8.	ក្រៅពីប្រមុខរដ្ឋ គេឃើញមានអគ្គទូតនានា និងអ្នករាជការ។	Besides the Chief of State, they see that there are various ambassadors and government officials.

Drill C. Double Substitution

1.	ក្លិង្គច្រើនលក់កំណាត់ ឯចាមវិញគេច្រើនទិញគោ ។	The Indians sell textiles. As for the Chams, they mostly buy cattle.
2.	ក្លិង្គច្រើននៅក្បែរផ្សារថ្មី ឯចាមវិញគេច្រើននៅជ្រោយចង្វារ ។	The Indians live near the New Market. As for the Chams, they mostly live in Chrui Changvar.
3.	ក្លិង្គច្រើននិយាយញាប់ ឯចាមវិញគេច្រើននិយាយមួយៗ ។	The Indians speak quickly. As for the Chams, they mostly speak slowly.
4.	ជនជាតិអេស្ប៉ាញ៉ុលច្រើននិយាយញាប់ ឯជនជាតិបារាំងវិញនិយាយខ្លាំងៗ ។	The Spanish speak quickly. As for the French, they mostly speak slowly.
5.	ជនជាតិអេស្ប៉ាញ៉ុលច្រើនឈរលេងនៅមុខផ្ទះ ឯជនជាតិបារាំងវិញគេច្រើននិយាយគ្នាលេងនៅក្នុងផ្ទះ ។	The Spanish stand around at leisure in front of the house. As for the French, they mostly talk to each other in the house.
6.	ជនជាតិអេស្ប៉ាញ៉ុលច្រើនធ្វើដំណើរ ឯជនជាតិបារាំងវិញគេច្រើននៅផ្ទះ ។	The Spanish travel. As for the French, they mostly stay home.
7.	បងខ្ញុំច្រើនធ្វើដំណើរ ឯកូនគាត់វិញវាច្រើននៅផ្ទះ ។	My older brother travels. As for his son he mostly stays at home.
8.	បងខ្ញុំច្រើនទៅធ្វើការ ឯកូនគាត់វិញវាច្រើននៅផ្ទះ	My older brother goes to work. As for his son he mostly stays home.

Drill D. Double Substitution

1.	ឡាវនៅស្រុកខ្មែរ ច្រើនតែជាកូនសិស្ស ។	The Lao in Cambodia are mostly students.
2.	ចាមនៅស្រុកខ្មែរច្រើនតែជាអ្នកទិញគោ ។	The Chams in Cambodia are mostly cattle merchants.
3.	បារាំងនៅស្រុកខ្មែរច្រើនតែជាគ្រូបង្រៀន ។	The French in Cambodia are mostly teachers.
4.	បារាំងនៅស្រុកយួនច្រើនតែជាអ្នកជំនួញ ។	The French in Vietnam are mostly businessmen.
5.	បារាំងនៅក្រុងនោះច្រើនតែជាកម្មករ ។	The French in this city are mostly workers.

6.	យួននៅភ្នំពេញច្រើនតែជាកម្មករ។	The Vietnamese in Phnom Penh are mostly workers.
7.	ខ្មែរនៅភ្នំពេញច្រើនតែជាអ្នករាជការ។	The Cambodians in Phnom Penh are mostly government officials.
8.	អ្នកធ្វើការនៅភ្នំពេញច្រើនតែអ្នកចេះនិយាយបារាំង។	The workers in Phnom Penh are mostly speakers of French.

Drill E. Positive Response

MODEL: គ្រូ: នៅប្រទេសកម្ពុជាមានចិនច្រើនទេ? — Teacher: Are there a lot of Chinese in Cambodia?

សិស្ស: បាទ ច្រើនគួរសំដែរ។ — Student: There are rather many.

1.	នៅភ្នំពេញមានឡានច្រើនទេ?	បាទ ច្រើនគួរសំដែរ។
2.	នៅវ៉ាស៊ីនតោនមានមនុស្សច្រើនទេ?	បាទ ច្រើនគួរសំដែរ។
3.	គេទៅបុណ្យនោះច្រើនទេ?	បាទ ច្រើនគួរសំដែរ។
4.	មានទាហានរៀននៅនោះច្រើនទេ?	បាទ ច្រើនគួរសំដែរ។
5.	សាលារៀននោះមានកូនសិស្សច្រើនទេ?	បាទ ច្រើនគួរសំដែរ។
6.	មានតាក់ស៊ីច្រើនទេ នៅញូវយក?	បាទ ច្រើនគួរសំដែរ។
7.	គេចញ្ចឹមគោច្រើនទេនៅស្រុកខ្មែរ?	បាទ ច្រើនគួរសំដែរ។

Drill F. Negative Response

MODEL: គ្រូ: នៅប្រទេសកម្ពុជាមានចិនច្រើនទេ? — Teacher: Are there a lot of Chinese in Cambodia?

សិស្ស: បាទ មិនជាច្រើនប៉ុន្មានទេ។ — Student: No, there aren't many.

1.	នៅភ្នំពេញមានឡានច្រើនទេ?	បាទ មិនជាច្រើនប៉ុន្មានទេ។
2.	នៅវ៉ាស៊ីនតោនមានមនុស្សច្រើនទេ?	បាទ មិនជាច្រើនប៉ុន្មានទេ។
3.	គេទៅបុណ្យនោះច្រើនទេ?	បាទ មិនជាច្រើនប៉ុន្មានទេ។
4.	មានទាហានរៀននៅនោះច្រើនទេ?	បាទ មិនជាច្រើនប៉ុន្មានទេ។
5.	សាលារៀននោះមានកូនសិស្សច្រើនទេ?	បាទ មិនជាច្រើនប៉ុន្មានទេ។
6.	មានតាក់ស៊ីច្រើនទេ នៅញូវយក?	បាទ មិនជាច្រើនប៉ុន្មានទេ។
7.	គេចញ្ចឹមគោច្រើនទេនៅស្រុកខ្មែរ?	បាទ មិនជាច្រើនប៉ុន្មានទេ។

Drill G. Transformation

MODEL: គ្រូ៖ ចាមមិនបរិភោគសាច់ជ្រូកទេ។ — **Teacher:** The Chams do not eat pork.

សិស្ស៖ តាមធម្មតា ចាមភាគច្រើន មិនបរិភោគសាច់ជ្រូកទេ។ — **Student:** The majority of Chams do not usually eat pork.

1.	កូនសិស្សមិនទៅរៀនថ្ងៃសៅរ៍។	តាមធម្មតាកូនសិស្សភាគច្រើនមិនទៅរៀនថ្ងៃសៅរ៍។
2.	ស្ត្រីខ្មែរមិនស្លៀកខោទេ។	តាមធម្មតាស្ត្រីខ្មែរភាគច្រើនមិនស្លៀកខោទេ។
3.	ចិនមិនធ្វើស្រែទេ។	តាមធម្មតាចិនភាគច្រើនមិនធ្វើស្រែទេ។
4.	អាមេរិកាំងកាន់សាសនាប្រូតេស្តង់។	តាមធម្មតាអាមេរិកាំងភាគច្រើនកាន់សាសនាប្រូតេស្តង់។
5.	អ្នកស្រុចត្រី ស្រុចនៅបឹងបុណ្យទន្លេ។	តាមធម្មតាអ្នកស្រុចត្រីភាគច្រើនស្រុចនៅបឹងបុណ្យទន្លេ។
6.	កូនសិស្សណាដែលខំរៀនច្រើនតែប្រឡងជាប់។	តាមធម្មតាកូនសិស្សណាដែលខំរៀនភាគច្រើនៗតែប្រឡងជាប់។
7.	ស្ត្រីអាមេរិកាំងមិនជក់បារីទេ។	តាមធម្មតាស្ត្រីអាមេរិកាំងភាគច្រើនមិនជក់បារីទេ។

Drill H. Response

MODEL: គ្រូ ៖ លោកពិសាសាច់ជ្រូកទេ? — **Teacher:** Do you eat pork?

សិស្ស៖ បាទ ខ្ញុំទទួលទានបាន មិនអីទេ។ — **Student:** It's O.K. for me to eat it.

1.	គេទៅបានទេ?	បាទ គេទៅបានមិនអីទេ។
2.	លោកជួយធ្វើការខ្ញុំមួយភ្លែតបានទេ?	បាទ ខ្ញុំជួយបាន មិនអីទេ។
3.	គាត់ជូនខ្ញុំទៅឯណោះមួយភ្លែតបានទេ?	បាទ គាត់ជូនបានមិនអីទេ។
4.	វាដើរកើតទេ?	បាទ វាដើរកើតមិនអីទេ។
5.	ខ្ញុំទៅជាមួយបានទេ?	បាទ លោកទៅជាមួយបាន មិនអីទេ?
6.	លោកអាចរៀនមេរៀននេះចប់ក្នុងមួយអាទិត្យបានទេ?	បាទ រៀន បាន មិនអីទេ។

Drill I. Response

MODEL:		
គ្រូ : ចាមរត់ចេញពីប្រទេសខ្លួន ទៅនៅប្រទេសណា? (កម្ពុជានិងឥណ្ឌូនេស៊ី)	Teacher:	To which country did the Chams flee from their own country? (Cambodia and Indonesia)
សិស្ស: តាមប្រវត្តិសាស្ត្រ ចាមរត់ចេញពីប្រទេសខ្លួនទៅនៅប្រទេសកម្ពុជានិងប្រទេសឥណ្ឌូនេស៊ី។	Student:	According to history, the Chams fled from their own country to Cambodia and Indonesia.

1.	គ្រិះស្តុស កូលុម រកអាមេរិកឃើញនៅសតវត្សណា? (ទី១៥)	តាមប្រវត្តិសាស្ត្រ គ្រិះស្តុស កូលុម រកស្រុកអាមេរិកឃើញនៅសតវត្សទី១៥។
2.	ប្រទេសកម្ពុជា ខ្លាំងពូកែបំផុតនៅសតវត្សណា? (ទី១៣)	តាមប្រវត្តិសាស្ត្រ ប្រទេសកម្ពុជា ខ្លាំងពូកែបំផុតនៅសតវត្សទី១៣។
3.	ប្រធានាធិបតីទី១នៃសហរដ្ឋ អាមេរិកឈ្មោះអ្វី? (វ៉ាស៊ីនតោន)	តាមប្រវត្តិសាស្ត្រ ប្រធានាធិបតីទី១នៃសហរដ្ឋអាមេរិកឈ្មោះវ៉ាស៊ីនតោន។
4.	ចំបាំងរវាងប្រទេសអង់គ្លេស និងសហរដ្ឋអាមេរិកនៅឆ្នាំណា? (ឆ្នាំ១៨១២)	តាមប្រវត្តិសាស្ត្រ ចំបាំងរវាងប្រទេសអង់គ្លេស និងសហរដ្ឋអាមេរិកនៅឆ្នាំ១៨១២។
5.	ចំបាំងលោក លើកទី២ ចប់នៅឆ្នាំណា? (ឆ្នាំ១៩៤៥)	តាមប្រវត្តិសាស្ត្រ ចំបាំងលោក លើកទី២ ចប់នៅឆ្នាំ១៩៤៥។

UNIT 70

NARRATION

1. លោកស្មិតបានដើរទៅជួបនឹងព្រះសង្ឃ១អង្គបានថ្វាយបង្គំសួរសុខទុក្ខព្រះសង្ឃនោះ។
2. ព្រះសង្ឃក៏មានពុទ្ធដីកាសួរទៅលោកស្មិតវិញ ហើយលោកស្មិតទូលលោកថា ខ្ញុំករុណាសុខសប្បាយដូចធម្មតា។
3. លោកស្មិតដឹងថាលោកនិមន្តទៅសាលារៀន ហើយក៏សួរថាសាលារៀនព្រះតេជព្រះគុណនៅឯណា?
4. ព្រះសង្ឃ ថាចំរើនពរ សាលាអាត្មានៅជិតវាំង។ សាលានោះឈ្មោះពុទ្ធិកវិទ្យាល័យព្រះសុរាមរិទ្ធិ។
5. ព្រះសង្ឃនេះរៀននៅនោះពីរឆ្នាំហើយ។ ឥឡូវនេះលោកចាប់រៀននៅថ្នាក់ទីបី។

1. Mr. Smith was taking a walk, met a monk, greeted him, and asked after his health.
2. The monk also asked after the health of Mr. Smith, and Mr. Smith told the monk "I'm well as usual."
3. Mr. Smith knew that the monk was going to school and asked him where the school was.
4. The monk said, "My school is near the palace. This school is called the Preah Suramarti Buddhist Lycée (Institute)."
5. The monks study there two years. Now the monk will begin to study in the third class.

1. នៅពុទ្ធិកវិទ្យាល័យព្រះសុរាមរិទ្ធិ គេបង្រៀនវិជ្ជាគ្រប់មុខ ដូចនៅវិទ្យាល័យឯទៀតដែរ ។
2. មិនតែប៉ុណ្ណោះគេបង្រៀនភាសាបាលីសំស្ក្រឹត ភាសាបរទេសដូចជាបារាំង អង់គ្លេស ហើយនិងសាសនាដែរ ។
3. លោកស្មិតឮដូច្នេះក៏សួរថាៈ ព្រះតេជព្រះគុណនិយាយភាសាអង់គ្លេសបានមែនទេ?
4. ព្រះសង្ឃមានពុទ្ធដីកាថា លោកនិយាយបានខ្លះដែរតែមិនស្គាល់ពាក្យច្រើនទេ ។
5. សព្វថ្ងៃលោកគង់នៅវត្តឧណ្ណាលោម ។
6. នៅវត្តនេះមានព្រះសង្ឃច្រើនដែរ ហើយមានសាលាពុទ្ធិកបឋមសិក្សាមួយ ។
7. ព្រះសង្ឃនិមន្តទៅរៀននៅសាលានេះ ខ្លះទៀតទៅពុទ្ធិកវិទ្យាល័យ ។

1. In the Preah Suramarit Buddhist Institute they teach all subjects just as in other lycées.
2. Not only this, but they teach Pali, Sanskrit and foreign languages like French and English, and religion too.
3. When Mr. Smith hears this he asks the monk if it's true that he speaks English.
4. The monk says he can speak some but he doesn't know many words.
5. At present the monk lives in Wat Unnalom.
6. In this wat there are many monks, and there is a Buddhist elementary school.
7. Some monks go to this school; some others go to the Buddhist Institute.

1. ព្រះសង្ឃឆាន់តែពីរពេលទេក្នុងមួយថ្ងៃ គឺពេលព្រឹកនិងថ្ងៃត្រង់។
2. លោកមិនឆាន់ពេលល្ងាចទេ តែបើលោកអស់កំឡាំង លោកអាចឆាន់ភេសជ្ជៈ ដូចជាកាហ្វេ
និងទឹកក្រូចជាដើមបាន។
3. នៅវត្តនីមួយៗ មានលោកគ្រូចៅអធិការ ដែលជាអ្នកមើលការខុសត្រូវ និងរបៀបគ្រប់គ្រង
ក្នុងវត្ត។
4. លោកនៅកុដិមួយខាងក្រោយវិហារ។
5. ថ្ងៃនេះលោកមិនគង់នៅវត្តទេ។ លោកនិងលោកគ្រូអាចារ្យទៅសូត្រមន្តនៅផ្ទះខាងកើតវត្ត។
6. ភិក្ខុសាមណេរឯទៀតនិមន្តទៅសូត្រមន្តក្នុងវិហារ។
7. ថ្ងៃដែលមិនមែនថ្ងៃសីលនិងថ្ងៃបុណ្យ លោកនិមន្តចេញទៅបិណ្ឌបាតនៅផ្ទះអ្នកស្រុកជិតវត្ត។
8. គេប្រគេនចង្ហាន់លោកឲ្យលោកយកទៅឆាន់ឯវត្ត។
9. ថ្ងៃបុណ្យនិងថ្ងៃសីលទេ គេតែងនាំគ្នាទៅប្រគេនចង្ហាន់លោកឯវត្ត។
10. ថ្ងៃបុណ្យខ្លះ គេនិមន្តលោកមកឆាន់នៅផ្ទះ។

1. The monks eat only twice a day, that is, in the morning and the time before noon.
2. The monks don't eat in the afternoon, but if they are tired they can drink beverages like tea, coffee and orange juice, for example.
3. In each wat there is a chief monk, who is the person who oversees and administers the affairs in the wat.
4. He lives in a house behind the temple.
5. Today he is not at the wat. He and the deputy went to pray in a house to the east of the wat.
6. The monks and the novices go to pray in the temple.
7. On days that are not holy days or holidays, the monks go seek alms at the houses of the peasants near the wat.
8. They (the peasants) offer food to the monks to take to eat in the wat.
9. Only on holidays and holy days do they normally go to offer food to the monks in the wat.
10. On some holidays, they invite the monks to come eat in their houses.

1. នៅប្រទេសកម្ពុជា ក្រៅពីចិន យួន និងជនជាតិអឺរ៉ុប គេឃើញមានក្លិង្គ លាវ និងចាម។
2. ក្លិង្គច្រើនរកស៊ីលក់កំណាត់ ឯលាវវិញគេច្រើនតែមករៀននៅសាលាផ្សេងៗនៅភ្នំពេញ។
3. ចាមមកសុំនៅស្រុកខ្មែរ ក្រោយប្រទេសចំប៉ា ទទួលបរាជ័យ ក្នុងការវាយរាតត្បាតពីប្រទេសអាណាមមក។
4. ដោយយួនធ្វើបាបគេខ្លាំង ចាមខ្លះទៀតក៏រត់ចេញពីប្រទេសខ្លួនទៅប្រទេសឥណ្ឌូណេស៊ី។
5. ចាមនៅស្រុកខ្មែរមានជាងដប់ម៉ឺននាក់ ហើយភាគច្រើនៗរកស៊ីខាងនេសាទ និងខាងជួញគោ។
6. គេច្រើននៅខេត្តកំពង់ចាម និងនៅជ្រោយចង្វារជិតភ្នំពេញ។
7. គេមានទំនៀមទម្លាប់មិនខុសពីខ្មែរប៉ុន្មានទេ។
8. តែករបៀបខ្លះដើម្បីឲ្យគេដឹងថាជាចាមបាន ព្រោះគេស្លៀកសារុង ហើយពាក់ក្រូបះ។
9. ចាមនិយាយខ្មែរច្បាស់គួរសមដែរ តែគេនៅនិយាយភាសាចាមក្នុងការទាក់ទងខាងគ្រួសារគេ។
10. គេកាន់សាសនាឥស្លាម តែវិហារគេមានក្បាច់ចនាតាមក្បាច់ខ្មែរដែរ។

1. In Cambodia, besides Chinese, Vietnamese and Europeans, one sees that there are Indians, Lao, and Chams.
2. The Indians mostly make a living selling cloth. As for the Lao, they mostly come to study in the various schools in Phnom Penh.
3. The Chams came to ask to stay in Cambodia after Champa was defeated in the invasion from Annam.
4. Since the Vietnamese made much hardship for them, some other Chams also fled from their country to Indonesia.
5. In Cambodia there are more than a hundred thousand Chams and the majority mostly make a living by fishing and by trading in cattle.
6. Mostly, they live in the province of Kompong Cham and in Chrui Changvar near Phnom Penh.
7. They have customs and traditions which are not very different from those of the Cambodians.
8. But there are some ways by which you can know that they are Chams, because they wear sarongs and Moslem hats.
9. The Chams speak Cambodian rather fluently, but they still speak Cham in their family dealings.
10. They are Moslems, but their temples are decorated in the Cambodian style.

UNIT 71

BASIC MONOLOGUE

1.	ទន្លេមេគង្គវែងជាងគេបំផុតនៅ ទ្វីបអាស៊ី។	The Mekong River is the largest in Asia.
2.	ទន្លេនេះចាប់កំណើតនៅភ្នំទីបេ ហើយមានប្រវែងចំនួន ២៧០០ ម៉ាយ ឬ ៤៣២០ គីឡូម៉ែត្រ។	This river originates in the mountains of Tibet and is 2,700 miles or 4320 kilometers long.
3.	ទន្លេមេគង្គហូរចូលមកក្នុងដែន ឥណ្ឌូចិន នៅប្រទេសលាវ ហើយចូល មកក្នុងដែនដីខ្មែរ នៅត្រង់កន្លែងទឹក ធ្លាក់ឈ្មោះខោន។	The Mekong flows into the territory of Indochina in Laos and enters Cambodian territory at the waterfall called Khone.
4.	ផ្លូវទឹក នេះមានប្រយោជន៍ច្រើន ណាស់ដល់ប្រទេសកម្ពុជានិងប្រទេស ឯទៀតនៅឥណ្ឌូចិន។	This waterway is of great use to Cambodia and the other countries of Indochina.
5.	ទីក្រុងខ្មែរធំៗខ្លះបានកើតឡើងនៅ តាមដងទន្លេនេះ ដូចជាក្រុងស្ទឹងត្រែង ក្រចេះ កំពង់ចាម និងភ្នំពេញជាដើម។	Several large Cambodian cities have been established along the shores of the river, for example, Stung Treng, Kratie, Kompong Cham and Phnom Penh.
6.	ក្រៅពីក្រុងទាំងនេះ មានស្រុក ច្រើនទៀតដែលមានប្រជាជនច្រើន ដែរ។	Besides all these cities, there are many other sroks (an administrative unit) which also have large populations.
7.	នៅស្រុកទាំងនោះ អ្នកស្រុកគេ ច្រើនធ្វើចំការផ្សេងៗ ដូចជាថ្នាំ ពោត សណ្តែក ហើយនិងបន្លែគ្រប់មុខ។	In all these sroks and villages, the country people for the most part cultivate various crops, such as tobacco, corn, beans, and all kinds of vegetables.

8.	អ្នកធ្វើដំណើរ តាមកប៉ាល់ ទៅកំពង់ចាមឬក្រចេះ គេនឹងឃើញ នូវចំការទាំងនេះសឹងតែមិនដាច់កន្ទុយ ភ្នែក។	Travellers by boat to Kompong Cham or Kratie can see all these plantations extending almost as far as the eye can see.
9.	នៅរដូវទឹកឡើង ទន្លេមេគង្គ ហើយនិងព្រែកទាំងប៉ុន្មាន ទឹកធំឡើង។	In the season of high water the Mekong and all the streams rise.
10.	ដោយសារទឹកព្រែកនោះ អ្នក ស្រុកនៅឆ្ងាយពីទន្លេធំ អាចទទួល ទឹកដោយបរិបូណ៌។	Because of the water in these streams, the peasants who live far from the large rivers can get plenty of water.
11.	កាលណាទឹកទន្លេហូរមកមាន ដីល្បាប់ជាប់មកជាមួយផង។	When the river water flows back, there is silt left behind.
12.	ដីល្បាប់នេះមានជីជាតិល្អ ណាស់។	This silt contains rich fertilizer.

DRILLS

Drill A. Substitution

1.	ទន្លេមេគង្គវែងជាងទន្លេឯទៀតទាំងអស់នៅអាស៊ី។	The Mekong is the longest river in Asia.
2.	ទន្លេមេគង្គធំជាងទន្លេឯទៀតទាំងអស់នៅអាស៊ី។	The Mekong is the largest river in Asia.
3.	ទន្លេមេគង្គធំជាងទន្លេឯទៀតទាំងអស់នៅអាស៊ីប៉ែកអាគ្នេយ៍។	The Mekong is the largest river in Southeast Asia.
4.	ទន្លេសាបធំជាងទន្លេឯទៀតទាំងអស់នៅអាស៊ីប៉ែកអាគ្នេយ៍។	Tonle Sap is the largest river in Southeast Asia.
5.	ទន្លេសាបធំជាងទន្លេឯទៀតទាំងអស់នៅប្រទេសកម្ពុជា។	Tonle Sap is the largest river in Cambodia.
6.	ទន្លេសាបមានត្រីច្រើនជាងទន្លេឯទៀតទាំងអស់នៅប្រទេសកម្ពុជា។	Tonle Sap is the river that has the most fish in Cambodia.
7.	ទន្លេសាបមានទឹកថ្លាជាងទន្លេឯទៀតទាំងអស់នៅប្រទេសកម្ពុជា។	Tonle Sap is the river that has the clearest water in Cambodia.
8.	ទន្លេបាសាក់មានទឹកថ្លាជាងទន្លេឯទៀតទាំងអស់នៅប្រទេសកម្ពុជា។	The Bassac is the river that has the clearest water in Cambodia.
9.	ទន្លេបាសាក់មានទឹករាក់ជាងទន្លេឯទៀតទាំងអស់នៅប្រទេសកម្ពុជា។	The Bassac is the river that has the most shallow water in Cambodia.
10.	ទន្លេបាសាក់មានទឹកជ្រៅជាងទន្លេឯទៀតទាំងអស់នៅប្រទេសកម្ពុជា។	The Bassac is the river that has the deepest water in Cambodia.

Drill B. Substitution

1.	នៅតាមមាត់ទន្លេគេឃើញមានភូមិនិងទីក្រុងដែរ។	Along the river bank you can see villages and cities too.
2.	នៅតាមផ្លូវជាតិលេខមួយគេឃើញមានភូមិ និងទីក្រុងដែរ។	Along National Route 1 you can see villages and cities too.
3.	នៅតាមផ្លូវជាតិលេខមួយគេឃើញមានផ្ទះអ្នកស្រុកច្រើន។	Along National Route 1 you can see many houses of peasants.
4.	នៅតាមផ្លូវជាតិលេខ១គេឃើញមានផ្សារនិងផ្ទះអ្នកស្រុកច្រើន។	Along National Route 1 you can see many markets and houses of peasants.

5.	នៅជិតផ្លូវជាតិលេខ១ គេឃើញមានផ្សារនិងផ្ទះអ្នកស្រុកច្រើន។	Near National Route 1 you can see many markets and houses of peasants.
6.	នៅជិតភ្នំពេញគេឃើញមានផ្សារនិងផ្ទះអ្នកស្រុកច្រើន។	Near Phnom Penh you can see many markets and houses of peasants.
7.	នៅជិតចំណតរទេះភ្លើងគេឃើញមានផ្សារនិងផ្ទះអ្នកស្រុកច្រើន។	Near the railroad station you can see many markets and houses of peasants.
8.	នៅជិតចំណតរទេះភ្លើងគេឃើញមានតាក់ស៊ីនិងស៊ីក្លូជាច្រើន។	Near the railroad station you can see there are many taxis and cyclos.
9.	នៅជិតចំណតរទេះភ្លើងគេឃើញមានអ្នកទេសចរជាច្រើន។	Near the railroad station you can see many tourists.
10.	នៅវាលយន្តហោះគេឃើញមានអ្នកទេសចរជាច្រើន។	At the airport you can see many tourists.

Drill C. Response

MODEL:	គ្រូ៖ ខេត្តខ្មែរណាខ្លះដែលមានទីក្រុងនៅជាប់ទន្លេមេគង្គ? (ស្ទឹងត្រែង ក្រចេះ កំពង់ចាម និង កណ្ដាល)	Teacher:	Which are the Cambodian Provinces which have cities on the Mekong? (Stung Treng, Kratie, Kompong Cham, and Kandal)
	សិស្ស៖ បាទ ខេត្ត ស្ទឹងត្រែង ក្រចេះ កំពង់ចាម និងកណ្ដាល មានទីក្រុងនៅជាប់ទន្លេមេគង្គ។	Student:	The provinces of Stung Treng, Kratie, Kompong Cham and Kandal have cities on the Mekong.

1.	ខេត្តខ្មែរណាដែលមានព្រំដែនជាប់និងប្រទេសថៃ? (ពោធិ៍សាត់ បាត់ដំបង ឧត្តរមានជ័យ និងព្រះវិហារ)	បាទ ខេត្តពោធិ៍សាត់ បាត់ដំបង ឧត្តរមានជ័យ និងព្រះវិហារ មានព្រំដែនជាប់និងប្រទេសថៃ។
2.	ខេត្តខ្មែរណាខ្លះដែលមានព្រំដែនជាប់និងប្រទេសលាវ? (ព្រះវិហារ ស្ទឹងត្រែង និងរតនគិរី)	បាទ ខេត្ត ព្រះវិហារ ស្ទឹងត្រែង និងរតនគិរី។
3.	ប្រទេសណាខ្លះដែលនៅជាប់និងប្រទេសកម្ពុជា? (ថៃ លាវ និងយួន)	បាទ ប្រទេសថៃ លាវ និងយួន នៅជាប់និងប្រទេសកម្ពុជា។

4. មេរៀនណាខ្លះដែលមិនទាន់ពន្យល់? (ទី៣ និងទី៧)	បាទ មេរៀនទី៣ និងទី៧ គេមិនទាន់បានពន្យល់ទេ។
5. ប៉ុស្តិ៍ណាខ្លះដែលគេយកទៅប្រឡំ? (លោកសេន និងលោកនិត)	បាទ ប៉ុស្តិ៍លោកសេននិងលោកនិតគេយកទៅប្រឡំ។

Drill D. Response

MODEL: គ្រូ: លោកដឹងទេ ទីក្រុងខ្មែរធំៗឈ្មោះអីខ្លះ? (ភ្នំពេញ កំពង់ចាម និងបាត់ដំបង)

Teacher: Do you know what the large Cambodian cities are called? (Phnom Penh, Kompong Cham, Battambang)

សិស្ស: បាទ តាមខ្ញុំដឹង ភ្នំពេញ កំពង់ចាម និងបាត់ដំបង ជាទីក្រុងខ្មែរធំៗ។

Student: According to what I know, Phnom Penh, Kompong Cham and Battambang are the large Cambodian cities.

1. លោកដឹងទេ ទីក្រុងអាមេរិកាំងធំៗឈ្មោះអីខ្លះ? (ញូវយ៉ក ស៊ីកាហ្គោ សាន់ហ្វ្រាន់ស៊ីស្កូ និងវ៉ាស៊ីនតោន)	បាទ តាមខ្ញុំដឹង ញូវយ៉ក ស៊ីកាហ្គោ សាន់ហ្វ្រាន់ស៊ីស្កូ និងវ៉ាស៊ីនតោន ជាទីក្រុងអាមេរិកាំងធំៗ។
2. លោកដឹងទេ អ្នករដ្ឋការអាមេរិកាំងធំៗឈ្មោះអីខ្លះ? (លោកចាម លោកស្ម៊ិត និងលោកស្ដ)	បាទ តាមខ្ញុំដឹង លោកចាម លោកស្ម៊ិត និងលោកស្ដ ជាអ្នករដ្ឋការអាមេរិកាំងធំៗ។
3. លោកដឹងទេ យានជំនិះសំខាន់នៅភ្នំពេញមានអីខ្លះ? (កង់ ស៊ីក្លូ និងឡាន)	បាទ តាមខ្ញុំដឹង កង់ ស៊ីក្លូ និងឡាន ជាយានជំនិះសំខាន់នៅភ្នំពេញ។
4. លោកដឹងទេ អ្នកណាជាអ្នកអភិបាលនៃមហាវិទ្យាល័យនេះ? (លោកគោ)	បាទ តាមខ្ញុំដឹង លោកគោជាអ្នកអភិ-បាលនៃមហាវិទ្យាល័យនេះ។
5. លោកដឹងទេ ផ្ទះលក់ថ្នាំណាបើកត្រូវថ្ងៃនេះ? (បូកគោ)	បាទ តាមខ្ញុំដឹង ផ្ទះលក់ថ្នាំបូកគោបើកត្រូវថ្ងៃនេះ។

Drill E. Interrogative Transformation

MODEL: គ្រូ: តាមខ្ញុំដឹង ភ្នំពេញ កំពង់ចាម និងបាត់ដំបង ជាទីក្រុងខ្មែរធំៗ។

Teacher: As far as I know Phnom Penh, Kompong Cham and Battambang are the large Cambodian cities.

សិស្ស: លោកដឹងទេ ទីក្រុងខ្មែរធំៗឈ្មោះអីខ្លះ?

Student: Do you know what the large Cambodian cities are called?

1. តាមខ្ញុំដឹង ញូវយ៉ក ស៊ីកាហ្គោ និងវ៉ាស៊ីនតោន ជាទីក្រុងធំៗអាមេរិកាំង។	លោកដឹងទេ ទីក្រុងអាមេរិកាំងធំៗឈ្មោះអីខ្លះ?

2.	តាមខ្ញុំដឹងលោកសោម នឹងលោកសួង ជាអ្នករដ្ឋការធំៗ នៅខេត្តអាំង ។	លោកដឹងទេ អ្នករដ្ឋការធំៗ នៅខេត្តអាំងឈ្មោះអ្វីខ្លះ?
3.	តាមខ្ញុំដឹងស៊ីក្លូ នឹងឡាន ជាយានជំនិះសំខាន់នៅភ្នំពេញ ។	លោកដឹងទេ យានជំនិះនៅភ្នំពេញអ្វីខ្លះ?
4.	តាមខ្ញុំដឹងលោកតា ជាអ្នកអភិបាលនៃមហាវិទ្យាល័យនោះ ។	លោកដឹងទេ អ្នកអភិបាលនៃមហាវិទ្យាល័យនោះឈ្មោះអ្វី?
5.	តាមខ្ញុំដឹងផ្ទះលក់ថ្នាំពេទ្យគេបើកថ្ងៃនេះ ។	លោកដឹងទេ ផ្ទះលក់ថ្នាំបើកតែថ្ងៃណា?

Drill F. Transformation and Substitution

MODEL: គ្រូ: គេច្រើនធ្វើចំការបន្លែនៅតាមមាត់ទន្លេមេគង្គ ។ (ទន្លេសាប)

Teacher: For the most part, they plant vegetable plots along the Mekong. (Tonle Sap)

សិស្ស: គេឃើញមានចំការបន្លែនៅតាមមាត់ទន្លេសាប ។

Student: They see that there are many vegetable plots along the Tonle Sap.

1.	គេច្រើនជិះកប៉ាល់ទៅកំពង់ចាម ។ (ព្រៃវែង)	គេឃើញមានកប៉ាល់ច្រើនទៅព្រៃវែង ។
2.	គេច្រើនប្រើទូកនេសាទនៅទន្លេមេគង្គ ។ (ទន្លេសាប)	គេច្រើនឃើញមានទូកនេសាទនៅទន្លេសាប ។
3.	គេច្រើននៅភូមិតូចៗ តាមមាត់ទន្លេ ។ (ផ្លូវជាតិលេខ១)	គេឃើញមានភូមិតូចៗច្រើន តាមផ្លូវជាតិលេខ១ ។
4.	គេច្រើនទៅវត្តនិងសនៅជិតសាលារៀន ។ (ភូមិ)	គេឃើញមានវត្តច្រើន និងសនៅជិតភូមិ ។
5.	គេ ច្រើនអ្នកទេសចរជិះកប៉ាល់ហោះនៅភ្នំពេញ ។ (ឃុំវាំង)	គេឃើញអ្នកទេសចរច្រើនជិះកប៉ាល់ហោះនៅឃុំវាំង ។

Drill G. Expansion

1.	ទន្លេមេគង្គជាផ្លូវទឹក ។	The Mekong is a waterway.
2.	ទន្លេមេគង្គជាផ្លូវទឹកមួយ ។	The Mekong is one waterway.
3.	ទន្លេមេគង្គជាផ្លូវទឹកធំមួយ ។	The Mekong is one large waterway.
4.	ទន្លេមេគង្គជាផ្លូវទឹកធំមួយសំខាន់ ។	The Mekong is one large important waterway.
5.	ទន្លេមេគង្គជាផ្លូវទឹកធំមួយសំខាន់នៅអាស៊ី ។	The Mekong is one large important waterway in Asia.
6.	គេដឹងថាទន្លេមេគង្គជាផ្លូវទឹកធំមួយ	They know the Mekong is one large

	សំខាន់នៅអាស៊ី។	important waterway in Asia.

Drill H. Reduction

1.	គេដឹងថាទន្លេមេគង្គជាផ្លូវទឹកធំមួយសំខាន់នៅអាស៊ី។	They know the Mekong is one large important waterway in Asia.
2.	ទន្លេមេគង្គជាផ្លូវទឹកមួយធំ សំខាន់នៅអាស៊ី។	The Mekong is one large important waterway in Asia.
3.	ទន្លេមេគង្គជាផ្លូវទឹកធំមួយសំខាន់។	The Mekong is one large important waterway.
4.	ទន្លេមេគង្គជាផ្លូវទឹកធំមួយ។	The Mekong is one large waterway.
5.	ទន្លេមេគង្គជាផ្លូវទឹកមួយ។	The Mekong is one waterway.
6.	ទន្លេមេគង្គជាផ្លូវទឹក។	The Mekong is a waterway.

UNIT 72

BASIC MONOLOGUE

1.	ជីនេះជួយធ្វើឲ្យដំណាំដុះបានផលល្អណាស់។	This fertilizer helps the plants to grow (for) good harvests.
2.	អ្នកស្រុកដែលមានចំការនៅមិនឆ្ងាយពីទន្លេ គេមិនបាច់ទិញជីដាក់ដីចំការគេទេ។	Peasants who have fields not far from the river do not have to buy fertilizer to put on their fields.
3.	នៅពេលទឹកឡើងម្ដងៗនោះ ទឹកទន្លេនាំដីល្បាប់មកស្រោចលើដីចំការ ដូចជាគេដាក់ជីថ្មីដូច្នេះដែរ។	Every time the water rises, the water of the river takes the silt and spreads it on the fields just as if the people had spread new fertilizer.
4.	នៅក្រុងភ្នំពេញទន្លេមេគង្គបែកចេញជាបួនមុខ។	At Phnom Penh the Mekong divides into four branches (faces).
5.	ដូច្នេះហើយបានជាអ្នកស្រុកនាំគ្នាហៅថា ទន្លេបួនមុខ ឬ ចតុមុខ។	That is why the peasants call it the four-faced river or Catomuk.
6.	នៅភ្នំពេញទឹកទន្លេមេគង្គហូរចាក់ទៅសមុទ្រចិនខាងត្បូងតាមទន្លេបាសាក់ និងទន្លេមេគង្គ។	In Phnom Penh the water from the Mekong flows into the South China Sea through the Bassac and the Mekong.
7.	ទឹកទន្លេនេះមួយផ្នែកហូរចាក់ទៅទន្លេសាប។	A part of the water of this river flows (up) into the Tonle Sap.
8.	បឹងធំនេះមានប្រយោជន៍ច្រើនណាស់ដល់ប្រទេសកម្ពុជា។	This large lake has a great deal of importance for Cambodia.

9.	គឺជាជុំរុំត្រីដ៏សំខាន់បំផុតនៅ អាស៊ីប៉ែកអាគ្នេយ៍។	That is, it is the most important concentration of fish in Southeast Asia.
10.	រាល់ឆ្នាំត្រីជាច្រើនតោនបាន ត្រូវគេចាប់យកទៅធ្វើជាអាហារ។	Every year many tons of fish are caught and taken to be made into food.
11.	គេយកត្រីជាច្រើនទៅធ្វើជា ត្រីងៀត ត្រីឆ្អើរ នឹងប្រហុក។	They use many fish to make dried fish, smoked fish, and prohok (fish paste).
12.	គ្រឿងបរិភោគទាំងនេះអាច ទុកយូរបានមិនខូច។	All these foods can be kept for a long time without spoiling.
13.	គេយកត្រីទាំងនេះមួយផ្នែក ធំលក់ចេញទៅបរទេស ជាពិសេស ទៅប្រទេសជិតខាងនៅអាស៊ីប៉ែក អាគ្នេយ៍	They take a large quantity of this (processed fish) and sell it abroad, especially in the neighboring countries in Southeast Asia.
14.	នៅរដូវទឹកស្រកទឹកទន្លេ សាបហូរចេញពីបឹងនោះមក វិញ។	In the season of low water, the water of Tonle Sap flows out of the lake.
15.	ឱកាសនោះហើយដែលខ្មែរ រៀបចំធ្វើបុណ្យមួយហៅថាបុណ្យ អុំទូក ឬប្រណាំងទូក។	It is on that occasion that the Cambodians celebrate a festival called the Water Festival. (literally: row the boats)

DRILLS

Drill A. Response

MODEL:	គ្រូ អ្នកស្រែចំការគេនិយមប្រើជីឬទេ?	Teacher: Do the peasants like to use fertilizer or not?
	សិស្ស ឥឡូវគេនិយមប្រើជីណាស់ ព្រោះប្រទេសកម្ពុជាមានរោងចក្រធ្វើជីហើយ។	Student: Now they like to use fertilizer a lot because Cambodia has a fertilizer factory.
1.	អ្នកស្រែចំការគេនិយមប្រើស៊ីម៉ង់ឬទេ?	ឥឡូវគេនិយមប្រើស៊ីម៉ង់ណាស់ ព្រោះប្រទេសកម្ពុជាមានរោងចក្រធ្វើស៊ីម៉ង់ហើយ។
2.	អ្នកស្រែចំការគេនិយមប្រើក្ដារបន្ទះឬទេ?	ឥឡូវគេនិយមប្រើក្ដារបន្ទះណាស់ ព្រោះប្រទេសកម្ពុជាមានរោងចក្រធ្វើក្ដារបន្ទះហើយ។
3.	អ្នកមានឡានគេនិយមប្រើកង់ឡានម៉ាកអង្គរទេ?	ឥឡូវគេនិយមប្រើកង់ឡានម៉ាកអង្គរណាស់ ព្រោះប្រទេសកម្ពុជាមានរោងចក្រធ្វើកង់ឡានហើយ។
4.	ខ្មែរនិយមប្រើវិទ្យុ[illegible]ជប៉ុនទេ?	ឥឡូវគេនិយមប្រើវិទ្យុ[illegible]ជប៉ុនណាស់ ព្រោះប្រទេសកម្ពុជាមានរោងចក្រធ្វើវិទ្យុ[illegible]ជប៉ុនហើយ។
5.	នៅស្រុកខ្មែរគេនិយមប្រើកញ្ចប់ប្លាស្ទិចទេ?	ឥឡូវគេនិយមប្រើកញ្ចប់ប្លាស្ទិចណាស់ ព្រោះប្រទេសកម្ពុជាមានរោងចក្រធ្វើកញ្ចប់ប្លាស្ទិចហើយ។

Drill B. Response

MODEL:	គ្រូ គេធ្វើបុណ្យអុំទូកនៅពេលណា? (ពេលទឹកស្រក)	Teacher: At what time do they celebrate the Water Festival? (when the water goes down)
	សិស្ស: គេធ្វើបុណ្យអុំទូកនៅពេលទឹកស្រក។	Student: They celebrate the Water Festival when the water goes down.
1.	គេធ្វើបុណ្យចូលឆ្នាំខ្មែរនៅខែណា? (ខែមេសា)	គេធ្វើបុណ្យចូលឆ្នាំខ្មែរនៅខែមេសា។
2.	គេធ្វើស្រែប្រាំងនៅរដូវណា? (រដូវក្ដៅ)	គេធ្វើស្រែប្រាំងនៅរដូវក្ដៅ។

3. គេធ្វើចំការ[illegible]នៅពេលណា? (ពេលក្រោយទឹកស្រក)	គេធ្វើចំការ[illegible]នៅពេលក្រោយទឹកស្រក។
4. តាម[illegible]ធ្វើ[illegible]នេះហើយ[illegible] ប៉ុន្មាន? ([illegible]រសៀល)	តាម[illegible]ធ្វើ[illegible]នេះហើយ[illegible] [illegible]រសៀល។
5. កាល[illegible]នេះនៅខែណា? (ខែ ២០ ខ្មែរ)	កាល[illegible]នេះនៅខែ ២០ ខ្មែរ។

Drill C. Substitution

1. នៅពេលទឹក[illegible] គេនាំគ្នាទៅអុំទូកលេង។	At the time the water rises they race boats for fun.
2. នៅពេលទឹក[illegible] គេនាំគ្នាទៅជិះទូកលេង។	At the time the water rises they ride boats for fun.
3. នៅពេលទឹក[illegible] គេនាំគ្នាទៅស្ទូចត្រីលេង។	At the time the water rises they fish for fun.
4. នៅពេលទឹក[illegible] គេនាំគ្នាទៅហែលទឹកលេង។	At the time the water rises they swim for fun.
5. នៅពេលទឹក[illegible] គេនាំគ្នាទៅងូតទឹកលេង។	At the time the water rises they bathe for fun.
6. នៅពេលទឹក[illegible] គេនាំគ្នាទៅជិះកប៉ាល់លេង។	At the time the water rises they ride boats for fun.

Drill D. Substitution

1. ត្រីជាអាហារសំខាន់មួយនៃប្រជាជនខ្មែរ។	Fish is an important food of the Cambodian people.
2. ត្រីជាអាហារសំខាន់មួយនៃប្រជាជននៅអាស៊ី។	Fish is an important food in Asia.
3. សាច់ជ្រូកជាអាហារសំខាន់មួយនៃប្រជាជននៅអាស៊ី។	Pork is an important food in Asia.
4. សាច់គោជាអាហារសំខាន់មួយនៃប្រជាជននៅអាស៊ី។	Beef is an important food in Asia.
5. សាច់ចៀមជាអាហារសំខាន់មួយនៃប្រជាជននៅអាស៊ី។	Mutton is an important food in Asia.
6. សាច់ចៀមជាអាហារសំខាន់មួយនៃប្រជាជននៅសហរដ្ឋអាមេរិក។	Mutton is an important food in America.

7. មាន់ជាអាហារសំខាន់មួយនៃប្រជាជន នៅសហរដ្ឋអាមេរិក។	Chicken is an important food in America.
8. មាន់ជាអាហារសំខាន់មួយនៃប្រជាជន នៅស្រុកខ្មែរ។	Chicken is an important food in Cambodia.

Drill E. Substitution

1. បឹងទន្លេសាបធំហើយមានត្រី ច្រើនផង។	The Tonle Sap is large and has a lot of fish too.
2. ផ្លូវទៅញូវយ៉កធំហើយមានផ្ទះសំណាក់ ច្រើនផង។	The road to New York is large and has a lot of places to stay too.
3. សាលារៀនខ្ញុំធំហើយមានកូនសិស្ស ច្រើនផង។	My school is large and has a lot of students too.
4. ភ្នំពេញជាទីក្រុងធំហើយមាន កន្លែងដើរលេងច្រើនផង។	Phnom Penh is a city and has a lot of places for amusement too.
5. តូក្យូជាទីក្រុងធំហើយមាន មនុស្សច្រើនផង។	Tokyo is a city and has a lot of people too.
6. នេះជាភ្លៀងធំហើយមានធ្លាក់ព្រឹល ច្រើនផង។	This is rain and there is a lot of hail falling too.
7. ទន្លេមេគង្គជាទន្លេធំហើយមានកប៉ាល់ ចុះឡើងច្រើនផង។	The Mekong is a river and has a lot of boats going back and forth too.
8. ពោធិចិនតុងជាវាលយន្តហោះធំ ហើយមានយន្តហោះចុះច្រើនផង។	Pochentong is a big airfield and has a lot of planes coming in too.

Drill F. Substitution

1. ត្រីមួយចំណែកគេទុកបរិភោគ សល់ពីនេះគេលក់ដោយនាំចេញទៅបរទេស។	One part of the fish they keep for food; what's left over they sell by exporting it abroad.
2. សាច់ជ្រូកមួយចំណែកគេទុកបរិភោគសល់ ពីនេះគេឲ្យអ្នកជិតខាង។	One part of the pork they keep for food; what's left over they give to their neighbors.
3. អង្ករមួយចំណែកគេទុកបរិភោគសល់ពីនេះ គេឲ្យប្រទេសក្រៅ។	One part of the rice they keep for food; what's left over they give to foreign countries.
4. សណ្ដែកដីមួយចំណែកគេទុកបរិភោគសល់ ពីនេះគេឲ្យរោងចក្រធ្វើប្រេង។	One part of the peanuts they keep for food; what's left over they give to oil factories.
5. ពោតមួយចំណែកគេទុកបរិភោគសល់ពីនេះ	One part of the corn they keep for

	គេឲ្យស្រុកបារាំងនិងជប៉ុន។	food; what's left over they give to France and Japan.
6.	សាច់គោ១ចំណែកគេទុកបរិភោគសល់ពីនេះគេឲ្យប្រទេសជិតខាង។	One part of the beef they keep for food; what's left over they give to neighboring countries.
7.	ទឹកត្រី១ចំណែកគេទុកបរិភោគសល់ពីនេះគេលក់ចេញទៅស្រុកជិតខាង។	One part of the fish sauce they keep for food; what's left over they sell to neighboring countries.
8.	ដើមអំពៅ១ចំណែកគេទុកបរិភោគសល់ពីនេះគេលក់ឲ្យរោងចក្រស្ករ។	One part of the sugar cane they keep for food; what's left over they sell to sugar factories.

Drill G. Expansion

1.	នៅពេលទឹកឡើង។	In the flood season
2.	នៅពេលទឹកឡើងម្ដងៗ។	Every flood season
3.	នៅពេលទឹកឡើងម្ដងៗទឹកទន្លេមេគង្គនាំដី។	Every flood season the Mekong brings silt.
4.	នៅពេលទឹកឡើងម្ដងៗទឹកទន្លេមេគង្គនាំដីជាច្រើន។	Every flood season the Mekong brings a lot of silt.
5.	នៅពេលទឹកឡើងម្ដងៗទឹកទន្លេមេគង្គនាំដីជាច្រើនទៅដាក់ចំការ។	Every flood season the Mekong brings a lot of silt to deposit on the fields.
6.	នៅពេលទឹកឡើងម្ដងៗទឹកទន្លេមេគង្គនាំដីជាច្រើនទៅដាក់ចំការទាំងឡាយ។	Every flood season the Mekong brings a lot of silt to deposit on all the fields.
7.	នៅពេលទឹកឡើងម្ដងៗទឹកទន្លេមេគង្គនាំដីជាច្រើនទៅដាក់ចំការទាំងឡាយដែលត្រូវទឹកលិច។	Every flood season the Mekong brings a lot of silt to deposit on all the fields that are flooded.

Drill H. Reduction

1.	នៅពេលទឹកឡើងម្ដងៗទឹកទន្លេមេគង្គនាំដីជាច្រើនទៅដាក់ចំការទាំងឡាយដែលត្រូវទឹកលិច។	Every flood season the Mekong brings a lot of silt to deposit on all the fields that are flooded.
2.	នៅពេលទឹកឡើងម្ដងៗទឹកទន្លេមេគង្គនាំដីជាច្រើនទៅដាក់ចំការទាំងឡាយ។	Every flood season the Mekong brings a lot of silt to deposit on all the fields.
3.	នៅពេលទឹកឡើងម្ដងៗទឹកទន្លេមេគង្គនាំដីជាច្រើនទៅដាក់ចំការ។	Every flood season the Mekong brings a lot of silt to deposit on the fields.
4.	នៅពេលទឹកឡើងម្ដងៗទឹកទន្លេមេគង្គនាំដីជាច្រើន។	Every flood season the Mekong brings a lot of silt.

5.	នៅពេលទឹកឡើងម្ដងៗ ទឹកទន្លេមេគង្គនាំល្បប់។	Every flood season the Mekong brings silt.
6.	នៅពេលទឹកឡើងម្ដងៗ។	Every flood season
7.	នៅពេលទឹកឡើង។	In the flood season

Drill I. Negative Response

MODEL:	គ្រូ: ត្រីដែលគេចាប់បានទាំងប៉ុន្មាន គេលក់ចេញទៅបរទេសទាំងអស់?	Teacher:	They sell as much fish as they catch abroad.
	សិស្ស: ត្រីដែលចាប់បានទាំងប៉ុន្មាន គេមិនលក់ចេញទៅបរទេសទាំងអស់ទេ គេទុកលក់ក្នុងប្រទេសខ្លះ។	Student:	They don't export as much fish as they catch abroad; they keep some to sell inside the country.

1.	ដើមឈើដែលគេកាប់បានទាំងប៉ុន្មាន គេលក់ចេញទៅបរទេសទាំងអស់?	ដើមឈើដែលកាប់បានទាំងប៉ុន្មាន គេមិនលក់ចេញទៅបរទេសទាំងអស់ទេ គេទុកលក់ក្នុងប្រទេសខ្លះ។
2.	មាន់ដែលគេចិញ្ចឹមបានទាំងប៉ុន្មាន គេលក់ចេញទៅបរទេសទាំងអស់?	មាន់ដែលចិញ្ចឹមបានទាំងប៉ុន្មាន គេមិនលក់ចេញទៅបរទេសទាំងអស់ទេ គេទុកលក់ក្នុងប្រទេសខ្លះ។
3.	ពោតដែលគេកាច់បានទាំងប៉ុន្មាន គេលក់ចេញទៅបរទេសទាំងអស់?	ពោតដែលកាច់បានទាំងប៉ុន្មាន គេមិនលក់ចេញទៅបរទេសទាំងអស់ទេ គេទុកលក់ក្នុងប្រទេសខ្លះ។
4.	ម្លូដែលគេបេះបានទាំងប៉ុន្មាន គេលក់ចេញទៅបរទេសទាំងអស់?	ម្លូដែលបេះបានទាំងប៉ុន្មាន គេមិនលក់ចេញទៅបរទេសទាំងអស់ទេ គេទុកលក់ក្នុងប្រទេសខ្លះ។
5.	របស់ដែលគេធ្វើបានទាំងប៉ុន្មាន គេលក់ចេញទៅបរទេសទាំងអស់?	របស់ដែលធ្វើបានទាំងប៉ុន្មាន គេមិនលក់ចេញទៅបរទេសទាំងអស់ទេ គេទុកលក់ក្នុងប្រទេសខ្លះ។

Drill J. Response

MODEL:	គ្រូ: នៅអាស៊ីគេច្រើនបរិភោគសាច់គោមែនទេ? (គេច្រើនញ៉ាំត្រីជាង)	Teacher:	In Asia, for the most part they eat beef don't they? (they normally eat fish more)
	សិស្ស: បាទ គេបរិភោគសាច់គោដែរ តែគេច្រើនញ៉ាំត្រីជាង។	Student:	They do eat some beef, but they normally eat fish more.
1.	នៅភ្នំពេញគេច្រើនញ៉ាំនំសួងចៀនមែនទេ? (គេច្រើនញ៉ាំបាយជាង)		បាទ គេញ៉ាំនំសួងចៀន តែគេច្រើនញ៉ាំបាយជាង។
2.	នៅខែត្រកណ្តាលគេច្រើនដាំសណ្តែកមែនទេ? (គេច្រើនលកទឹកកកជាង)		បាទ គេដាំសណ្តែកដែរ តែគេច្រើនលក់ទឹកកកជាង។
3.	នៅមុខវាំងគេច្រើនលក់សណ្តែកដីមែនទេ? (គេច្រើនលក់ពោតជាង)		បាទ គេលក់សណ្តែកដីដែរ តែគេច្រើនលក់ពោតជាង។
4.	នៅស្រុកនេះគេច្រើនធ្វើស្រូវប្រាំងមែនទេ? (គេច្រើនធ្វើស្រូវវស្សាជាង)		បាទ គេធ្វើស្រូវប្រាំងដែរ តែគេច្រើនធ្វើស្រូវវស្សាជាង។
5.	នៅទន្លេសាបគេច្រើនធ្វើត្រីឆ្អើរមែនទេ? (គេច្រើនធ្វើត្រីងៀតជាង)		បាទ គេធ្វើត្រីឆ្អើរដែរ តែគេច្រើនធ្វើត្រីងៀតជាង។

UNIT 73

BASIC DIALOGUE

Sok

1. ជំរាបសួរលោកពូ សុខសប្បាយជាទេ?

Hello. How are you?

Pon

2. បាទ ខ្ញុំសុខសប្បាយជាទេ។ ចុះលោក កូនចៅអីសុខសប្បាយជាទេ? ម៉េចក៏មិនយកមកលេងផង។

I'm fine, and you? Are your children well? How come you didn't bring them along to visit too?

Sok

3. បាទ គេសុខសប្បាយទាំងអស់គ្នាទេ តែខ្ញុំមិនឲ្យមកជាមួយទេព្រោះខ្ញុំត្រូវរៀបចំមកប្រញាប់ប្រញាល់ពេក។

They're all well, but I didn't let them come along because I had to get ready very quickly.

Pon

4. លោកអញ្ជើញមកមានការអីឬ?

Did you come on business?

Sok

5. បាទទេ គ្មានការអីសំខាន់ណាស់ណាទេ។ ខ្ញុំទៅមើលសាលារៀនថ្មីនៅភូមិត្របែក ហើយខ្ញុំឆ្លៀតមកលេងលោកពូតែម្ដងទៅ។

No I don't have any very important business. I was going to see the new school in Phum Trabek and I just came to visit you.

Pon

6. ម៉េចទៅសាលារៀន? ខ្ញុំមិនទាន់បានទៅឃើញទេ តែឮគេថាល្អណាស់។

How is the school? I haven't had a chance to go see it, but I hear that it's very pretty.

Sok

7. បាទ ល្អណាស់។ តែឥឡូវគេមិនទាន់ធ្វើហើយអស់ផង។ បើការធ្វើហើយអស់មុខជាស្អាតជាងនេះទៅទៀត។

Yes, it's very nice. At present they still haven't finished building it completely.

		Pon	
8.	អាទិត្យក្រោយខ្ញុំនឹងទៅមើល មិនខាន។		Next week I'll go look at it, without fail.
		Sok	
9.	លោកពូរវល់ណាស់ឬឥឡូវ?		Are you very busy now?
		Pon	
10.	បាទ ឥឡូវនេះកំពុងតែចំពេល ប្រញឹកហើយ។ ភ្លៀងប៉ុន្មានអាទិត្យ មុននេះធ្វើឲ្យមានទឹកបរិបូណ៌ណាស់។		Yes, now I'm in my busy time. The rain a few weeks ago has given us plenty of water.
		Sok	
11.	បាទ អញ្ចឹងហើយ ព្រឹកមិញ ខ្ញុំឃើញគេភ្ជួររាស់ ពាសពេញ ស្ទើងតែគ្រប់កន្លែង។		This morning I saw them plowing and harrowing almost everywhere.
		Pon	
12.	ខ្ញុំភ្ជួររួចមកប៉ុន្មានថ្ងៃហើយ ឥឡូវ បានភ្លៀងមកនេះ គឺល្មម រាស់សាបតែម្ដង។		I finished plowing a few days ago. Now since there is enough rain, (I can) harrow and sow at the same time.
		Sok	
13.	លោកពូនឹងសាបស្រូវអី?		What kind of rice will you sow?
		Pon	
14.	បាទ ខ្ញុំសាបស្រូវខ្សាយ។		I'll sow ordinary rice.

DRILLS

Drill A. Substitution

1.	ខ្ញុំប្រញាប់ប្រញាល់មកពេកបាន ជាមិនបានយកកូនមកលេង។	I was in too much of a hurry to take the children to visit.
2.	ខ្ញុំប្រញាប់ប្រញាល់មកពេកបានជាមិន យកសៀវភៅមកជូន។	I was in too much of a hurry to take the book to you.
3.	ខ្ញុំប្រញាប់ប្រញាល់មកពេកបានជា មិនបានយកខោអាវទៅបោក។	I was in too much of a hurry to take the clothes to be laundered.
4.	ខ្ញុំប្រញាប់ប្រញាល់មកពេកបានជា មិនបានយកអីវ៉ាន់មកជូន។	I was in too much of a hurry to take the things to you.
5.	ខ្ញុំប្រញាប់ប្រញាល់មកពេកបានជា មិនបានយកឡានទៅលាង។	I was in too much of a hurry to take the car to be washed.
6.	ខ្ញុំប្រញាប់ប្រញាល់មកពេកបានជា មិនបានយកកង់ទៅជូត។	I was in too much of a hurry to take the bicycle to be washed.
7.	ខ្ញុំប្រញាប់ប្រញាល់ពេក បានជាមិន បានយកសំបុត្រទៅដាក់ប៉ុស្តិ៍។	I was in too much of a hurry to take the letter to mail.
8.	ខ្ញុំប្រញាប់ប្រញាល់មកពេកបានជា មិនបានយកសំរាមទៅចោល។	I was in too much of a hurry to take the garbage to throw out.

Drill B. Substitution

1.	គាត់អញ្ជើញទៅមើលស្រុកនោះ ប្រហែល១អាទិត្យ ហើយហួសមក សាលារៀននេះ។	He went to see that place for about a week, and then he came on over to this school.
2.	គាត់អញ្ជើញទៅមើលស្រុកនោះប្រហែល ១អាទិត្យ ហើយហួសមកកន្លែងនេះ។	He went to see that place for about a week, and then he came on over to this place.
3.	គាត់អញ្ជើញទៅមើលស្រុកនោះប្រហែល១ អាទិត្យ ហើយហួសមកភូមិនេះ។	He went to see that place for about a week, and then he came on over to this village.
4.	គាត់អញ្ជើញទៅមើលស្រុកនោះប្រហែល១ អាទិត្យ ហើយហួសមកលេងមើលលោក។	He went to see that place for about a week, and then he came on over to visit you.
5.	គាត់អញ្ជើញទៅមើលស្រុកនោះប្រហែល ១អាទិត្យ ហើយហួសមកជួបនឹងលោក។	He went to see that place for about a week, and then he came on over to meet you.
6.	គាត់អញ្ជើញទៅមើលស្រុកនោះប្រហែល	He went to see that place for about

	១អាទិត្យ ហើយហួសមកសួរលោក។	a week, and then he came on over to question you.
7.	គាត់អញ្ជើញទៅមើលស្រុកនោះប្រហែល១ អាទិត្យ ហើយហួសមកមើលក្រុងឯនេះ។	He went to see that place for about a week, and then he came on over to see this city.
8.	គាត់អញ្ជើញទៅមើលស្រុកនោះប្រហែល ១អាទិត្យ ហើយហួសមកសម្រាកនៅនេះ។	He went to see that place for about a week, and then he came on over to rest here.

Drill C. Variable Substitution

1.	ខ្ញុំឮគេថាទីក្រុងនោះស្អាតណាស់តែខ្ញុំ មិនទាន់បានទៅឃើញទេ។	I hear that that city is very pretty, but I haven't gone to see it yet.
2.	ខ្ញុំឮគេថាកន្លែងនោះស្អាតណាស់តែខ្ញុំមិន ទាន់បានទៅឃើញទេ។	I hear that that place is very pretty, but I haven't gone to see it yet.
3.	ខ្ញុំឮគេថាកន្លែងនោះសប្បាយណាស់តែ ខ្ញុំមិនទាន់បានទៅឃើញទេ។	I hear that that place is very nice, but I haven't gone to see it yet.
4.	ខ្ញុំឮគេថាកន្លែងនោះសប្បាយណាស់តែ ខ្ញុំមិនទាន់បានទៅលេងទេ។	I hear that that place is very nice, but I haven't gone to visit it yet.
5.	ខ្ញុំឮគេថាកន្លែងនោះសប្បាយណាស់តែ ខ្ញុំមិនទាន់បានទៅដល់ទេ។	I hear that that place is very nice, but I haven't arrived (there) yet.
6.	ខ្ញុំឮគេថាឆ្នេរសមុទ្រនោះសប្បាយ ណាស់តែខ្ញុំមិនទាន់បានទៅដល់ទេ។	I hear that that seashore is very nice, but I haven't arrived (there) yet.
7.	ខ្ញុំឮគេថាឆ្នេរសមុទ្រនោះមានមនុស្ស ច្រើនណាស់តែខ្ញុំមិនទាន់បានទៅដល់ទេ។	I hear that that seashore has a lot of people, but I haven't arrived (there) yet.
8.	ខ្ញុំឮគេថាឆ្នេរសមុទ្រនោះមានខ្សាច់ល្អ ណាស់តែខ្ញុំមិនទាន់បានទៅដល់ទេ។	I hear that that seashore has very nice sand, but I haven't arrived (there) yet.

Drill D. Double Substitution

1.	ទំរាំតែគាត់ទៅដល់ គេនាំគ្នាចេញ ទៅអស់ហើយ។	Just as soon as he arrived, they all left.
2.	ទំរាំតែគាត់ធ្វើហើយ គេនាំគ្នាចេញ ពីសាលារៀនអស់ហើយ។	Just as soon as he finished they all left the school.
3.	ទំរាំតែគាត់បានមើល គេនាំគ្នាបិទ ទ្វារបន្ទប់អស់ហើយ។	Just as soon as he looked they all closed the door of the room.
4.	ទំរាំតែគាត់បានជួប គេនាំគ្នារៀបចំ ធ្វើដំណើរទៅមុខអស់ហើយ។	Just as soon as he met (them) they all prepared to continue the trip.

5. ទំរាំតែគាត់ដឹង គេនាំគ្នាទៅឆ្ងាយអស់ហើយ។

Just as soon as he knew, they all went away.

6. ទំរាំតែគាត់បានឮ គេនាំគ្នារត់បាត់អស់ហើយ។

Just as soon as he heard, they all ran away.

7. ទំរាំតែគាត់បានឃើញ គេនាំគ្នាឡើងឡានជិតអស់ហើយ។

Just as soon as he saw (them), they almost all got in the car.

8. ទំរាំតែគាត់បានមកដល់ គេនាំគ្នាឈប់ធ្វើការអស់ហើយ។

Just as soon as he arrived, they all stopped work.

Drill E. Triple Substitution

1. ឥឡូវគេមានភ្លៀងបរិបូណ៌ហើយៗ គេអាចចាប់ភ្ជួរបាន។

Now they have abundant rain, and they can begin to plow.

2. ថ្ងៃនេះគេមានទឹកកកបរិបូណ៌ហើយៗ គេអាចទៅរអិលស្គីបាន។

Today they have abundant snow, and they can go skiing.

3. ឆ្នាំនេះគេមានស្រូវបរិបូណ៌ហើយៗគេអាចលក់ចេញទៅបរទេសបាន។

This year they have abundant rice, and they can export it abroad.

4. ខែនេះគេមានទឹកភ្លៀងបរិបូណ៌ហើយៗ គេអាចសាបបាន។

This month they have abundant rain, and they can sow.

5. ឥឡូវគេមានលុយបរិបូណ៌ហើយៗគេអាចទិញឡានបាន។

Now they have abundant money, and they can buy cars.

6. អាទិត្យក្រោយគេមានចំនួនពាក្យបរិបូណ៌ ហើយគេអាចនិយាយខ្មែរខ្លះបាន។

Next week they will have an abundant number of words, and will be able to speak some Cambodian.

Drill F. Response

MODEL: គ្រូៈ ខែនេះគេច្រើនតែរវល់ធ្វើអី? (ទឹកភ្លៀង ស្ទូង)

Teacher: This month what are they mostly busy doing? (rain, plant)

សិស្សៈ ខែនេះមានទឹកភ្លៀងច្រើនគួរសម គេច្រើនតែរវល់ស្ទូង។

Student: This month there's rather a lot of rain; they're mostly busy planting.

1. ថ្ងៃនេះគេច្រើនតែរវល់ធ្វើអី? (ទឹកភ្លៀងខ្លាំង [illegible])

ថ្ងៃនេះមានទឹកភ្លៀងខ្លាំង គេច្រើនតែរវល់ [illegible]។

2. ឆ្នាំនេះគេរវល់ធ្វើអី? (កូនសិស្សច្រើន រកគ្រូបង្រៀន)

ឆ្នាំនេះមានកូនសិស្សច្រើន គេច្រើនតែរវល់រកគ្រូបង្រៀន។

3.	និស្សិតគេច្រើនតែរវល់ធ្វើអ្វី? (ការប្រឡងឯកច្រើន រៀន)	និស្សិតនេះមានការប្រឡងឯកច្រើន គេច្រើនតែរវល់រៀន។
4.	ខែវស្សានេះគាត់រវល់ធ្វើអ្វី? (ភ្លៀងច្រើនណាស់ ដកស្ទូង)	ខែនេះមានភ្លៀងច្រើនណាស់ គាត់ច្រើនតែរវល់ដកស្ទូងភ្ជួរ។
5.	ពេលក្រោយគាត់ច្រើនតែរវល់ធ្វើអ្វី? (កូនសិស្សរៀនគាត់, ពន្យល់គេ)	ពេលក្រោយមានកូនសិស្សមករៀនគាត់ គាត់ច្រើនតែរវល់ពន្យល់គេ។

Drill G. Extension

MODEL: គ្រូ: រដូវនេះគាត់ច្រើនតែមិននៅផ្ទះទេ។ (នេសាទ នៅទន្លេធំ)

សិស្ស: គាត់ទៅនេសាទនៅទន្លេធំ។

Teacher: This season mostly he is not at home. (fishing in Tonle Thom)

Student: He has gone fishing at Tonle Thom.

1.	ពេលនេះគាត់ច្រើនតែមិននៅកន្លែងធ្វើការទេ។ (រៀនអង់គ្លេស)	គាត់ទៅរៀនអង់គ្លេស។
2.	ថ្ងៃសៅរ៍គាត់ច្រើនតែមិននៅផ្ទះទេ។ (ធ្វើការ ហើយ ទៅបណ្ណាល័យ)	គាត់ទៅធ្វើការ ហើយទៅបណ្ណាល័យ។
3.	ថ្ងៃអាទិត្យគាត់ច្រើនមិននៅផ្ទះទេ។ (ស្ទូចត្រីនៅស្ទឹងសង្កែ)	គាត់ទៅស្ទូចត្រីនៅស្ទឹងសង្កែ។
4.	ខែនេះគេច្រើនតែមិនទៅលេងឆ្ងាយទេ។ (ឆ្ងាយមិនបាន ព្រោះភ្លៀងខ្លាំងណាស់)	គេទៅលេងឆ្ងាយមិនបាន ព្រោះភ្លៀងខ្លាំងណាស់។
5.	ពេលនេះគេច្រើនតែមិនគង់ចាប់ផ្ដើមការងារទេ។ (ញ៉ាំចាយថ្ងៃបុណ្យ)	គេទៅញ៉ាំចាយថ្ងៃបុណ្យ។

Drill H. Expansion

1.	គេចាប់ភ្ជួររាស់។	They begin to plow and harrow.
2.	កាលណាមានភ្លៀងគេចាប់ភ្ជួររាស់។	Whenever there is rain they begin to plow and harrow.
3.	កាលណាមានភ្លៀងគ្រប់គ្រាន់គេចាប់ភ្ជួររាស់។	Whenever there is sufficient rain they begin to plow and harrow.
4.	កាលណាមានភ្លៀងគ្រប់គ្រាន់គេចាប់ភ្ជួររាស់ហើយនិងដាំ។	Whenever there is sufficient rain they begin to plow, harrow, and plant.
5.	កាលណាមានភ្លៀងគ្រប់គ្រាន់គេចាប់ភ្ជួររាស់ហើយនិងដាំស្រូវ។	Whenever there is sufficient rain they begin to plow, harrow, and plant rice.
6.	កាលណាមានភ្លៀងគ្រប់គ្រាន់គេចាប់ភ្ជួររាស់ហើយនិងដាំស្រូវដែលគេបានបណ្ដុះ។	Whenever there is sufficient rain they begin to plow, harrow, and plant rice which they have grown.

7.	កាលណាមានភ្លៀងគ្រប់គ្រាន់គេចាប់ភ្ជួររាស់ ហើយគេសាបស្រូវដែលគេបណ្ដុះពីមុននោះ។	Whenever there is sufficient rain they begin to plow, harrow, and plant rice which they have grown previously.

Drill I. Reduction

1.	កាលណាមានភ្លៀងគ្រប់គ្រាន់គេចាប់ភ្ជួររាស់ហើយគេសាបស្រូវដែលគេបណ្ដុះពីមុននោះ។	Whenever there is sufficient rain they begin to plow, harrow, and plant rice which they have grown previously.
2.	កាលណាមានភ្លៀងគ្រប់គ្រាន់គេចាប់ភ្ជួររាស់ហើយគេសាបស្រូវដែលគេបណ្ដុះ។	Whenever there is sufficient rain they begin to plow, harrow, and plant rice which they have grown.
3.	កាលណាមានភ្លៀងគ្រប់គ្រាន់គេចាប់ភ្ជួររាស់ហើយគេសាបស្រូវ។	Whenever there is sufficient rain they begin to plow, harrow, and plant rice.
4.	កាលណាមានភ្លៀងគ្រប់គ្រាន់គេចាប់ភ្ជួររាស់ហើយគេសាប។	Whenever there is sufficient rain they begin to plow, harrow, and plant.
5.	កាលណាមានភ្លៀងគ្រប់គ្រាន់គេចាប់ភ្ជួររាស់។	Whenever there is sufficient rain they begin to plow and harrow.
6.	កាលណាមានភ្លៀងគេចាប់ភ្ជួររាស់។	Whenever there is rain they begin to plow and harrow.
7.	គេចាប់ភ្ជួររាស់។	They begin to plow and harrow.

UNIT 74

BASIC DIALOGUE

Sok

1. លោកពូត្រាំពូជប៉ុន្មានថ្ងៃហើយ?
How many days ago did you soak the seeds?

Pon

2. ខ្ញុំទើបនឹងត្រាំពីម្សិលមិញ។
I just soaked them yesterday.

Sok

3. ប៉ុន្មានថ្ងៃទៅអញ្ចឹងបានល្មមយកទៅសាប?
How many days until they are ready to be sown?

Pon

4. អូ ធម្មតាបីបួនថ្ងៃ។ តាមខ្ញុំមើលទៅថ្ងៃស្អែកឬខានថ្ងៃស្អែកហ្នឹង ពូជនេះដុះល្មមយកទៅសាបបាន។
Oh, usually three or four days. As I figure it tomorrow or the day after tomorrow.

Sok

5. ពូ យកទៅសាបឯណាទៅ?
Where are you going to sow?

Pon

6. បាទ នៅស្រែពីរ ខាងត្បូងផ្ទះ។
In the two fields south of the house.

Sok

7. ឃើ ម៉េចក៏សាបតែស្រែពីរអញ្ចឹង?
How come you're sowing only two fields?

Pon

8. បាទ តាមខ្ញុំស្មានមើលទៅសំណាបពីរស្រែហ្នឹង ល្មមសម្រាប់យកទៅស្ទូងឯត្រពាំងចក។
I think maybe sowing two fields will be sufficient to make a transplant in Trapeang Chak.

Sok

9. ត្រពាំងចកធំណាស់អញ្ចឹង។
Then Trapeang Chak is very big?

Pon

10. បាទ ធំគួរសមដែរ បើមានគ្នាបួននាក់ត្រូវស្ទូងប្រហែលជាប្រាំថ្ងៃបានហើយ។
Big enough. If four people together had to transplant it, it would take about five days.

Sok

11. ធម្មតាត្រពាំងមានទឹកជាប់ជានិច្ច
Does the pond usually have water?

		មែនទេ?	
	Pon		
12.		បាទ អញ្ចឹងហើយ តែត្រពាំងណារាក់ជួនកាលហួតទឹកជិតអស់នៅរដូវក្ដៅ។	Right, but at times in the hot season some shallow ponds evaporate until the water is almost gone.
	Sok		
13.		បើលោកពូស្ទូងខែក្រោយ អង្កាល់ទៅបានច្រូតបាន?	If you transplant next month, when will you be able to reap?
	Pon		
14.		ស្រូវនេះស្រាលទេ មើលទៅបួនប្រាំខែ អាចច្រូតបានហើយ។	This rice is early maturing - it seems that in four or five months it can be reaped.
	Sok		
15.		មិនយូរទេ អញ្ចឹង ភ្លេចត្រទៀតបន្តិចទៅបានស្រូវដាក់ជង្រុកហើយ។ លោកពូច្រូតខ្លួនឯងឬក៏ជួលគេឲ្យច្រូត។	Not very long, in that case. Let it go for a little while, and then you can put it in the granary. Do you harvest yourself or do you hire people to harvest?
	Pon		
16.		បាទ ខ្ញុំមើលទៅជួលគេខ្លះមិនខាន ព្រោះត្រពាំងនេះធំណាស់ បើខ្ញុំច្រូតតែពីរបីនាក់មិនងាយហើយទេ។	I guess I'll hire some, because the pond is very big. If I harvest with only two or three people it's not easy.
	Sok		
17.		ចុះដឹកយកមកផ្ទះលោកពូជួលគេមកជួយបញ្ជូនដាក់ជង្រុកទៀតឬ?	As for carrying it to the house, will you hire somebody to help put it in the granary (place where cattle are used to thresh the grain)?
	Pon		
18.		បាទទេ ខ្ញុំអាចធ្វើបន្តិចៗទៅបាន។	No, this I can do little by little.
	Sok		
19.		ចាំមើលប្រហែលដល់ពេលនោះ ខ្ញុំមកលេងលោកពូទៀត។	Wait and maybe at that time I'll come visit you again.
	Pon		
20.		បាទ អញ្ជើញមកពេលណាក៏បានដែរ។	Please come. Any time is O.K.

DRILLS

Drill A. Substitution

1.	ស្អែកឡើងខ្ញុំទៅជួយសាបលោកពូ មិនបានទេ។	Tomorrow I can go help my uncle plant seed.
2.	ស្អែកឡើងខ្ញុំទៅជួយភ្ជួរលោកពូមិនបានទេ។	Tomorrow I can go help my uncle plow.
3.	ស្អែកឡើងខ្ញុំទៅជួយរាស់ លោកពូ មិនបានទេ។	Tomorrow I can go help my uncle harrow.
4.	ស្អែកឡើងខ្ញុំទៅជួយស្ទូង លោកពូមិនបានទេ។	Tomorrow I can go help my uncle transplant.
5.	ស្អែកឡើងខ្ញុំទៅជួយច្រូតលោកពូមិនបានទេ។	Tomorrow I can go help my uncle reap.
6.	ស្អែកឡើងខ្ញុំទៅជួយរៀបចំផ្ទះលោកពូមិនបានទេ។	Tomorrow I can go help my uncle straighten up the house.
7.	ស្អែកឡើងខ្ញុំទៅជួយធ្វើឡានលោកពូ មិនបានទេ។	Tomorrow I can go help my uncle repair the car.
8.	ស្អែកឡើងខ្ញុំទៅជួយបង្រៀនលោកពូ មិនបានទេ។	Tomorrow I can go help my uncle teach.

Drill B. Substitution

1.	ធម្មតាខែណាស្រូវទុំ ច្រូតបាន?	Usually in the month the rice is ripe, can they harvest?
2.	ធម្មតាខែណាសំណាបធំ ដកបាន?	Usually in the month the seedlings are large, can they pull (them)?
3.	ធម្មតាខែណា មានទឹកច្រើន ស្ទូងបាន?	Usually in the month there is a lot of water, can they transplant?
4.	ធម្មតាខែណាមានទឹកកកធ្លាក់ច្រើន ដើរទៅមិនបាន?	Usually in the month a lot of snow falls, can they walk?
5.	ធម្មតាខែណាមានភ្លៀងច្រើន ពិបាកធ្វើដំណើរទេ។	Usually in the month there is a lot of rain, is it difficult to travel?
6.	ធម្មតាខែណាទឹកស្រកបើកឡានទៅបាន?	Usually in the month the water is low, can they drive the car?
7.	ធម្មតាខែណា ក្តៅខ្លាំងបំផុត ពិបាកដើរលេង?	Usually in the month it is the hottest, is it difficult to go out for a good time?
8.	ធម្មតាខែណាត្រជាក់ខ្លាំង ពិបាកបញ្ឆេះឡាន?	Usually in the month it is very cold, is it hard to start the car?

Drill C. Substitution

1.	ឥឡូវនេះភ្លៀងច្រើនណាស់គេសាបមិនបានទេ។	Now that there is a lot of rain, they can't plant.
2.	ឥឡូវនេះខ្យល់ខ្លាំងណាស់ គេអុំទូកមិនបានទេ។	Now that the wind is strong, they can't row the boats.
3.	ឥឡូវនេះទឹកជ្រៅណាស់គេស្ទូងមិនបានទេ។	Now that the water is deep, they can't transplant.
4.	ឥឡូវនេះទឹកហូរខ្លាំងណាស់គេហែលមិនបានទេ។	Now that the water flows swiftly, they can't swim.
5.	ឥឡូវនេះសំណាបខ្លីណាស់គេដកមិនបានទេ។	Now that the seedlings are short, they can't pull (them).
6.	ឥឡូវនេះក្ដៅណាស់គេដើរមិនបានទេ។	Now that it is very hot, they can't walk.
7.	ឥឡូវនេះត្រជាក់ណាស់គេងូតទឹកមិនបានទេ។	Now that it is very cool they can't take a bath.
8.	ឥឡូវនេះស្រូវទុំច្រើនណាស់គេច្រូតតែពីរនាក់មិនបានទេ។	Now that the rice is very ripe, they can't reap with only 2 people.

Drill D. Substitution

1.	តាមខ្ញុំស្មានត្រពាំងចក មានទឹកច្រើនពេកពិបាកស្ទូងណាស់។	I think that since Trapeang Chak has too much water, it's difficult to transplant.
2.	តាមខ្ញុំដឹង ត្រពាំងចកមានទឹកជ្រៅពេកពិបាករាស់ណាស់។	I know that since Trapeang Chak has deep water, it's difficult to harrow.
3.	តាមខ្ញុំឃើញត្រពាំងចកមានស្មៅច្រើនពេកពិបាកភ្ជួរណាស់។	I see that since Trapeang Chak has a lot of grass, it's difficult to plow.
4.	តាមខ្ញុំយល់ត្រពាំងចកនៅឆ្ងាយពេកពិបាកទៅមើលណាស់។	I understand that since Trapeang Chak is too far away, it's difficult to go see (it).
5.	តាមខ្ញុំដឹងសាលារៀននោះនៅឆ្ងាយពេកពិបាកឲ្យកូនទៅរៀនណាស់។	I know that since that school is too far away, it's difficult for the students to go study.
6.	តាមខ្ញុំគិតមើលទៅឥឡូវត្រជាក់ពេកពិបាកទៅកំពេណាស់។	I think that since now it's cold, it's difficult to go camping.
7.	តាមខ្ញុំស្មាន ឆ្នាំមុនទឹកឡើងខ្លាំងពេកពិបាកធ្វើដំណើរណាស់។	I think that since last year the water rose very high, it's difficult to make a trip.

8.	តាមខ្ញុំឃើញ ថ្នាក់នោះមានកូនសិស្សច្រើនពេក ពិបាករៀនណាស់។	I see that since that class has too many students, it's difficult to study.

Drill E. Response

MODEL: គ្រូ: ត្រពាំងចកមានទឹកច្រើនល្មមស្ទូងបានទេ? (ស្មាន)

Teacher: Does Trapeang Chak have enough water in it to plant? (think)

សិស្ស: តាមខ្ញុំស្មានឥឡូវទឹកច្រើនណាស់ ស្ទូងមិនទាន់បានទេ។

Student: I think that since there is a lot of water now, you can't plant yet.

1.	ត្រពាំងចកមានទឹកជ្រៅល្មមពាស់បានទេ? (ដឹង)	តាមខ្ញុំដឹង ឥឡូវទឹកជ្រៅណាស់ ពាស់មិនទាន់បានទេ។
2.	គេមានសំណាបរឹងល្មមស្ទូងបានទេ? (ឃើញ)	តាមខ្ញុំឃើញ ឥឡូវសំណាបរឹងណាស់ ស្ទូងមិនទាន់បានទេ។
3.	នៅមាត់សមុទ្រមានអាកាសត្រជាក់ល្មមកំពេ បានទេ? (ដឹង)	តាមខ្ញុំដឹង ឥឡូវអាកាសត្រជាក់ណាស់ កំពេ មិនទាន់បានទេ។
4.	នៅតាមទន្លេនោះមាន ខ្យល់ខ្លាំងល្មមដាក់ក្ដោងទូកបានទេ? (ស្មាន)	តាមខ្ញុំស្មានឥឡូវ ខ្យល់ខ្លាំងណាស់ ដាក់ក្ដោងទូកមិនទាន់បានទេ។
5.	នៅជិតបឹងនោះមានដីរឹងល្មមភ្ជួរបានទេ? (ទៅឃើញ)	តាមខ្ញុំទៅឃើញ ឥឡូវដីរឹងណាស់ ភ្ជួរមិនទាន់បានទេ។

Drill F. Response

MODEL: គ្រូ: អង្កាល់ទៅបានគេចាប់ស្ទូងបាន? (ទឹក)

Teacher: When can they begin to plant? (water)

សិស្ស: ឥឡូវគេចាប់ស្ទូងមិនទាន់បានទេ គេចាំឲ្យមានទឹកបន្តិចទៀតសិន។

Student: They can't start to plant yet. They are waiting to have a little more water first.

1.	អង្កាល់ទៅគេចាប់ច្រូតបាន? (ស្រូវទុំ)	ឥឡូវគេចាប់ច្រូតមិនទាន់បានទេ គេចាំឲ្យស្រូវទុំបន្តិចទៀតសិន។
2.	អង្កាល់ទៅគេចាប់ភ្ជួរបាន? (មានទឹក)	ឥឡូវគេចាប់ភ្ជួរមិនទាន់បានទេ គេចាំឲ្យមានទឹកបន្តិចទៀតសិន។
3.	អង្កាល់ទៅបានគេចាប់ធ្វើស្រែបាន? (មានភ្លៀង)	ឥឡូវគេចាប់ធ្វើមិនទាន់បានទេ គេចាំឲ្យមានភ្លៀងបន្តិចទៀតសិន។
4.	អង្កាល់ទៅបានគេចាប់បញ្ចាំងកុននោះបាន? (មានមនុស្សច្រើន)	ឥឡូវគេចាប់បញ្ចាំងមិនទាន់បានទេ គេចាំឲ្យមានមនុស្សច្រើនបន្តិចទៀតសិន។

5. អង្កាល់ទៅបានគេចាប់ឲ្យវាទៅសាលារៀន? (វាមានអាយុច្រើន)	ពីព្រោះគេឲ្យវាទៅរៀនមិនទាន់បានទេ គេចាំឲ្យវាមានអាយុច្រើនសិន។

Drill G. Response

MODEL: គ្រូ ម៉េចក៏គេទុកសំណាបឲ្យវែងអញ្ចឹង? (ដើម្បីឲ្យស្រួលដក)	**Teacher:** How come they let the seedlings get so long? (so it's easy to transplant)
សិស្ស: គេទុកសំណាបឲ្យវែងបន្តិចទៀតសិន ដើម្បីឲ្យស្រួលដក។	**Student:** They let the seedlings get a little longer first so they're easy to transplant.
1. ម៉េចក៏គេទុកស្រូវនេះឲ្យទុំអញ្ចឹង? (ដើម្បីឲ្យស្រួលបោក)	គេទុកស្រូវឲ្យទុំបន្តិចទៀតសិន ដើម្បីឲ្យស្រួលបោក។
2. ម៉េចក៏គេទុកទឹកឲ្យហូរចេញពីត្រពាំងអញ្ចឹង? (ដើម្បីឲ្យស្រួលស្ទូង)	គេទុកទឹកឲ្យហូរចេញពីត្រពាំងបន្តិចទៀតសិន ដើម្បីឲ្យស្រួលស្ទូង។
3. ម៉េចក៏គាត់ទុកពោតឲ្យទុំអញ្ចឹង? (ដើម្បីឲ្យវាទុំបានល្អ)	គាត់ទុកពោតឲ្យទុំបន្តិចទៀតសិន ដើម្បីឲ្យទុំបានល្អ។
4. ម៉េចក៏វាទុកឡានឲ្យឆេះអញ្ចឹង? (ដើម្បីឲ្យក្ដៅម៉ាស៊ីន)	វាទុកឡានឲ្យឆេះបន្តិចទៀតសិន ដើម្បីឲ្យក្ដៅម៉ាស៊ីន។
5. ម៉េចក៏គាត់នៅរៀនខ្មែរទៀតអញ្ចឹង? (ដើម្បីឲ្យចេះសរសេរត្រឹមត្រូវ)	គាត់នៅរៀនខ្មែរបន្តិចទៀតសិន ដើម្បីឲ្យចេះសរសេរត្រឹមត្រូវ។

Driil H. Response

MODEL: គ្រូ គេស្ទូងស្រែនេះប៉ុន្មានថ្ងៃបានហើយ? (ដីមិនរឹងទេ)	**Teacher:** In how many days can they finish planting this paddy? (the earth is not hard)
សិស្ស: មិនយូរទេ តាមខ្ញុំស្មានព្រោះដីមិនរឹងទេ។	**Student:** Not long, according to me, because the earth is not hard.
1. គេជួសស្ពាននេះប៉ុន្មានខែបានហើយ? (វាមិនខូចច្រើនទេ)	មិនយូរទេ តាមខ្ញុំស្មានព្រោះវាមិនខូចច្រើនទេ។
2. លោកបើកឡានទៅឯណោះប៉ុន្មានថ្ងៃបានដល់? (ផ្លូវល្អគួរសមដែរ)	មិនយូរទេ តាមខ្ញុំស្មានព្រោះផ្លូវល្អគួរសមដែរ។
3. លោកត្រឡប់មកវិញអង្កាល់។ (ខ្ញុំត្រូវចូលរៀនហើយពីរខែទៀត)	មិនយូរទេ តាមខ្ញុំស្មានព្រោះចូលរៀនហើយពីរខែទៀត។
4. គាត់វាស់ប៉ុន្មានខែទៀតបានហើយ? (នៅវាស់ដីតែបន្តិចទៀតទេ)	មិនយូរ តាមខ្ញុំស្មាន ព្រោះនៅវាស់ដីតែបន្តិចទៀតទេ។
5. លោកដឹងទេ លោកស្មិតមកវិញអង្កាល់?	មិនយូរ តាមខ្ញុំស្មាន ព្រោះបានជំរាប

6.	(ខ្ញុំបានជំរាបគាត់ហើយថាលោកនឹងមកជួប)	គាត់ហើយ ថាលោកនឹងមកជួប។

Drill I. Transformation

MODEL:	គ្រូ៖ ថ្ងៃស្អែកគាត់ត្រូវទៅភ្ជួរត្រពាំងចក។ (អង្កាល់)	**Teacher:** Tomorrow he has to go plow Trapeang Chak. (when)
	សិស្ស៖ គាត់ត្រូវទៅភ្ជួរត្រពាំងចកអង្កាល់?	**Student:** When does he have to go plow Trapeang Chak?
1.	ម្សិលមិញលោកស្មិតឈប់រៀន។ (ពីអង្កាល)	លោកស្មិតឈប់រៀនពីអង្កាល់?
2.	ថ្ងៃក្រោយលោកត្រូវទៅភ្នំពេញ។ (អង្កាល)	លោកត្រូវទៅភ្នំពេញអង្កាល់?
3.	វាបាត់សៀវភៅរឿងហើយ។ (អី)	វាបាត់សៀវភៅអី?
4.	គេឲ្យគាត់ទៅស្រុកខ្មែរ។ (ឯណា)	គេឲ្យគាត់ទៅឯណា?
5.	កូនគាត់ទៅច្រូតស្រូវ។ (ធ្វើអី)	កូនគាត់ទៅធ្វើអី?
6.	គាត់គិតស្ទូងនៅស្រុកនេះ។ (ធ្វើអី)	គាត់គិតធ្វើអីនៅស្រុកនេះ?

UNIT 75

NARRATION

1. ទន្លេមេគង្គជាទន្លេធំជាងគេបំផុតនៅអាស៊ី។
2. ទន្លេនេះចាប់ដើមកំណើតនៅភ្នំទីបេ ហើយហូរចាក់ទៅសមុទ្រនៅប្រទេសយួនខាងត្បូង។
3. ទន្លេមេគង្គហូរកាត់ប្រទេសកម្ពុជាពីកន្លែងទឹកធ្លាក់ឈ្មោះខោន មកដល់ព្រំដែនខាងត្បូងរវាងប្រទេសកម្ពុជានឹងប្រទេសយួន ត្រង់ព្រំដែនខេត្តព្រៃវែង នឹងតាកែវ។
4. ផ្លូវទឹកនេះមានប្រយោជន៍ច្រើនណាស់ដល់ប្រទេសកម្ពុជា នឹងប្រទេសឯទៀតនៅឥណ្ឌូចិន។
5. នៅតាមដងទន្លេនេះគេឃើញទីក្រុងកើតឡើង ដូចជាក្រុងស្ទឹងត្រែង ក្រចេះ កំពង់ចាម នឹងភ្នំពេញជាដើម។
6. ក្រៅពីក្រុងទាំងនេះមានស្រុកនឹងភូមិឯទៀតច្រើន ហើយអ្នកស្រុកនៅទីនោះតែងដាំដំណាំផ្សេងៗ ដូចជាថ្នាំ ពោត សណ្តែក នឹងបន្លែគ្រប់មុខ។
7. អ្នកធ្វើដំណើរតាមកប៉ាល់ឬតាមឡានតាមដងទន្លេមេគង្គ នឹងតាមដៃទន្លេនេះអាចឃើញចំការដំណាំទាំងឡាយលាតសន្ធឹងសឹងតែដាច់កន្ទុយភ្នែក។
8. នៅរដូវទឹកឡើង ទន្លេមេគង្គហើយនឹងព្រែកទាំងប៉ុន្មានក៏ធំឡើង។
9. ដោយសារទឹកព្រែកនេះហើយ អ្នកស្រុកដែលនៅឆ្ងាយពីទន្លេធំ អាចទទួលទឹកបានដោយបរិបូណ៌។
10. ទៅអនាគត ទន្លេមេគង្គមុខនឹងផ្តល់កម្លាំងអគ្គិសនីដ៏ធំមួយ ដល់ប្រទេសទាំងឡាយនៅតំបន់នោះ។

1. The Mekong River is the largest river in Asia.
2. This river rises in the mountains of Tibet and flows into the sea in South Vietnam.
3. The Mekong River flows through Cambodia from the waterfall called Khone to the southern border of Cambodia and Vietnam, just at the border of Prev Veng and Takeo provinces.
4. This waterway has great importance to Cambodia and the other countries in Indochina.
5. Along the course of the river you can see many cities grow up, such as Stung Treng, Kratie, Kompong Cham and Phnom Penh for example.
6. Besides all these cities there are many other sroks and villages, and the peasants living here usually plant various crops such as tobacco, corn, beans, and all kinds of vegetables.
7. Travellers by boat or by car along the banks of the Mekong and the tributaries of this river can see all the fields extending as far as one can see.
8. In the season of high water, the Mekong river and all the creeks rise.
9. By means of these creeks, peasants who live far from the Mekong can get abundant water.

10. In the future, the Mekong will supply a large amount of electric energy to all the countries in that region.

1. នៅពេលទឹកឡើងទន្លេមេគង្គហូរចូលទៅលើស្រែចំការទាំងឡាយដែលនៅមិនឆ្ងាយពីទន្លេ ។
2. ទឹកនេះនាំដីល្បប់មកជាមួយហើយស្រោចដីល្បប់នេះទៅលើស្រែចំការទាំងនោះ ។
3. ដីល្បប់នេះជាជីមួយយ៉ាងសំខាន់ដែលជួយឲ្យដំណាំដុះបានល្អរាល់រដូវ ។
4. ទន្លេមេគង្គបែកជាបួនមុខនៅភ្នំពេញ ។
5. ដូច្នេះហើយបានជាគេហៅថាទន្លេចតុមុខ ។
6. ទឹកទន្លេនេះមួយចំណែកហូរឡើងទៅទន្លេសាបដែលជាបឹងមួយដ៏សំខាន់នៃប្រទេសកម្ពុជា ។
7. បឹងធំនេះជាជំរុំត្រីជាច្រើនតោនដែលគេចាប់យកទៅធ្វើជាអាហារនិងលក់ចេញទៅបរទេសរាល់ឆ្នាំ ។
8. គេយកត្រីខ្លះទៅធ្វើជាងៀត ឆ្អើ ឬប្រហុកដើម្បីទុកឲ្យបានយូរមិនខូច ។
9. នៅពេលទឹកស្រកទន្លេសាបហូរចេញពីបឹងនោះមកវិញ ។
10. ក្នុងពេលនេះហើយដែលខ្មែររៀបចំធ្វើបុណ្យមួយហៅថាបុណ្យអុំទូក ឬប្រណាំងទូក ។

1. At the time of high waters, the Mekong flows over all the fields which are not far from the river.
2. This water carries silt along with it and spreads this silt on all those fields.
3. This silt is a kind of important fertilizer which helps the crops grow well every season.
4. The Mekong splits into four arms at Phnom Penh.
5. That is why they call it Catomuk (Four Faces, Four Arms).
6. One part of the water flows up to the Tonle Sap, which is a very important lake in Cambodia.
7. This large lake has a concentration of many tons of fish, which they catch to make into food to export to foreign countries every year.
8. They take some fish to make it into dried fish, smoked fish, or prohok, so it can be kept a long time without spoiling.
9. At the time the water (from the streams) recedes, the water from the Tonle Sap flows back out of this lake.
10. It is at this time that the Cambodians celebrate a festival which is called the Festival of Rowing Pirogues or Racing Pirogues (Water Festival).

1. ពេលនេះនៅស្រុកស្រែចំការគេកំពុងរវល់ណាស់។
2. ក្នុងប៉ុន្មានអាទិត្យមុនមានភ្លៀងច្រើន ដូច្នេះហើយ បានជាអ្នកស្រុកនាំគ្នាភ្ជួររាស់ពាស ពេញសឹងតែគ្រប់កន្លែង។
3. អ្នកស្រែចំការខ្លះភ្ជួររួចហើយៗ ដល់កាលណាមានទឹកភ្លៀង ដូច្នេះគេទៅរាស់ដើម្បីសាប ស្រូវ។
4. គេធ្វើដីស្រែឲ្យទន់ល្មមទើបគេចាប់សាប។
5. អ្នកខ្លះសាបស្រូវខ្សាយធម្មតា ខ្លះទៀតសាបស្រូវដំណើប។
6. កាលណាគេសាបស្រូវឡើងទឹក គេមិនបាច់រៀបចំដីស្រែឲ្យល្អប៉ុន្មានទេ ពីព្រោះស្រូវឡើង ទឹកស្រួលដុះណាស់ឲ្យតែមានទឹកបរិបូណ៌។
7. ស្រូវដែលគេយកទៅសាបនោះគេហៅថាស្រូវពូជ។
8. គេត្រូវត្រាំពូជ ឲ្យគ្រាប់ស្រូវដុះបានបន្តិចទើបគេយកទៅសាប។

1. At this time in the fields they are very busy.

2. In the few weeks of heavy rains, all the peasants plow and harrow almost everywhere.

3. Some peasants have already plowed, and therefore when there is rain they go to harrow in order to plant rice.

4. They make the soil of the field sufficiently soft, and only then can they begin to plant.

5. Some people sow ordinary rice, others sow glutinous rice.

6. When they sow floating rice they don't have to prepare the field very well because floating rice can grow easily as long as it's watered.

7. The rice they take to sow, they call seed.

8. They have to soak the seed so it can grow a little (germinate) and only then can they take it to sow.

1. ធម្មតាកាលណាគេត្រាំពូជបានបីបួនថ្ងៃ គេអាចយកទៅសាបបាន។
2. គេសាបត្រូវមិនឲ្យច្រើនហួសចំនួនក្រឡាដីស្រែដែលគេត្រូវស្ទូងទេ។
3. ក្នុងរវាងពីបីខែ គេអាចដកស្រូវយកទៅស្ទូងបាន។
4. ស្រែដែលគេស្ទូងត្រូវមានទឹកយ៉ាងតិចពាក់កណ្ដាលកំពស់សន្ទូង។
5. ដូច្នេះហើយបានជាអ្នកខ្លះចូលចិត្តស្ទូងនៅក្នុងត្រពាំង។
6. ត្រពាំងច្រើនធំហើយជ្រៅផង។
7. នៅរដូវក្ដៅត្រពាំងមិនសូវរីងទឹកទេ។
8. គឺនៅរដូវក្ដៅនេះហើយដែលគេចាប់ច្រូតស្រូវយកទៅបោក រួចន បញ្ជូន
ដាក់ជង្រុក។

1. Usually, when they have soaked the seed for 3 or 4 days, they can sow it.
2. They sow no more than they have land to transplant onto.
3. In 2 or 3 months they can pull up the rice and transplant it.
4. The fields where they transplant must at least have water up to nearly half the height of the seedlings.
5. That is why some people prefer to transplant in ponds.
6. Many ponds are large and deep too.
7. In the hot season, the ponds hardly evaporate at all.
8. It is in the hot season that they begin to reap the rice, take it to be threshed and put it in the granary.

UNIT 76

BASIC DIALOGUE

	Kim	
1.	លោកមកដល់នេះពីអង្កាល់?	Paul, when did you arrive here?
	Paul	
2.	ខ្ញុំមកដល់បីថ្ងៃហើយ តែគ្មានបាន ជួបអ្នកណាដែលខ្ញុំធ្លាប់ស្គាល់សោះ។	I arrived three days ago but I haven't had the opportunity to meet anyone that I know at all.
	Kim	
3.	លោកនៅនេះយូរឬអី?	Are you going to stay long?
	Paul	
4.	បាទ ទេ ខ្ញុំបានឈប់តែមួយខែទេ ហើយខ្ញុំឆ្លៀតពេលនេះធ្វើដំណើរមក លេងកន្លែងផ្សេងៗនៅអាស៊ីនេះ។	No, I can stay only a month and I'm taking advantage of this time to travel to visit various places in Asia.
	Kim	
5.	លោកមកជាមួយក្រុមទេសចរ ឬមកម្នាក់ឯង?	Did you come with a group of tourists or by yourself?
	Paul	
6.	បាទខ្ញុំមកជាមួយក្រុមទេសចរ ឯទៀត។ អញ្ចឹងហើយបានជាខ្ញុំមិនទាន់ មានឱកាសទៅសួររកពួកម៉ាកណាម្នាក់ សោះ។ តាំងពីខ្ញុំមកដល់បានមួយថ្ងៃ ក្រុមហ៊ុនទេសចរណ៍ខ្មែរគេនាំដើរមើលស្ទើរ តែគ្រប់កន្លែង។	I came with another group of tourists. That's why I haven't yet had the opportunity to visit a single friend. Since I have been here for a day, the Cambodian Tourist Office has taken us to see almost every place.
	Kim	
7.	លោកបានឃើញអ្វីខ្លះហើយ?	What things have you seen already?
	Paul	
8.	បាទខ្ញុំបានទៅឃើញអង្គរវត្ត ហើយ។ ល្អហើយគួរឲ្យស្ញប់ស្ញែង ណាស់។	I've seen Angkor Wat; it's beautiful and very impressive.

Kim

9. លោកបានទៅឃើញអង្គរវត្តហើយ!
You've already had the chance to go to Angkor Wat?

Paul

10. បាទ ខ្ញុំមកពីរ៉ងហ្គូនត្រង់ទៅសៀមរាបតែម្តង។
Yes, I came directly from Rangoon to Siem Reap.

Kim

11. អូ អញ្ចឹងលោកបាននៅសៀមរាបប៉ុន្មានថ្ងៃហើយ?
Oh, then how many days did you spend in Siem Reap?

Paul

12. បាទ ខ្ញុំនៅមួយអាទិត្យ។ បានទៅមើលអង្គរវត្តរាល់ថ្ងៃ។
I stayed one week. I went to see Angkor Wat every day.

Kim

13. លោកមើលអស់ទេ?
Did you see it all?

Paul

14. បាទ មើលអស់ហើយ តែដូចលោកជ្រាបស្រាប់ ខ្ញុំដើរមើលមួយអាទិត្យឲ្យអស់អញ្ចឹង មើលមិនបានល្អទេ។
Yes, I saw it all, but as you already know, when I tried to walk to see it all in one week, (I) couldn't see it very well.

Kim

15. លោកបានទៅដល់បន្ទាយស្រីទេ?
Did you go to Banteay Srey?

Paul

16. បាទ ខ្ញុំបានទៅឃើញដែរ។ នេះជាប្រាសាទមួយដែលនៅស្អាតជាងគេបង្អស់។ ក្បាច់រចនាលេចឡើងលើថ្មដូចជានៅស្រស់ៗ ។ ខ្ញុំថតបានច្រើនដែរ។
Yes, I went to see it too. It's the prettiest temple of all. The decoration on the stone looks as if it were newly done. I took a lot of pictures too.

Kim

17. លោកឃើញចម្លាក់នៅតាមកំពែងអង្គរទេ?
Did you see the sculpture along the walls of Angkor?

Paul

18. បាទ ចម្លាក់នេះនៅល្អដែរ ហើយអ្នកណាក៏ចង់ស្ទាបអង្អែលដែរ។ ឥឡូវរលោងល្អណាស់។
Oh, yes the sculpture is also beautiful and everyone wants to touch and rub it. Now it's shiny.

	ខ្ញុំទៅអង្គរវត្តដងណាក៏ខ្ញុំនឹកឆ្ងល់ថា តើខ្មែរពីដើមគេសង់អង្គរវត្តនេះយ៉ាងម៉េច?។ គេចេះយកថ្មទាំងដុំធំៗដូចនេះ មកដាក់លើគ្នាហើយគ្មានទាំងស៊ីម៉ង់ផង។	Whenever I went to Angkor Wat I wondered. I didn't know how the ancient Khmers built Angkor; that they took all those big blocks of stone and placed them one on the other, and they didn't even have cement.
	Kim	
19.	បាទ នេះគួរឲ្យអស្ចារ្យណាស់។ នៅសារៈមន្ទីរជាតិឯភ្នំពេញនេះខ្ញុំក៏ឃើញក្បាច់ចម្លាក់របៀបបុរាណនឹងរបៀបសម័យទំនើប។	Yes, it's really marvelous. In the National Museum in Phnom Penh I also saw ancient and modern scupture.
20.	លោកបានអញ្ជើញទៅមើលវាំងនឹងវត្តព្រះកែវហើយឬនៅ?	Have you gone to see the Palace and the Emerald Pagoda yet?
	Paul	
21.	បាទ ខ្ញុំនឹងទៅមើលថ្ងៃស្អែកព្រឹក។ មានអីខ្លះខ្ញុំគួរមើល?	I'm going to go see them tomorrow morning. Is there anything else I should see?
	Kim	
22.	បាទលោកគួរទៅមើលសារៈមន្ទីរតាំងគ្រឿងឥស្សរៈយសដែលស្ដេចពាក់នៅពេលឡើងសោយរាជ្យ ព្រះទីនាំងទេវាវិនិច្ឆ័យដែលមានព្រះរាជបល្ល័ង្កនៅនោះ នឹងវត្តព្រះកែវ។ ព្រះវិហារព្រះកែវនេះក្រាលសុទ្ធតែប្រាក់។	Yes, you should go see the museum displaying the Regalia worn when the king is crowned, the court where the throne is, and the Emerald Pagoda. The temple of the Emerald Pagoda is floored entirely in silver.
	Paul	
23.	អញ្ចឹងថ្ងៃស្អែកខ្ញុំនឹងទៅមើលកន្លែងទាំងអស់នេះមុនធ្វើអីទៀតទាំងអស់។	In that case tomorrow I will go see all these places before I do anything else.
	Kim	
24.	លោកបានឃើញវិមានឯករាជ្យនឹងវត្តភ្នំហើយ តាមខ្ញុំស្មាន។	I guess you have seen Independence Monument and Wat Phnom already?
	Paul	
25.	បាទខ្ញុំទៅថតពីម្សិលមិញ។ ខ្ញុំមើលទៅក្បាច់នៅវិមានឯករាជ្យជាក្បាច់លាយ	I went to take pictures yesterday. I see that the decoration on the

បុរាណនិងសម័យ ។

Independence Monument blends the ancient and the modern.

DRILLS

Drill A. Substitution

1.	ខ្ញុំមកដល់ពីរបីថ្ងៃហើយតែមិនទាន់បានទៅជួបអ្នកណាសោះ។	I arrived here 2 or 3 days ago, but I haven't met anybody at all yet.
2.	ខ្ញុំមកដល់ពីរបីថ្ងៃហើយតែមិនទាន់បានទៅឃើញអ្នកណាសោះ។	I arrived here 2 or 3 days ago, but I haven't seen anybody at all yet.
3.	ខ្ញុំមកដល់ពីរបីថ្ងៃហើយតែមិនទាន់បានទៅរកអ្នកណាសោះ។	I arrived here 2 or 3 days ago, but I haven't gone to look for anybody at all yet.
4.	ខ្ញុំមកដល់ពីរបីថ្ងៃហើយតែមិនទាន់បានទៅតេឡេហ្វូនទៅអ្នកណាសោះ។	I arrived here 2 or 3 days ago, but I haven't telephoned anybody at all yet.
5.	ខ្ញុំមកដល់ពីរបីថ្ងៃហើយតែមិនទាន់បានទៅផ្ទះអ្នកណាសោះ។	I arrived here 2 or 3 days ago, but I haven't gone to anyone's house at all yet.
6.	ខ្ញុំមកដល់ពីរបីថ្ងៃហើយតែមិនទាន់បានទៅលេងអ្នកណាសោះ។	I arrived here 2 or 3 days ago, but I haven't gone to visit anybody at all yet.
7.	ខ្ញុំមកដល់ពីរបីថ្ងៃហើយតែមិនទាន់បានទៅស្គាល់អ្នកណាសោះ។	I arrived here 2 or 3 days ago, but I haven't got acquainted with anybody at all yet.
8.	ខ្ញុំមកដល់ពីរបីថ្ងៃហើយតែមិនទាន់បានទៅសួររកអ្នកណាសោះ។	I arrived here 2 or 3 days ago, but I haven't asked to be taken to visit anybody at all yet.

Drill B. Substitution

1.	ម្សិលមិញខ្ញុំឆ្លៀតទៅធ្វើការបានពីរបីម៉ោង។	Yesterday I took advantage of being able to go to work for 2 or 3 hours.
2.	ម្សិលមិញខ្ញុំឆ្លៀតទៅជួបគាត់បានពីរបីម៉ោង។	Yesterday I took advantage of being able to meet him for 2 or 3 hours.
3.	ម្សិលមិញខ្ញុំឆ្លៀតទៅស្តាប់ខ្សែសំឡេងបានពីរបីម៉ោង។	Yesterday I took advantage of being able to listen to tapes for 2 or 3 hours.
4.	ម្សិលមិញខ្ញុំឆ្លៀតទៅមើលគេអុំទូកបានពីរបីម៉ោង។	Yesterday I took advantage of being able to watch them row boats for 2 or 3 hours.
5.	ម្សិលមិញខ្ញុំឆ្លៀតទៅមើលសាលតាំងវត្ថុបានពីរបីម៉ោង។	Yesterday I took advantage of being able to look at the exhibition hall for 2 or 3 hours.
6.	ម្សិលមិញខ្ញុំឆ្លៀតទៅលេងមុខវាំងបាន	Yesterday I took advantage of being

ពីរបីម៉ោង។	able to enjoy myself in front of the palace.
7. ថ្ងៃមុនខ្ញុំឆ្លៀតទៅលេងមុខវាំងបានពីរបីម៉ោង។	A day before I took advantage of being able to enjoy myself in front of the palace.
8. អាទិត្យមុនខ្ញុំឆ្លៀតទៅលេងមុខវាំងបានពីរបីម៉ោង។	A week before I took advantage of being able to enjoy myself in front of the palace.

Drill C. Substitution

1. ខ្ញុំមិនទាន់ទៅមើលអង្គរវត្តទេ ឮតែគេថាគួរស្ញប់ស្ញែងណាស់។	I haven't gone to see Angkor Wat yet, I only hear that it is admirable.
2. ខ្ញុំមិនទាន់ទៅមើលហ្វីលនោះទេ ឮតែគេថាល្អមើលណាស់។	I haven't gone to see that film yet; I only hear that it's good to see.
3. ខ្ញុំមិនទាន់ទៅមើលកន្លែងនោះទេ ឮតែគេថាខ្លាចណាស់។	I haven't gone to see that place yet; I only hear that it is frightening.
4. ខ្ញុំមិនទាន់ទៅមើលវត្តព្រះកែវទេ ឮតែគេថាទាក់ចិត្តណាស់។	I haven't gone to see the Emerald Pagoda yet; I only hear that it is attractive.
5. ខ្ញុំមិនទាន់ទៅមើលវត្តភ្នំទេ ឮតែគេថាសប្បាយណាស់។	I haven't gone to see Wat Phnom yet; I only hear that it is pleasant.
6. ខ្ញុំមិនទាន់ទៅមើលវាំងទេ ឮតែគេថាចង់ទៅឃើញណាស់។	I haven't gone to see the palace yet; I only hear that it makes you want to go see it.
7. ខ្ញុំមិនទាន់ទៅមើលក្រុងសីហនុទេ ឮតែគេថាសប្បាយណាស់។	I haven't gone to see Sihanoukville yet; I only hear that it is pleasant.
8. ខ្ញុំមិនទាន់ទៅមើលផ្ទះនោះទេ ឮតែគេថាចង់ទៅនៅណាស់។	I haven't gone to see that house yet; I only hear that it makes you want to live in it.

Drill D. Substitution

1. ខ្ញុំទៅជួបគាត់តាំងពីខ្ញុំមកដល់បានមួយថ្ងៃ។	I went to see him a day after I got here.
2. វាមកជួបខ្ញុំតាំងពីខ្ញុំមកដល់បានមួយថ្ងៃ។	He came to see me a day after I got here.
3. គាត់មកសួរខ្ញុំ តាំងពីខ្ញុំមកដល់បានមួយថ្ងៃ។	He came to see (ask) me a day after I got here.
4. លោកស្មិតមកលេងផ្ទះនេះតាំងពីខ្ញុំ	Mr. Smith came to visit this house

មកដល់បានមួយថ្ងៃ។ — a day after I got here.

5. លោកស្មិតមកលេងផ្ទះនេះ តាំងពីព្រឹក។ — Mr. Smith has been visiting this house since this morning.

6. លោកស្មិតមកលេងផ្ទះនេះតាំងតែពីវាចេញទៅក្រៅ។ — Mr. Smith has been visiting this house since he went out.

7. លោក ស្មិតមកលេងផ្ទះនេះតាំងតែពីគាត់មកដល់ភ្លាម។ — Mr. Smith has been visiting this house since immediately after he arrived.

8. លោកស្មិតមកលេងផ្ទះនេះតាំងតែពីខ្ញុំចូលមកដល់។ — Mr. Smith has been visiting this house since I came in.

Drill E. Response

MODEL: គ្រូ: ម្សិលមិញលោកទៅលេងឯណា? (មើលវាំងនឹងវិចិត្រសិល្បៈ)

Teacher: Where did you go yesterday? (to see the palace and the School of Fine Arts)

សិស្ស: បាទម្សិលមិញគេជូនខ្ញុំទៅមើលវាំងនឹងសាលាវិចិត្រសិល្បៈ។

Student: Yesterday they took me to see the palace and the School of Fine Arts.

1. ម្សិលមិញលោកទៅមើលអី? (មើលគេប្រណាំងទូក)
បាទ ម្សិលមិញគេជូនទៅមើលគេប្រណាំងទូក។

2. ម្សិលមិញលោកទៅណា? (មើលអង្គរ ហើយនាំគ្នាមកទិញអីវ៉ាន់វិញ)
បាទ ម្សិលមិញគេជូនទៅមើលអង្គរហើយនាំគ្នាមកទិញអីវ៉ាន់វិញ។

3. ម្សិលម្ងៃលោកធ្វើអី? (ថតរូបកំប្លែងផ្សេងៗ ហើយនឹងជិះកប៉ាល់មើលភ្នំពេញ)
បាទ ម្សិលម្ងៃគេជូនទៅថតរូបកំប្លែង ហើយនឹងជិះកប៉ាល់មើលភ្នំពេញ។

4. ថ្ងៃមុនលោបានទៅឃើញអី? (មើលក្រុងកំពង់ចាម នឹងចំការកៅស៊ូ)
បាទ ថ្ងៃមុនគេជូនខ្ញុំទៅមើលក្រុងកំពង់ចាម នឹងចំការកៅស៊ូ។

5. ស្អែកលោកគិតធ្វើអី? (ទៅវត្តភ្នំហើយនឹងដើរថតរូបលេង)
បាទស្អែកគេជូនខ្ញុំទៅវត្តភ្នំហើយនឹងដើរថតរូបលេង។

Drill F. Response

MODEL: គ្រូ: លោកបានអញ្ជើញទៅលេងសៀមរាបទេ? (នៅយូរ)

Teacher: Have you ever gone to visit Siem Reap? (stay a long time)

សិស្ស: បាទ ខ្ញុំទៅលេងហើយតែខ្ញុំស្ដាយណាស់មិនបាននៅយូរ។

Student: Yes, I have visited it, but I regret that I couldn't stay a long time.

1. លោកបានអញ្ជើញទៅលេងកែបទេ? (នៅយូរ)	បាទ ខ្ញុំទៅលេងហើយតែខ្ញុំស្តាយណាស់ដោយមិនបាននៅយូរ។
2. លោកបានអញ្ជើញទៅមើលកុនខ្មែរទេ? (មើលចប់)	បាទ ខ្ញុំទៅមើលហើយតែខ្ញុំស្តាយណាស់ដោយមិនបានមើលចប់។
3. លោកបានអញ្ជើញទៅជួបលោកស្នេហាទេ? (និយាយគ្នាយូរ)	បាទ ខ្ញុំបានទៅជួបហើយតែខ្ញុំស្តាយណាស់ដោយមិនបាននិយាយយូរ។
4. លោកបានអញ្ជើញទៅឃើញវិត្តព្រះកែវទេ? (មើលអស់)	បាទ ខ្ញុំបានទៅឃើញហើយតែខ្ញុំសាយណាស់ដោយមិនបានមើលអស់។
5. លោកបានអញ្ជើញទៅស្តាប់សមាជជាតិទេ? (នៅដល់ចប់ស្រួលបួល)	បាទ ខ្ញុំបានទៅស្តាប់ហើយតែខ្ញុំស្តាយណាស់ដោយមិនបាននៅដល់ចប់ស្រួលបួល។

Drill G. Transformation

MODEL:	គ្រូ: គាត់មកតែម្នាក់ឯងទេ។ (ជាមួយក្រុមទេសចរ)	Teacher:	Did he come alone? (with a group of tourists)
	សិស្ស: បាទ ទេ គាត់មិនមកតែម្នាក់ឯងទេ គាត់មកជាមួយក្រុមទេសចរ។	Student:	No, he didn't come alone. He came with a group of tourists.

1. លោកទៅបាត់ដំបងតែម្នាក់ឯងឬអី? (ជាមួយពួកម៉ាកខ្ញុំពីរនាក់)	បាទទេ ខ្ញុំមិនទៅបាត់ដំបងតែម្នាក់ឯងទេ ខ្ញុំទៅជាមួយពួកម៉ាកខ្ញុំពីរនាក់។
2. គាត់មកសហរដ្ឋតែម្នាក់ឯងឬ? (ជាមួយប្រពន្ធគាត់និងកូនបីនាក់)	បាទទេ គាត់មិនមកសហរដ្ឋតែម្នាក់ឯងទេ គាត់មកជាមួយប្រពន្ធគាត់និងកូនបីនាក់។
3. វាទៅតែម្នាក់ឯងទេឬ? (ជាមួយខ្ញុំ)	បាទទេ វាមិនទៅតែម្នាក់ឯងទេ វាទៅជាមួយខ្ញុំ។
4. លោកជិះឡាននេះតែម្នាក់ឯងទេឬ? (ជាមួយលោកសិត)	បាទទេ ខ្ញុំមិនជិះតែម្នាក់ឯងទេ ខ្ញុំជិះជាមួយលោកសិត។
5. លោកតាគាត់អញ្ជើញមកតែម្នាក់ឯងទេឬ? (ជាមួយចៅគាត់ម្នាក់)	បាទទេ គាត់មិនអញ្ជើញមកតែម្នាក់ឯងទេ គាត់មកជាមួយចៅគាត់ម្នាក់។

Drill H. Expansion

1.	ខ្ញុំទៅមើលអង្គរវត្ត។	I'm going to see Angkor Wat.
2.	ខ្ញុំទៅមើលអង្គរវត្តនៅប្រទេសកម្ពុជា។	I'm going to see Angkor Wat in Cambodia.
3.	ខ្ញុំទៅមើលអង្គរវត្តនៅប្រទេសកម្ពុជា តែខ្ញុំចង់ចុះនៅហុងកុង។	I'm going to see Angkor Wat in Cambodia, but I want to get off in Hong Kong.
4.	ខ្ញុំទៅមើលអង្គរវត្តនៅប្រទេសកម្ពុជា តែខ្ញុំចង់ចុះនៅហុងកុងពីរបីថ្ងៃ។	I'm going to see Angkor Wat in Cambodia, but I want to get off in Hong Kong for two or three days.
5.	ខ្ញុំទៅមើលអង្គរវត្តនៅប្រទេសកម្ពុជា តែខ្ញុំចង់ចុះនៅហុងកុងពីរបីថ្ងៃ ដើម្បីនឹងទិញប្រដាប់ថតរូបមួយ។	I'm going to see Angkor Wat in Cambodia, but I want to get off in Hong Kong for two or three days in order to buy a camera.
6.	ខ្ញុំទៅមើលអង្គរវត្តនៅប្រទេសកម្ពុជា តែខ្ញុំចង់ចុះនៅហុងកុងពីរបីថ្ងៃ ដើម្បីនឹងទិញប្រដាប់ថតរូបមួយ នឹងកាត់ខោអាវ។	I'm going to see Angkor Wat in Cambodia, but I want to get off in Hong Kong for two or three days in order to buy a camera and have some clothes made.
7.	ខ្ញុំទៅមើលអង្គរវត្តនៅប្រទេសកម្ពុជា តែខ្ញុំចង់ចុះនៅហុងកុងពីរបីថ្ងៃ ដើម្បីនឹងទិញប្រដាប់ថតរូបមួយ នឹងកាត់ខោអាវពណ៌ស។	I'm going to Angkor Wat in Cambodia, but I want to get off in Hong Kong for 2 or 3 days in order to buy a camera and have some white clothes made.
8.	ខ្ញុំទៅមើលអង្គរវត្តនៅប្រទេសកម្ពុជា តែខ្ញុំចង់ចុះនៅហុងកុងពីរបីថ្ងៃ ដើម្បីនឹងទិញប្រដាប់ថតរូបមួយ នឹងកាត់ខោអាវពណ៌សពីរប្រដាប់។	I'm going to Angkor Wat in Cambodia, but I want to get off in Hong Kong for 2 or 3 days in order to buy a camera and have two white suits made.

Drill I. Reduction

1.	ខ្ញុំទៅមើលអង្គរវត្តនៅប្រទេសកម្ពុជា តែខ្ញុំចង់ចុះនៅហុងកុងពីរបីថ្ងៃ ដើម្បីនឹងទិញប្រដាប់ថតរូបមួយ នឹងកាត់ខោអាវពណ៌សពីរប្រដាប់។	I'm going to Angkor Wat in Cambodia, but I want to get off in Hong Kong for 2 or 3 days in order to buy a camera and have two white suits made.
2.	ខ្ញុំទៅមើលអង្គរវត្តនៅប្រទេសកម្ពុជា តែខ្ញុំចង់ចុះនៅហុងកុងពីរបីថ្ងៃ ដើម្បីនឹងទិញប្រដាប់ថតរូបមួយ នឹងកាត់ខោអាវពណ៌ស។	I'm going to Angkor Wat in Cambodia, but I want to get off in Hong Kong for 2 or 3 days in order to buy a camera and have some white clothes made.
3.	ខ្ញុំទៅមើលអង្គរវត្តនៅប្រទេសកម្ពុជា	I'm going to see Angkor Wat in

	តែខ្ញុំចង់ចុះនៅហុងកុងពីរបីថ្ងៃ ដើម្បីនឹងទិញប្រដាប់ថតរូបមួយ និងកាត់ខោអាវ។	Cambodia, but I want to get off in Hong Kong for two or three days in order to buy a camera and have some clothes made.
4.	ខ្ញុំទៅមើលអង្គរវត្តនៅប្រទេសកម្ពុជា តែខ្ញុំចង់ចុះនៅហុងកុងពីរបីថ្ងៃ ដើម្បីនឹងទិញប្រដាប់ថតរូបមួយ។	I'm going to see Angkor Wat in Cambodia, but I want to get off in Hong Kong for two or three days in order to buy a camera.
5.	ខ្ញុំទៅមើលអង្គរវត្តនៅប្រទេសកម្ពុជា តែខ្ញុំចង់ចុះនៅហុងកុងពីរបីថ្ងៃ។	I'm going to see Angkor Wat in Cambodia, but I want to get off in Hong Kong for two or three days.
6.	ខ្ញុំទៅមើលអង្គរវត្តនៅប្រទេសកម្ពុជា តែខ្ញុំចង់ចុះនៅហុងកុង។	I'm going to see Angkor Wat in Cambodia, but I want to get off in Hong Kong.
7.	ខ្ញុំទៅមើលអង្គរវត្តនៅប្រទេសកម្ពុជា។	I'm going to see Angkor Wat in Cambodia.
8.	ខ្ញុំទៅមើលអង្គរវត្ត។	I'm going to see Angkor Wat.

UNIT 77

BASIC DIALOGUE

John

1. លោកសាន លោករវល់ទេស្អែក? បើលោកមិនរវល់ លោកទៅជួយទិញ អីវ៉ាន់ខ្ញុំមួយភ្លែតបានទេ?

Mr. San, are you busy tomorrow? If you're not busy can you go for a little while to help me buy some things?

San

2. បាទមិនអីទេ លោកចង់ទិញអីខ្លះ?

O. K. What do you want to buy?

John

3. ខ្ញុំចង់ទៅរកមើលគ្រឿងប្រាក់ ឬ កំណាត់សំពត់ខ្មែរ ផ្ញើទៅចងដៃប្អូនស្រី ខ្ញុំ ។

I want to go look for some silver or Cambodian cloth for a Cambodian sampot to send for the wedding of my younger sister.

San

4. អូ! គាត់ការអង្កាល់?

Oh, when's she getting married?

John

5. បាទ ខែក្រោយណេះ ។

Next month.

San

6. បើអញ្ចឹងយើងអាចទៅរកមើល បានទៅពីរបីកន្លែង ទៅផ្សារចាស់ ផ្សារ ថ្មី នឹងសណ្ឋាគារព្រះកុសុមៈ ។

In that case we can go to two or three places, to the Old Market, to the New Market, or the Kossamak Hotel.

John

7. លោកជួយគិតមើលត្រូវទិញអី?

Help me think of what to buy.

San

8. បាទ នេះពិបាកនិយាយណាស់ តែកាល ណាយើងទៅ លោកអាចឃើញរបស់ ច្រើន ហើយលោកមុខតែមិនពិបាក រើសទេ ។

That's very hard to say, but when we go you will be able to see a lot of things, and you won't have any difficulty in choosing.

John

9. ខ្ញុំឃើញគេទិញបានប្រអប់ប្រាក់
ល្អៗណាស់។

I've seen people buying very pretty silver boxes.

San

10. បាទ ជាងប្រាក់ខ្មែរគេចេះធ្វើ
ក្បាច់ល្អៗមែន។ គេធ្វើខ្សែក្រវាត់
ប្រាក់សម្រាប់ស្រីៗ ប្រអប់ដាក់ម្សៅ
លាបមុខ ខ្សែក និងបន្តោងមាសធ្វើ
ជារូបសត្វផ្សេងៗ ។

Yes, Cambodian silversmiths really know how to make beautiful designs. They make silver belts for women, powder boxes, necklaces and gold pendants in the shapes of various animals.

John

11. គេមានធ្វើរូបខ្មែរមានសំលៀក
បំពាក់ជាតិទេ?

Do they make Cambodian dolls dressed in the national dress?

San

12. បាទ មាន គេធ្វើអំពីកៅស៊ូក៏មាន
អំពីស្ពាន់ក៏មាន ហើយគេមានទាំង
ធ្វើរូបផ្សេងៗទៀតផងដូចជាក្រុមរបាំ
ព្រះរាជទ្រព្យ មានរូបអ្នករាំ រូប
អប្សរា និងប្រដាប់ប្រដាភ្លេងជាដើម។

They do. They make them out of rubber, and out of copper. They even make different kinds such as the Royal Ballet, with dancers, apsaras, and the musical instruments, for example.

John

13. របស់អស់នេះខ្ញុំអាចទិញចងដៃ
បាន។ ចុះសំពត់និងសារុងមានបែប
ណាខ្លះ?

I can buy all these things for a wedding. As for sampots and sarongs, what kinds are there?

San

14. បាទ របៀបណាក៏មានដែរ។មាន
សំពត់ហូល សំពត់ផាមួង និងក្រមា
តូចសឹងតែគ្រប់ពណ៌។ របស់ទាំងនេះ
សុទ្ធតែធ្វើអំពីសូត្រ។ បើលោកចង់
ទិញក្រវាត់ឲ្យពួកម៉ាកលោក គេ
មានលក់ដែរ។ ក្រវាត់នោះធ្វើអំពី
សូត្រល្អៗណាស់។

There are all kinds. There are somput houl, somput promuang, and small kramas in almost every color. All these things are made out of silk. If you want to buy ties for your friends, they have them for sale too. The ties are made of pretty silk.

John

15. គេធ្វើរបស់អស់នេះនៅឯណា?

Where do they make all these things?

San

16. បាទ មានជាងឯកជនច្រើនគេរក
ស៊ីតាមនេះ ហើយសាលាវិជ្ជាសិល្បៈក៏មាន
ធ្វើច្រើនដែរ។

There are a lot of private artisans who make a living this way, and the School of Fine Arts also makes a lot.

John

17. នេះធ្វើឲ្យខ្ញុំចាំសឹងតែមិនបាន។
ខ្ញុំចង់ទៅឃើញភ្លាម។

I can hardly wait. I want to go see right away.

San

18. មិនអីទេលោក ថ្ងៃស្អែក
ម៉ោង១០ លោកមកជួបខ្ញុំចុះ!

All right. Tomorrow morning at ten o'clock come meet me.

John

19. បាទ អញ្ចឹងខ្ញុំលាសិនហើយ។
ថ្ងៃស្អែកយើងនឹងជួបគ្នា។

O.K. I'll say goodbye now, and tomorrow we'll meet.

DRILLS

Drill A. Response

MODEL:	គ្រូ: ថ្ងៃស្អែកលោកទៅជួយទិញអីវ៉ាន់ខ្ញុំមួយភ្លែតបានទេ? (ចេញទៅក្រៅក្រុង)	**Teacher:** Can you help me go shopping for a while tomorrow? (go out of town)
	សិស្ស: អូ សុំទោស ថ្ងៃស្អែកហ្នឹងខ្ញុំមិននៅផ្ទះទេ ខ្ញុំត្រូវចេញទៅក្រៅក្រុង។	**Student:** Excuse me, tomorrow I won't be home. I have to go out of town.
1.	អាទិត្យក្រោយលោកទៅជួយធ្វើការខ្ញុំពីរបីម៉ោងបានទេ? (ទៅទីក្រុងព្រៃវែង១អាទិត្យ)	អូ សុំទោស អាទិត្យក្រោយខ្ញុំមិននៅផ្ទះទេ ខ្ញុំត្រូវទៅទីក្រុងព្រៃវែង១អាទិត្យ។
2.	ថ្ងៃស្អែកលោកទៅលេងផ្ទះខ្ញុំបានទេ? (ទៅចាំទទួលប្រពន្ធខ្ញុំនៅកំពង់សោម)	អូ សុំទោស ថ្ងៃស្អែកហ្នឹងខ្ញុំមិននៅផ្ទះទេ ខ្ញុំត្រូវទៅចាំទទួលប្រពន្ធខ្ញុំនៅកំពង់សោម។
3.	ថ្ងៃសៅរ៍ហ្នឹងលោកជួយទៅរកជួលផ្ទះខ្ញុំមួយភ្លែតបានទេ? (ទៅជួបពេទ្យធ្មេញខ្ញុំ)	អូ សុំទោស ថ្ងៃសៅរ៍ហ្នឹងខ្ញុំមិននៅផ្ទះទេ ខ្ញុំត្រូវទៅជួបពេទ្យធ្មេញខ្ញុំ។
4.	ខែក្រោយលោកមកជួបខ្ញុំទៀតបានទេ? (ចេញទៅបង្រៀននៅស្រុកខ្មែរ)	អូ សុំទោស ខែក្រោយហ្នឹងខ្ញុំមិននៅផ្ទះទេ ខ្ញុំទៅបង្រៀននៅស្រុកខ្មែរ។
5.	ល្ងាចថ្ងៃសុក្រលោកទៅបាយផ្ទះខ្ញុំបានទេ? (ទៅជុំនុំ)	អូ សុំទោស ល្ងាចថ្ងៃសុក្រហ្នឹងមិននៅផ្ទះទេ ខ្ញុំត្រូវទៅជុំនុំ។

Drill B. Response

MODEL:	គ្រូ: គាត់ចង់ទៅទិញអី? (ទិញគ្រឿងប្រាក់និងកំណាត់សំពត់ខ្មែរ)	**Teacher:** What does he want to go buy? (buy silver and Cambodian sampots)
	សិស្ស: បាទ គាត់ទៅទិញគ្រឿងប្រាក់និងកំណាត់សំពត់ខ្មែរ។	**Student:** He wants to go buy silver and Cambodian sampots.
1.	វ៉ាទៅធ្វើអី? (មើលល្ខោនព្រះរាជទ្រព្យ)	បាទ វ៉ាទៅមើលល្ខោនព្រះរាជទ្រព្យ។
2.	លោកចង់ទៅមើលអី? (មើលផ្សារ វាំង និង វត្តភ្នំ)	បាទ លោកចង់ទៅមើលផ្សារ វាំង និង វត្តភ្នំ។
3.	គាត់ចូលចិត្តធ្វើអី? (លេងបាល់និងហែលទឹក)	បាទ គាត់ចូលចិត្តលេងបាល់និងហែលទឹក។

4.	វានិយាយរឿងអ្វី? (អំពីការធ្វើដំណើរទៅអង្គរវត្ត)	បាទ វានិយាយអំពីការធ្វើដំណើរទៅអង្គរវត្ត។
5.	លោកគិតធ្វើអ្វី? (ទៅលេងមុខវាំងហើយទៅមើលកុន)	បាទ លោក (ខ្ញុំ) គិតទៅលេងមុខវាំងហើយទៅមើលកុន។

Drill C. Response

MODEL:	គ្រូ: លោកដឹងទេ កន្លែងលក់គ្រឿងប្រាក់នៅឯណា? (ផ្សារចាស់ជិតវាំង)	Teacher: Do you know where the place they sell silver is? (Old Market near the palace)
	សិស្ស: បាទ កន្លែងលក់ប្រាក់នៅផ្សារចាស់ជិតវាំង។	Student: The place where they sell silver is at the Old Market near the palace.
1.	លោកដឹងទេ ផ្ទះជួសជុលវិទ្យុនៅឯណា? (ជិតផ្សារថ្មី)	បាទ ផ្ទះជួសជុលវិទ្យុនៅជិតផ្សារថ្មី។
2.	លោកដឹងទេ ក្រសួងឃោសនាការនៅឯណា? (ជិតវត្តភ្នំ)	បាទ ក្រសួងឃោសនាការនៅជិតវត្តភ្នំ។
3.	លោកដឹងទេ លោករដ្ឋហា ធ្វើការនៅឯណា? (ក្រសួងការបរទេស)	បាទ លោករដ្ឋហា ធ្វើការនៅក្រសួងការបរទេស។
4.	លោកស្រីដឹងទេ បន្ទប់លោកស្មិតនៅឯណា? (ជាន់ទី៧ លេខ១១)	ចា៎ បន្ទប់លោកស្មិតនៅជាន់ទី៧ លេខ ១១។
5.	លោកដឹងទេ ធម្មតាគេទៅលេងឯណាថ្ងៃអាទិត្យ។ (វត្តភ្នំ, មុខវាំង ឬចេញទៅក្រៅទីក្រុង)	បាទ ធម្មតា គេទៅលេងវត្តភ្នំ មុខវាំង ឬចេញទៅក្រៅទីក្រុង។

Drill D. Transformation

MODEL:	គ្រូ: គេលក់ខ្សែក្រវាត់ប្រាក់សំរាប់ស្រីៗ ប្រអប់ដាក់ម្សៅលាបមុខ ខ្សែក បន្តោងមាស។	Teacher: They sell silver belts for women, powder boxes, necklaces, and gold pendants.
	សិស្ស: ក្រៅពីបន្តោងមាស លោកស្រីអាចទិញខ្សែក្រវាត់ប្រាក់សំរាប់ស្រីៗ ប្រអប់ដាក់ម្សៅលាបមុខ និងខ្សែក។	Student: Besides gold pendants, you can buy silver belts for women, powder boxes and necklaces.
1.	គេលក់រូបសម្ភារធ្វើអំពីស្ពាន់ គ្រឿងក្លួងរឹង និងកំណាត់សំពត់សូត្រ។	ក្រៅពីកំណាត់សំពត់សូត្រ លោកស្រីអាចទិញរូបសម្ភារធ្វើអំពីស្ពាន់ និងគ្រឿង

		គ្រឿងកែវ។
2.	គេធ្វើរូបចម្លាក់នឹងវត្ថុចម្លាក់យ៉ាងល្អ ហើយនឹងរូបសត្វផ្សេងៗធ្វើអំពីកែវ។	ក្រៅពីរូបសត្វផ្សេងៗធ្វើអំពីកែវ លោកស្រីអាចទិញរូបចម្លាក់នឹងវត្ថុចម្លាក់យ៉ាងល្អ។
3.	គេមានសារុងសូត្រ ចានប្រាក់នឹងប្រអប់ប្រាក់មានរាងជាសត្វផ្សេងៗ។	ក្រៅពីប្រអប់ប្រាក់មានរាងផ្សេងៗ លោកស្រីអាចទិញសារុងសូត្រនឹងចានប្រាក់។
4.	នៅផ្សារថ្មី គេលក់តាំងពីគ្រឿងឈើ ម្ហូបអាហារ ទៅដល់គ្រឿងស្លៀកពាក់។	ក្រៅពីគ្រឿងស្លៀកពាក់ លោកស្រីអាចទិញគ្រឿងឈើ នឹងម្ហូបអាហារ។
5.	គេលក់ខោអាវ ប្រដាប់ប្រដា កូនសិស្ស វត្ថុក្រដាស នឹងគ្រឿងម៉ាស៊ីន។	ក្រៅពីគ្រឿងម៉ាស៊ីន លោកស្រីអាចទិញខោអាវ ប្រដាប់ប្រដា កូនសិស្ស នឹងវត្ថុក្រដាស។

Drill E. Substitution

1.	របស់អស់នេះខ្ញុំទិញឯប្រទេសកម្ពុជា។	I bought all these things in Cambodia.
2.	តុនឹងទូនេះខ្ញុំទិញឯប្រទេសកម្ពុជា។	I bought this table and wardrobe in Cambodia.
3.	ក្រវាត់នេះខ្ញុំទិញឯប្រទេសកម្ពុជា។	I bought this tie in Cambodia.
4.	សារុងនេះខ្ញុំទិញឯប្រទេសកម្ពុជា។	I bought this sarong in Cambodia.
5.	សារុងនេះគេធ្វើនៅប្រទេសកម្ពុជា។	This sarong was made in Cambodia.
6.	រូបចម្លាក់នេះគេធ្វើនៅប្រទេសកម្ពុជា។	This sculpture was made in Cambodia.
7.	ឡានម៉ាក អង្គរ នេះគេធ្វើនៅប្រទេសកម្ពុជា។	This Angkor automobile was made in Cambodia.
8.	កៅអីនេះគេធ្វើនៅប្រទេសកម្ពុជា។	This chair was made in Cambodia.

Drill F. Multiple Substitution

1.	ខ្ញុំចង់ទៅផ្សារម៉ោងពីរ ដើម្បីរកទិញអាវមួយ។	I want to go to the market for an hour or two to try to find a shirt.
2.	ខ្ញុំចង់ទៅផ្ទះកាត់ខោអាវ ដើម្បីកាត់អាវមួយ។	I want to go to the tailor shop for an hour or two to have a shirt made.
3.	ខ្ញុំចង់ទៅផ្ទះលក់គ្រឿងប្រាក់ដើម្បីទិញប្រអប់ម្សៅមួយឲ្យប្រពន្ធខ្ញុំ។	I want to go to the silver shop for an hour or two to buy a powder box for my wife.
4.	ខ្ញុំចង់ទៅផ្សារថ្មី ដើម្បីទិញខ្សែកមួយឲ្យបងស្រីខ្ញុំ។	I want to go to the New Market for an hour or two to buy a necklace for my older sister.
5.	ខ្ញុំចង់ទៅស្ថានទូតខ្មែរដើម្បីសុំវីសាឲ្យប្រពន្ធខ្ញុំ។	I want to go to the Cambodian Embassy for an hour or two to get a visa for my wife.
6.	ខ្ញុំចង់ទៅសាលាបង្រៀនភាសាដើម្បីចុះឈ្មោះឲ្យប្រពន្ធខ្ញុំ។	I want to go to the language school for an hour or two to register my wife's name.
7.	ខ្ញុំចង់ទៅក្រសួងការបរទេស ដើម្បីទៅជួបលោករដ្ឋមន្ត្រី។	I want to go to the Foreign Ministry for an hour or two to meet the Minister.

Drill G. Variable Multiple Substitution

1.	សំពត់ទាំងអស់សុទ្ធតែធ្វើអំពីសូត្រ។	All the sampots are made of silk.
2.	អាវទាំងអស់សុទ្ធតែធ្វើអំពីកប្បាស។	All the shirts are made of cotton.
3.	អាវទាំងអស់សុទ្ធតែធ្វើពីសូត្រនិងកប្បាស។	All the shirts are made of silk and cotton.
4.	កំណាត់ដែលខ្ញុំឃើញសុទ្ធតែធ្វើពីសូត្រនិងកប្បាស។	The cloth I saw is made of silk and cotton.
5.	កំណាត់ដែលខ្ញុំឃើញសុទ្ធតែធ្វើពីនីឡុង។	The cloth I saw is made of nylon.
6.	ខ្ញុំចង់ទិញកង់ឡានធ្វើពីនីឡុង។	I want to buy tires made of nylon.
7.	ខ្ញុំចង់ទិញកង់ឡានថ្មីពីរ ធ្វើពីនីឡុង។	I want to buy two new tires made of nylon.
8.	ខ្ញុំចង់ទិញខោថ្មីពីរ ធ្វើពីនីឡុង។	I want to buy two pair of new pants made of nylon.
9.	ខ្ញុំទើបទិញបានខោថ្មីពីរ ធ្វើពីនីឡុង។	I just bought two pair of new pants made of nylon.

Drill H. Expansion

1.	ស្អែកលោកមកជួបខ្ញុំ។	Come meet me tomorrow.
2.	ស្អែកសុំលោកមកជួបខ្ញុំ។	Please come meet me tomorrow.
3.	ស្អែកសុំលោកមកជួបខ្ញុំម៉ោងដប់។	Please come meet me tomorrow at 10 o'clock.
4.	ស្អែកសុំលោកមកជួបខ្ញុំម៉ោងដប់ព្រឹក។	Please come meet me tomorrow at 10 o'clock in the morning.
5.	ស្អែកសុំលោកមកជួបខ្ញុំម៉ោងដប់ព្រឹករួចយើងទៅញ៉ាំកាហ្វេ។	Please come meet me tomorrow at 10 o'clock in the morning; then we'll go drink coffee.
6.	ស្អែកសុំលោកមកជួបខ្ញុំម៉ោងដប់ព្រឹករួចទៅញ៉ាំកាហ្វេនៅអូតែលមនោរម្យ។	Please come meet me tomorrow at 10 o'clock in the morning; then we'll go drink coffee at the Hotel Monorom.
7.	ស្អែកសុំលោកមកជួបខ្ញុំម៉ោងដប់ព្រឹករួចយើងទៅញ៉ាំកាហ្វេនៅអូតែលមនោរម្យហើយចាំយើងទៅមើលសាលារៀនឯកជន។	Please come meet me tomorrow at 10 o'clock in the morning; then we'll go drink coffee at the Hotel Monorom, and remember, we'll go see a private school.
8.	ស្អែកសុំលោកមកជួបខ្ញុំម៉ោងដប់ព្រឹករួចយើងទៅញ៉ាំកាហ្វេនៅអូតែលមនោរម្យហើយចាំយើងទៅមើលសាលាឯកជននិងសាលាវិចិត្រសិល្បៈ។	Please come meet me tomorrow at 10 o'clock in the morning; then we'll go drink coffee at the Hotel Monorom, and remember, we'll go see a private school and the School of Fine Arts.

Drill I. Reduction

1.	ស្អែកសុំលោកមកជួបខ្ញុំម៉ោងដប់ព្រឹករួចយើងទៅញ៉ាំកាហ្វេនៅអូតែលមនោរម្យហើយចាំយើងទៅមើលសាលាឯកជននិងសាលាវិចិត្រសិល្បៈ។	Please come meet me tomorrow at 10 o'clock in the morning; then we'll go drink coffee at the Hotel Monorom, and remember, we'll go see a private school and the School of Fine Arts.
2.	ស្អែកសុំលោកមកជួបខ្ញុំម៉ោងដប់ព្រឹករួចយើងទៅញ៉ាំកាហ្វេនៅអូតែលមនោរម្យហើយចាំយើងទៅមើលសាលារៀនឯកជន។	Please come meet me tomorrow at 10 o'clock in the morning; then we'll go drink coffee at the Hotel Monorom, and remember, we'll go see a private school.
3.	ស្អែកសុំលោកមកជួបខ្ញុំម៉ោងដប់ព្រឹករួចយើងទៅញ៉ាំកាហ្វេនៅអូតែលមនោរម្យ។	Please come meet me tomorrow at 10 o'clock in the morning; then we'll go drink coffee at the Hotel Monorom.
4.	ស្អែកសុំលោកមកជួបខ្ញុំម៉ោងដប់ព្រឹករួចយើងទៅញ៉ាំកាហ្វេ។	Please come meet me tomorrow at 10 o'clock in the morning; then we'll go drink coffee.
5.	ស្អែកសុំលោកមកជួបខ្ញុំម៉ោង១០ព្រឹក។	Please come meet me tomorrow at 10 o'clock in the morning.
6.	ស្អែកសុំលោកមកជួបខ្ញុំម៉ោង១០។	Please come meet me tomorrow at 10 o'clock.
7.	ស្អែកសុំលោកមកជួបខ្ញុំ។	Please come meet me tomorrow.
8.	ស្អែកលោកមកជួបខ្ញុំ។	Come meet me tomorrow.

UNIT 78

BASIC DIALOGUE

John

1. ជំរាបសួរលោកគន លោកអញ្ជើញមកដល់វ៉ាស៊ីនតោន ពីអង្កាល់?

Hello, Kon. When did you arrive in Washington?

Kon

2. បាទ ខ្ញុំមកដល់ពីម្សិលមិញ។

I arrived yesterday.

John

3. សុំលោកប្រាប់ខ្ញុំមើល មានអ្វីប្លែកខ្លះនៅភ្នំពេញ?

Tell me, is there anything new in Phnom Penh?

Kon

4. អូ ឥឡូវនេះបើលោកអញ្ជើញទៅឃើញភ្នំពេញ លោកមុខតែភ្ញាក់មិនខាន។ គេបង្កើតផ្លូវថ្មីៗស្អាតណាស់ហើយទីក្រុងក៏កាន់តែរីកធំឡើង។

Now if you went to see Phnom Penh you'd certainly be surprised. They built new roads that are very good and the city is getting bigger and bigger.

John

5. ខ្ញុំឃើញរូបថតមហាវិទ្យាល័យស្អាតណាស់។

I've seen pictures of pretty universities.

Kon

6. បាទ តាំងពីខ្មែរបានឯករាជមក គេខំសង់សាលារៀនច្រើនណាស់ ហើយឥឡូវនេះ គេមានសាលាចង់ច្រើនជាងគ្រូផង។

Yes, since the Cambodians got their independence they have tried to build many schools and now they have almost more schools than teachers.

John

7. ចុះរោងចក្រផ្សេងៗ គេបានបង្កើតបានយ៉ាងណាទៅ?

As for the various factories, how have they been established?

Kon

8. បាទ ខាងឧស្សាហកម្មនេះ ស្រុកខ្មែរឥឡូវ បានលូតលាស់ខ្លាំងណាស់។ គេមានរោងចក្រធ្វើគ្រឿងបរិភោគនិងធ្វើប្រដាប់ប្រដា ដ៏ចាំបាច់ផ្សេងៗទៀត។

In industry Cambodia is growing very strong. They have factories which make foodstuffs and make various necessary tools.

John

9. កាលខ្ញុំចេញពីភ្នំពេញ គេមានរោងចក្រស៊ីម៉ង់ត៍ រោងចក្រធ្វើបន្ទះក្ដារ រោងចក្រធ្វើក្រដាស់ និងរោងចក្រអាររណឈើ។

When I left Phnom Penh they had a cement factory, a plywood factory, a paper factory and sawmills.

Kon

10. បាទ ឥឡូវនេះចំនួនរោងចក្របានកើនឡើងច្រើនណាស់។ គេធ្វើស្រា ធ្វើឡាប៊ីយែរ ធ្វើម្ហូបកំប៉ុង ធ្វើចានឆ្នាំង រហូតដល់ ដំឡើងម៉ាស៊ីន និងតួឡាន ឬត្រាក់ទ័រ ធ្វើកង់ឡាន និងចម្រាញ់ប្រេងកាត ប្រេងសាំងផង។

Now the number of factories is increasing very much. They make alcohol, beer, canned food, and chinaware. They also assemble automobile and tractor bodies, make automobile tires, and refine kerosene and gasoline.

John

11. នេះគួរឲ្យកោតសរសើរណាស់។ លោកដឹងទេ ក្នុងចំណោមរោងចក្រទាំងអស់មានប៉ុន្មាន ជាជំនួយបរទេស?

This is really praiseworthy. Do you know how many of all these factories come from foreign aid?

Kon

12. រោងចក្រទាំងអស់សព្វថ្ងៃនេះ មាន ៣៣ ។ ក្នុងចំនួននេះ មួយភាគបី ជាជំនួយបរទេស ក្រៅពីនោះជារោងចក្ររបស់ជាតិ ឬរបស់ឯកជន។

At present all the factories number 33. Of this number a third come from foreign aid. Aside from this there are state factories and private factories.

John

13. រោងចក្រដែលជាជំនួយបរទេស គេធ្វើឲ្យទទេ ឬយ៉ាងណា?

The factories which come from foreign aid: were they given without strings, or what?

Kon

14. ជំនួយបរទេសនេះមិនមែនមានន័យថា គេឲ្យរបស់ទទេទាំងអស់ទេ គឺគេជួយឲ្យខ្ចីលុយដោយយកការតិច គេលក់គ្រឿងម៉ាស៊ីនឲ្យថោក ឬគេឲ្យអ្នកបច្ចេកទេសមកជួយមើលការ។

Foreign aid doesn't mean that they give things without strings. That is, they help by loaning money with low interest, they sell equipment cheaply, or they send technicians to help supervise the work.

John

15. ដំណឹងទាំងអស់នេះធ្វើឲ្យខ្ញុំនឹកទៅភ្នំពេញ ណាស់។ កាលណាខ្ញុំបានផ្លាស់ទៅជិតៗ ប្រទេសកម្ពុជា ខ្ញុំនឹងទៅជួបមិត្តសំឡាញ់ ឯទៀតនៅភ្នំពេញ។	All this news makes me long to go to Phnom Penh. When I am transferred near Cambodia, I'll go meet other friends in Phnom Penh.

DRILLS

Drill A. Substitution

1.	នៅភ្នំពេញគេពង្រីកផ្លូវធំៗហើយស្អាតផង។	In Phnom Penh they are expanding the streets, and they are clean too.
2.	នៅភ្នំពេញគេឃើញផ្លូវធំៗ ហើយស្អាតផង។	In Phnom Penh they see the large streets, and they are clean too.
3.	នៅភ្នំពេញគេធ្វើផ្លូវធំៗ ហើយស្អាតផង។	In Phnom Penh they are making streets, and they are clean too.
4.	នៅភ្នំពេញគេមានផ្លូវធំៗ ហើយស្អាតផង។	In Phnom Penh they have large streets, and they are clean too.
5.	នៅភ្នំពេញខ្ញុំជិះស៊ីក្លូតាមផ្លូវធំៗហើយស្អាតផង។	In Phnom Penh I take a cyclo along large streets, and they are clean too.
6.	នៅភ្នំពេញខ្ញុំដើរលេងតាមផ្លូវធំៗហើយស្អាតផង។	In Phnom Penh I go for a walk on the large streets, and they are clean too.
7.	នៅភ្នំពេញគេដាំផ្កាតាមផ្លូវធំៗហើយស្អាតផង។	In Phnom Penh they plant flowers along the large streets, and they are clean too.
8.	នៅភ្នំពេញខ្ញុំបើកឡានតាមផ្លូវធំៗហើយស្អាតផង។	In Phnom Penh I drive along large streets, and they are clean too.

Drill B. Substitution

1.	ឥឡូវប្រទេសកម្ពុជាមានសាលារៀនគ្រប់គ្រាន់ហើយ។	Now Cambodia has sufficient schools.
2.	ឥឡូវនៅប្រទេសកម្ពុជាមានរោងចក្រជាច្រើន។	Now Cambodia has a lot of factories.
3.	ឥឡូវនៅប្រទេសកម្ពុជាមានផ្លូវធំៗជាច្រើន។	Now Cambodia has a lot of large roads.
4.	ឥឡូវនៅគ្រប់ខេត្តមានមានផ្លូវធំៗជាច្រើន។	Now every province has a lot of large roads.
5.	ឥឡូវនៅគ្រប់ខេត្តមានវាលយន្តហោះមួយ។	Now every province has one airfield.
6.	ឥឡូវនៅគ្រប់ខេត្តមានវិទ្យាល័យមួយយ៉ាងតិច។	Now every province has one lycée at least.
7.	ឥឡូវនៅគ្រប់ខេត្តមានសាកលវិទ្យាល័យ។	Now every province has one university.

Drill C. Double Substitution

1.	កាលខ្ញុំទៅលេងស្រុកខ្មែរ ខ្ញុំបានទៅមើលចំការកៅស៊ូនិងរោងចក្រធ្វើកង់ឡាន។	When I went to visit Cambodia, I went to see the rubber plantations and the tire factory.
2.	កាលខ្ញុំនៅស្រុកខ្មែរ ខ្ញុំបានទៅមើលចំការកៅស៊ូនិងរោងចក្រធ្វើកង់ឡាន។	When I was in Cambodia I went to look at the rubber plantations and the tire factory.
3.	កាលខ្ញុំនៅភ្នំពេញ ខ្ញុំបានទៅរៀនខ្មែរ និងបង្រៀនអង់គ្លេស។	When I was in Phnom Penh I studied Cambodian and taught English.
4.	កាលខ្ញុំនៅភ្នំពេញ ខ្ញុំបានទៅមើលវាំង និងទៅលេងអង្គរ។	When I was in Phnom Penh I went to see the palace and visited Angkor.
5.	កាលខ្ញុំនៅភ្នំពេញ ខ្ញុំបានធ្វើការនៅស្ថានទូត និងបង្រៀននៅវិទ្យាល័យ។	When I was in Phnom Penh I worked in the embassy and taught in the lycée.
6.	កាលខ្ញុំនៅវ៉ាស៊ីនតោន ខ្ញុំធ្វើការនៅស្ថានទូត និងរៀននៅសាកលវិទ្យាល័យ។	When I was in Washington I worked in the embassy and studied at the university.
7.	កាលខ្ញុំនៅវ៉ាស៊ីនតោន ខ្ញុំបានទៅធ្វើការផង និងទៅរៀនផង។	When I was in Washington I worked and studied as well.

Drill D. Substitution

1.	ក្នុងក្រសួងមួយៗមានអ្នកធ្វើការច្រើន។	In every ministry there are a lot of workers.
2.	ក្នុងរោងចក្រមួយៗមានកម្មករច្រើន។	In every factory there are a lot of workers.
3.	ក្នុងសាលារៀនមួយៗមានកូនសិស្សច្រើន។	In every school there are a lot of students.
4.	ក្នុងមន្ទីរពេទ្យមួយៗមានវេជ្ជបណ្ឌិតច្រើន។	In every school there are a lot of doctors.
5.	ក្នុងបន្ទាយទាហានមួយៗមានកាំភ្លើងច្រើន។	In every barracks there are a lot of guns.
6.	ក្នុងចំណតរថយន្តមួយៗមានអ្នកធ្វើដំណើរច្រើន។	In every bus station there are a lot of travellers.
7.	ក្នុងបណ្ណាល័យមួយៗមានសៀវភៅច្រើន។	In every library there are a lot of books.
8.	ក្នុងបន្ទប់មួយៗមានមនុស្សច្រើន។	In every room there are a lot of people.

Drill E. Response

MODEL:	គ្រូ: ក្រោយបានឯករាជមក គេឃើញអីប្លែកនៅស្រុកខ្មែរ? (សាលារៀន រោងចក្រ និងមន្ទីរពេទ្យច្រើន)	Teacher:	After getting independence, was anything strange seen in Cambodia? (schools, factories, and hospitals)
	សិស្ស: ក្រោយបានឯករាជមក គេឃើញសាលារៀន រោងចក្រ	Student:	After getting independence, they saw schools, factories, and hospitals.

និងមន្ទីរពេទ្យច្រើន។

1. ក្រោយបានឯករាជមក គេបង្កើតឲ្យមានអ្វីនៅស្រុកខ្មែរ? (ចលនាយុវជនរាជសង្គមនិយមខ្មែរ)	ក្រោយបានឯករាជមក គេបង្កើតឲ្យមានចលនាយុវជនរាជសង្គមនិយមខ្មែរ។
2. ក្រោយពីបានឯករាជមក គេសង់បានអ្វីខ្លះពីភ្នំពេញទៅកំពង់សោម? (ផ្លូវរទេះភ្លើងនិងផ្លូវថ្នល់ធំៗ)	ក្រោយពីបានឯករាជមក គេសង់បានផ្លូវរទេះភ្លើងនិងផ្លូវធំៗ។
3. ក្រោយពីបានឯករាជមក គេសង់បានវិមានអ្វីខ្លះនៅភ្នំពេញ? (វិមានឯករាជ)	ក្រោយពីបានឯករាជមក សង់បានវិមានឯករាជ។
4. ក្រោយពីបានទៅដល់សៀមរាប គេនាំគ្នាធ្វើអី? (ទៅមើលអង្គរ)	ក្រោយពីបានទៅដល់សៀមរាប គេនាំគ្នាទៅមើលអង្គរ។
5. ក្រោយពីបានទៅឃើញភ្នំពេញ លោកយល់យ៉ាងម៉េច? (ជាទីក្រុងមួយស្អាតណាស់នៅអាស៊ី)	ក្រោយពីបានទៅឃើញភ្នំពេញ ខ្ញុំយល់ថាជាទីក្រុងមួយស្អាតណាស់នៅអាស៊ី។

Drill F. Response

MODEL:	គ្រូ: ឥឡូវគេមានរោងចក្រធ្វើអ្វីខ្លះ? (ធ្វើស៊ីម៉ង់ បន្ទះក្ដារ ស្រានិងម្ហូបកំប៉ុង)	Teacher: Now what things do the factories make? (make cement, plywood, liquor and canned foods)
	សិស្ស: បាទ ឥឡូវគេមានរោងចក្រធ្វើស៊ីម៉ង់ បន្ទះក្ដារ ស្រានិងម្ហូបកំប៉ុង។	Student: Now they have factories that make cement, plywood, liquor and canned foods.

1. ឥឡូវគេមានម៉ាស៊ីនធ្វើអ្វីខ្លះ? (អាររឈើ ធ្វើក្រដាស ត្បាញនិងមូរបារី)	បាទ ឥឡូវគេមានម៉ាស៊ីនអាររឈើ ធ្វើក្រដាស ត្បាញនិងមូរបារី។
2. ឥឡូវគេមាន[illegible]ធ្វើអ្វីខ្លះ? (ថតរូប និងផ្ដិតរូបថត)	បាទ ឥឡូវមាន[illegible]ថតរូបនិងផ្ដិតរូបថត។
3. ឥឡូវគេមានអ្នកធ្វើការអ្វីខ្លះ? (គ្រឿងម៉ាស៊ីន សាងឡាន និងលក់ឡាន)	បាទ ឥឡូវមានអ្នកធ្វើការខាងគ្រឿងម៉ាស៊ីន សាងឡាន និងលក់ឡាន។
4. ឥឡូវគេមានសាលារៀនខាងមុខវិជ្ជាអ្វីខ្លះ? (វិស្វកម្ម កសិកម្ម និងវិជ្ជាបច្ចេកទេស)	បាទ ឥឡូវមានសាលារៀនខាងវិស្វកម្ម កសិកម្ម និងវិជ្ជាបច្ចេកទេស។
5. ឥឡូវនេះគេមានរទេះភ្លើងទៅឯណាខ្លះ? (បាត់ដំបង និងកំពង់សោម)	បាទ ឥឡូវមានរទេះភ្លើងទៅបាត់ដំបង និងកំពង់សោម។

Drill G. Response

MODEL:	គ្រូ : គេធ្វើអ្វីទៀតទេ ក្រៅពីធ្វើកែវ? (ធ្វើចាននឹង ថូផ្កា)	**Teacher:** Do they make anything besides glasses? (dishes and vases)
	សិស្ស: បាទ ក្រៅពីធ្វើកែវ គេធ្វើចាននឹង ថូផ្កាដែរ។	**Student:** Besides (making) glasses they make dishes and vases too.
1.	គេធ្វើអ្វីទៀតទេ ក្រៅពីធ្វើកង់ឡាន? (ធ្វើកង់ធម្មតា និងពោះវៀនកង់)	បាទ ក្រៅពីធ្វើកង់ឡាន គេធ្វើកង់ធម្មតានិង ពោះវៀនកង់។
2.	គេធ្វើអ្វីទៀតទេ ក្រៅពីដំឡើងត្រាក់ទ័រ? (ដំឡើងម៉ាស៊ីនឡាន តួឡាន និងតួម៉ូតូ)	បាទ ក្រៅពីដំឡើងត្រាក់ទ័រ គេដំឡើង ម៉ាស៊ីនឡាន តួឡាន និងតួម៉ូតូ ។
3.	គេធ្វើអ្វីទៀតទេ ក្រៅពីធ្វើម្ហូបកំប៉ុង? (ធ្វើស្រា និងឡាប៊ីយែរ)	បាទ ក្រៅពីធ្វើម្ហូបកំប៉ុង គេធ្វើស្រានិង ឡាប៊ីយែរ។
4.	គេរៀនអ្វីទៀតទេ ក្រៅពីរៀនខ្មែរ? (រៀនបារាំង ជប៉ុន និងភូមា)	បាទ ក្រៅពីរៀនខ្មែរ គេរៀនបារាំង ជប៉ុន និងភូមា។
5.	គេទៅណាទៀតទេ ក្រៅពីទៅមើលវាំង? (ទៅទិញអីវ៉ាន់ និងទិញផ្លែឈើនៅផ្សារថ្មី)	បាទ ក្រៅពីទៅមើលវាំង គេទៅទិញ អីវ៉ាន់ និងទិញផ្លែឈើនៅផ្សារថ្មី។

Drill H. Expansion with Substitution

MODEL:	គ្រូ: តាមលោកស្មានគេធ្វើរោងចក្រនោះហើយអង្កាល់? (ចាប់ធ្វើការ)	**Teacher:** When do you think they'll build that factory? (start to work)
	សិស្ស: ហើយគេនឹងចាប់ធ្វើការខែណា?	**Student:** And what month will they start to work?
1.	តាមលោកស្មានគេធ្វើផ្លូវនោះហើយអង្កាល់? (អាចប្រើបាន)	ហើយគេអាចប្រើបានខែណា?
2.	តាមលោកស្មានគេធ្វើសាលារៀននោះហើយអង្កាល់? (បើកឲ្យរៀននៅ)	ហើយគេបើកឲ្យរៀននៅខែណា?
3.	តាមលោកស្មានគេធ្វើផ្លូវនោះហើយអង្កាល់? (បើកឲ្យប្រើ)	ហើយគេបើកឲ្យប្រើខែណា?
4.	តាមលោកស្មានគេធ្វើស្ពាននោះហើយអង្កាល់? (ចាប់លាបពណ៌)	ហើយគេចាប់លាបពណ៌ខែណា?
5.	តាមលោកស្មានគេធ្វើផ្ទះនោះហើយអង្កាល់? (ចូលទៅនៅ)	ហើយគេចូលទៅនៅខែណា?

Drill I. Expansion

1.	គេបានបង្កើតឲ្យមានរោងចក្រច្រើន។	They have established many factories.
2.	នៅប្រទេសកម្ពុជាគេបានបង្កើតឲ្យមានរោងចក្រច្រើន។	They have established many factories in Cambodia.
3.	តាំងពីបានឯករាជមក នៅប្រទេសកម្ពុជាគេបានបង្កើតឲ្យមានរោងចក្រច្រើន។	Since gaining independence they have established many factories in Cambodia.
4.	តាំងពីបានឯករាជមក នៅប្រទេសកម្ពុជាគេបានបង្កើតឲ្យមានរោងចក្រច្រើនផលិតវត្ថុរបស់សំខាន់ៗច្រើនយ៉ាង។	Since gaining independence they have established many factories in Cambodia which manufacture many kinds of important products.
5.	តាំងពីបានឯករាជមក នៅប្រទេសកម្ពុជាគេបានបង្កើតឲ្យមានរោងចក្រច្រើនផលិតវត្ថុរបស់សំខាន់ៗច្រើនយ៉ាងសំរាប់ការត្រូវការរបស់ជាតិ។	Since gaining independence they have established many factories in Cambodia which manufacture many kinds of important products used for the needs of the people.

Drill J. Reduction

1.	តាំងពីបានឯករាជមក នៅប្រទេសកម្ពុជាគេបានបង្កើតឲ្យមានរោងចក្រច្រើនផលិតវត្ថុរបស់សំខាន់ៗច្រើនយ៉ាងសំរាប់ការត្រូវការរបស់ជាតិ។	Since gaining independence they have established many factories in Cambodia which manufacture many kinds of important products used for the needs of the people.
2.	តាំងពីបានឯករាជមក នៅប្រទេសកម្ពុជាគេបានបង្កើតឲ្យមានរោងចក្រច្រើនផលិតវត្ថុរបស់សំខាន់ៗច្រើនយ៉ាង។	Since gaining independence they have established many factories in Cambodia which manufacture many kinds of important products.
3.	តាំងពីបានឯករាជមក នៅប្រទេសកម្ពុជាគេបានបង្កើតឲ្យមានរោងចក្រច្រើន។	Since gaining independence they have established many factories in Cambodia.
4.	នៅប្រទេសកម្ពុជាគេបង្កើតឲ្យមានរោងចក្រច្រើន។	They have established many factories in Cambodia.
5.	គេបានបង្កើតឲ្យមានរោងចក្រច្រើន។	They have established many factories.

UNIT 79

BASIC DIALOGUE

	Nancy	
1.	ជំរាបសួរលោកស្រស់ លោកជួយឲ្យយោបល់ខ្ញុំបន្តិចបានទេ?	Hello, Sroh. Can you give me a little suggestion?
	Sroh	
2.	បាទមានអី លោកស្រីមានការអី?	All right. What's the matter?
	Nancy	
3.	ចា៎ ខ្ញុំកំពុងតែរៀបចំអីវ៉ាន់យកទៅភ្នំពេញ។ លោកប្រាប់ខ្ញុំបានទេ ខ្ញុំត្រូវយកអី ទុកអី?	I'm getting things ready to take to Phnom Penh. Can you tell me what I should take, and what I should leave behind?
	Sroh	
4.	ការនេះបើលោកស្រីមិនចង់ពិបាកច្រើន លោកស្រីយកតែអីវ៉ាន់បន្តិចបន្តួចទៅបានហើយ ដូចជាប្រដាប់ប្រដាផ្សេងៗសម្រាប់ប្រើនៅផ្ទះ។	In this case, if you don't want a lot of trouble, take only a few things, like various appliances for use in the house.
	Nancy	
5.	ដូចជាចានឆ្នាំងអីៗឬ?	Like china and things like that?
	Sroh	
6.	បាទ ហើយរបស់នេះទៀត លោកស្រីមិនបាច់យកទៅក៏បាន ព្រោះនៅភ្នំពេញគេមានលក់របស់អស់នេះល្អៗដែរ។	These things you don't need to take either, because in Phnom Penh they sell all these things and they're pretty too.
	Nancy	
7.	គេលក់ថ្លៃទេ?	Are they expensive?
	Sroh	
8.	ទេ គេលក់ថោកល្មម ព្រោះគេមានរោងឧស្សាហកម្មធ្វើរបស់អស់នេះនៅក្នុងស្រុក។	No. They sell them cheap because they have factories which make all these in the country.
	Nancy	
9.	អញ្ចឹងស្រួលណាស់ ខ្ញុំអាចឲ្យក្រុមហ៊ុនដឹកនាំអីវ៉ាន់ទុកអីវ៉ាន់ខ្ញុំនៅក្នុងឃ្លាំងគេ។	In that case it'll be convenient. I can have the transfer company put my things in storage in their warehouse.

	Sroh	
10.	បាទ ហើយដល់លោកស្រីទៅដល់ភ្នំពេញ លោកស្រីមុខតែនឹងជួលបន្ទប់ឬផ្ទះមានតុ ទូ អីៗស្រាប់។	And when you arrive in Phnom Penh you should rent an apartment or a house with tables and chests and things like that.
	Nancy	
11.	ខ្ញុំអាចជួលផ្ទះឬបន្ទប់ទទេ ទេ?	Can I rent an unfurnished apartment or house?
	Sroh	
12.	បាទ លោកស្រីអាចជួលបាន ហើយ លោកស្រីអាចទិញតុ ទូ គ្រែ តាមលោកស្រីចូលចិត្ត។ គេមានធ្វើគ្រែតុទូកៅអីល្អៗណាស់។ មានទូដាក់ខោអាវធ្វើពីឈើល្អៗណាស់ មានពូកកៅស៊ូ មានកៅអីផ្ដៅធ្វើតាមរបៀបសម័យ នឹងបុរាណ ឬតាមលោកស្រីចង់បាន។	Yes you can, and you can buy tables, chests and beds according to your desire. They make very good beds, tables, wardrobes and chairs. They have wardrobes made of good wood; they have foam-rubber mattresses; they have rattan chairs made in the modern or old style, or however you want.
	Nancy	
13.	នៅស្រុកខ្មែរ មានគេលក់ចង្ក្រានដុតហ្គាស ទេ?	Do they sell gas stoves in Cambodia?
	Sroh	
14.	បាទ មាន ដុតហ្គាស ឬដុតប្រេងកាត តែបើលោកស្រីទៅនៅផ្ទះដែលធ្វើសំរាប់អាមេរិកាំងនោះលោកស្រីមិនបាច់ព្រួយទេ។	Yes, they do. They burn gas or kerosene,but if you go to live in a house built for Americans, you needn't worry.
	Nancy	
15.	ចាស ទេ ខ្ញុំមុខតែទៅនៅបន្ទប់ឬល្វែងៗ មានតុទូ នឹងរបៀបសំអាងខ្មែរទាំងអស់ហើយ ខ្ញុំនឹងរៀបតាមរបៀបខ្ញុំ។	No, I will go live in an apartment or "compartment house" which has all the tables and wardrobes in the Cambodian style, and I'll arrange it my own way.
	Sroh	
16.	អញ្ចឹងលោកស្រីមិនបាច់យកអីទៅច្រើនទេ បើលោកស្រីគិតដូច្នេះ។ ហើយខ្ញុំសង្ឃឹមថាបេសកកម្មលោកស្រីមុខតែបានសំរេចដោយសុភមង្គល។	In that case you needn't take a lot, if that's the way you think. And I hope that your mission will end in success.
	Nancy	
17.	ចាស ខ្ញុំសុំអរគុណច្រើនណាស់។	Thank you very much.

DRILLS

Drill A. Substitution

1.	សុំទោស លោកជួយឲ្យយោបល់ខ្ញុំបន្តិចបានទេ?	Excuse me, would you help me think a little bit.
2.	សុំទោស លោកជួយរៀបផ្ទះខ្ញុំបន្តិចបានទេ?	Excuse me, would you help me put the house in order a little bit.
3.	សុំទោស លោកជួយធ្វើការខ្ញុំបន្តិចបានទេ?	Excuse me, would you help me work a little bit.
4.	សុំទោស លោកជួយយកអីវ៉ាន់ខ្ញុំបន្តិចបានទេ?	Excuse me, would you help me carry the things a little bit.
5.	សុំទោស លោកជួយរៀបអីវ៉ាន់ខ្ញុំបន្តិចបានទេ?	Excuse me, would you help me prepare the things a little bit.
6.	សុំទោស លោកជួយហៅស៊ីក្លូខ្ញុំបន្តិចបានទេ?	Excuse me, would you help me call a cyclo a little bit.
7.	សុំទោស លោកជួយមើលកូនខ្ញុំបន្តិចបានទេ?	Excuse me, would you help me look after the children a little bit.
8.	សុំទោស លោកជួយទិញសៀវភៅខ្ញុំបន្តិចបានទេ?	Excuse me, would you help me buy books a little bit.

Drill B. Substitution

1.	ផ្ទះណាមានលក់ចង្ក្រានដុតហ្គាស?	Which store has gas stoves for sale?
2.	ផ្ទះណាមានលក់ទូទឹកកក?	Which store has refrigerators for sale?
3.	ផ្ទះណាមានលក់កង់ឡានល្អៗ?	Which store has good tires for sale?
4.	ផ្ទះណាមានលក់សៀវភៅអង់គ្លេស?	Which store has English books for sale?
5.	បណ្ណាគារណាមានលក់សៀវភៅអង់គ្លេស?	Which book store has English books for sale?
6.	បណ្ណាគារណាមានលក់កាសែតនិងទស្សនាវដ្ដីបារាំង?	Which book store has French newspapers and magazines for sale?
7.	នៅឯណាមានលក់ កាសែតនិងទស្សនាវដ្ដី?	Where are French newspapers and magazines for sale?
8.	នៅឯណាមានលក់គ្រែនិងទូ?	Where are beds and wardrobes for sale?

Drill C. Substitution

1. លោកមិនបាច់យកអីវ៉ាន់ទៅទេ គេមានរបស់លក់នៅឯនោះមិនខ្វះទេ។
You don't have to take things; they have many things to sell there.

2. លោកមិនបាច់ឲ្យគាត់ទៅទេ គេមានមនុស្សនៅឯនោះមិនខ្វះទេ។
You don't have to let him go; they have many people there.

3. លោកមិនបាច់យកឡានទៅទេ នៅឯនោះគេមានស៊ីក្លូមិនខ្វះទេ។
You don't have to take the car; they have many cyclos there.

4. លោកមិនបាច់ផ្ញើសៀវភៅទៅទេ គេមានសៀវភៅលក់មិនខ្វះទេនៅឯនោះ។
You don't have to send the book; they have many books for sale there.

5. លោកមិនបាច់កាត់ខោអាវច្រើនទេ គេមានអ្នកកាត់ខោអាវនៅឯនោះមិនខ្វះទេ។
You don't have to have a lot of clothes made; they have many tailors there.

6. លោកមិនបាច់ទិញផ្លែឈើយកទៅច្រើនទេ គេមានអ្នកលក់នំនៅឯនោះមិនខ្វះទេ។
You don't have to buy fruit to take along; they have many cake sellers there.

7. លោកមិនបាច់អញ្ជើញទៅទេ គេមានអ្នកធ្វើការនៅឯនោះមិនខ្វះទេ។
You don't have to go; they have many workers there.

8. លោកមិនបាច់តេឡេហ្វូនទៅទេ គេមានលក់នៅឯនោះមិនខ្វះទេ។
You don't have to telephone; they have many to sell there.

Drill D. Multiple Substitution

1. ខ្ញុំមុខតែនឹងរកជួលផ្ទះល្វែងមួយនៅជិតកន្លែងធ្វើការ។
I will try to rent a "compartment house" near my place of work.

2. ខ្ញុំមុខតែនឹងរកទិញផ្ទះល្វែងមួយនៅឆ្ងាយពីកន្លែងលក់អីវ៉ាន់។
I will try to buy a "compartment house" far from where things are sold.

3. ខ្ញុំមុខតែនឹងទិញដីមួយកន្លែងនៅឆ្ងាយពីទីក្រុង។
I will try to buy a piece of land far from the city.

4. ខ្ញុំមុខតែនឹងរកទិញផ្ទះមួយនៅជិតស្ថានទូត។
I will try to buy a house near the embassy.

5. ខ្ញុំមុខតែនឹងរកទិញឡានមួយនៅពេលខ្ញុំទៅដល់។
I will try to buy a car when I arrive.

6. ខ្ញុំមុខតែនឹងជួលឡានមួយនៅពេលខ្ញុំនៅភ្នំពេញ។
I will try to rent a car when I'm in Phnom Penh.

7. ខ្ញុំមុខតែនឹងរកជួលកង់មួយពេលខ្ញុំទៅដល់អង្គរវត្ត។
I will try to rent a bicycle when I arrive in Angkor Wat.

8. ខ្ញុំមុខតែនឹងរកជួលបន្ទប់មួយនៅពេលខ្ញុំ
I will try to rent a room when I

ហាត់ធ្វើការបរណៈ ។

work there.

Drill E. Equivalence

1.	កាលណាខ្ញុំទៅដល់ភ្នំពេញ បងខ្ញុំនឹងមកទទួលខ្ញុំ ។	ដល់ខ្ញុំទៅដល់ភ្នំពេញ បងខ្ញុំនឹងមកទទួលខ្ញុំ ។
2.	កាលណាខ្ញុំជួបគាត់ ខ្ញុំនឹងជំរាបគាត់ ។	ដល់ខ្ញុំជួបគាត់ ខ្ញុំនឹងជំរាបគាត់ ។
3.	កាលណាខ្ញុំឃើញគាត់ ខ្ញុំនឹងឲ្យគាត់ ។	ដល់ខ្ញុំឃើញគាត់ ខ្ញុំនឹងឲ្យគាត់ ។
4.	កាលណាវាមក ខ្ញុំនឹងប្រាប់វា ។	ដល់វាមក ខ្ញុំនឹងប្រាប់វា ។
5.	កាលណាខ្ញុំទៅ ខ្ញុំនឹងផ្ញើជូន ។	ដល់ខ្ញុំទៅ ខ្ញុំនឹងផ្ញើជូន ។

Drill F. Transformation

1.	ខ្ញុំចង់ទិញពូកកៅស៊ូធំមួយ ។	លោកមានពូកកៅស៊ូធំលក់ទេ?
2.	គាត់ចង់បានចង្ក្រានដុតហ្គាសមួយ ។	លោកមានចង្ក្រានលក់ទេ?
3.	ខ្ញុំចង់បានទូដាក់ចានមួយ ។	លោកមានទូដាក់ចានលក់ទេ?
4.	ខ្ញុំចង់ទិញគ្រែធំមួយ ។	លោកមានគ្រែធំលក់ទេ?
5.	ខ្ញុំចង់ជួលវិទ្យុមួយគ្រឿង ។	លោកមានវិទ្យុលក់ទេ?

Drill G. Response

MODEL: គ្រូ : ម្ដេចក៏លោកយកអីវ៉ាន់ទៅច្រើនម្ល៉េះ? (របស់)

សិស្ស: បាទទេ នេះជារបស់ដែលខ្ញុំត្រូវការភ្លាមទេ ។ របស់ឯទៀតខ្ញុំនឹងទិញនៅភ្នំពេញ ។

Teacher: How come you're taking so many things? (things)

Student: No, these are just the things I need right away. The other things I'll buy in Phnom Penh.

1.	ម្ដេចក៏លោកយកសៀវភៅទៅច្រើនម្ល៉េះ? (សៀវភៅ)	បាទទេ នេះជាសៀវភៅដែលខ្ញុំត្រូវការភ្លាមៗទេ សៀវភៅឯទៀតខ្ញុំនឹងទិញនៅភ្នំពេញ ។
2.	ម្ដេចក៏លោកយកខោអាវទៅច្រើនម្ល៉េះ? (ខោអាវ)	បាទទេ នេះជាខោអាវដែលខ្ញុំត្រូវការភ្លាមៗទេ ខោអាវឯទៀតខ្ញុំនឹងទិញនៅភ្នំពេញ ។
3.	ម្ដេចក៏លោកស្រីយកចានឆ្នាំងទៅច្រើនម្ល៉េះ? (ចានឆ្នាំង)	ចាស៎ទេ នេះជាចានឆ្នាំងដែលខ្ញុំត្រូវការភ្លាមៗទេ ចានឆ្នាំងឯទៀតខ្ញុំនឹងទិញនៅភ្នំពេញ ។
4.	ម្ដេចក៏លោកយកតុទូអីទៅច្រើនម្ល៉េះ? (របស់)	បាទទេ នេះជារបស់ដែលខ្ញុំត្រូវការភ្លាមៗទេ របស់ឯទៀតខ្ញុំនឹងទិញនៅភ្នំពេញ ។
5.	ម្ដេចក៏លោកស្រីយកទឹកទិតៅបីទៅច្រើនម្ល៉េះ? (ទឹកទិតៅបី)	ចាស៎ទេ នេះជាទឹកទិតៅបីដែលខ្ញុំត្រូវការភ្លាមៗទេ ទឹកទិតៅបីឯទៀតខ្ញុំនឹងទិញនៅភ្នំពេញ ។

Drill H. Response

MODEL:	គ្រូ: នៅផ្ទះលោកមានទូដាក់ខោអាវទេ? (បន្ទប់ដាក់ខោអាវ)	Teacher: Do you have a wardrobe at your house? (closets)
	សិស្ស: បាទខ្ញុំគ្មានទេ តែខ្ញុំមានបន្ទប់ដាក់ខោអាវ។	Student: I don't have one, but I do have closets.
1.	នៅផ្ទះលោកមានកៅអីផ្តៅទេ? (កៅអីឈើបួន)	បាទខ្ញុំគ្មានទេ តែខ្ញុំមានកៅអីឈើបួន។
2.	នៅផ្ទះលោក លោកមានតុទូរបៀបបុរាណទេ? (របស់បុរាណផ្សេងៗទៀត)	បាទខ្ញុំគ្មានទេ តែខ្ញុំមានរបស់បុរាណផ្សេងៗទៀត។
3.	នៅបន្ទប់លោកលោកមានតុដាក់សៀវភៅទេ? (ទូដាក់សៀវភៅមួយ)	បាទទេខ្ញុំគ្មានទេ តែខ្ញុំមានទូដាក់សៀវភៅមួយ។
4.	នៅបន្ទប់លោក លោកមានកែវដាក់ទឹកទេ? (ថូផ្កាមួយខ្ញុំទិញនៅស្រុកខ្មែរ)	បាទខ្ញុំគ្មានទេ តែខ្ញុំមានថូផ្កាមួយខ្ញុំទិញនៅស្រុកខ្មែរ។
5.	នៅបន្ទប់លោកលោកមានរូបចិត្រព្យួរនៅជញ្ជាំងទេ? (ផែនទីពិភពលោក១ និងផែនទីស្រុកខ្មែរ១)	បាទខ្ញុំគ្មានទេ តែខ្ញុំមានផែនទីពិភពលោកមួយ និងផែនទីស្រុកខ្មែរមួយ។

Drill I. Expansion

1.	គេមានរោងចក្រឧស្សាហកម្ម។	There are factories.
2.	គេមានរោងចក្រឧស្សាហកម្មជាច្រើន។	There are a lot of factories.
3.	គេមានរោងចក្រឧស្សាហកម្មជាច្រើនធ្វើរបស់ប្រើប្រាស់។	There are a lot factories making utensils.
4.	គេមានរោងចក្រឧស្សាហកម្មជាច្រើនធ្វើរបស់ប្រើប្រាស់ផ្សេងៗ។	There are a lot of factories making various utensils.
5.	គេមានរោងចក្រឧស្សាហកម្មជាច្រើនធ្វើរបស់ប្រើប្រាស់ផ្សេងៗមានឆ្នាំងកែវចានជាដើម។	There are a lot of factories making various utensils such as pots, glasses, and dishes.
6.	គេមានរោងចក្រឧស្សាហកម្មជាច្រើនធ្វើរបស់ប្រើប្រាស់ផ្សេងៗមានឆ្នាំងកែវចានជាដើមដែលមានគុណភាពយ៉ាងប្រសើរ។	There are a lot of factories making various utensils such as pots, glasses, and dishes of excellent quality.
7.	គេមាន រោងចក្រឧស្សាហកម្មជាច្រើនធ្វើរបស់ប្រើប្រាស់ផ្សេងៗមានឆ្នាំងកែវចានជាដើមដែលមានគុណភាពយ៉ាងប្រសើរ មិនចាញ់របស់បរទេស។	There are a lot of factories making various utensils such as pots, glasses, and dishes of excellent quality unsurpassed by foreign products.

Drill J. Reduction

1.	គេមានរោងឧស្សាហកម្មជាច្រើនធ្វើរបស់ប្រើប្រាស់ផ្សេងៗមានឆ្នាំងកែវចានជាដើមដែលគុណភាពយ៉ាងប្រសើរមិនចាញ់របស់បរទេសទេ។	There are a lot of factories making various utensils such as pots, glasses, and dishes of excellent quality unsurpassed by foreign products.
2.	គេមានរោងឧស្សាហកម្មជាច្រើនធ្វើរបស់ប្រើប្រាស់ផ្សេងៗមានឆ្នាំងកែវចានជាដើមដែលគុណភាពយ៉ាងប្រសើរ។	There are a lot of factories making various utensils such as pots, glasses, and dishes of excellent quality.
3.	គេមានរោងឧស្សាហកម្មជាច្រើនធ្វើរបស់ប្រើប្រាស់ផ្សេងៗមានឆ្នាំងកែវចានជាដើម។	There are a lot of factories making various utensils such as pots, glasses, and dishes.
4.	គេមានរោងឧស្សាហកម្មជាច្រើនធ្វើរបស់ប្រើប្រាស់ផ្សេងៗ។	There are a lot of factories making various utensils.
5.	គេមានរោងឧស្សាហកម្មជាច្រើនធ្វើរបស់ប្រើប្រាស់។	There are a lot of factories making utensils.
6.	គេមានរោងឧស្សាហកម្មជាច្រើន។	There are a lot of factories.
7.	គេមានរោងឧស្សាហកម្ម។	There are factories.

UNIT 80

NARRATION

1. លោកប៉ូលជាទេសចរម្នាក់ក្នុងចំណោមអ្នកទេសចរឯទៀតដែលបានទៅប្រទេសកម្ពុជាលេង។
2. លោកមិនទាន់មានឱកាសទៅជួបពួកម៉ាកខ្មែរណាម្នាក់សោះ។
3. គាត់មកពីក្រុងរ៉ង់ហ្គូនត្រង់ទៅសៀមរាប។
4. នៅនោះគាត់បានទៅមើលអង្គរវត្តអស់មួយអាទិត្យ។
5. លោកប៉ូលបានទៅឃើញប្រាសាទផ្សេងៗជាច្រើន ហើយគាត់ស្រឡាញ់ប្រាសាទបន្ទាយស្រីណាស់ ព្រោះក្បាច់រចនានៅល្អច្រើន។
6. នៅតាមកំពែងអង្គរគាត់ក៏ក្បាច់ចម្លាក់ល្អដែរ ហើយរលោងផង ព្រោះអ្នកណាដែលទៅឃើញគេតែងតែស្ទាបអង្អែលជានិច្ច។
7. លោកប៉ូលនឹកឆ្ងល់មិនចេះចប់ថាតើខ្មែរពីដើមគេសង់អង្គរវត្តយ៉ាងម៉េច? ព្រោះគេឃើញសុទ្ធតែថ្មទាំងដុំៗ ដាក់លើគ្នាដោយគ្មានទាំងស៊ីម៉ង់ផង។
8. ឥឡូវក្រុមហ៊ុនទេសចរខ្មែរបាននាំគាត់មកភ្នំពេញ។
9. នៅទីនេះគាត់បានឃើញកន្លែងផ្សេងៗ មានសារមន្ទីរជាតិនិងវាំងជាដើម។
10. ស្អែកគាត់ទៅមើលវត្តព្រះកែវ ដែលមានវិហារក្រាលសុទ្ធតែប្រាក់ និងទៅមើលវិមានឯករាជ ដែលមានក្បាច់លាយបុរាណនិងសម័យ។

1. Paul is a tourist among other tourists who have gone to visit Cambodia.
2. He still has not had the opportunity to go look for a single Cambodian friend.
3. He came from Rangoon directly to Siem Reap.
4. There he had the opportunity to go see Angkor Wat for a whole week.
5. Paul went to see many different monuments and he likes Banteay Srey very much because the sculptures are still very pretty.
6. Along the walls of Angkor he also saw that the sculpture is beautiful, and smooth too, because whoever goes to see it always touches and rubs it.
7. Paul constantly wonders how the ancient Khmer could build Angkor because he sees stones placed one on top of the other without even having cement.
8. Now the Cambodian Tourist Office has brought him to Phnom Penh.
9. Here he can go see various places, the National Museum and the Palace, for example.
10. Tomorrow he will go to see the Preah Keo Pagoda, in which the floor is completely tiled in silver, and he will see the Independence Monument, which has been decorated by mixing the ancient with the modern.

1. នៅភ្នំពេញគេមិនពិបាករកទិញគ្រឿងប្រាក់ កំណាត់សំពត់ឬរូបចម្លាក់ផ្សេងៗនោះទេ។
2. ក្រៅពីផ្ទះលក់តូចៗឯទៀត គេអាចទៅមើលនៅកន្លែងធំៗបួនគឺ ផ្សារចាស់ ផ្សារថ្មី សណ្ឋាគារកុសមៈ និងបន្ទប់លក់របស់នៅសាលាវិចិត្រសិល្ប។
3. គេអាចទិញប្រអប់ប្រាក់ សំពត់ហោល សារុងឬក្រវ៉ាត់សូត្រ។
4. រូបចម្លាក់ផ្សេងៗធ្វើអំពីភ្លុក ស្ពាន់ និងឈើក៏មិនខ្វះដែរ។
5. ក្រៅពីរបស់ទាំងនេះគេអាចទិញខ្សែក្រវ៉ាត់ប្រាក់សម្រាប់ស្រីៗ ប្រអប់ដាក់ម្សៅលាបមុខ ខ្សែក និងបន្តោងមាសធ្វើជារូបសត្វផ្សេងៗ។
6. គេមានលក់រូបចម្លាក់តូចដូចជារូបអប្សរា និងគ្រឿងភ្លេងខ្មែរជាដើម។
7. បើគេចង់ទៅទិញរបស់អស់នេះនៅសាលាវិចិត្រសិល្ប គេអាចទៅមើលជាងចម្លាក់ឬអ្នកត្បាញដែរ។
8. អ្នកអស់នោះជានិស្សិត រហូតដល់កាលណាគេរៀនចប់ គេនឹងចេញទៅធ្វើជាជាងឯកជនរៀងខ្លួន។

1. In Phnom Penh it is not difficult to buy silver articles, sampot cloth, or various sculptures.
2. Besides the other small businesses, they can go look in four large places, the Old Market, the New Market, the Kossamak Hotel, and the salesroom of the School of Fine Arts.
3. They can buy silver boxes, sampot houl, sarongs, or silk ties.
4. There are a lot of various carvings made of ivory, copper, and wood.
5. Besides all these things they can buy silver belts for ladies, compacts, gold necklaces and pendants made in the shapes of various animals.
6. They offer for sale small sculptures such as apsaras and Cambodian orchestras, for example.
7. If they want to go buy all these things in the School of Fine Arts they can go watch the sculptors or the weavers.
8. All these people are students until the time they have finished studying and leave to be private artisans.

1. នៅភ្នំពេញក៏ដូចនៅទីក្រុងដទៃទៀតដែរ ការរៀបចំទីក្រុងឲ្យបានស្អាតជាការប្រព្រឹត្តទៅរាល់ពេល តាំងពីតែប្រទេសខ្មែរបានឯករាជមក។
2. គេពង្រីកផ្លូវធំៗស្អាតហើយទីក្រុងក៏រីកធំឡើងដែរ។
3. ចំនួនមហាវិថីក៏មានកាន់តែច្រើនឡើងហើយផ្លូវឯទៀតក៏មានពង្រីកទៅស្ទើរតែគ្រប់កន្លែង។
4. នៅតាមស្រុកនិងភូមិគេសាងសាលារៀនឲ្យបានគ្រប់គ្រាន់ហើយនៅភ្នំពេញនិងខេត្តខ្លះគេបង្កើតឲ្យមានមហាវិទ្យាល័យ។
5. ខាងផ្នែកសុខាភិបាលវិញ គេមានចំនួនឱសថដ្ឋាន គិលានុប្បដ្ឋាន និងមន្ទីរពេទ្យរហូតដល់ទីជនបទ។
6. ខាងឧស្សាហកម្មប្រទេសកម្ពុជាក៏មានជំហានលឿនណាស់ដែរ។
7. ពីដើមមុនឯករាជ្យ គេមិនសូវឃើញមានរោងឧស្សាហកម្មប៉ុន្មានទេ។
8. សព្វថ្ងៃគេឃើញមានរោងចក្រធ្វើរបស់ប្រើប្រាស់ផ្សេងៗស្ទើរតែគ្រប់មុខ។
9. ក្នុងចំណោមរោងចក្រនេះ មួយភាគបីជាជំនួយបរទេស ក្រៅពីនោះគឺជារោងចក្ររបស់ជាតិឬរបស់ឯកជន។
10. ការលូតលាស់នេះធ្វើឲ្យអ្នកដែលធ្លាប់ស្គាល់ស្រុកខ្មែរពីដើម ភ្ញាក់ផ្អើលណាស់។

1. Since Cambodia became independent , Phnom Penh, like other Cambodian cities, has constantly been active in keeping itself clean.

2. They are expanding the main roads and enlarging the cities also.

3. The number of universities is getting larger and larger, and other roads are also expanding almost everywhere.

4. In the sroks and villages they are building schools so as to have enough, and in Phnom Penh and some provinces they are establishing universities.

5. As for health, they have a number of pharmacies, health centers, and hospitals even in the remote villages.

6. In industry, Cambodia has also made quick strides.

7. At present they have factories making various equipment of almost all kinds.

8. Among these factories, one third are foreign aid.

9. Besides that there are state and private factories.

10. This expansion would surprise people who knew Cambodia before.

1. លោកស្រីម្នាក់ដែលរៀបចំទៅធ្វើការ ឯភ្នំពេញ បានសួរថាតើ គាត់ត្រូវយកអ្វីទៅខ្លះ។
2. ខ្មែរម្នាក់បានប្រាប់គាត់ថាមិនបាច់យកអីវ៉ាន់ទៅច្រើនទេនាំឲ្យតែពិបាក។
3. លោកស្រីអាចយកសំលៀកបំពាក់ខែក្តៅទៅនិងរបស់ខ្លះទៀតដែលជារបស់ចាំបាច់។
4. ចាន ឆ្នាំងផ្សេងៗមិនបាច់យកទៅទេ ព្រោះនៅឯនោះគេមានរបស់អស់នឹងហើយ
ថោកផង។
5. នៅស្រុកខ្មែរមានរោងឧស្សាហកម្មធ្វើរបស់អស់នេះមិនចាញ់របស់ពីបរទេសឯទៀតទេ។
6. បើលោកស្រីទៅជួលផ្ទះដែលមានតុទូស្រាប់នោះក៏កាន់តែស្រួលទៅទៀត។
7. គេមានតុទូធ្វើពីឈើយ៉ាងល្អ មានពូកនិងកៅអី ធ្វើអំពីកៅស៊ូ តាមរបៀបសម័យ
ឬបុរាណមិនខ្វះ។
8. បើលោកស្រីអញ្ជើញទៅនៅផ្ទះសំរាប់តែអ្នករាជការអាមេរិកាំងនោះស្រួលណាស់ព្រោះ
គេមានគ្រឿងប្រដាប់ច្រើនដាក់នៅល្វែងនីមួយៗ។
9. បើលោកស្រីចង់ជួលបន្ទប់ឬជួលផ្ទះល្វែងដែលគ្មានតុទូ នោះលោកស្រីអាចរៀបចំផ្ទះ
តាមចិត្តបាន។
10. ដូច្នេះគាត់អាចរៀបផ្ទះតាមរបៀបខ្មែរឬរបៀបអាមេរិកាំងបានហើយ ដោយពិសេស
ផង។

1. A lady who is preparing to go to work in Phnom Penh asks what things she must take.
2. A Cambodian tells her that she needn't take a lot of things; taking them would only make things difficult.
3. The lady can take clothes for the hot months and some other things which are necessities.
4. She needn't take dishes and various pots because they have all these things; they're nice and they're cheap too.
5. In Cambodia they have factories which make all these things, which are not inferior to foreign products.
6. If the lady is going to rent a house which already has furniture, so much the easier.
7. They have tables and cabinets made from good wood; they have mattresses and chairs made of foam rubber in both the modern and ancient style, and there are a lot of them.
8. If the lady goes to live in a house only for American officials it would be very easy, because they have many appliances installed in each house or apartment.
9. If she wants to rent an apartment or a "compartment house" which doesn't have furniture, she can fix up the house as she wishes.
10. Thus, she can fix up the house in the Cambodian style or specially in the American style.

UNIT 81

BASIC DIALOGUE

John

1. ជំរាបសួរលោកសារំ លោកទៅណាណឹង? — Hello, Sarom. Where are you going?

Sarom

2. ខ្ញុំទៅផ្ទះ។ ខ្ញុំទើបនឹងត្រឡប់មកពីវាលយន្តហោះ។ — I'm going home. I'm just returning from the airport.

John

3. លោកទៅទទួលអ្នកណាឬអី? — Did you meet someone?

Sarom

4. ទេ ខ្ញុំជូនប្អូនខ្ញុំទៅឡើងយន្តហោះ។ — No, I took my younger brother to get a plane.

John

5. អូ អញ្ចឹង! គេទៅរៀនអី? — Is that so? What's he going to study?

Sarom

6. វាទៅរៀនខាងវិស្វកម្មនៅសាកលវិទ្យាល័យ ខរណែល។ — He's going to study engineering at Cornell.

John

7. គេទៅរៀនប៉ុន្មានឆ្នាំ? — How many years is he going to study?

Sarom

8. វាបានអាហារូបករណ៍តែមួយឆ្នាំទេ ប៉ុន្តែបើវារៀនល្អគេនឹងបន្តអាហារូបករណ៍ឲ្យគេទៅរៀនត។ — He got a scholarship for just one year, but if he studies well they will extend the scholarship.

John

9. នៅប្រទេសកម្ពុជាមានសាកលវិទ្យាល័យទេ? — Are there universities in Cambodia?

Sarom

10. បាទ គឺនៅក្រុងភ្នំពេញ នឹងកំពង់ចាម នឹងបាត់ដំបង តែសិស្សណាដែលបានអាហារូបករណ៍ទៅរៀនខាងមុខវិជ្ជាគេទៅរៀនមុខវិជ្ជាណាដែលយើងមិនទាន់ — Yes, in Phnom Penh, Kompong Cham and Battambang, but students who get scholarships go (abroad) to study subjects which we don't have yet.

	មាន។		
11.	មានសាកលវិទ្យាល័យទាំងអស់ប៉ុន្មាន នៅស្រុកខ្មែរ។	John	How many universities are there altogether in Cambodia?
12.	មានប្រាំបួនឥឡូវ។ ប្រាំពីរនៅភ្នំពេញ នឹងពីរទៀតនៅកំពង់ចាម នឹងបាត់ដំបង។	Sarom	There are eight now. Six in Phnom Penh and two others, in Kompong Cham and Battambang.
13.	នៅសាកលវិទ្យាល័យទាំងនេះ មាននិស្សិតបរទេសទេ?	John	Are there foreign students in all these universities?
14.	បាទ មាន ភាគច្រើនមកពីស្រុកលាវ ស្រុកយួន នឹងស្រុកបារាំងខ្លះ។	Sarom	Yes, mostly they come from Laos, Vietnam, and some from France.
15.	គេមករៀនខាងអ្វី?	John	What do they come to study?
16.	បាទ ភាគច្រើនគេរៀនខាងសេដ្ឋកិច្ច ខាងច្បាប់ ខាងពេទ្យ ខាងកសិកម្ម នឹងខាងវិជ្ជាបច្ចេកទេសផ្សេងៗ ដូចជាខាងគ្រឿងឡាន នឹងកាត់ខោអាវជាដើម។	Sarom	For the most part they study economics, law, medicine, agriculture, and various technical subjects, such as repairing autos and tailoring.
17.	សាលារៀននៅស្រុកខ្មែរថ្លៃទេ?	John	Are the schools in Cambodia expensive?
18.	ទេ មិនថ្លៃទេ។ សាលាស្ទើរតែទាំងអស់សុទ្ធតែសាលារាជការ។ គេយកតែថ្លៃប្រឡងយកសញ្ញាបត្រប៉ុណ្ណោះទេ។ ថ្លៃពី ១០០ ទៅ ៥០០ រៀលមួយឆ្នាំ។	Sarom	They're not expensive. Almost all the schools are government schools. They charge just according to the price of taking the exam and the diploma. It costs from 100 to 500 riels a year.

DRILLS

Drill A. Substitution

1.	ខ្ញុំទើបនឹងត្រឡប់មកពីផ្សារ។	I just came back from the market.
2.	ខ្ញុំទើបនឹងត្រឡប់មកពីវាលយន្តហោះ។	I just came back from the airport.
3.	ខ្ញុំទើបនឹងត្រឡប់មកពីសាលារៀន។	I just came back from the school.
4.	ខ្ញុំទើបនឹងត្រឡប់មកពីធ្វើការ។	I just came back from work.
5.	ខ្ញុំទើបនឹងត្រឡប់មកពីកាត់សក់។	I just came back from getting a haircut.
6.	ខ្ញុំទើបនឹងត្រឡប់មកពីបណ្ណាល័យ។	I just came back from the bookstore.
7.	ខ្ញុំទើបនឹងត្រឡប់មកពីចំណតរទេះភ្លើង។	I just came back from the railroad station.
8.	ខ្ញុំទើបនឹងត្រឡប់មកពីមន្ទីរពេទ្យ។	I just came back from the hospital.

Drill B. Substitution

1.	ខ្ញុំរៀនទាំងច្បាប់ផងទាំងសេដ្ឋកិច្ចផង។	I study both law and economics.
2.	ខ្ញុំរៀនទាំងច្បាប់ផងទាំងប្រវត្តិសាស្ត្រផង។	I study both law and history.
3.	ខ្ញុំរៀនទាំងច្បាប់ផងទាំងទស្សនវិជ្ជាផង។	I study both law and philosophy.
4.	ខ្ញុំរៀនទាំងច្បាប់ផងទាំងពាណិជ្ជវិជ្ជាផង។	I study both law and commerce.
5.	ខ្ញុំរៀនទាំងច្បាប់ផងគណិតសាស្ត្រផង។	I study both law and mathematics.
6.	ខ្ញុំរៀនទាំងច្បាប់ផងទាំងវិជ្ជាពេទ្យផង។	I study both law and medicine.
7.	ខ្ញុំរៀនទាំងច្បាប់ផងទាំងវិស្វកម្មផង។	I study both law and engineering.
8.	ខ្ញុំរៀនទាំងច្បាប់ផងទាំងភូមិសាស្ត្រផង។	I study both law and geography.

Drill C. Variable Substitution

1.	សាកលវិទ្យាល័យនៅស្រុកខ្មែរមិនថ្លៃទេ ព្រោះជាសាលារាជការ។	Universities in Cambodia are not expensive because they are state schools.
2.	វិទ្យាល័យខ្លះនៅស្រុកខ្មែរមិនថ្លៃទេ ព្រោះជាសាលារាជការ។	Some lycées in Cambodia are not expensive because they are state schools.
3.	វិទ្យាល័យខ្លះនៅភ្នំពេញមិនថ្លៃទេ ព្រោះជាសាលារាជការ។	Some lycées in Phnom Penh are not expensive because they are state schools.
4.	វិទ្យាល័យខ្លះនៅខេត្តមិនថ្លៃទេ ព្រោះជាសាលារាជការ។	Some lycées in the provinces are not expensive because they are state schools.
5.	វិទ្យាល័យខ្លះនៅខេត្តថ្លៃ ព្រោះ	Some lycées in the provinces are

	ជាសាលាឯកជន។	expensive because they are private schools.
6.	វិទ្យាល័យខ្លះនៅខេត្តថ្លៃណាស់ព្រោះជាសាលាឯកជន។	Some lycées in the provinces are very expensive because they are private schools.
7.	វិទ្យាល័យខ្លះនៅស្រុកខ្មែរថ្លៃណាស់ព្រោះជាសាលាឯកជន។	Some lycées in Cambodia are very expensive because they are private schools.
8.	សាលារៀនខ្លះនៅស្រុកខ្មែរថ្លៃណាស់ព្រោះជាសាលារៀនឯកជន។	Some schools in Cambodia are very expensive because they are private schools.

Drill D. Double Substitution

1.	វាបានអាហារូបករណ៍ទៅរៀនខាងកសិកម្ម។	He got a scholarship to study agriculture.
2.	វាបានប្រាក់ខែទៅរៀនខាងពេទ្យ។	He got a salary to study medicine.
3.	វាបានជំនួយទៅរៀនខាងវិជ្ជាបច្ចេកទេស។	He got help to study technology.
4.	វាបានលុយខ្លះទៅរៀនខាងភាសាបរទេស។	He got some money to study foreign languages.
5.	វាបានគេជួយឲ្យទៅរៀនខាងវិស្វកម្ម។	He was helped by them to study engineering.
6.	វាបានរាជការជួយឲ្យទៅរៀនខាងសេដ្ឋកិច្ច។	He was helped by the government to study economics.
7.	វាបានរកលុយបានទៅរៀនខាងគណិតសាស្ត្រ។	He earned money to study mathematics.
8.	វាបានប៊ួរ្ស៍ទៅរៀនខាងនយោបាយ។	He got a scholarship to study political science.

Drill E. Triple Substitution

1.	នៅប្រទេសកម្ពុជា សាលាសឹងតែទាំងអស់សុទ្ធតែសាលារាជការ។	In Cambodia, schools are almost all state schools.
2.	នៅប្រទេសអាមេរិក រោងចក្រសឹងតែទាំងអស់សុទ្ធតែរោងចក្រឯកជន។	In America, factories are almost all private factories.
3.	នៅប្រទេសបារាំង ឡានសឹងតែទាំងអស់សុទ្ធតែឡានតូចៗ។	In France, cars are almost all small cars.
4.	នៅប្រទេសយួន ផ្លូវសឹងតែទាំងអស់	In Vietnam, roads are almost all bad

ស្ទើរតែថ្នល់ជ័រល្អ ។ — roads.

5. នៅប្រទេសជប៉ុន ឡានសឹងតែទាំងអស់ ស្ទើរតែឡានធ្វើនៅស្រុកគេ ។ — In Japan, cars are almost all made there.

6. នៅប្រទេសសៀម ឡានសឹងតែទាំងអស់ ស្ទើរតែឡាន អង់គ្លេស ។ — In Thailand, cars are almost all English cars.

7. នៅប្រទេសលាវ ភូមិ សឹងតែទាំងអស់ ស្ទើរតែភូមិតូចៗ ។ — In Laos, villages are almost all small villages.

8. នៅប្រទេសកម្ពុជា ទីក្រុង សឹងតែទាំងអស់ ស្ទើរតែទីក្រុងស្អាតៗ ។ — In Cambodia, cities are almost all pretty cities.

Drill F. Response

MODEL: គ្រូ: សាលារៀននៅស្រុកខ្មែរ ថ្លៃទេ? (សាលារាជការ) — Teacher: Are schools in Cambodia expensive? (state schools)

សិស្ស: បាទទេ មិនថ្លៃទេ ព្រោះជា សាលារាជការ ។ — Student: No, they're not expensive, because they're state schools.

1. សាកលវិទ្យាល័យនៅស្រុកខ្មែរ ថ្លៃទេ? (សាកលវិទ្យាល័យរាជការ) — បាទទេ មិនថ្លៃទេ ព្រោះជាសាកលវិទ្យាល័យរាជការ ។

2. ម្ហូបនៅក្នុងសាលាថ្លៃទេ? (ម្ហូបលក់ដោយម៉ាស៊ីន) — បាទទេ មិនថ្លៃទេ ព្រោះជាម្ហូបលក់ដោយម៉ាស៊ីន ។

3. ផ្លែឈើស្រស់ៗនៅភ្នំពេញថ្លៃទេ? (ផ្លែឈើនៅក្នុងស្រុក) — បាទ មិនថ្លៃទេ ព្រោះជាផ្លែឈើនៅក្នុងស្រុក ។

4. កង់ឡានលក់នៅភ្នំពេញថ្លៃទេ? (កង់ធ្វើនៅរោងចក្រតាខ្មៅ) — បាទទេ មិនថ្លៃទេ ព្រោះជាកង់ធ្វើនៅរោងចក្រតាខ្មៅ ។

5. កំណាត់និងចាន ឆ្នាំងលក់នៅស្រុកខ្មែរថ្លៃទេ? (របស់ដែលគេធ្វើនៅស្រុកខ្មែរ) — បាទទេ មិនថ្លៃទេ ព្រោះជារបស់ដែលគេធ្វើនៅស្រុកខ្មែរ ។

Drill G. Response

MODEL: គ្រូ: នៅសាកលវិទ្យាល័យខ្មែរមាននិស្សិតបរទេសទេ? (លាវ យួន និងបារាំងជាដើម) — Teacher: Do foreign students go to study in Cambodia? (Lao, Vietnamese, and French, for example)

សិស្ស: បាទ និស្សិតដែលទៅរៀនសាកលវិទ្យាល័យខ្មែរមានលាវ យួន និង — Student: Foreign students who study in Cambodian universities are Lao,

បារាំងជាដើម ។	Vietnamese, and French, for example.
1. នៅសាលារៀនខាងវិជ្ជាពេទ្យមាននិស្សិតបរទេសរៀនទេ? (លាវ យួន ចិន និងបារាំង ជាដើម)	បាទ និស្សិតបរទេសដែលរៀននៅសាលារៀន ខាងវិជ្ជាពេទ្យ មានលាវ យួន ចិន និងបារាំង ជាដើម ។
2. នៅសាលារៀនលោកមាននិស្សិតបរទេសមករៀនទេ? (មកពីប្រទេសជិតខាងច្រើន)	បាទនិស្សិតបរទេសដែលមករៀននៅសាលារៀននុ៎ះ មកពីប្រទេសជិតខាងច្រើន ។
3. នៅសាលារៀនខាងវិស្វកម្មមាននិស្សិតបរទេសរៀនទេ? (ក្លិង្គ ចិន និងយួន ជាដើម)	បាទនិស្សិតបរទេសដែលរៀននៅសាលារៀនខាងវិស្វកម្ម មានក្លិង្គ ចិន និងយួនជាដើម ។
4. នៅកន្លែងនោះមាននិស្សិតបរទេសទៅធ្វើការទេ? (បារាំង ខ្មែរ និងអង់គ្លេស)	បាទនិស្សិតដែលទៅធ្វើការនៅកន្លែងនោះមាន បារាំង ខ្មែរ និងអង់គ្លេស ជាដើម ។
5. នៅអង្គការសហប្រជាជាតិមានជនបរទេសទៅធ្វើការទេ? (មកពីគ្រប់ប្រទេសសមាជិកទាំងអស់)	បាទ ជនបរទេសដែលទៅធ្វើការនៅអង្គការសហប្រជាជាតិមានមកពីគ្រប់ប្រទេសសមាជិកទាំងអស់ ។

Drill H. Response

MODEL: គ្រូ: គេជួយគាត់ឲ្យទៅរៀនខាងអ្វី? (អាហារូបករណ៍ ខាងពេទ្យ)	**Teacher**: What do they help him study? (scholarship, medicine)
សិស្ស: បាទ គាត់បានអាហារូបករណ៍ទៅរៀនខាងពេទ្យ ។	**Student**: He got a scholarship to study medicine)
1. គេបញ្ជូនគាត់ឲ្យទៅរៀនខាងអ្វី? (ប្រាក់ខែ កសិកម្ម)	បាទ គាត់បានប្រាក់ខែទៅរៀនខាងកសិកម្ម ។
2. រាជការឲ្យលោកទៅរៀនខាងអ្វី? (ជំនួយពីរាជការ សេដ្ឋកិច្ច)	បាទគាត់បានជំនួយ ពីរាជការទៅរៀនខាងសេដ្ឋកិច្ច ។
3. គាត់បានអាហារូបករណ៍ទៅរៀនខាងអ្វី? (អាហារូបករណ៍ ភាសាអង់គ្លេស)	បាទ គាត់បានអាហារូបករណ៍ទៅរៀនភាសាអង់គ្លេស ។
4. លោកសារុន បានប្រាក់ខែទៅរៀនខាងអ្វី? (ប្រាក់ខែ នយោបាយ)	បាទ លោកសារុន បានប្រាក់ខែទៅរៀនខាងនយោបាយ ។
5. ប្អូនលោកបានអាហារូបករណ៍ទៅរៀនខាងអ្វី? (ជំនួយ ពីរាជការ វិស្វកម្ម)	បាទវាបានជំនួយពីរាជការ ទៅរៀនខាងវិស្វកម្ម ។

Drill I. Expansion

1.	ខ្ញុំបានអាហារូបករណ៍។	I got a scholarship.
2.	ខ្ញុំបានអាហារូបករណ៍ពីរាជការ។	I got a scholarship from the government.
3.	ខ្ញុំបានអាហារូបករណ៍ពីរាជការខ្មែរ។	I got a scholarship from the Cambodian government.
4.	ឥឡូវនេះខ្ញុំបានអាហារូបករណ៍ពីរាជការខ្មែរ។	Now I have a scholarship from the Cambodian government.
5.	ឥឡូវនេះខ្ញុំបានអាហារូបករណ៍ពីរាជការខ្មែរទៅរៀនខាងកសិកម្ម។	Now I have a scholarship from the Cambodian government to go study agriculture.
6.	ឥឡូវនេះខ្ញុំបានអាហារូបករណ៍ពីរាជការខ្មែរទៅរៀនខាងកសិកម្មនៅមហាវិទ្យាល័យប៉ារីស។	Now I have a scholarship from the Cambodian government to go study agriculture at the University of Paris.

Drill J. Reduction

1.	ឥឡូវនេះខ្ញុំបានអាហារូបករណ៍ពីរាជការខ្មែរទៅរៀនខាងកសិកម្មនៅមហាវិទ្យាល័យប៉ារីស។	Now I have a scholarship from the Cambodian government to go study agriculture at the University of Paris.
2.	ឥឡូវនេះខ្ញុំបានអាហារូបករណ៍ពីរាជការខ្មែរទៅរៀនខាងកសិកម្ម។	Now I have a scholarship from the Cambodian government to go study agriculture.
3.	ឥឡូវនេះខ្ញុំបានអាហារូបករណ៍ពីរាជការខ្មែរ	Now I have a scholarship from the Cambodian government.
4.	ខ្ញុំបានអាហារូបករណ៍ពីរាជការខ្មែរ។	I got a scholarship from the Cambodian government.
5.	ខ្ញុំបានអាហារូបករណ៍ពីរាជការ។	I got a scholarship from the government.
6.	ខ្ញុំបានអាហារូបករណ៍។	I got a scholarship.

UNIT 82

BASIC DIALOGUE

John

1. និស្សិតខ្មែរដែលទៅបន្តវិជ្ជានៅបរទេស គេទៅប្រទេសណាខ្លះ?

Cambodian students who go abroad to continue studying in their field go to which countries?

Sarom

2. ធម្មតាគេចូលចិត្តទៅរៀននៅស្រុកបារាំងព្រោះគេចេះភាសានេះស្រាប់។

Usually they like to go to study in France, because they already know French.

3. តែក្រៅពីស្រុកបារាំងមាននិស្សិតខ្លះបានអាហារូបករណ៍ទៅរៀននៅប្រទេសផ្សេងៗទៀត ដូចជាប្រទេសជប៉ុន អាល្លឺម៉ង់ រុស្ស៊ី ចិន និងអង់គ្លេសជាដើម។

But besides France, there are some students who get scholarships to go and study in various countries, such as Japan, Germany, Russia, China, and England.

John

4. របៀបរៀននៅស្រុកខ្មែរដូចម្ដេច?

What is the system of study like in Cambodia?

Sarom

5. គេរៀននៅសាលាបឋមសិក្សា ៦ ឆ្នាំ ហើយបន្ទាប់ពីនោះគេរៀននៅសាលាមធ្យមសិក្សា ឬវិទ្យាល័យ ៧ ឆ្នាំ។

They study in elementary schools for six years, and after this they study in middle school or the lycée for seven years.

6. ពីដើមនៅថ្នាក់បឋមសិក្សាគេអាចប្រឡងយកវិញ្ញាបនប័ត្របឋមសិក្សានៅចុងឆ្នាំទី ៦ ។

Before, in the elementary section they could take a test and get an elementary certificate at the end of the sixth year.

7. ឥឡូវគេមិនប្រឡងទេ ព្រោះគេឈប់ទទួលស្គាល់វិញ្ញាបនប័ត្របឋមសិក្សាហើយ ពេលគេទៅរកការធ្វើ។

Now they don't take a test, because they have stopped accepting the the elementary certificate when people look for work.

8. កាលណាគេរៀនបានលេខល្អ គេអាចទៅចូលរៀននៅវិទ្យាល័យ ឬអនុវិទ្យាល័យតែម្ដង។

When they study and get good grades, they can go to a lycée or junior high.

9. នៅវិទ្យាល័យគេប្រឡងយក សញ្ញាប័ត្របានបីដង គឺនៅឆ្នាំទី៤ ទី៦ និងទី៧ ។	In the lycée they take a test for a diploma three times. That is, in the fourth year, the sixth and the seventh.
10. នៅចុងឆ្នាំសិក្សាទី៤ គេប្រឡង យកសញ្ញាប័ត្រមធ្យមសិក្សាហើយ នៅចុងឆ្នាំទី៦ និងទី៧គេប្រឡងយក មធ្យមសិក្សាប័ត្រភាគទី១និងទី២ ។	At the end of four years, they take the test for the middle diploma and at the end of the sixth year and seventh year they take a test for parts 1 and 2 of the baccalaureat.
11. កាលណាគេរៀនចប់ថ្នាក់មធ្យម- សិក្សាហើយគេអាចចេញទៅរក ការធ្វើបាន ។	When they finish studying in the middle school they can go look for work.
12. និស្សិតណាដែលចង់រៀនតទៅ មុខទៀត នោះគេអាចរើសមុខវិជ្ជា ផ្សេងៗ នៅសាកលវិទ្យាល័យដើម្បី រៀបចំខ្លួនជាអ្នកឯកទេសទៅថ្ងៃ មុខ ។	Any student who wants to continue can choose to take various subjects at the university in order to prepare himself as an expert for the future.

DRILLS

Drill A. Substitution

1.	តាមធម្មតាលោកចូលចិត្តលេងបាល់ បោះទេ?	Do you usually like to play basketball?
2.	តាមធម្មតាលោកចូលចិត្តទៅអុំទូកទេ?	Do you usually like to go rowing?
3.	តាមធម្មតាលោកចូលចិត្តបើកឡានទេ?	Do you usually like to drive a car?
4.	តាមធម្មតាលោកចូលចិត្តដើរលេងទេ?	Do you usually like to go out?
5.	តាមធម្មតាលោកចូលចិត្តញ៉ាំបៀរទេ?	Do you usually like to drink beer?
6.	តាមធម្មតាលោកចូលចិត្តញ៉ាំម្ហូបចិនទេ?	Do you usually like to eat Chinese food?
7.	តាមធម្មតាលោកចូលចិត្តរៀនអង់គ្លេស ទេ?	Do you usually like to study English?
8.	តាមធម្មតាលោកចូលចិត្តហាត់ប្រាណ នៅពេលព្រឹកទេ?	Do you usually like to do calisthenics in the morning?

Drill B. Substitution

1.	ខ្ញុំធ្លាប់ទៅរៀននៅសាលានោះដែរ កាលខ្ញុំនៅពីក្មេង។	I used to go to that school when I was still young.
2.	ខ្ញុំធ្លាប់ទៅរៀននៅវិទ្យាល័យនោះដែរ កាលខ្ញុំនៅពីក្មេង។	I used to go to that lycée when I was still young.
3.	ខ្ញុំធ្លាប់ទៅរៀននៅមហាវិទ្យាល័យនោះ ដែរកាលខ្ញុំនៅពីក្មេង។	I used to go to that university when I was still young.
4.	ខ្ញុំធ្លាប់ទៅរៀននៅវត្តនោះដែរកាលខ្ញុំនៅ ពីក្មេង។	I used to go to that wat when I was still young.
5.	ខ្ញុំធ្លាប់ទៅរៀននៅសាលាភាសាបរទេស នោះដែរកាលខ្ញុំនៅពីក្មេង។	I used to go to that foreign language school when I was still young.
6.	ខ្ញុំធ្លាប់ទៅបង្រៀននៅសាលាភាសា បរទេសនោះដែរកាលខ្ញុំនៅពីក្មេង។	I used to go teach at that foreign language school when I was still young.
7.	ខ្ញុំធ្លាប់ទៅធ្វើការនៅសាលាភាសា បរទេសនោះដែរកាលខ្ញុំនៅពីក្មេង។	I used to go to work at that foreign language school when I was still young.
8.	ខ្ញុំធ្លាប់ទៅស្តាប់គេបង្រៀននៅសាលា ភាសាបរទេសនោះដែរកាលខ្ញុំនៅពី ក្មេង។	I used to listen to them teaching at that foreign language school when I was still young.

Drill C. Double Substitution

1. ក្រោយពីរៀននៅសាលាបឋមសិក្សា៦ឆ្នាំមក ខ្ញុំទៅរៀននៅសាលាមធ្យមសិក្សា។	After having studied in elementary school for six years, I went to study in the middle school.
2. ក្រោយពីរៀននៅវិទ្យាល័យ៦ឆ្នាំមក ខ្ញុំទៅរៀននៅមហាវិទ្យាល័យ។	After having studied in the lycée for six years, I went to study in the university.
3. ក្រោយពីរៀនខាងបច្ចេកទេស៦ឆ្នាំមក ខ្ញុំចេញទៅធ្វើការ។	After having studied technology for six years, I left to go to work.
4. ក្រោយពីរៀនខាងសេដ្ឋកិច្ច៦ឆ្នាំមក ខ្ញុំបានសញ្ញាបត្រជាន់ខ្ពស់។	After having studied economics for six years, I got an advanced degree.
5. ក្រោយពីធ្វើទាហាន៦ឆ្នាំមក ខ្ញុំទៅរៀនម្ដងទៀត។	After having been a soldier for six years, I went back to school again.
6. ក្រោយពីធ្វើការនៅក្រសួងការបរទេស៦ឆ្នាំមក ខ្ញុំចេញទៅរៀនខាងច្បាប់។	After having worked in the Foreign Ministry for six years, I left to study law.
7. ក្រោយពីរៀនខ្មែរអស់៦ឆ្នាំមក ខ្ញុំជាអ្នកជំនាញខាងភាសាខ្មែរ។	After having studied Cambodian for six years, I became an expert in Cambodian.
8. ក្រោយពីនៅបរទេសអស់៦ឆ្នាំមក ខ្ញុំភ្លេចភាសាបារាំងស្ទើរអស់។	After having lived abroad for six years, I forgot most of my French.

Drill D. Multiple Substitution

1. នៅចុងឆ្នាំទី៤នៃវិទ្យាល័យគេ ត្រូវប្រឡងយកមធ្យមសិក្សាបឋមភូមិ។	At the end of the fourth year of lycée they have to take a test for the middle diploma (certificate).
2. នៅចុងឆ្នាំទី៤នៃមហាវិទ្យាល័យគេ អាចប្រឡងយកសញ្ញាបត្របរិញ្ញាបត្រ។	At the end of the fourth year of the university they can take a test for the Bachelor's degree.
3. នៅចុងឆ្នាំទី៦នៃមហាវិទ្យាល័យគេ អាចប្រឡងយកសញ្ញាបត្រអនុបណ្ឌិត។	At the end of the sixth year of the university they can take a test for the Master's degree.
4. នៅចុងឆ្នាំទី១នៃមហាវិទ្យាល័យគេមិន អាចប្រឡងយកសញ្ញាបត្រអ្វីទេ។	At the end of the first year of the university they can't take a test for any degree at all.
5. នៅចុងឆ្នាំទី៥នៃមហាវិទ្យាល័យគេ អាចប្រឡងយកសញ្ញាបត្រអនុបណ្ឌិតបាន។	At the end of the fifth year at the university they can take the test for the Master's degree.

6. នៅចុងឆ្នាំទី៣នៃមហាវិទ្យាល័យគេអាចប្រឡងយកសញ្ញាប័ត្រមួយ។

At the end of the third year at the university they can take the test for a degree.

Drill E. Response

MODEL: គ្រូ: និស្សិតដែលបានអាហារូបករណ៍ គេទៅរៀនតែស្រុកបារាំងទេ ឬទៅស្រុកណាទៀត? (ស្រុកអាមេរិក កាណាដា និងជប៉ុនជាដើម)

Teacher: Do students who receive scholarships only go to France to study or to other countries? (America, Canada, and Japan)

សិស្ស: បាទ និស្សិតដែលបានអាហារូបករណ៍ គេទៅរៀននៅស្រុកបារាំងហើយនិងស្រុកឯទៀតដែរ ដូចជាស្រុកអាមេរិក កាណាដា និងជប៉ុនជាដើម ។

Student: Students who receive scholarships go to France and other countries such as America, Canada and Japan.

1. កូនសិស្សដែលបានអាហារូបករណ៍ គេទៅរៀនតែស្រុកអាមេរិកទេ ឬស្រុកណាទៀត? (ស្រុកបារាំង អង់គ្លេស និងស្វ៊ីសជាដើម)

បាទ កូនសិស្សដែលបានអាហារូបករណ៍ គេទៅរៀននៅស្រុកអាមេរិកហើយនិងស្រុកឯទៀតដែរ ដូចជាស្រុកបារាំង អង់គ្លេស និងស្វ៊ីសជាដើម ។

2. អ្នកការងារដែលក្រសួងបញ្ជូនទៅហ្វឹកហាត់នៅបរទេស គេទៅតែស្រុកអាល្លឺម៉ង់ទេ ឬស្រុកណាទៀត? (ស្រុកជប៉ុន រុស្ស៊ី និងចិនជាដើម)

បាទ អ្នកការងារដែលក្រសួងបញ្ជូនទៅហ្វឹកហាត់នៅបរទេស គេទៅស្រុកអាល្លឺម៉ង់ហើយនិងស្រុកឯទៀតដូចជាស្រុកជប៉ុន ចិន និងរុស្ស៊ីជាដើម ។

3. និស្សិតដែលទៅរៀនពេទ្យធ្មេញនៅបរទេស គេទៅតែស្រុកបារាំងទេ ឬស្រុកណាទៀត? (ស្រុកស្វ៊ីស ជប៉ុន និងអាមេរិកជាដើម)

បាទ និស្សិតដែលទៅរៀនពេទ្យធ្មេញនៅបរទេស គេទៅស្រុកបារាំងហើយនិងស្រុកឯទៀតដែរ ដូចជាស្រុកស្វ៊ីស ជប៉ុន និងអាមេរិកជាដើម ។

4. គ្រូបង្រៀនដែលទៅរៀនវិធីបង្រៀនភាសាបរទេស គេទៅតែស្រុកអង់គ្លេសទេ ឬស្រុកណាទៀត? (ស្រុកអាល្លឺម៉ង់ និងស្រុកបារាំងជាដើម)

បាទ គ្រូបង្រៀនដែលទៅរៀនវិធីបង្រៀនភាសាបរទេស គេទៅស្រុកអង់គ្លេសហើយនិងស្រុកឯទៀតដែរ ដូចជាអាល្លឺម៉ង់ និងស្រុកបារាំងជាដើម ។

5. គ្រូពេទ្យដែលទៅហាត់ការនៅបរទេស គេទៅតែស្រុកបារាំងទេ ឬស្រុកណាទៀត?

បាទ គ្រូពេទ្យដែលទៅហាត់ការនៅបរទេស គេទៅស្រុកបារាំងហើយនិងស្រុកឯទៀតដែរ

(ស្រុកចិននិងស្រុកក្លិងជាដើម)	ដូចជាស្រុកចិននិងស្រុកក្លិងជាដើម។

Drill F. Response

MODEL:	គ្រូ : ឆ្នាំនេះគេត្រូវប្រឡងចូលទេ? (មានបេក្ខជនតិច)	**Teacher:** Do they have to take an examination to get in this year?
	សិស្ស : បាទតាមខ្ញុំដឹង គេមិនបាច់ ប្រឡងទេ ព្រោះមានបេក្ខ- ជនតិច។	**Student:** As far as I know they don't have to take a test because there are few candidates this year.
1.	ឆ្នាំនេះគេត្រូវបង្រៀនពីរវេនទេ? (មានកូនសិស្សតិច)	បាទតាមខ្ញុំ គេមិនបាច់បង្រៀនទេ ព្រោះមានកូនសិស្សតិច។
2.	សិស្សឆ្នាំនេះគេត្រូវទៅធ្វើការទេ? (គេឲ្យឈប់១ឆ្នាំ)	តាមខ្ញុំដឹង គេមិនបាច់ទៅធ្វើទេ ព្រោះ គេឲ្យឈប់១ឆ្នាំ។
3.	សិស្សឆ្នាំនេះគេត្រូវ[illegible]ទៅហាត់ទេ? (ទើបនឹងហាត់ពីម្សិលមិញហើយ)	បាទ តាមខ្ញុំដឹង គេមិនបាច់ទៅហាត់ទេ ព្រោះទើបនឹងហាត់ពីម្សិលមិញហើយ។
4.	ថ្ងៃនេះលោកទៅសាលារៀនទេ? (កូនសិស្សគេ[illegible]រៀន)	បាទ តាមខ្ញុំដឹង គេមិនបាច់ទៅសាលារៀន ទេ ព្រោះកូនសិស្សគេ[illegible] រៀន។
5.	ថ្ងៃនេះគេទៅប្ដូរកាតរៀនទេ? (កាតបានប្ដូរអស់ហើយពីម្សិល មិញ)	បាទ តាមខ្ញុំដឹង គេមិនបាច់ទៅប្ដូរកាត ទេ ព្រោះពីម្សិលមិញ កាតបាន ប្ដូរអស់ហើយ។

Drill G. Response

MODEL:	គ្រូ : កាលណាលោករៀនបានសញ្ញា ប័ត្រមធ្យមសិក្សាហើយ លោកគិតធ្វើអ្វី? (ទៅរៀន ខាងសេដ្ឋកិច្ច)	**Teacher:** When you have studied and gotten your middle certificate, what do you plan to do? (go study economics)
	សិស្ស : កាលណាខ្ញុំរៀនបានសញ្ញា ប័ត្រមធ្យមសិក្សាហើយ ខ្ញុំទៅរៀនខាងសេដ្ឋកិច្ច។	**Student:** When I have studied and gotten my middle certificate, I will go study economics.
1.	កាលណាលោករៀនបានសញ្ញា ប័ត្រពេទ្យស្រីហើយលោកគិតធ្វើអ្វី? (ទៅយក [illegible])	កាលណាខ្ញុំរៀនបានសញ្ញាប័ត្រ ពេទ្យស្រីហើយ ខ្ញុំទៅយក[illegible]។

2.	កាលណាលោកចេញពីសាលានេះទៅ លោកគិតទៅធ្វើអី? (ទៅបង្រៀននៅវិទ្យាល័យ)	កាលណាខ្ញុំចេញពីសាលានេះទៅ ខ្ញុំទៅបង្រៀននៅវិទ្យាល័យ។
3.	កាលណាលោកទៅដល់ភ្នំពេញភ្លាម លោកគិតធ្វើអី? (ទៅរកបន្ទប់១នៅសណ្ឋាគារ)	កាលណាខ្ញុំទៅដល់ភ្នំពេញភ្លាម ខ្ញុំទៅរកបន្ទប់មួយនៅសណ្ឋាគារ។
4.	កាលណាលោកទៅជួបគាត់លោកគិតនិយាយអំពីអី? (និយាយអំពីកូនសិស្សដែលមិនមករៀន)	កាលណាខ្ញុំទៅជួបនឹងគាត់ ខ្ញុំនិយាយអំពីកូនសិស្សដែលមិនមករៀន។
5.	កាលណាលោកមកពីប្រទេសកម្ពុជាវិញ លោកគិតធ្វើអី? (នឹងទៅជួបគ្រួសារខ្ញុំ)	កាលណាខ្ញុំមកពីប្រទេសកម្ពុជាវិញ ខ្ញុំនឹងទៅជួបគ្រួសារខ្ញុំ។

Drill H. Expansion

1.	នៅប្រទេសកម្ពុជាមានសាលារៀន	There are schools in Cambodia.
2.	សព្វថ្ងៃនេះនៅប្រទេសកម្ពុជាមានសាលារៀន។	These days there are schools in Cambodia.
3.	សព្វថ្ងៃនេះនៅប្រទេសកម្ពុជាមានសាលារៀនគ្រប់គ្រាន់ហើយ។	These days there are sufficient schools in Cambodia.
4.	សព្វថ្ងៃនេះនៅប្រទេសកម្ពុជាមានសាលារៀនគ្រប់គ្រាន់ហើយ។ ចំនួនអ្នកដែលមិនចេះអក្សរ។	These days there are sufficient schools in Cambodia and a number of people who are illiterate.
5.	សព្វថ្ងៃនេះនៅប្រទេសកម្ពុជាមានសាលារៀនគ្រប់គ្រាន់ហើយ។ ចំនួនអ្នកដែលមិនចេះអក្សរមានយ៉ាងច្រើនណាស់។	These days there are sufficient schools in Cambodia and quite a number of people who are illiterate.
6.	សព្វថ្ងៃនេះនៅប្រទេសកម្ពុជាមានសាលារៀនគ្រប់គ្រាន់ហើយ។ ចំនួនអ្នកដែលមិនចេះអក្សរមានយ៉ាងច្រើនណាស់ប្រហែលពីរភាគរយ។	These days there are sufficient schools in Cambodia, and at the most two percent of the people are illiterate.
7.	សព្វថ្ងៃនេះនៅប្រទេសកម្ពុជាមានសាលារៀនគ្រប់គ្រាន់ហើយ។ ចំនួនអ្នកដែលមិនចេះអក្សរមានយ៉ាងច្រើនណាស់ប្រហែលពីរភាគរយប៉ុណ្ណោះ។	These days there are sufficient schools in Cambodia, and at the most only two percent of the people are illiterate.

Drill I. Reduction

1.	សព្វថ្ងៃនេះនៅប្រទេសកម្ពុជាមានសាលារៀនគ្រប់គ្រាន់ហើយ។ចំនួនអ្នកដែលមិនចេះអក្សរនោះមានយ៉ាងច្រើនណាស់ត្រឹមតែពីរភាគរយប៉ុណ្ណោះ។	These days there are sufficient schools in Cambodia, and at the most only two percent of the people are illiterate.
2.	សព្វថ្ងៃនេះនៅប្រទេសកម្ពុជាមានសាលារៀនគ្រប់គ្រាន់ហើយ។ចំនួនអ្នកដែលមិនចេះអក្សរនោះមានយ៉ាងច្រើនណាស់ត្រឹមតែពីរភាគរយ។	These days there are sufficient schools in Cambodia, and at the most two percent of the people are illiterate.
3.	សព្វថ្ងៃនេះនៅប្រទេសកម្ពុជាមានសាលារៀនគ្រប់គ្រាន់ហើយ។ចំនួនអ្នកដែលមិនចេះអក្សរនោះមានយ៉ាងច្រើនណាស់។	These days there are sufficient schools in Cambodia and quite a number of people who are illiterate.
4.	សព្វថ្ងៃនេះនៅប្រទេសកម្ពុជាមានសាលារៀនគ្រប់គ្រាន់ហើយ។ចំនួនអ្នកដែលមិនចេះអក្សរ។	These days there are sufficient schools in Cambodia and a number of people who are illiterate.
5.	សព្វថ្ងៃនេះនៅប្រទេសកម្ពុជាមានសាលារៀនគ្រប់គ្រាន់ហើយ។	These days there are sufficient schools in Cambodia.
6.	សព្វថ្ងៃនេះនៅប្រទេសកម្ពុជាមានសាលារៀន។	These days there are schools in Cambodia.
7.	នៅប្រទេសកម្ពុជាមានសាលារៀន។	There are schools in Cambodia.

UNIT 83

BASIC DIALOGUE

John

1. តាមខ្ញុំមើលទៅរបៀបបង្រៀននៅស្រុកខ្មែរមិនខុសពីស្រុកបារាំងទេ។

As I see it, the system of education in Cambodia is not different from that in France.

Sarom

2. បាទត្រូវហើយ គេត្រូវប្រឡងយកសញ្ញាបត្រផ្សេងៗនៅឆ្នាំដែលគេបានរៀនចប់កម្មវិធីសិក្សា។

Right. They have to take a test for the various diplomas in the year that they finish the education program.

John

3. គេរៀនចប់កម្មវិធីសិក្សាក្នុង១ឆ្នាំម្ដងឬអី?

Do they finish the education program once a year?

Sarom

4. បាទ ថាអញ្ចឹងក៏បានដែរ ក្នុង១ឆ្នាំៗ គេមានកម្មវិធី១សម្រាប់ថ្នាក់ដែលមានលំដាប់ស្មើគ្នា។

Yes, you can say that, because in each year they have one program for the classes that are at the same level.

John

5. សុំលោកឲ្យឧទាហរណ៍ខ្ញុំបានទេ?

Can you give me an example?

Sarom

6. បាទ ឧបមា ដូចជា កូនសិស្សរៀននៅថ្នាក់ទី២នៅវិទ្យាល័យឬអនុវិទ្យាល័យគេមានកម្មវិធី១ដូចគ្នាទាំងអស់។

Yes. For example, students studying in the second class of the high school or the lycée all have the same program.

7. តែដើម្បីឡើងទៅថ្នាក់ទី១ គេមិនបាច់ប្រឡងទេ។ គេត្រូវរៀនឲ្យបានលេខល្អ បើមិនបានទេ គេត្រូវតែរៀនថ្នាក់ដដែលមួយឆ្នាំទៀត។

But in order to pass up to the first class they don't have to take a test. They have to study to get good marks. If they don't get them they have to study the same class for another year.

John

8. ខ្ញុំយល់ហើយ អញ្ចឹងគឺគេប្រឡងយកសញ្ញាបត្រតែកាលណាគេរៀនចប់លំដាប់សិក្សាមួយៗ ដូចជាប្រឡងយក

I understand. They take an exam for a diploma when they finish studying each level. For example, they take an examination for the middle

	សញ្ញាបត្រមធ្យមសិក្សា ក្រោយរៀនបាន ៤ឆ្នាំនៅវិទ្យាល័យ។		certificate after having studied four years at the lycée.
9.	បាទ អញ្ចឹងហើយ។ លោកដឹងទេ កូនសិស្សណាដែលរៀនពូកែ គេអាចសុំទៅប្រឡងយកសញ្ញាបត្របានមុនពេលកំណត់។	Sarom	That's it. And you know, students who study well can ask to take the examination for a diploma outside the scheduled time.
10.	អញ្ចឹងបើគេប្រឡងជាប់គេចំណេញឆ្នាំ។	John	If they pass they gain a year.
11.	បាទ ហ្នឹងហើយ ហើយគេផ្លោះ ១ថ្នាក់ទៅរៀននៅថ្នាក់ខ្ពស់។	Sarom	That's right, and they skip one class to go on to study in a higher class.
12.	កូនសិស្សច្រើនផ្លោះថ្នាក់ទេ?	John	Are there a lot of students who skip a class?
13.	បាទ ១ឆ្នាំៗមានខ្លះជានិច្ច។ កូនសិស្សពូកែៗគេច្រើនតែទៅប្រឡង។	Sarom	Each year there are always some. Good students usually (go) take the test.
14.	កូនសិស្សខ្លះគេខំទៅរៀនឈ្នួលនៅពេលវ៉ាកង់ ដើម្បីឲ្យបានពូកែ ឬដើម្បីបញ្ចប់កម្មវិធីសិក្សានិងប្រឡង។		Some students try to study in a private school during vacation in order to get better or in order to finish the educational program and take the test.

DRILLS

Drill A. Substitution

1.	តាមខ្ញុំមើលទៅគេរៀនថ្ងៃនេះ។	I guess they are studying today.
2.	តាមខ្ញុំមើលទៅគាត់មកដល់ស្អែក។	I guess he'll arrive tomorrow.
3.	តាមខ្ញុំមើលទៅថ្ងៃនេះភ្លៀងមិនខាន។	I guess it'll rain without fail today.
4.	តាមខ្ញុំមើលទៅគាត់ភ្លេចហើយ។	I guess he has forgotten.
5.	តាមខ្ញុំមើលទៅគេនាំគ្នាទៅវត្ត។	I guess they're going together to the wat.
6.	តាមខ្ញុំមើលទៅខ្ញុំត្រូវតែទៅ។	I guess I must go.
7.	តាមខ្ញុំមើលទៅប្រពន្ធខ្ញុំមិនបានទៅទេ។	I guess my wife didn't go.
8.	តាមខ្ញុំមើលទៅខ្ញុំត្រូវទៅដល់ថ្ងៃសុក្រ។	I guess I'll have to arrive Friday.

Drill B. Substitution

1.	កម្មវិធីបង្រៀននៅវិទ្យាល័យនោះយ៉ាងម៉េច?	What is the program of study in that lycée?
2.	កម្មវិធីបង្រៀននៅសាលានោះយ៉ាងម៉េច?	What is the program of study in that school?
3.	កម្មវិធីបង្រៀននៅសាលា FSI យ៉ាងម៉េច?	What is the program of study at FSI?
4.	កម្មវិធីបង្រៀននៅសាលាអាមេរិកាំងយ៉ាងម៉េច?	What is the program of study in that American school?
5.	កម្មវិធីបង្រៀននៅសាលារៀនខ្មែរយ៉ាងម៉េច?	What is the program of study in that Cambodian school?
6.	កម្មវិធីបង្រៀននៅសាកលវិទ្យាល័យយ៉ាងម៉េច?	What is the program of study in that university?
7.	កម្មវិធីបង្រៀននៅសាលាទាហានយ៉ាងម៉េច?	What is the program of study in that military school?
8.	កម្មវិធីបង្រៀននៅសាលាឈ្នួលយ៉ាងម៉េច?	What is the program of study in that private school?

Drill C. Unpredictable Multiple Substitution

1.	ភាគច្រើននៃកូនសិស្សដែលរៀនបានមធ្យមសិក្សាច្រើនរៀនតទៅទៀតខាងវិទ្យា	The majority of pupils who study and get the middle certificate

វិជ្ជាផ្សេងៗ។	for the most part continue to study various subjects.
2. ភាគច្រើននៃនិស្សិតដែលរៀននៅមហាវិទ្យាល័យច្រើនរៀនតទៅទៀតខាងមុខវិជ្ជាផ្សេងៗ។	The majority of students who study in the university for the most part continue to study various subjects.
3. ភាគច្រើននៃមន្ត្រីរាជការដែលរៀននៅមហាវិទ្យាល័យច្រើនរៀនយកបាឆឺល័រខាងមុខវិជ្ជាផ្សេងៗ។	The majority of government officials who study in the university for the most part take the Bachelor's degree in various subjects.
4. ភាគច្រើននៃព្រះសង្ឃដែលរៀននៅមហាវិទ្យាល័យច្រើនរៀនខាងសាសនាតែខ្លះទៀតខាងមុខវិជ្ជាផ្សេងៗ។	The majority of monks who study in the university for the most part study religion, but others study various subjects.
5. ភាគច្រើនកូនសិស្សដែលរៀននៅ FSI ច្រើនរៀនខាងភាសាបរទេស។	The majority of students who study at FSI for the most part study foreign languages.
6. ភាគច្រើនទាហានដែលរៀននៅ FSI ច្រើនរៀនខាងភាសាយួន។	The majority of soldiers who study at FSI for the most part study Vietnamese.
7. ភាគច្រើនគ្រូបង្រៀនដែលរៀននៅមហាវិទ្យាល័យច្រើនរៀនយកសញ្ញាបត្រជាន់ខ្ពស់។	The majority of teachers who study at the university for the most part study for advanced degrees.
8. ភាគច្រើននៃនិស្សិតបរទេសដែលរៀននៅមហាវិទ្យាល័យច្រើនរៀនយកបាឆឺល័រ។	The majority of foreign students who study at the university for the most part study for the Bachelor's degree.

Drill D. Double Substitution

1. ក្នុងមួយឆ្នាំៗគេមានកម្មវិធីថ្មីសម្រាប់ថ្នាក់ជាន់ខ្ពស់។	Every year they have a new program for the advanced classes.
2. ក្នុងមួយឆ្នាំៗគេបង្កើតឡើងនូវកម្មវិធីថ្មីសម្រាប់ថ្នាក់ទីបី។	Every year they establish a new program for the third class.
3. ក្នុងមួយឆ្នាំៗគេធ្វើសាលារៀនថ្មីសម្រាប់ថ្នាក់ទី១២។	Every year they build a new school for the twelfth class.
4. ក្នុងមួយខែៗគេរៀបចំបន្ទប់ថ្មីសម្រាប់ថ្នាក់ទី១២។	Every month they arrange (prepare) a new room for the twelfth class.
5. ក្នុងមួយខែៗគេត្រូវជួសជុលបន្ទប់រៀនសម្រាប់ថ្នាក់ទី៦។	Every month they have to repair the classroom for the 6th class.
6. ក្នុងមួយអាទិត្យៗគេត្រូវប្តូរគ្រូបង្រៀនថ្មី	Every week they change the teacher

ទី៦។	of the 6th class.

Drill E. Double Substitution

1.	កាលណាកូនសិស្សមិនយល់ គ្រូបង្រៀនឲ្យឧទាហរណ៍។	When the students don't understand, the teacher gives them an example.
2.	កាលណាកូនសិស្សមិនយល់ច្បាស់ គ្រូបង្រៀនពន្យល់ថែម។	When the students don't understand clearly, the teacher explains some more.
3.	កាលណាកូនសិស្សនិយាយក្នុងថ្នាក់ គ្រូបង្រៀនប្រាប់ឲ្យគេនៅស្ងៀម។	When the students talk in the classroom, the teacher tells them to be quiet.
4.	កាលណាកូនសិស្សថាមិនច្បាស់ គ្រូបង្រៀនប្រាប់ឲ្យគេថាម្តងទៀត។	When the students don't speak clearly, the teacher tells them to say it once more.
5.	កាលណាកូនសិស្សមិនមករៀនច្រើនដង គ្រូបង្រៀនប្តឹងទៅនាយកសាលា។	When the students don't come to school many times, the teacher reports it to the principal of the school.
6.	កាលណាកូនសិស្សខ្ជិលពេក គ្រូបង្រៀនដាក់ទោស។	When the students are very lazy, the teacher punishes them.
7.	កាលណាកូនសិស្សមាត់ច្រើន គ្រូបង្រៀនឲ្យធ្វើការច្រើន។	When the students talk too much, the teacher has them do a lot of work.
8.	កាលណាកូនសិស្សរៀនពូកែ គ្រូបង្រៀនសប្បាយចិត្ត។	When the students study well, the teacher is content.

Drill F. Response

MODEL:	គ្រូ ៖ របៀបបង្រៀននៅស្រុកខ្មែរយ៉ាងម៉េច? (ប្រហែលគ្នានឹងរបៀបបង្រៀននៅស្រុកបារាំង)	Teacher: What is the method of teaching in Cambodia? (almost the same as the method of teaching in France)
	សិស្ស៖ របៀបបង្រៀននៅស្រុកខ្មែរប្រហែលគ្នានឹងរបៀបបង្រៀននៅស្រុកបារាំង។	Student: The method of teaching in Cambodia is almost the same as the method of teaching in France.
1.	របៀបបង្រៀននៅស្រុកអាមេរិកយ៉ាងម៉េច? (ប្រហែលគ្នានឹងរបៀបបង្រៀននៅស្រុកអង់គ្លេស)	របៀបបង្រៀននៅស្រុកអាមេរិកប្រហែលគ្នានឹងរបៀបបង្រៀននៅស្រុកអង់គ្លេស។
2.	របៀបធ្វើការនៅស្រុកអង់គ្លេសយ៉ាងម៉េច? (ប្រហែលគ្នានឹងរបៀបធ្វើការនៅអាមេរិក)	របៀបធ្វើការនៅស្រុកអង់គ្លេសប្រហែលគ្នានឹងរបៀបធ្វើការនៅអាមេរិក។

3. គេបើកឡាននៅស្រុកអង់គ្លេសយ៉ាងម៉េច? (ដូចគេបើកនៅហុងកុង)	គេបើកឡាននៅស្រុកអង់គ្លេសដូចគេបើកនៅហុងកុង។
4. គេធ្វើដំណើរទៅស្រុកអាមេរិកយ៉ាងម៉េច? (តាមកប៉ាល់ហោះ)	គេធ្វើដំណើរទៅស្រុកអាមេរិកតាមកប៉ាល់ហោះ។
5. គាត់ទៅធ្វើការយ៉ាងម៉េច? (តាមឡានឈ្នួល)	គាត់ទៅធ្វើការតាមឡានឈ្នួល។

Drill G. Response

MODEL:	គ្រូ ថ្នាក់ណាដែលមានកូនសិស្សរៀនពូកែច្រើនជាងគេ? (ថ្នាក់ទី៥ ខ)	Teacher: Which class is it that has the students who study the best? (Five B)
	សិស្ស៖ ថ្នាក់ទី៥ ខ មានកូនសិស្សរៀនពូកែច្រើនជាងគេ។	Student: Class Five B has the students who study the best.

1. ថ្នាក់ណាដែលមានកូនសិស្សក្មេងៗច្រើនជាងគេ? (ថ្នាក់ទី១ ក)	ថ្នាក់ទី១ ក មានកូនសិស្សក្មេងៗច្រើនជាងគេ។
2. ខេត្តណាដែលមានកូនសិស្សច្រើនជាងគេ? (ខេត្តកណ្តាល)	ខេត្តកណ្តាលមានកូនសិស្សច្រើនជាងគេ។
3. សាលាណាដែលមានកូនសិស្សច្រើនជាងគេ? (វិទ្យាល័យស៊ីសុវត្ថិ)	វិទ្យាល័យស៊ីសុវត្ថិមានកូនសិស្សច្រើនជាងគេ។
4. ស្រុកណាដែលមានផ្ទះច្រើនជាងគេ? (ស្រុកខៀនស្វាយ)	ស្រុកខៀនស្វាយមានផ្ទះច្រើនជាងគេ។
5. ភូមិណាដែលមានមនុស្សច្រើនជាងគេ? (ភូមិមួយនៅប្រហែលពីរគីឡូពីក្រុងនេះ)	ភូមិមួយនៅប្រហែលពីរគីឡូពីក្រុងនេះមានមនុស្សច្រើនជាងគេ។

Drill H. Expansion

1. នៅពេលវិស្សមកាល	At vacation time
2. នៅពេលវិស្សមកាលម្តងៗ	At every vacation time
3. នៅពេលវិស្សមកាលម្តងៗកូនសិស្សខ្លះ	At every vacation time some students
4. នៅពេលវិស្សមកាលម្តងៗកូនសិស្សខ្លះទៅជួលគ្រូបង្រៀន។	At every vacation time some students go hire teachers.
5. នៅពេលវិស្សមកាលម្តងៗកូនសិស្សខ្លះទៅជួលគ្រូបង្រៀនដើម្បីបង្ខំខ្លួនឲ្យរៀនឲ្យបានពូកែ។	At every vacation time some students go hire teachers so they will force themselves to study to become good.

6.	នៅពេលវិស្សមកាលម្ដងៗកូនសិស្សខ្លះទៅជួលគ្រូបង្រៀនដើម្បីខំរៀនឲ្យបានពូកែឬចង់ប្រឡងរំលងថ្នាក់។	At every vacation time some students go hire teachers so they will force themselves to study to become good or (because they) want to take a test to skip a class.
7.	នៅពេលវិស្សមកាលម្ដងៗកូនសិស្សខ្លះទៅជួលគ្រូបង្រៀនដើម្បីខំរៀនឲ្យបានពូកែឬចង់ប្រឡងរំលងថ្នាក់នៅឆ្នាំខាងមុខ។	At every vacation time some students go hire teachers so they will force themselves to study to become good or (because they) want to take a test to skip a class in the next year.

Drill I. Reduction

1.	នៅពេលវិស្សមកាលម្ដងៗកូនសិស្សខ្លះទៅជួលគ្រូបង្រៀនដើម្បីខំរៀនឲ្យបានពូកែឬចង់ប្រឡងរំលងថ្នាក់នៅឆ្នាំខាងមុខ។	At every vacation time some students go hire teachers so they will force themselves to study to become good or (because they) want to take a test to skip a class in the next year.
2.	នៅពេលវិស្សមកាលម្ដងៗកូនសិស្សខ្លះទៅជួលគ្រូបង្រៀនដើម្បីខំរៀនឲ្យបានពូកែឬចង់ប្រឡងរំលងថ្នាក់។	At every vacation time some students go hire teachers so they will force themselves to study to become good or (because they) want to take a test to skip a class.
3.	នៅពេលវិស្សមកាលម្ដងៗកូនសិស្សខ្លះទៅជួលគ្រូបង្រៀនដើម្បីខំរៀនឲ្យបានពូកែ។	At every vacation time some students go hire teachers so they will force themselves to study to become good.
4.	នៅពេលវិស្សមកាលម្ដងៗកូនសិស្សខ្លះទៅជួលគ្រូបង្រៀន។	At every vacation time some students go hire teachers.
5.	នៅពេលវិស្សមកាលម្ដងៗកូនសិស្សខ្លះ	At every vacation time some students
6.	នៅពេលវិស្សមកាលម្ដងៗ	At every vacation time
7.	នៅពេលវិស្សមកាល	At vacation time

UNIT 84

BASIC DIALOGUE

	John	
1.	លោកសារុម របៀបប្រឡងនៅស្រុកខ្មែរយ៉ាងម៉េច?	What is the method of examination in Cambodia?
	Sarom	
2.	បាទ ការប្រឡងយកសញ្ញាប័ត្រមធ្យមសិក្សានិងសញ្ញាប័ត្រជាន់ខ្ពស់ៗទៀតនោះមានធ្វើពីរដងក្នុងមួយឆ្នាំ នៅចុងឆ្នាំសិក្សា។	Examinations for the middle school certificate and other higher certificates are taken twice a year - at the end of the school year.
3.	ក្នុងពេលមួយអាទិត្យមុនដំបូងគេត្រូវទៅប្រឡងផ្នែកសរសេរ។ ក្នុងពេលនេះកូនសិស្សប្រឡងគ្រប់វិជ្ជាដែលគេបានរៀន ដូចមានការតែងសេចក្ដី គណិតសាស្ត្រ គីមី វិជ្ជាសាស្ត្រ និងរូបសាស្ត្រជាដើម។	During the first week they have to take the written examination. At this time the students take examinations in all the subjects that they have studied, such as composition, mathematics, chemistry, science and physics.
	John	
4.	តាមខ្ញុំស្មានមើលទៅគេមានប្រឡងមួយ ១ ថ្ងៃ ។	I think they have one subject a day.
	Sarom	
5.	បាទ តាមធម្មតាបើមុខវិជ្ជានោះពិបាក ដូចជាខាងគណិតសាស្ត្រ គីមី វិជ្ជាសាស្ត្រជាដើមនេះ គេប្រឡងមុខវិជ្ជាមួយ ១ ថ្ងៃ ។	Yes. Usually, if that subject is as difficult as mathematics, chemistry or science, for example, they take one subject a day.
	John	
6.	គេឲ្យប៉ុន្មានម៉ោងទៅអញ្ចឹង?	How many hours do they allow?
	Sarom	
7.	ប្រឡងក្នុង ១ ថ្ងៃ?	For examinations in a day?

John

8. បាទ សំរាប់តែងសេចក្ដីឬធ្វើចំណោទ អីៗអញ្ចឹង ។

Yes. For composition or (to do) problems and things like that.

Sarom

9. អូ បីឬបួនម៉ោង ។

Oh, four or five hours.

John

10. កាលណាប្រឡងខាងផ្នែកសរសេរ ហើយ កូនសិស្សដឹងថាគេជាប់ឬធ្លាក់ ភ្លាមឬអី?

When they have finished the written exam, do the students know if they have passed or failed right away?

Sarom

11. បាទ ការហ្នឹងគេអាចថាបានតែ កូនសិស្សណាគេដឹងខ្លួនគេ ច្បាស់ថា គេធ្វើល្អឬមិនល្អ ។ បើចង់ឲ្យដឹងច្បាស់ តាមផ្លូវរាជការ គេត្រូវចាំ១ថ្ងៃឬពីរ ថ្ងៃ ទំរាំគ្រូៗគេពិនិត្យចប់អស់ ។

That they can say only for the students they know well themselves, whether they did well or not. To know officially for sure, they must wait a day or two until the teachers have finished correcting everything.

John

12. បើគេដឹងថាជាប់ហើយគេធ្វើអីទៀត?

If they know they have passed, what else do they do?

Sarom

13. បាទ គេត្រូវប្រឡងផ្នែកសួរផ្ទាល់មាត់ បើគេប្រឡងធ្លាក់ខាងផ្នែកនេះគេមិន អាចទទួលសញ្ញាបត្របានទេ តែគេ អាចទៅប្រឡងលើកពីរម្ដងទៀត ។

They must take the oral examinations. If they fail this section they don't get a certificate but they can take the oral test once more.

John

14. ប្រឡងលើកទី២ ក្រោយលើកទី១ ប៉ុន្មានខែ?

The second examination is how many months after the first test?

Sarom

15. ប្រហែលជាពីរខែ ។

Maybe two months.

John

16. ចុះអ្នកដែលប្រឡងធ្លាក់តាំងពី ផ្នែកសរសេរ គេទៅប្រឡងលើកទី២ បានទេ?

And how about the people who fail the written part: can they take the examination the second time?

Sarom

17. បាទ និងកូនសិស្សណាដែលប្រឡង បានពិន្ទុល្អគួរសំ ទើបគេអនុញ្ញាតឲ្យ ទៅប្រឡងលើកទី២ ។	Yes. And if the students who take the examination get rather good marks, only then are they permitted to take the second examination.
18. កាលណាគេប្រឡងធ្លាក់នៅលើក ទី២ ខាងសរសេរឬខាងសួរក៏ដោយគេ ត្រូវចាំមួយឆ្នាំទៀតទើបគេអាចទៅ ប្រឡងយកសញ្ញាប័ត្រដដែលទៀត បាន ។	If they fail the examination the second time-either the written part or the oral part-they have to wait another year. Only then can they take the examination for the same certificate.

DRILLS

Drill A. Substitution

1.	គេអាចទៅប្រឡងយកសញ្ញាប័ត្រមធ្យមសិក្សាពីរដងក្នុងមួយឆ្នាំ។	They can go take the examination for the middle certificate two times a year.
2.	គេអាចទៅប្រឡងយកសញ្ញាប័ត្រជាន់ខ្ពស់២ដងក្នុងមួយឆ្នាំ។	They can go take the examination for the advanced certificate two times a year.
3.	គេអាចទៅប្រឡងយកសញ្ញាប័ត្រខ្លះបាន២ដងក្នុងមួយឆ្នាំ។	They can go take the examination for some certificates two times a year.
4.	គេអាចទៅប្រឡងយកសញ្ញាប័ត្រប៊ីអេបាន២ដងក្នុងមួយឆ្នាំ។	They can go take the examination for the B.A. degree two times a year.
5.	គេអាចទៅប្រឡងយកសញ្ញាប័ត្របឋមសិក្សា២ដងក្នុងមួយឆ្នាំ។	They can go take the examination for the elementary certificate two times a year.
6.	គេអាចទៅប្រឡងយកសញ្ញាប័ត្រគរុវិជ្ជា២ដងក្នុងមួយឆ្នាំ។	They can go take the examination for the teaching certificate two times a year.
7.	គេអាចទៅប្រឡងយកសញ្ញាប័ត្រខាងពេទ្យ២ដងក្នុងមួយឆ្នាំ។	They can go take the examination for the medical certificate two times a year.
8.	គេអាចទៅប្រឡងយកសញ្ញាប័ត្រនៅសាលាទាហានពីរដងក្នុងមួយឆ្នាំ។	They can go take the examination for the certificate in the military school two times a year.

Drill B. Variable Substitution

1.	នៅអាទិត្យមុនដំបូងគេត្រូវប្រឡងខាងវិធីកសរសេរ។	In the first week they have to take the written test.
2.	នៅអាទិត្យទី២គេត្រូវប្រឡងខាងវិធីកសរសេរ។	In the second week they have to take the written test.
3.	នៅអាទិត្យទី២គេត្រូវផ្លាស់កន្លែងប្រឡង។	In the second week they have to change the examination site.
4.	នៅអាត្យទី២គេត្រូវចាប់ប្រឡងខាងសួរផ្ទាល់មាត់។	In the second week they have to begin to take the oral test.
5.	នៅអាទិត្យក្រោយបង្អស់គេត្រូវចាប់ប្រឡងខាងសួរផ្ទាល់មាត់។	In the last week they have to begin to take the oral test.
6.	នៅអាទិត្យក្រោយបង្អស់គេទៅមើលឈ្មោះនៅសាលា។	In the last week they have to go look for their names at the school.
7.	នៅអាទិត្យក្រោយបង្អស់គេបង្ហាញខ្លួនម្តងទៀត។	In the last week they have to appear once more.

8. នៅអាទិត្យក្រោយបង្អស់គេត្រូវស្តាប់គេហៅឈ្មោះ។	In the last week they have to listen when they call their names.

Drill C. Double Substitution

1. តាមខ្ញុំដឹងគេទៅសាលារៀនពីរដង១ថ្ងៃ។	As far as I know they go to school twice a day.
2. តាមខ្ញុំដឹងគេធ្វើការនៅសាលារៀនបីម៉ោង១ថ្ងៃ។	As far as I know they work in school three hours a day.
3. តាមខ្ញុំដឹងគេបើកឡានទៅសាលារៀន១ដង១ថ្ងៃ។	As far as I know they drive to school once a day.
4. តាមខ្ញុំដឹងគេត្រូវមកសាលារៀនពីរដង១ថ្ងៃ។	As far as I know they have to come to school twice a day.
5. តាមខ្ញុំដឹងគេសំអាតសាលារៀនច្រើនដង១ថ្ងៃ។	As far as I know they clean the school many times a day.
6. តាមខ្ញុំដឹងគេទៅសាលារៀនតែម្តងទេ១ថ្ងៃ។	As far as I know they go to school only once a day.

Drill D. Multiple Substitution

1. ក្នុង១អាទិត្យមុនដំបូងគេត្រូវប្រឡងខាងផ្នែកសរសេរ។	In the first week they have to take the written part of the exam.
2. ក្នុង១ថ្ងៃមុនដំបូងគេឲ្យធ្វើចំណោទខាងគីមី។	On the first day they have them do problems in chemistry.
3. ក្នុង១ខែមុនដំបូងគេត្រូវរៀនខាងផ្នែកម៉ាស៊ីន។	In the first month they have to study machinery.
4. ក្នុង១ម៉ោងដំបូងគេឲ្យប្រឡងខាងបើលសញ្ញាបើកឡាន។	In the first hour they have them take the test for a driving license.
5. ក្នុង១ឆ្នាំមុនដំបូងគេរៀនខាងមុខវិជ្ជាទូទៅ។	In the first year they study general subjects.
6. ក្នុង១អាទិត្យមុនដំបូងគេត្រូវប្រឡងខាងភាសាបរទេស។	In the first week they have to take an examination in foreign languages.
7. ក្នុង១ខែមុនដំបូងគេឲ្យហាត់តែខាងលោតកំពស់។	In the first month they have them train to high jump.
8. ក្នុង១ថ្ងៃមុនដំបូងគេពន្យល់តែខាងរបៀបសរសេរ។	In the first day they explain only the method of writing.

Drill E. Response

MODEL:	គ្រូ : កាលណាគេប្រឡងផ្នែកសរសេរចប់ហើយគេធ្វើអីទៀត? (ចាំស្ដាប់លទ្ធផលនៃការប្រឡង)	Teacher:	When they finish taking the written exam, what else do they do? (wait to hear the results of the examination)
	សិស្ស: កាលណាគេប្រឡងខាងផ្នែកសរសេរចប់ហើយគេចាំស្ដាប់លទ្ធផលនៃការប្រឡង។	Student:	When they finish taking the written part of the exam, they wait to hear the results of the exam.

1.	កាលណាគេប្រឡងរួច១ផ្នែកហើយគេធ្វើអីទៀត? (គេចាប់ប្រឡង១ផ្នែកទៀត)	កាលណាគេប្រឡងរួចមួយផ្នែកហើយគេចាប់ប្រឡង១ផ្នែកទៀត។
2.	កាលណាគេរៀនចប់ផ្នែកបឋមសិក្សាហើយគេរៀនអីទៀត? (គេទៅតនៅផ្នែកមធ្យមសិក្សា)	កាលណាគេរៀនចប់ផ្នែកបឋមសិក្សាហើយទៅរៀនតនៅផ្នែកមធ្យមសិក្សាទៀត។
3.	កាលណាគេរៀនភាសាខ្មែរនៅFSIចប់ហើយគេធ្វើអីទៀត? (គេឡើងទៅធ្វើការនៅស្ថានទូតនៅភ្នំពេញ)	កាលណារៀនភាសាខ្មែរនៅFSIចប់ហើយគេឡើងទៅធ្វើការនៅស្ថានទូតនៅភ្នំពេញ។
4.	កាលណាគេទៅដល់រោងកុនហើយគេធ្វើអីទៀត? (ទិញសំបុត្រ)	កាលណាគេទៅដល់រោងកុនគេទិញសំបុត្រ។
5.	កាលណាគេបានទទួលសញ្ញាបត្រមធ្យមសិក្សាហើយគេធ្វើអីទៀត? (និស្សិតចេញទៅរកការធ្វើ)	កាលណា បានទទួលសញ្ញាបត្រមធ្យមសិក្សាហើយនិស្សិតខ្លះចេញទៅរកការធ្វើ។

Drill F. Response

MODEL:	គ្រូ: លោកដឹងថាលោកត្រូវចេញទៅភ្នំពេញអង្កាល់ទេ? (ខ្ញុំនៅចាំបង្គាប់ពីក្រសួងការបរទេស)	Teacher:	Do you know when you will have to go to Phnom Penh? (I'm still waiting for orders from the Foreign Ministry)
	សិស្ស បាទ ខ្ញុំមិនទាន់ដឹងច្បាស់ថាខ្ញុំត្រូវទៅភ្នំពេញអង្កាល់ទេ ខ្ញុំនៅចាំបង្គាប់ពីក្រសួងការបរទេស។	Student:	I don't know for sure yet when I have to go to Phnom Penh; I'm still waiting for orders from the Foreign Ministry.

1.	លោកដឹងថាលោកត្រូវខ្វល់រឿងការអង្កាលទេ? (ខ្ញុំកំពុងតែចាំស្ដាប់ដំណឹងនេះ)	បាទ ខ្ញុំមិនទាន់ដឹងច្បាស់ថាខ្ញុំត្រូវខ្វល់រឿងការអង្កាល់ទេ ខ្ញុំកំពុងតែចាំស្ដាប់ដំណឹងនេះ។
2.	លោកដឹងថាលោកត្រូវប្រឡងថ្ងៃណាទេ? (តែខ្ញុំឮគេថានឹងចាប់ធ្វើថ្ងៃអង្គារក្រោយ)	បាទ ខ្ញុំមិនដឹងច្បាស់ថាខ្ញុំត្រូវប្រឡងថ្ងៃណាទេ តែខ្ញុំឮគេថានឹងចាប់ធ្វើថ្ងៃអង្គារក្រោយ។
3.	គេដឹងថាគេត្រូវទៅជាមួយលោកទេ? (ព្រោះខ្ញុំគ្មានអ្នកណាប្រាប់គេ)	បាទ ខ្ញុំមិនទាន់ដឹងច្បាស់ថាតើគេទៅជាមួយខ្ញុំទេ ព្រោះខ្ញុំគ្មានអ្នកណាប្រាប់គេ។
4.	គាត់ដឹងថាគាត់ទៅពិសាបាយល្ងាចនេះទេ? (ព្រោះខ្ញុំមិនទាន់និយាយគាត់)	បាទ ខ្ញុំមិនទាន់ដឹងច្បាស់ថាគាត់ទៅពិសាបាយល្ងាចនេះទេ ព្រោះខ្ញុំមិនទាន់និយាយគាត់។
5.	គាត់ដឹងថាប្រពន្ធគាត់មករកគាត់ទេ? (ព្រោះគេគ្រាន់តែប្រាប់គាត់ថាមានភ្ញៀវ)	បាទ គាត់មិនទាន់ដឹងច្បាស់ថាប្រពន្ធគាត់មករកគាត់ទេ ព្រោះគេគ្រាន់តែប្រាប់គាត់ថាមានភ្ញៀវ។

Drill G. Expansion

1.	កូនសិស្សដែលប្រឡងបានពិន្ទុល្អ	Students who take the test with good grades
2.	កូនសិស្សដែលប្រឡងបានពិន្ទុល្អគួរសម	Students who take the test with rather good grades
3.	កូនសិស្សដែលប្រឡងបានពិន្ទុល្អគួរសម តែមិនអាចឲ្យជាប់បាន	Students who take the test with rather good grades but who don't pass
4.	កូនសិស្សដែលប្រឡងបានពិន្ទុល្អគួរសម តែមិនអាចឲ្យជាប់បាន គេអនុញ្ញាតឲ្យទៅប្រឡង	Students who take the test with rather good grades but who don't pass have permission to take the test.
5.	កូនសិស្សដែលប្រឡងបានពិន្ទុល្អគួរសម តែមិនអាចឲ្យជាប់បាន គេអនុញ្ញាតឲ្យទៅប្រឡងលើកទីពីរទៀត។	Students who take the test with rather good grades but who don't pass have permission to take the test a second time.

Drill H. Reduction

1.	កូនសិស្សដែលប្រឡងបានពិន្ទុល្អគួរសមតែមិនអាចឲ្យជាប់បាន គេអនុញ្ញាតឲ្យទៅប្រឡងលើកទី២ទៀត។	Students who take the test with rather good grades but who don't pass have permission to take the test a second time.

2.	កូនសិស្សដែលប្រឡងបានពិន្ទុល្អគួរសមតែមិនអាចឡើងជាប់បាន គេអនុញ្ញាតឲ្យទៅប្រឡង	Students who take the test with rather good grades but who don't pass have permission to take the test.
3.	កូនសិស្សដែលប្រឡងបានពិន្ទុល្អគួរសម តែមិនអាចឡើងជាប់បាន	Students who take the test with rather good grades but who don't pass
4.	កូនសិស្សដែលប្រឡងបានពិន្ទុល្អគួរសម	Students who take the test with rather good grades
5.	កូនសិស្សដែលប្រឡងបានពិន្ទុល្អ	Students who take the test with good grades

UNIT 85

NARRATION

1. លោកសារ៉ុមទើបនឹងត្រឡប់មកពីវាលយន្តហោះវិញក្រោយពីដែលគាត់បានជូនប្អូនគាត់ទៅឡើងយន្តហោះ។
2. ប្អូនគាត់ទៅរៀនខាងវិស្វកម្មនៅសាកលវិទ្យាល័យខ័រណែល។
3. គេបានអាហារូបករណ៍តែមួយឆ្នាំទេ តែបើគេរៀនបានល្អ គេនឹងអាចបានអាហារូបករណ៍តទៅទៀត។
4. នៅប្រទេសកម្ពុជាមានសាកលវិទ្យាល័យដែរ តែគេមិនទាន់បង្រៀនគ្រប់មុខវិជ្ជាទេ។
5. អ្នកដែលបានអាហារូបករណ៍ទៅរៀនខាងមុខវិជ្ជាដែលយើងគ្មាន ទៅបន្តវិជ្ជាថ្នាក់ខ្ពស់ឬទៅធ្វើការហ្វឹកហ្វឺនខាងវិជ្ជាណាមួយ។
6. នៅសាកលវិទ្យាល័យខ្មែរគេបង្រៀនខាងសេដ្ឋកិច្ច ខាងច្បាប់ ខាងពេទ្យ ខាងកសិកម្ម ខាងវិជ្ជាបច្ចេកទេសផ្សេងៗ និងខាងវិស្វកម្ម។
7. និស្សិតបរទេសខ្លះបានមករៀននៅសាកលវិទ្យាល័យខ្មែរដែរ។
8. មាននិស្សិតមកពីស្រុកលាវ យួន និងបារាំងខ្លះ។
9. និស្សិតខ្លះទទួលអាហារូបករណ៍ពីរាជការខ្មែរ ខ្លះទៀតមករៀនលុយខ្លួនឯង។
10. តែរៀននៅស្រុកខ្មែរមិនថ្លៃទេ។ គេគ្រាន់តែមានលុយសម្រាប់ស៊ីនៅ ទិញសៀវភៅ និងបង់ថ្លៃប្រឡងបន្តិចបណ្ណោះអស់ហើយ។

1. Sarom has just returned from the airport after having taken his younger brother to board a plane.
2. His younger brother will go study engineering at Cornell University.
3. He received a scholarship for only one year, but if he studies well he will get a scholarship to continue.
4. In Cambodia there are universities also, but they still do not teach all subjects.
5. Persons who receive scholarships go to study subjects which we don't have, to continue higher studies or to train in some subject.
6. In the Cambodian universities they teach economics, law, medicine, agriculture, various technical subjects and engineering.
7. Some foreign students have come to study in the Cambodian universities also.
8. There are some students who come from Laos, Vietnam and France.
9. Some students receive scholarships from the Cambodian government; some others come to study with their own money.
10. But studying in Cambodia is not expensive. They only need money for living, buying books and paying the expenses of testing.

1. និស្សិតខ្មែរដែលទៅបន្តវិជ្ជានៅបរទេស គេច្រើនទៅប្រទេសបារាំង ព្រោះគេចេះភាសានេះ
ស្រាប់ ហើយសាលានៅស្រុកបារាំងក៏មិនសូវថ្លៃដូចនៅប្រទេសឯទៀតដែរ។
2. ក្រៅពីនេះ និស្សិតខ្លះទៀតទៅរៀននៅប្រទេសអាល្លឺម៉ង់ រុស្ស៊ី ចិន ឬ អង់គ្លេស និងអាមេរិក។
3. និស្សិតក្រុមនេះច្រើនបានអាហារូបករណ៍ពីប្រទេសដែលគេទៅរៀន ឬពីរាជការខ្មែរដែល
បញ្ជូនគេឲ្យទៅរៀន។
4. កាលគេទៅរៀននៅប្រទេសឯទៀតក្រៅពីប្រទេសបារាំង គេមានការពិបាកខ្លះ ដោយរបៀប
រៀនខុសគ្នា។
5. នៅស្រុកខ្មែររបៀបបង្រៀនប្រហែលគ្នានឹងរបៀបបង្រៀនបារាំង។
6. គេរៀននៅសាលាបឋមសិក្សា៦ឆ្នាំ ហើយបន្ទាប់ពីនោះនៅសាលាមធ្យមសិក្សាឬវិទ្យា-
ល័យប្រាំពីរឆ្នាំ។
7. កាលណាកូនសិស្សរៀនបានលេខល្អ នៅថ្នាក់បឋមសិក្សា គេអាចទៅចូលរៀននៅវិទ្យា-
ល័យ ឬអនុវិទ្យាល័យ តែម្ដងដោយមិនបាច់ប្រឡងចូលដូចពីមុនទេ។
8. នៅវិទ្យាល័យគេអាចប្រឡងយកសញ្ញាបត្របានបីដងគឺនៅឆ្នាំទី៤ ទី៦ និង៧។
9. នៅអនុវិទ្យាល័យគេអាចប្រឡងយកបានតែសញ្ញាបត្រនៅចុងឆ្នាំទី៤ទេ។
10. កាលណារៀនចប់មធ្យមសិក្សាហើយ និស្សិតដែលចង់បន្តវិជ្ជាតទៅថ្ងៃមុខ គេត្រូវទៅរៀន
នៅសាកលវិទ្យាល័យ។

1. Cambodian students who continue their studies abroad usually go to France because they know the language already, and schools in France are not as expensive as in other countries.

2. Besides this some other students go to study in Germany, Russia, China, England and the United States.

3. This group of students for the most part receive scholarships from the countries where they are going to study or from the Cambodian government, which sends them to study.

4. When they go to study in other countries besides France, they have some difficulties because the methods of instruction are different.

5. In Cambodia the methods of instruction are approximately like the French method of instruction.

6. They study six years in the elementary school; following this (they study) seven years in the middle school or lycée.

7. When students study and get good grades in the elementary section, they can enter the lycée or the junior high school without having to take an entrance exam as (was the case) before.

8. In the lycée they can take a test for a degree three times, that is, in the fourth year, the sixth year and the seventh year.

9. In the junior high they can take an exam for a certificate at the end of the fourth year only.

10. When they have finished the middle school, students who want to continue their studies must go to study in the university.

1. កូនសិស្សប្រឡងយកសញ្ញាបត្រផ្សេងៗ រាល់ឆ្នាំ តែគេមិនប្រឡងទាំងអស់គ្នាទេ ។
2. និស្សិតណាដែលរៀនចប់ផ្នែកមួយហើយ គេត្រូវតែទៅប្រឡងយកសញ្ញាបត្រ ។
3. និស្សិតដែលរៀនមិនទាន់ចប់គេអាចឡើងថ្នាក់បាន កាលណាគេរៀនចប់លេខល្អ ។
4. ដូច្នេះកូនសិស្សដែលនៅរៀនថ្នាក់ទី៤ អាចឡើងទៅថ្នាក់ទី៣ បានកាលណាគេរៀនចប់លេខល្អ ។
5. កូនសិស្សដែលរៀនពូកែនៅថ្នាក់ទី៤ ឬទី២ អាចសុំក្រសួងសិក្សាធិការទៅប្រឡងយកសញ្ញាបត្រជាមួយសិស្សឯទៀតដែរ ។
6. បើគេប្រឡងជាប់គេចំណេញ១ឆ្នាំដោយគេអាចឆ្លងថ្នាក់ទៅរៀននៅថ្នាក់ខ្ពស់ ។
7. សិស្សជំពូកនេះមានរាល់ឆ្នាំ ។
8. ខ្លះខំទៅរៀនឈ្នួលនៅពេលវិស្សមកាលដើម្បីរៀបចំខ្លួនឲ្យបានពូកែនិងទៅប្រឡង ។
9. គេត្រូវរៀនឲ្យចប់កម្មវិធីសិក្សានៃផ្នែកដែលគេត្រូវប្រឡងនោះដែរ ។

1. Students take a test for various certificates every year, but they don't all take tests.

2. Any student who has finished one part must go to take a test for a certificate.

3. Students who have not yet finished can advance a class whenever they finish studying with excellent grades.

4. Thus, a student studying in the fourth class can advance to the third class when he completes his studies with good grades.

5. Students who study very well in the fourth class or the second class can ask the Ministry of Education to take a test for a certificate with the other students.

6. If they pass, they advance one year by being able to skip a class and going to study in a high class.

7. There are students like this every year.

8. Some try to study privately during vacation to prepare themselves to be better and to take the tests.

9. They must study to finish the educational program of the section in which they must take the test.

1. របៀបប្រឡងនៅស្រុកខ្មែរមិនដូចនៅសហរដ្ឋទេ។
2. នៅប្រទេសកម្ពុជាគេប្រឡងយកសញ្ញាបត្រមធ្យមសិក្សានិងសញ្ញាបត្រជាន់ខ្ពស់ៗទៀត នោះមានធ្វើពីរដងក្នុង១ឆ្នាំសិក្សា។
3. ក្នុងពេល១អាទិត្យមុនដំបូងគេត្រូវតែប្រឡងខាងវិធីសរសេរ។
4. គេប្រឡងខាងមុខវិជ្ជាផ្សេងៗ ដូចជាតែងសេចក្តី គណិតសាស្ត្រ គីមីវិទ្យាសាស្ត្រ និងរូបសាស្ត្រជាដើម។
5. គេតែប្រឡងប្រមាណមួយឬពីរក្នុង១ថ្ងៃ។
6. គេឲ្យបីឬបួនម៉ោងក្នុងប្រមាណមួយៗ។
7. កាលណាគេប្រឡងខាងសរសេរចប់ហើយបើគេជាប់គេនឹងតែប្រឡងខាងសួរផ្ទាល់មាត់ទៀត។
8. ពេលប្រឡងសួរផ្ទាល់មាត់គេសួរសំពីមុខវិជ្ជាទាំងឡាយ ដូចកាលគេប្រឡងខាងសរសេរនិង។
9. អ្នកដែលប្រឡងជាប់ខាងសួរផ្ទាល់មាត់គេបានទទួលសញ្ញាបត្រជាសម្រេច។
10. និស្សិតដែលប្រឡងធ្លាក់តាំងតែពីខាងសរសេរ តែខ្វះពិន្ទុបន្តិចបន្តួច អាចតែប្រឡងលើកទីពីរបាន។

1. The method of taking a test in Cambodia is not like that in the United States.
2. In Cambodia the tests are taken for certificates and higher diplomas twice in the school year.
3. In the first week (the students) must take the written examination.
4. They take tests in the various subjects such as composition, mathematics, chemistry, science and physics, for example.
5. They have to take a test in one or two subjects a day.
6. They give three or four hours for each subject.
7. When they have taken the written test and if they have passed, they must take the oral test also.
8. During the oral exam (the examiners) ask about all the subjects that were given in the written exam.
9. The people who pass the oral section receive a passing certificate.
10. Students who fail in the written test but miss by just a few points can take the exam a second time.

UNIT 86

BASIC DIALOGUE

		John	
1.	នៅភ្នំពេញមានកាសែតច្រើនទេ?		Are there a lot of newspapers in Phnom Penh?
		Sarom	
2.	បាទ មានច្រើនគួរសំដែរ ។		There are rather a lot.
3.	កាសែតខ្លះចេញរាល់ថ្ងៃ ខ្លះទៀតចេញមួយអាទិត្យម្តង ។		Some newspapers come out every day, others come out once a week.
		John	
4.	គេមានកាសែតជាភាសាអ្វីខ្លះក្រៅពីខ្មែរ?		They have newspapers in what languages besides Cambodian?
		Sarom	
5.	បាទ មាន កាសែតជាភាសាបារាំង ចិន និងយួនដែរ ។		There are newspapers in French, Chinese, and Vietnamese.
		John	
6.	ចុះកាសែតជាភាសាអង់គ្លេសមានទេ?		How about papers in English, are there any?
		Sarom	
7.	បាទ គ្មានទេ តែគេមានទស្សនាវដ្តីជាអង់គ្លេសដែរ ។		There aren't any, but there are magazines in English.
		John	
8.	កាសែតមួយថ្លៃប៉ុន្មានរៀល?		How many riels does a paper cost?
		Sarom	
9.	កាសែតខ្លះថ្លៃ៥រៀល ខ្លះទៀត១០រៀលឬ១៥រៀលមួយ ។		Some papers cost 5 riels, others 10 or 15 riels.
10.	កាសែតខ្លះមាន៨ទំព័រ ខ្លះទៀតមានច្រើនទំព័រ ។		Some papers have 8 pages, others have many pages.

		John	
11.	កាសែតណាធំជាងគេបង្អស់?		Which newspaper is the biggest of all?
		Sarom	
12.	បាទ កាសែតអ្នកជាតិនិយមជា កាសែតធំជាងគេបង្អស់ ។		The newspaper Neak Cheat Niyum is the biggest newspaper of all.
		John	
13.	គេចេញប៉ុន្មានដងក្នុងមួយអា- ទិត្យ?		How many times a week is it issued?
		Sarom	
14.	បាទគេចេញតែម្ដងទេ តែគេមាន ច្រើនទំព័រ ។		They issue it just once, but it has a lot of pages.
15.	កាសែតនេះច្រើននិយាយអំពីសកម្ម- ភាពផ្សេងៗនៅក្នុងស្រុក ហើយនិង អំពីវប្បធម៌ និងច្បាប់ទម្លាប់ខ្មែរ ។		This newspaper, for the most part, talks about various activities in the country and about the culture and the traditional Cambodian laws.
		John	
16.	គេឲ្យដំណឹងអីៗ អំពីបរទេសទេ?		Do they give some kind of foreign news?
		Sarom	
17.	បាទ តែការអប់រំប្រជារាស្ត្រឲ្យ ចេះដឹងខាងរបៀបកសិកម្មថ្មីៗ ខាងការ ចិញ្ចឹមសត្វ ខាងអនាម័យ និងខាង ពាណិជ្ជកម្ម ជាដើមនេះ ជារឿងសំខាន់ៗ ក្នុងកាសែត ។		Yes, but educating the people to know new methods in agriculture, in raising livestock, in health, and in commerce, for example, are the important stories in this paper.
		John	
18.	របៀបនេះល្អណាស់ព្រោះរាស្ត្រខ្មែរ ត្រូវទទួលការអប់រំដូច្នេះ ។		This is very good because the Cambodian people must receive training like that.

DRILLS

Drill A. Substitution

1.	កាសែតខ្លះសរសេរជាអង់គ្លេស ខ្លះទៀតជាខ្មែរ។	Some newspapers are written in English, others in Cambodian.
2.	កាសែតខ្លះសរសេរជាបារាំង ខ្លះទៀតជាខ្មែរ។	Some newspapers are written in French, others in Cambodian.
3.	កាសែតខ្លះសរសេរជាចិន ខ្លះទៀតជាខ្មែរ។	Some newspapers are written in Chinese, others in Cambodian.
4.	កាសែតខ្លះសរសេរជាយួន ខ្លះទៀតជាខ្មែរ។	Some newspapers are written in Vietnamese, others in Cambodian.
5.	កាសែតខ្លះសរសេរជាអារ៉ាប់ ខ្លះទៀតជាខ្មែរ។	Some newspapers are written in Arabic, others in Cambodian.
6.	កាសែតខ្លះសរសេរជាហិណ្ឌូ ខ្លះទៀតជាខ្មែរ។	Some newspapers are written in Indian, others in Cambodian.
7.	កាសែតខ្លះសរសេរជាចាម ខ្លះទៀតជាខ្មែរ។	Some newspapers are written in Cham, others in Cambodian.

Drill B. Substitution

1.	នៅភ្នំពេញគេច្រើនមើលកាសែតអ្នកជាតិនិយម។	In Phnom Penh for the most part they read the newspaper Neak Cheat Niyum.
2.	នៅភ្នំពេញគេច្រើនមើលកាសែតរេអាលីតេ។	In Phnom Penh for the most part they read the newspaper Realités.
3.	នៅភ្នំពេញគេច្រើនមើលកាសែតមាតុភូមិ។	In Phnom Penh for the most part they read the newspaper Meatophum.
4.	នៅភ្នំពេញគេច្រើនមើលកាសែតសរសេរជាខ្មែរ។	In Phnom Penh for the most part they read the newspapers written in Cambodian.
5.	នៅភ្នំពេញគេច្រើនមើលកាសែតសរសេរជាបារាំង។	In Phnom Penh for the most part they read the newspapers written in French.
6.	នៅភ្នំពេញគេច្រើនមើលកាសែតសរសេរជាអង់គ្លេស។	In Phnom Penh for the most part they read the newspapers written in English.
7.	នៅភ្នំពេញគេច្រើនមើលកាសែតវត្តភ្នំ។	In Phnom Penh for the most part they read the newspaper Wat Phnom.

Drill C. Substitution

1.	គេសរសេរអំពីការបរទេស កសិកម្ម និងកីឡា ។	They write about foreign affairs, agriculture, and sports.
2.	គេសរសេរអំពីដំណឹងក្នុងស្រុក កសិកម្ម និងកីឡា ។	They write about domestic affairs, agriculture, and sports.
3.	គេសរសេរអំពីដំណឹងខ្លីៗ កសិកម្មនិងកីឡា ។	They write (about) short news stories, agriculture, and sports.
4.	គេសរសេរអំពីការធ្វើដំណើរ កសិកម្ម និងកីឡា ។	They write about travel, agriculture, and sports.
5.	គេសរសេរអំពីសេដ្ឋកិច្ច កសិកម្មនិងកីឡា ។	They write about economics, agriculture, and sports.
6.	គេសរសេរអំពីការចិញ្ចឹមសត្វ កសិកម្ម និងកីឡា ។	They write about livestock raising, agriculture, and sports.
7.	គេសរសេរអំពីសំណង់ថ្មីៗ កសិកម្ម និងកីឡា ។	They write about new construction, agriculture, and sports.
8.	គេសរសេរអំពីការចំរើនខាងសុខភាព កសិកម្ម និងកីឡា ។	They write about progress in health, agriculture, and sports.

Drill D. Double Substitution

1.	កាសែតខ្លះថ្លៃ៧រៀល ខ្លះទៀត១០រៀល ។	Some papers cost seven riels, others ten riels.
2.	ទស្សនាវដ្ដីខ្លះថ្លៃ៧រៀល ខ្លះទៀតជាង១០រៀល ។	Some magazines cost seven riels, others more than ten riels.
3.	សៀវភៅខ្លះថ្លៃ៧រៀល ខ្លះទៀត២០រៀល ។	Some books cost seven riels, others twenty riels.
4.	រូបចម្លាក់ខ្លះថ្លៃ៧រៀល ខ្លះទៀតជាង១៥រៀល ។	Some rubbings cost seven riels, others more than 15 riels.
5.	រូបថតខ្លះថ្លៃ៧រៀល ខ្លះទៀតប្រហែល៧រៀល ។	Some photos cost seven riels, others almost seven riels.
6.	សំបុត្រកុនខ្លះថ្លៃ៧រៀល ខ្លះទៀត៤០រៀល ។	Some movie tickets cost seven riels, others 40 riels.
7.	សំបុត្រល្ខោនខ្លះថ្លៃ៧រៀល ខ្លះទៀត៣០រៀល ។	Some theatre tickets cost seven riels, others 30 riels.
8.	មុខម្ហូបខ្លះថ្លៃ៧រៀល ខ្លះទៀតជាង២០រៀល ។	Some kinds of dishes (food) cost seven riels, others more than 20 riels.

Drill E. Double Substitution

1.	កាសែតអ្នកជាតិនិយមនិយាយអំពីដំណឹងក្នុងស្រុកក្រៅប្រទេសនិងវប្បធម៌ខ្មែរ។	The newspaper Neak Cheat Niyum talks about domestic news, foreign news, and Cambodian culture.
2.	ទស្សនាវដ្តីកម្ពុជានិយាយអំពីដំណឹងក្នុងស្រុកក្រៅប្រទេសនិងសេដ្ឋកិច្ចខ្មែរ។	The magazine Kampuchea talks about domestic news, foreign news, and Cambodian economics.
3.	កាសែតរេអាលីតេនិយាយអំពីដំណឹងក្នុងស្រុកក្រៅប្រទេសនិងកីឡាខ្មែរ។	The newspaper Realités talks about domestic news, foreign news, and Cambodian sports.
4.	កាសែតកម្ពុជានិយាយអំពីដំណឹងក្នុងស្រុកក្រៅប្រទេសនិងពាណិជ្ជកម្មខ្មែរ។	The newspaper Kampuchea talks about domestic news, foreign news, and Cambodian commerce.
5.	ទស្សនាវដ្តីសង្គមនិយាយអំពីដំណឹងក្នុងស្រុក ក្រៅប្រទេស និងនយោបាយខ្មែរ។	The magazine Sangkum talks about domestic news, foreign news, and Cambodian politics.
6.	កាសែតវត្តភ្នំព្រឹកមិញនិយាយអំពីដំណឹងក្នុងស្រុក ក្រៅប្រទេស និងរោងចក្រខ្មែរ។	The newspaper Wat Phnom this morning talked about domestic news, foreign news, and Cambodian factories.
7.	រាល់ថ្ងៃកាសែតកម្ពុជានិយាយអំពីដំណឹងក្នុងស្រុក ក្រៅប្រទេស និងវប្បធម៌ខ្មែរ។	Every day the newspaper Kampuchea talks about domestic news, foreign news, and Cambodian culture.
8.	រាល់អាទិត្យកាសែតអ្នកជាតិនិយមនិយាយអំពីដំណឹងក្នុងស្រុក ក្រៅប្រទេសនិងកីឡាខ្មែរ។	Every week the newspaper Neak Cheat Niyum talks about domestic news, foreign news, and Cambodian sports.

Drill F. Response

MODEL:	គ្រូៈ កាសែតកម្ពុជាសរសេរអំពីអ្វីខ្លះ? (ដំណឹងក្នុងប្រទេស ក្រៅប្រទេស និងកីឡា)	Teacher:	What things does the newspaper Kampuchea write about? (domestic and foreign news and sports)
	សិស្សៈ កាសែតកម្ពុជាសរសេរអំពីដំណឹងក្នុងប្រទេសក្រៅប្រទេសនិងកីឡា។	Student:	The newspaper Kampuchea writes about domestic and foreign news and sports.

1. កាសែតរេអាលីតេសរសេរអំពីអ្វីខ្លះ? (ដំណឹងផ្សេងៗ វប្បធម៌និងសេដ្ឋកិច្ច)

កាសែតរេអាលីតេសរសេរអំពីដំណឹងផ្សេងៗ វប្បធម៌និងសេដ្ឋកិច្ច។

2. កាសែតអ្នកជាតិនិយមសរសេរអំពីអ្វីខ្លះ?
(ដំណឹងសំខាន់ៗទាំងឡាយក្នុងប្រទេសនិងក្រៅប្រទេស)

កាសែតអ្នកជាតិនិយម សរសេរអំពីដំណឹងសំខាន់ៗទាំងឡាយក្នុងប្រទេសនិងក្រៅប្រទេស។

3. កាសែតមាតុភូមិនិយាយអំពីអ្វីខ្លះ?
(នយោបាយ សេដ្ឋកិច្ច និងដំណឹងក្នុងស្រុក)

កាសែតមាតុភូមិ និយាយអំពីនយោបាយសេដ្ឋកិច្ចនិងដំណឹងក្នុងស្រុក។

4. ទស្សនាវដ្ដីសង្គមសរសេរពីអ្វីខ្លះ?
(ដំណឹងផ្សេងៗក្នុងប្រទេសនិងនយោបាយ)

ទស្សនាវដ្ដីសង្គមសរសេរពីដំណឹងផ្សេងៗក្នុងប្រទេសនិងនយោបាយ។

5. ទស្សនាវដ្ដីកម្ពុជាសរសេរពីអ្វីខ្លះ?
(នយោបាយនិងសេដ្ឋកិច្ច)

ទស្សនាវដ្ដីកម្ពុជាសរសេរពីនយោបាយនិងសេដ្ឋកិច្ច។

Drill G. Response

MODEL: គ្រូ: នៅភ្នំពេញគេច្រើនមើលកាសែតអី? (អ្នកជាតិនិយម)

Teacher: In Phnom Penh what newspaper do they read for the most part? (Neak Cheat Niyum)

សិស្ស: នៅភ្នំពេញខ្ញុំឃើញគេច្រើនតែមើលកាសែតអ្នកជាតិនិយម។

Student: In Phnom Penh they read the newspaper Neak Cheat Niyum for the most part.

1. នៅប្រទេសកម្ពុជាគេច្រើនមើលកាសែតអី? (រេអាល្លីតេនិងអ្នកជាតិនិយម)

នៅប្រទេសកម្ពុជាខ្ញុំឃើញគេច្រើនមើលកាសែតរេអាល្លីតេនិងអ្នកជាតិនិយម។

2. នៅវ៉ាស៊ីនតោនគេច្រើនមើលកាសែតអី? (វ៉ាស៊ីនតោនប៉ុស្តិ៍)

នៅវ៉ាស៊ីនតោនខ្ញុំឃើញគេច្រើនមើល កាសែតវ៉ាស៊ីនតោនប៉ុស្តិ៍។

3. នៅញូវយកគេច្រើនមើលកាសែតអី? (ញូវយកថែម)

នៅញូវយកខ្ញុំឃើញគេច្រើនមើលកាសែតញូវយកថែម។

4. នៅទីក្រុងក្រៅគេច្រើនមើលកាសែតអី? (កម្ពុជា)

នៅទីក្រុងក្រៅខ្ញុំឃើញគេច្រើនមើលកាសែតកម្ពុជា។

5. នៅភ្នំពេញគេច្រើនមើលទស្សនាវដ្ដីអី? (កម្ពុជា)

នៅភ្នំពេញ ខ្ញុំឃើញគេច្រើនមើលទស្សនាវដ្ដីកម្ពុជា។

Drill H. Transformation

MODEL:	គ្រូ៖ ក្រៅពីឲ្យដំណឹងផ្សេងៗក្នុងស្រុកនិងក្រៅស្រុក គេមានទំព័រកីឡា វិទ្យាសាស្ត្រ និងកសិកម្ម។ (សរសេរអំពី)	Teacher: Besides giving various domestic and foreign news stories, they have a page each of sports, of science and of agriculture. (write about)
	សិស្ស៖ ក្រៅពីសរសេរអំពីដំណឹងផ្សេងៗក្នុងស្រុកនិងក្រៅស្រុក គេមានទំព័រកីឡា, វិទ្យាសាស្ត្រ និងកសិកម្ម។	Student: Besides writing about various domestic and foreign news stories they have a page each of sports, of science and of agriculture.
1.	ក្រៅពីសរសេរ វប្បធម៌និងនយោបាយ គេសរសេរអំពីសេដ្ឋកិច្ចដែរ។ (រៀបរៀង)	ក្រៅពីរៀបរៀងវប្បធម៌និងនយោបាយ គេសរសេរអំពីសេដ្ឋកិច្ចដែរ។
2.	ក្រៅពីគូររូបដាក់ក្នុងកាសែត គេសរសេររឿងខ្លីៗក្នុងស្រុក។ (ផ្តិត)	ក្រៅពីផ្តិតរូបដាក់ក្នុងកាសែត គេសរសេររឿងខ្លីៗក្នុងស្រុក។
3.	ក្រៅពីមើលរឿងផ្សេងៗក្នុងកាសែត ខ្ញុំរៀនភាសាខ្មែរ។ (សរសេរ)	ក្រៅពីសរសេររឿងផ្សេងៗក្នុងកាសែត ខ្ញុំរៀនភាសាខ្មែរ។
4.	ក្រៅពីធ្វើការនៅ FSI ខ្ញុំបើកតាក់ស៊ី។ (រៀន)	ក្រៅពីរៀននៅ FSI ខ្ញុំបើកតាក់ស៊ី។

Drill I. Response

MODEL:	គ្រូ៖ កាសែតណាធំជាងគេបង្អស់នៅភ្នំពេញ? (អ្នកជាតិនិយម)	Teacher: Which newspaper is the largest of all in Phnom Penh? (Neak Cheat Niyum)
	សិស្ស៖ នៅភ្នំពេញ កាសែតអ្នកជាតិនិយមជាកាសែតធំជាងគេបង្អស់។	Student: In Phnom Penh the newspaper Neak Cheat Niyum is the largest newspaper of all.
1.	កាសែតណាធំជាងគេបង្អស់នៅវ៉ាស៊ីនតោន? (វ៉ាស៊ីនតោនប៉ុស្តិ៍)	នៅវ៉ាស៊ីនតោន កាសែតវ៉ាស៊ីនតោនប៉ុស្តិ៍ ជាកាសែតធំជាងគេបង្អស់។
2.	កាសែតណាធំជាងគេបង្អស់នៅញូវយ៉ក? (ញូវយ៉កថាម)	នៅញូវយ៉ក កាសែតញូវយ៉កថាមជាកាសែតធំជាងគេបង្អស់។
3.	ទស្សនាវដ្តីណាធំជាងគេបង្អស់នៅភ្នំពេញ? (កម្ពុជា)	នៅភ្នំពេញ ទស្សនាវដ្តីកម្ពុជា ជាទស្សនាវដ្តីធំជាងគេបង្អស់។
4.	ភោជនីយដ្ឋានណាល្អជាងគេបង្អស់នៅភ្នំពេញ? (ពោធិ៍ចិនតុង)	នៅភ្នំពេញ ភោជនីយដ្ឋានពោធិ៍ចិនតុងជាភោជនីយដ្ឋានល្អជាងគេបង្អស់។

UNIT 87

BASIC DIALOGUE

	John		
1.		កាសែតអ្នកជាតិនិយមជាកាសែតរបស់រាជការឬរបស់ឯកជន ?	Is the newspaper Neak Cheat Niyum a government paper or(is it)private?
	Sarom		
2.		បាទ របស់រាជការសង្គមរាស្ត្រនិយម ។	It's (published by) the Sangkum government.
	John		
3.		គេមានលក់កាសែតនេះនៅស្រុកក្រៅទេ?	Is this newspaper sold abroad?
	Sarom		
4.		បាទមានដែរតែមិនច្រើនទេ គេច្រើនមើលបានតែវិចារណកថា ព្រោះជាទំព័រមួយដែលមានសរសេរជាបារាំងឬអង់គ្លេសផង ។	It is, but not very much. For the most part they (foreigners) only read the editorial because it's a page written in French or English.
	John		
5.		លោកចូលចិត្តមើលកាសែតទេ?	Do you like to read newspapers?
	Sarom		
6.		បាទ ខ្ញុំចូលចិត្តមើលកាសែតណាស់ ព្រោះឥឡូវដូចលោកជ្រាបស្រាប់ហើយ មានព្រឹត្តិការណ៍ដ៏ប្រែប្រួលរាល់ថ្ងៃ ។	I like to read papers very much, because now, as you know, there are important changing events every day.
	John		
7.		បាទ អញ្ចឹងហើយខ្ញុំក៏មើលកាសែតច្រើនដែរ តែខ្ញុំមើលបានតែកាសែតបារាំងនឹងអង់គ្លេសទេ ។	Ah, I also read a lot of papers. But I can only read French and English papers.
8.		ខ្ញុំមុខតែនឹងមើលកាសែតអ្នកជាតិនិយមដែរ កាលណាខ្ញុំចេះខ្មែរបានល្អ ។	When I know how to read Cambodian well, I will probably read Neak Cheat Niyum, too.
	Sarom		
9.		លោកដែលឃើញកាសែតកម្ពុជាទេ? កាសែតនេះសរសេរជាខ្មែរដែរ ហើយចេញរាល់ថ្ងៃផង ។	Have you ever seen the paper Kampuchea? This newspaper is written in Cambodian and comes out every day.

	John	
10.	បាទទេ ខ្ញុំគ្រាន់តែឮគេប្រាប់ខ្ញុំម្ដង ថាកាសែតនេះចេញពីក្រសួងឃោសនា ការ ។	No. I've only heard them say once that this newspaper is issued by the Ministry of Information.
	Sarom	
11.	បាទ អញ្ចឹងហើយៗ ក្រសួងនេះ ចេញកាសែតមួយទៀតរាល់ថ្ងៃជាភា- សាបារាំងដែរ ។	That's right, and this Ministry issues another paper every day in French.
	John	
12.	បាទ ខ្ញុំមើល ប៊ូឡេតាំង នៃ ទីភ្នាក់ងារ សារពត៌មានខ្មែរនេះស្ទើរតែរាល់ថ្ងៃដែរ ។	I read the bulletin of the AKP (Agence Khmere de Presse) almost every day.
	Sarom	
13.	ខ្ញុំក៏ចូលចិត្តមើលដែរ ព្រោះគេមាន សរសេររឿងណាដែលផ្សេងៗ ច្រើនហើយថែម ទាំងមាន កម្មវិធី ទូរទស្សន៍ និងវិទ្យុ ដែរ ។	I like to read it too, because they write a lot of different stories, and in addition they have the television and radio schedules too.
	John	
14.	បាទ ប្រពន្ធខ្ញុំក៏ត្រូវការកម្មវិធី ទាំងនេះដែរ ។	Yes, my wife wants all these schedules too.

DRILLS

Drill A. Substitution

1.	ខ្ញុំមិនចេះមើលកាសែតជាភាសាខ្មែរទេ តែខ្ញុំមើលកាសែតបារាំងបាន។	I don't know how to read newspapers in Cambodian, but I can read French newspapers.
2.	ខ្ញុំមិនចេះមើលកាសែតជាភាសាចិនទេ តែខ្ញុំមើលកាសែតបារាំងបាន។	I don't know how to read newspapers in Chinese, but I can read French newspapers.
3.	ខ្ញុំមិនចេះមើលកាសែតជាភាសាយួនទេ តែខ្ញុំមើលកាសែតបារាំងបាន។	I don't know how to read newspapers in Vietnamese, but I can read French newspapers.
4.	ខ្ញុំមិនចេះមើលកាសែតជាភាសាសៀមទេ តែខ្ញុំមើលកាសែតបារាំងបាន។	I don't know how to read newspapers in Thai, but I can read French newspapers.
5.	ខ្ញុំមិនចេះមើលកាសែតជាភាសាអង់គ្លេសទេ តែខ្ញុំមើលកាសែតបារាំងបាន។	I don't know how to read newspapers in English, but I can read French newspapers.
6.	ខ្ញុំមិនចេះមើលកាសែតជាភាសាក្លិងទេ តែខ្ញុំមើលកាសែតបារាំងបាន។	I don't know how to read newspapers in Indian, but I can read French newspapers.
7.	ខ្ញុំមិនចេះមើលកាសែតជាភាសាភូមាទេ តែខ្ញុំមើលកាសែតបារាំងបាន។	I don't know how to read newspapers in Burmese, but I can read French newspapers.
8.	ខ្ញុំមិនចេះមើលកាសែតជាភាសាឥណ្ឌូនេស៊ីទេ តែខ្ញុំមើលកាសែតបារាំងបាន។	I don't know how to read newspapers in Indonesian, but I can read French newspapers.

Drill B. Substitution

1.	រាល់ព្រឹកខ្ញុំភ្ញាក់ពីព្រលឹម មើលកាសែតហើយទៅធ្វើការ។	Every morning I wake up early, read the paper, and go to work.
2.	រាល់ព្រឹកខ្ញុំភ្ញាក់ពីព្រលឹម រៀនខ្មែរហើយទៅធ្វើការ។	Every morning I wake up early, study Cambodian, and go to work.
3.	រាល់ព្រឹកខ្ញុំភ្ញាក់ពីព្រលឹម រៀនអង់គ្លេសហើយទៅធ្វើការ។	Every morning I wake up early, study English, and go to work.
4.	រាល់ព្រឹកខ្ញុំភ្ញាក់ពីព្រលឹម ហាត់ប្រាណហើយទៅធ្វើការ។	Every morning I wake up early, do calisthenics, and go to work.
5.	រាល់ព្រឹកខ្ញុំភ្ញាក់ពីព្រលឹម បញ្ឆេះឡានហើយទៅធ្វើការ។	Every morning I wake up early, start the car, and go to work.

6.	រាល់ព្រឹកខ្ញុំភ្ញាក់ពីព្រលឹម ធ្វើបាយព្រឹក ហើយទៅធ្វើការ។	Every morning I wake up early, make breakfast, and go to work.
7.	រាល់ព្រឹកខ្ញុំភ្ញាក់ពីព្រលឹម ងូតទឹក ហើយទៅធ្វើការ។	Every morning I wake up early, take a shower, and go to work.
8.	រាល់ព្រឹកខ្ញុំភ្ញាក់ពីព្រលឹម មើលទីវី ហើយទៅធ្វើការ។	Every morning I wake up early, watch TV, and go to work.

Drill C. Transformation

MODEL:	គ្រូ: ខ្ញុំមិនចេះមើលកាសែតជាភាសាខ្មែរទេ តែខ្ញុំមើលកាសែតបារាំងបាន។	Teacher: I don't know how to read papers in Cambodian, but I can read French papers.
	សិស្ស: ខ្ញុំអាចមើលកាសែតខ្មែរនិងបារាំងបានគួរសមដែរ។	Student: I can read Cambodian and French papers rather well.

1.	ខ្ញុំមិនចេះមើលកាសែតជាភាសាចិនទេ តែខ្ញុំមើលកាសែតបារាំងបាន។	ខ្ញុំអាចមើលកាសែតចិននិងបារាំងបានគួរសមដែរ។
2.	ខ្ញុំមិនចេះមើលកាសែតយួនទេ តែខ្ញុំមើលកាសែតបារាំងបាន។	ខ្ញុំអាចមើលកាសែតយួននិងបារាំងបានគួរសមដែរ។
3.	ខ្ញុំមិនចេះមើលកាសែតជាភាសាសៀមទេ តែខ្ញុំមើលកាសែតបារាំងបាន។	ខ្ញុំអាចមើលកាសែតសៀមនិងបារាំងបានគួរសមដែរ។
4.	ខ្ញុំមិនចេះមើលកាសែតជាភាសាអង់គ្លេសទេ តែខ្ញុំមើលកាសែតបារាំងបាន។	ខ្ញុំអាចមើលកាសែតអង់គ្លេសនិងបារាំងបានគួរសមដែរ។
5.	ខ្ញុំមិនចេះមើលកាសែតក្លិង្គទេ តែខ្ញុំមើលកាសែតបារាំងបាន។	ខ្ញុំអាចមើលកាសែតក្លិង្គនិងបារាំងបានគួរសមដែរ។

Drill D. Double Substitution

1.	លោកឃើញស្រាប់ហើយ នៅមន្ទីរឃោសនាការ គេចូលចិត្តមើលកាសែតណាស់។	As you see, they like to read newspapers in the Information Office.
2.	លោកជ្រាបស្រាប់ហើយ នៅមន្ទីរឃោសនាការ គេច្រើនមើលកាសែតណាស់។	As you know, for the most part they read newspapers in the Information Office.
3.	លោកដឹងស្រាប់ហើយ នៅមន្ទីរឃោសនាការ គេនិយមមើលកាសែតណាស់។	As you know, they like to read newspapers in the Information Office.

4. លោកយល់ស្រាប់ហើយនៅមន្ទីរឃោស-
នាការគេត្រូវការមើលកាសែតណាស់ ។

As you understand, they need to read newspapers in the Information Office.

5. លោកឃើញស្រាប់ហើយនៅមន្ទីរ
ឃោសនាការគេខំមើលកាសែតណាស់ ។

As you see, they try to read newspapers in the Information Office.

6. លោកឮស្រាប់ហើយនៅមន្ទីរឃោសនា-
ការគេថាគេចង់មើលកាសែតណាស់ ។

As you heard, they say they want to read newspapers in the Information Office.

7. លោកដឹងស្រាប់ហើយនៅមន្ទីរឃោសនា
ការគេច្រើនមើលកាសែតណាស់ ។

As you know, they for the most part read newspapers in the Information Office.

8. លោកជ្រាបស្រាប់ហើយនៅមន្ទីរឃោ
សនាការគេចូលចិត្តមើលកាសែត
ណាស់ ។

As you know, they like to read newspapers in the Information Office.

Drill E. Multiple Substitution

1. ខ្ញុំមិនទាន់បានមើលកាសែតទេតែខ្ញុំ
ឮដំណឹងនោះតាមវិទ្យុព្រឹកមិញ ។

I haven't read the newspaper yet, but I heard that news on the radio this morning.

2. ខ្ញុំមិនទាន់បានមើលទស្សនាវដ្ដីទេ តែខ្ញុំដឹង
ដំណឹងនោះតាមវិទ្យុពីមុន ។

I haven't read the magazine yet, but I knew that news before.

3. ខ្ញុំមិនទាន់បានមើលប្រកាសនោះទេ តែខ្ញុំ
ស្ដាប់ដំណឹងនោះតាមវិទ្យុយប់មិញ ។

I haven't read the declaration yet, but I listened to that news last night.

4. ខ្ញុំមិនទាន់បានមើលរឿងនោះទេ តែខ្ញុំឮដំ
ណឹងនោះតាមវិទ្យុពេលខ្ញុំមកធ្វើការ ។

I haven't read the story yet, but I heard that news when I went to work.

5. ខ្ញុំមិនទាន់បានមើលសំបុត្រគាត់ទេ តែខ្ញុំ
ដឹងដំណឹងនោះតាមវិទ្យុព្រឹកមិញ ។

I haven't read his letter yet, but I knew that news this morning.

6. ខ្ញុំមិនទាន់បានមើលកាសែតទេ តែខ្ញុំស្ដាប់
ដំណឹងនោះតាមវិទ្យុម្សិលមិញ ។

I haven't read the newspaper yet, but I listened to that news yesterday.

Drill F. Response

MODEL:

គ្រូ: លោកឮប្រកាសនោះទេពីព្រឹក
មិញ? (កាសែតមួយមើល)

Teacher: Did you hear that declaration this morning? (a newspaper to read it)

សិស្ស: បាទទេ ខ្ញុំមិនទាន់បានឮទេ ខ្ញុំនឹង
ទិញកាសែតមួយមើល ។

Student: No, I didn't hear it; I will buy a newspaper to read it.

1.	លោកឮដំណឹងនោះទេពីព្រឹកមិញ? (ទស្សនាវដ្ដីមួយមើល)	បាទ ទេមិនទាន់បានឮទេ ខ្ញុំនឹងទិញ ទស្សនាវដ្ដីមួយមើល។
2.	លោកបានដឹងរឿងនោះទេ ពីម្សិលមិញ? (វិទ្យុមួយទុកស្ដាប់)	បាទ ទេ ខ្ញុំមិនទាន់ដឹងទេ ខ្ញុំនឹងទិញ វិទ្យុមួយ ទុកស្ដាប់។
3.	លោកមើលរឿងនោះទេពីថ្ងៃមុន? (សំបុត្រ១ទៅមើលស្អែក)	បាទទេ ខ្ញុំមិនទាន់បានមើលទេ ខ្ញុំនឹង ទិញសំបុត្រ១ទៅមើលស្អែក។
4.	លោកអញ្ជើញទៅមើលទេ ពីម្សិលមិញ? (សំបុត្រទៅមើលស្អែក)	បាទទេ ខ្ញុំមិនទាន់បានទៅមើលទេ ខ្ញុំនឹង ទិញសំបុត្រទៅមើលស្អែក។
5.	លោកដឹងដំណឹងហ្នឹងទេ? (កាសែតមើលតិប្លូទិ)	បាទទេ ខ្ញុំមិនទាន់បានដឹងទេ ខ្ញុំនឹងទិញ កាសែតមើលតិប្លូទិ។

Drill G. Response

MODEL: គ្រូ: លោកឮប្រកាសនោះទេពីព្រឹកមិញ? (កាសែត១មើលថែមទៀត)

Teacher: Did you hear that declaration this morning? (a newspaper to read more about it)

សិស្ស: បាទ ខ្ញុំឮដែរ ហើយខ្ញុំនឹងទិញកាសែត១មើលថែមទៀត។

Student: Yes, I heard it, and I'm going to buy a paper to read more about it.

1.	លោកឮដំណឹងនោះទេពីព្រឹកមិញ? (ទស្សនាវដ្ដី១មើលថែមទៀត)	បាទ ខ្ញុំឮដែរ ហើយខ្ញុំនឹងទិញទស្សនាវដ្ដី១មើលថែមទៀត។
2.	លោកបានដឹងរឿងនោះទេ ពីម្សិលមិញ? (វិទ្យុ១ទុកស្ដាប់ថែមទៀត)	បាទ ខ្ញុំបានដឹងដែរ ហើយខ្ញុំនឹងទិញ វិទ្យុ១ទុកស្ដាប់ថែមទៀត។
3.	លោកមើលរឿងនោះទេពីថ្ងៃមុន? (សំបុត្រ១ទៅមើលថែមទៀត)	បាទ ខ្ញុំមើលដែរ ហើយខ្ញុំនឹងទិញសំបុត្រ១ទៅមើលថែមទៀត។
4.	លោកអញ្ជើញទៅមើលទេពីម្សិលមិញ? (សំបុត្រទៅមើលស្អែកទៀត)	បាទ ខ្ញុំទៅមើលដែរ ហើយខ្ញុំនឹងទិញ សំបុត្រទៅមើលស្អែកទៀត។
5.	លោកដឹងដំណឹងហ្នឹងទេ? (កាសែតមើលតិប្លូទិទៀត)	បាទ ខ្ញុំដឹងដែរ ហើយនឹងទិញកាសែតមើលតិប្លូទិទៀត។

Drill H. Transformation

MODEL: គ្រូ: នៅក្នុងកាសែតខ្លះ ដូចជាកាសែតកម្ពុជានិងប៊ុលេតាំងនៃទីភ្នាក់ងារសារពត៌មានខ្មែរជាតិផង គេមានចុះកម្មវិធីទូរទស្សន៍។

Teacher: In some newspapers, such as the newspaper Kampuchea and the Bulletin of Agence Khmere Presse, they publish the TV programs.

សិស្ស: ខ្ញុំចូលចិត្តមើលកាសែតកម្ពុជានិងប៊ុលេតាំងនៃភ្នាក់ងារសារពត៌-

Student: I like to read the newspaper Kampuchea and the Bulletin of Agence Khmere

	មានវិទ្យុ ព្រោះគេមានចុះកម្មវិធីទូរទស្សន៍ ។	Presse because they publish the TV programs.
1.	នៅក្នុងកាសែតខ្លះដូចជាកាសែតវ៉ាស៊ីនតោនប៉ុស្តិ៍ នឹងស្តា ជាដើម គេមានចុះកម្មវិធីកីឡា ។	ខ្ញុំចូលចិត្តមើលកាសែតវ៉ាស៊ីនតោនប៉ុស្តិ៍ នឹងស្តា ព្រោះគេមានចុះកម្មវិធីកីឡា ។
2.	នៅក្នុងទស្សនាវដ្ដីខ្លះដូចជាទស្សនាវដ្ដីកម្ពុជា នឹងសើសង្គម ជាដើម គេមានចុះអំពីសេដ្ឋកិច្ចវិទូ ។	ខ្ញុំចូលចិត្តមើលទស្សនាវដ្ដីកម្ពុជា នឹងសើសង្គម ព្រោះគេមានចុះអំពីសេដ្ឋកិច្ចវិទូ ។
3.	នៅក្នុងសៀវភៅខ្លះដូចជាសៀវភៅកំណាព្យនឹងចម្រៀងជាដើម គេមិនសរសេរអំពីនយោបាយ ។	ខ្ញុំចូលចិត្តសៀវភៅកំណាព្យនឹងចម្រៀង ព្រោះគេមិនសរសេរអំពីនយោបាយ ។
4.	នៅក្នុងកាសែតខ្លះដូចជាកាសែតអ្នកជាតិនិយម នឹងវត្តភ្នំ ជាដើម គេមានចុះគំនូរកំប្លែងច្រើន ។	ខ្ញុំចូលចិត្តកាសែតអ្នកជាតិនិយម នឹងវត្តភ្នំ ព្រោះគេមានចុះគំនូរកំប្លែងច្រើន ។

Drill I. Extension

MODEL:	គ្រូ: ខ្ញុំមើលកាសែតរាល់ព្រឹក ។ (ចេញមកសាលារៀន)	Teacher: I read the paper every morning. (leave to come to school)
	សិស្ស: ខ្ញុំមើលកាសែតរាល់ព្រឹកមុនខ្ញុំចេញមកសាលារៀន ។	Student: I read the paper every morning before leaving to come to school.
1.	ខ្ញុំហាត់រាល់ថ្ងៃ ។ (កាលណាខ្ញុំចេញពីធ្វើការវិញ)	ខ្ញុំហាត់រាល់ថ្ងៃ កាលណាខ្ញុំចេញពីធ្វើការវិញ ។
2.	ខ្ញុំទិញទស្សនាវដ្ដីមើលរាល់អាទិត្យ ។ (ព្រោះខ្ញុំចង់ដឹងព្រឹត្តិការណ៍ថ្មីៗ)	ខ្ញុំទិញទស្សនាវដ្ដីមើលរាល់អាទិត្យ ព្រោះខ្ញុំចង់ដឹងព្រឹត្តិការណ៍ថ្មីៗ ។
3.	ខ្ញុំដើរទៅរៀនរាល់ថ្ងៃ ។ (ព្រោះខ្ញុំនៅមិនឆ្ងាយពីសាលាទេ)	ខ្ញុំដើរទៅរៀនរាល់ថ្ងៃ ព្រោះខ្ញុំនៅមិនឆ្ងាយពីសាលាទេ ។
4.	ខ្ញុំស្ដាប់វិទ្យុរាល់ព្រឹក ។ (ដើម្បីឲ្យចេះនិយាយខ្មែរបានល្អ)	ខ្ញុំស្ដាប់វិទ្យុរាល់ព្រឹកដើម្បីឲ្យចេះនិយាយខ្មែរបានល្អ ។

UNIT 88

BASIC DIALOGUE

	John	
1.	លោកដឹងទេ កាសែតខ្មែរគេបោះពុម្ពផ្សាយ១លើកៗប៉ុន្មានច្បាប់?	Do you konw how many copies of each issue a Cambodian newspaper prints?
	Sarom	
2.	ខ្ញុំមិនដឹងប្រាកដទេ ប្រហែលរវាង ៨០០០, ៩០០០ យ៉ាងតិច។	I don't know for sure, maybe between eight and nine thousand at least.
3.	ពីដើមមនុស្សនៅខេត្តក្រៅមិនសូវអានកាសែតទេ។ គេច្រើនតែស្ដាប់ពត៌មានតាមវិទ្យុ។	Formerly, the people in the outer provinces didn't read papers much; for the most part they only listened to news on the radio.
4.	ឥឡូវគេមានមន្ទីរឃោសនាការច្រើន ហើយមានអ្នកនិយមមើលកាសែតកាន់តែច្រើនឡើង។	Now, they have many information centers, and the number of people who like to read newspapers is getting larger.
	John	
5.	តាមខ្ញុំស្មានវិទ្យុជាគ្រឿងប្រដាប់ផ្សាយដំណឹងសំខាន់ណាស់ហើយរហ័សផង។	I think radio is a very important tool for broadcasting news, and it's quick too.
	Sarom	
6.	បាទ វិទ្យុមានប្រយោជន៍ណាស់ នៅស្រុកណាក៏ដូចស្រុកណាដែរ ព្រោះគេអាចដឹងដំណឹងភ្លាមៗបានទោះគេនៅឆ្ងាយពីទីក្រុងក៏ដោយ។	The radio is very useful. Every country is the same, because (people) can know the news immediately even though they live far from the cities.
	John	
7.	បាទ អញ្ចឹងហើយៗជាពិសេសអ្នកស្រែចំការ មិនអាចចំណាយលុយទិញកាសែតទេ។ គេទៅស្ដាប់វិទ្យុនៅផ្ទះជិតខាងដែលមានវិទ្យុឬនៅក្រសួងឃោសនាការ។	And the peasants especially don't have to spend and buy papers. They can hear the radio at the houses of neighbors who have radios or at the Ministry of Information.

Sarom

8. ឥឡូវដូចលោកជ្រាបស្រាប់ហើយ
វិទ្យុមិនថ្លៃដូចពីពេលមុនទេ។ គេអាច
ទិញវិទ្យុប្រើថ្មពិលបានថោក
គួរសម។

As you already know, radios are not as expensive as before. (People)can buy a battery radio rather cheaply.

John

9. ខ្ញុំឃើញអ្នកនៅជនបទប្រើ
វិទ្យុច្រើនគ្នាណាស់ ព្រោះគេ
អាចទិញបានថោកគួរសម ហើយគេ
មិនពិបាកទិញថ្មពិលទេ។

I see that villagers use radios a lot because they can buy them rather cheaply, and they don't have any difficulty buying batteries.

10. នៅស្រុកខ្មែរមានរោងចក្រធ្វើថ្ម
ពិលហើយមែនទេ?

There is a factory making batteries, isn't there?

Sarom

11. បាតសព្វថ្ងៃនេះយើងមានថ្មពិល
គ្រប់គ្រាន់ហើយ។

These days we have enough batteries.

John

12. នេះជាការល្អមួយ គួរឲ្យសរសើរ
ពីមុន ពីដើមខ្មែរទិញរបស់ប្រើប្រាស
ពីបរទេសស្ទើរតែគ្រប់យ៉ាង។

That's very good. Before,Cambodians bought almost all their goods from abroad.

DRILLS

Drill A. Substitution

1.	គេចង់បោះពុម្ពឱ្យពយសៀវភៅនេះប៉ុន្មានក្បាល?	How many copies of this book do they want to print?
2.	គេចង់បោះពុម្ពអត្ថបទនេះប៉ុន្មានសន្លឹក?	How many copies of this article do they want to print?
3.	គេចង់បោះពុម្ពរឿងនេះប៉ុន្មានច្បាប់?	How many volumes of this story do they want to print?
4.	គេចង់បោះពុម្ពទស្សនាវដ្ដីនេះប៉ុន្មានក្បាល?	How many copies of this magazine do they want to print?
5.	គេចង់បោះពុម្ពកាសែតនេះប៉ុន្មានដង?	How many times do they want to print this newspaper?
6.	គេចង់បោះពុម្ពសៀវភៅនេះប៉ុន្មានដង?	How many times do they want to print this book?
7.	គេចង់បោះពុម្ពដំណឹងនេះប៉ុន្មានសន្លឹក?	How many sheets of this news story do they want to print?
8.	គេចង់បោះពុម្ពរឿងនេះប៉ុន្មានដង?	How many times do they want to print this story?

Drill B. Substitution

1.	ឥឡូវគេមានវិទ្យុស្ដាប់ស្ទើរតែគ្រប់គ្នា បើមិនដូច្នេះទេគេទៅស្ដាប់នៅមន្ទីរឃោសនាការ។	Now almost everyone has a radio to listen to; if not, he goes to listen at the information kiosk.
2.	ឥឡូវគេមានវិទ្យុស្ដាប់ស្ទើរតែគ្រប់គ្នា បើមិនដូច្នេះទេគេទៅស្ដាប់ឯសាលាស្រុក។	Now almost everyone has a radio to listen to; if not, he goes to listen at the sala srok (headquarters of the srok).
3.	ឥឡូវគេមានកង់ស្ទើរតែគ្រប់គ្នា បើមិនដូច្នេះទេគេទៅសាលាតាមស៊ីក្លូ ឬឡានឈ្នួល។	Now almost everyone has a bicycle; if not, he goes to school by cyclo or bus.
4.	ឥឡូវគេមានសៀវភៅមើលស្ទើរតែគ្រប់គ្នា បើមិនដូច្នេះទេគេទៅមើលឯបណ្ណាល័យ។	Now almost everyone has books to read; if not, he goes to read at the library.
5.	ឥឡូវគេមានការធ្វើស្ទើរតែគ្រប់គ្នា បើមិនដូច្នេះទេគេទៅសុំការធ្វើឯក្រសួងការងារ។	Now almost everyone has work to do; if not, he goes to ask for work at the Ministry of Labor.
6.	ឥឡូវគេមានខ្មៅដៃស្ទើរតែគ្រប់គ្នា បើមិនដូច្នេះទេគេទៅសុំពីស្មៀន។	Now almost everyone has pencils; if not, he goes to ask the clerk.
7.	ឥឡូវគេមានទូរសព្ទស្ទើរតែគ្រប់គ្នា បើមិនដូច្នេះទេគេទៅសុំឲ្យគេដាក់។	Now almost everyone has telephones; if not, he goes to ask for them to be installed.

Drill C. Substitution

1.	គេមានរោងចក្រដំឡើងប៉ុស្តិ៍វិទ្យុត្រង់ស៊ីស្ទ័រនៅភ្នំពេញ។	They have factories to assemble transistor radios in Phnom Penh.
2.	គេមានរោងចក្រដំឡើងតួឡាននៅភ្នំពេញ។	They have factories to assemble auto bodies in Phnom Penh.
3.	គេមានរោងចក្រដំឡើងម៉ូតូនៅភ្នំពេញ។	They have factories to assembe motos (motor scooters) in Phnom Penh.
4.	គេមានរោងចក្រដំឡើងគ្រឿងម៉ាស៊ីនផ្សេងៗនៅភ្នំពេញ។	They have factories to assemble various machine parts in Phnom Penh.
5.	គេមានរោងចក្រដំឡើងគ្រឿងអគ្គិសនីនៅភ្នំពេញ។	They have factories to assemble electrical appliances in Phnom Penh.
6.	គេមានរោងចក្រដំឡើងម៉ាស៊ីនឡាននៅភ្នំពេញ។	They have factories to assemble automobile motors in Phnom Penh.

Drill D. Double Substitution

1.	ថ្មពិលក៏ថោក វិទ្យុក៏ថោកព្រោះគេធ្វើនៅក្នុងស្រុកទាំងអស់។	Batteries are cheap and radios are cheap, because they're all made in the country.
2.	ថ្មពិលក៏ថោក ក្រដាសក៏ថោកព្រោះគេធ្វើនៅក្នុងស្រុកទាំងអស់។	Batteries are cheap and paper is cheap, because they're all made in the country.
3.	ស៊ីម៉ង់ក៏ថោក ក្រដាសក៏ថោកព្រោះគេធ្វើនៅក្នុងស្រុកទាំងអស់។	Cement is cheap and paper is cheap, because it's all made in the country.
4.	ស៊ីម៉ង់ក៏ថោក ក្តារបន្ទះក៏ថោកព្រោះគេធ្វើនៅក្នុងស្រុកទាំងអស់។	Cement is cheap and plywood is cheap, because it's all made in the country.
5.	ស្រាក៏ថោក ក្តារបន្ទះក៏ថោកព្រោះគេធ្វើនៅក្នុងស្រុកទាំងអស់។	Liquor is cheap and plywood is cheap, because it's all made in the country.
6.	ស្រាក៏ថោក កង់ឡានក៏ថោកព្រោះគេធ្វើនៅក្នុងស្រុកទាំងអស់។	Liquor is cheap and tires are cheap, because they're all made in the country.
7.	កែវក៏ថោក កង់ឡានក៏ថោកព្រោះគេធ្វើនៅក្នុងស្រុកទាំងអស់។	Glassware is cheap and tires are cheap, because they're all made in the country.
8.	កែវក៏ថោក ក្រណាត់ក៏ថោកព្រោះគេធ្វើនៅក្នុងស្រុកទាំងអស់។	Glassware is cheap and textiles are cheap, because they're all made in the country.

Drill E. Variable Simple Substitution

1.	អ្នកនៅស្រុកស្រែចំការអាចទៅមើលកាសែតនៅមន្ទីរឃោសនាការឬសាលាឃុំ។	People who live in the countryside can go read newspapers in the information kiosks or in the sala khum (headquarters of the khum).
2.	អ្នកនៅស្រុកស្រែចំការអាចទៅមើលកាសែតនៅមន្ទីរឃោសនាការឬសាលាស្រុក។	People who live in the countryside can go read newspapers in the information kiosks or in the sala srok.
3.	អ្នកនៅស្រុកស្រែចំការអាចទៅមើលកាសែតនៅមន្ទីរឃោសនាការបណ្ណាល័យស្រុក។	People who live in the countryside can go read newspapers in the information kiosks or in the library of the srok.
4.	អ្នកនៅស្រុកស្រែចំការអាចទៅខ្ចីកាសែតនៅមន្ទីរឃោសនាការឬបណ្ណាល័យស្រុក។	People who live in the countryside can go borrow newspapers in the information kiosks or at the library of the srok.
5.	អ្នកនៅស្រុកស្រែចំការអាចទៅខ្ចីទស្សនាវដ្តីនៅមន្ទីរឃោសនាការឬបណ្ណាល័យស្រុក។	People who live in the countryside can go borrow magazines at the information kiosks or at the library of the srok.
6.	អ្នកនៅទីជនបទអាចទៅខ្ចីទស្សនាវដ្តីនៅមន្ទីរឃោសនាការឬបណ្ណាល័យស្រុក។	People who live in remote villages can go borrow magazines at the information kiosks or at the library of the srok.
7.	អ្នកនៅជិតសាលាស្រុកអាចទៅខ្ចីទស្សនាវដ្តីនៅមន្ទីរឃោសនាការឬបណ្ណាល័យស្រុក។	People who live near the sala srok can go borrow magazines at the information kiosks or at the library of the srok.
8.	ប្រជាជនដែលរស់នៅជិតសាលាស្រុកអាចទៅខ្ចីទស្សនាវដ្តីនៅមន្ទីរឃោសនាការឬបណ្ណាល័យស្រុក។	People who live near the sala srok can go borrow magazines at the information kiosks or at the library of the srok.

Drill F. Response

MODEL:	គ្រូៈ អ្នកនៅទីក្រុងច្រើនបានដំណឹងតាមអី?(វិទ្យុ ទីវី និងកាសែត)	Teacher:	For the most part how do people who live in the cities get their news? (radio, TV and newspapers)
	សិស្សៈ អ្នកនៅទីក្រុងច្រើនបានដំណឹងតាមវិទ្យុ ទីវី និងកាសែត។	Student:	For the most part, people who live in the cities get their news by radio, TV and newspapers.

1.	អ្នកនៅស្រុកស្រែចំការច្រើនបានដំណឹងតាមអី?(វិទ្យុ)	អ្នកនៅស្រុកស្រែចំការច្រើនបានដំណឹងតាមវិទ្យុ។
2.	អ្នកនៅឆ្ងាយពីភ្នំពេញច្រើនធ្វើដំណើរទៅភ្នំពេញតាមអី?(តាមឡានឈ្នួល)	អ្នកនៅឆ្ងាយពីភ្នំពេញធ្វើដំណើរទៅភ្នំពេញតាមឡានឈ្នួល។

3. អ្នកដែលនៅជិតភ្នំពេញច្រើនទៅធ្វើការតាមអ្វី? (កង់ និងឡាន)	អ្នកដែលនៅជិតភ្នំពេញច្រើនទៅធ្វើការតាមកង់និងឡាន។
4. កូនសិស្សច្រើនទៅរៀនតាមអ្វី? (កង់)	កូនសិស្សច្រើនទៅរៀនតាមកង់។
5. បើគេចង់ទៅលេងក្រចេះ គេអាចទៅតាមអ្វី? (កប៉ាល់)	បើគេចង់ទៅលេងក្រចេះ គេអាចទៅតាមកប៉ាល់។

Drill G. Response

MODEL:	គ្រូៈ នៅមន្ទីរឃោសនាការគេចែកកាសែតឲ្យប្រជារាស្ត្រទេ? (រូបថត និងប៊ុល្លេតាំង)	Teacher: In the information kiosks do they distribute newspapers to the people?
	សិស្សៈ បាទទេ គេមិនចែកកាសែតឲ្យប្រជារាស្ត្រទេ តែគេអាចឲ្យរូបថតនិងប៊ុល្លេតាំងខ្លះបាន។	Student: No, they don't distribute newspapers to the people, but they can give them some pictures and bulletins.

1. នៅសាលារៀននេះគេចែកសៀវភៅសរសេរឲ្យកូនសិស្សទេ? (សៀវភៅមើល និងប៊ិច)	បាទគេមិនចែកសៀវភៅសរសេរឲ្យកូនសិស្សទេ តែគេអាចចែកសៀវភៅមើលនិងប៊ិចឲ្យខ្លះបាន។
2. នៅសាលាឃុំគេចែកកាសែតឲ្យអ្នកស្រុកទេ? (ខ្ចីកាសែតនិងទស្សនាវដ្តី)	បាទទេ គេមិនចែកកាសែតឲ្យអ្នកស្រុកទេ តែគេអាចឲ្យខ្ចីកាសែតនិងទស្សនាវដ្តីខ្លះបាន។
3. នៅកន្លែងនោះគេចែកម្ហូបឲ្យអ្នកក្រទេ? (ខោអាវ និងលុយ)	បាទទេ គេមិនចែកម្ហូបឲ្យអ្នកស្រុកទេ តែគេអាចឲ្យខោអាវនិងលុយខ្លះបាន។
4. នៅក្រសួងលោកគេចែកទស្សនាវដ្តីឲ្យអ្នកធ្វើការទេ? (ខ្ចីមើល)	បាទទេ គេមិនចែកទស្សនាវដ្តីឲ្យអ្នកធ្វើការទេ តែគេអាចឲ្យខ្ចីមើលខ្លះបាន។
5. នៅបណ្ណាល័យគេចែកសៀវភៅឲ្យអ្នកស្រុកទេ? (ខ្ចីយកទៅផ្ទះ)	បាទទេ គេមិនចែកសៀវភៅឲ្យអ្នកស្រុកទេ តែគេអាចឲ្យខ្ចីយកទៅផ្ទះខ្លះបាន។

Drill H. Expansion

1. ប្រជារាស្ត្រខ្មែរអាចទៅមន្ទីរឃោសនាការ	The Cambodian people can go to information kiosks.
2. ឥឡូវប្រជារាស្ត្រខ្មែរអាចទៅមន្ទីរឃោសនាការ	Now the Cambodian people can go to information kiosks.
3. ឥឡូវប្រជារាស្ត្រខ្មែរអាចទៅមន្ទីរឃោសនាការឬទៅបណ្ណាល័យ	Now the Cambodian people can go to information kiosks or libraries.
4. ឥឡូវប្រជារាស្ត្រខ្មែរអាចទៅមន្ទីរឃោសនាការឬបណ្ណាល័យដើម្បីមើលសៀវភៅ។	Now the Cambodian people can go to information kiosks or libraries in order to read books.

5.	ឥឡូវប្រជារាស្ត្រខ្មែរអាចទៅមន្ទីរឃោសនាការឬបណ្ណាល័យដើម្បីមើលសៀវភៅកាសែតឬទស្សនាវដ្តី	Now the Cambodian people can go to information kiosks or libraries in order to read books newspapers, and magazines.
6.	ឥឡូវប្រជារាស្ត្រខ្មែរអាចទៅមន្ទីរឃោសនាការឬបណ្ណាល័យដើម្បីមើលសៀវភៅកាសែតឬទស្សនាវដ្តី ហើយនឹងស្តាប់ការផ្សាយផ្សេងៗ ។	Now the Cambodian people can go to information kiosks or libraries in order to read books, newspapers, and magazines, and listen to various broadcasts.
7.	ឥឡូវប្រជារាស្ត្រខ្មែរអាចទៅមន្ទីរឃោសនាការឬបណ្ណាល័យដើម្បីមើលសៀវភៅកាសែតឬទស្សនាវដ្តីហើយនឹងស្តាប់ការផ្សាយផ្សេងៗ តាមវិទ្យុនិងទូរទស្សន៍ ។	Now the Cambodian people can go to information kiosks or libraries in order to read books, newspapers, and magazines, and listen to various broadcasts on the radio and TV.

Drill I. Reduction

1.	ឥឡូវប្រជារាស្ត្រខ្មែរអាចទៅមន្ទីរឃោសនាការឬបណ្ណាល័យដើម្បីមើលសៀវភៅកាសែតឬទស្សនាវដ្តីហើយនឹងស្តាប់ការផ្សាយផ្សេងៗ តាមវិទ្យុនិងទូរទស្សន៍ ។	Now the Cambodian people can go to information kiosks or libraries in order to read books, newspapers, and magazines, and listen to various broadcasts on the radio and TV.
2.	ឥឡូវប្រជារាស្ត្រខ្មែរអាចទៅមន្ទីរឃោសនាការឬបណ្ណាល័យដើម្បីមើលសៀវភៅកាសែតឬទស្សនាវដ្តី ហើយនឹងស្តាប់ការផ្សាយផ្សេងៗ ។	Now the Cambodian people can go to information kiosks or libraries in order to read books, newspapers, and magazines, and listen to various broadcasts.
3.	ឥឡូវប្រជារាស្ត្រខ្មែរអាចទៅមន្ទីរឃោសនាការឬបណ្ណាល័យដើម្បីមើលសៀវភៅកាសែតឬទស្សនាវដ្តី ។	Now the Cambodian people can go to information kiosks or libraries in order to read books, newspapers, and magazines.
4.	ឥឡូវប្រជារាស្ត្រខ្មែរអាចទៅមន្ទីរឃោសនាការឬបណ្ណាល័យដើម្បីមើលសៀវភៅ ។	Now the Cambodian people can go to information kiosks or libraries in order to read books.
5.	ឥឡូវប្រជារាស្ត្រខ្មែរអាចទៅមន្ទីរឃោសនាការឬបណ្ណាល័យ	Now the Cambodian people can go to information kiosks or libraries.
6.	ឥឡូវប្រជារាស្ត្រខ្មែរអាចទៅមន្ទីរឃោសនាការ	Now the Cambodian people can go to information kiosks.
7.	ប្រជារាស្ត្រខ្មែរអាចទៅមន្ទីរឃោសនាការ	The Cambodian people can go to information kiosks.

UNIT 89

BASIC DIALOGUE

John

1. វិទ្យុលោកម៉ាកអី? — What brand is your radio?

Sarom

2. បាទ ម៉ាក សូនី ធ្វើនៅជប៉ុន — A Sony, made in Japan.

John

3. អូ ខ្ញុំមានមួយដែរ ខ្ញុំទិញនៅតូក្យូយ៉ូ ។ របស់លោកយ៉ាងម៉េច? — Ah so, I have one too. I bought it in Tokyo. What kind is yours?

Sarom

4. បាទ របស់ខ្ញុំប្រើថ្មពិលក៏បានប្រើ ភ្លើងក៏បាន ។ — Mine uses both batteries and electricity.

John

5. អូ អញ្ចឹងដូចរបស់ខ្ញុំហើយ លោកចាប់ប៉ុស្តិ៍បានច្រើនទេ? ខ្ញុំចាប់ប៉ុស្តិ៍បានច្រើនណាស់ ជាពិសេសនៅពេលយប់ ។ — Oh, like mine. Can you get a lot (on it)? I can get a lot of stations, especially at night.

Sarom

6. បាទ ខ្ញុំក៏ចាប់ប៉ុស្តិ៍បានច្រើនដែរ ។ ក្រោយពីស្តាប់កម្មវិធីខ្មែរទៅ ខ្ញុំតែងតែស្តាប់ភ្លេងផ្សេងៗខាងអឺរ៉ុប ។ — I can get a lot of stations too. Besides listening to the Cambodian programs, I always listen to different kinds of music from Europe.

John

7. ខ្ញុំចាប់បានប៉ុស្តិ៍ពីអឺរ៉ុបខ្លះមិនសូវច្បាស់ទេ ព្រោះខ្ញុំគ្មានអង្តែនខ្ពស់ ។ — I can't get European stations very clearly because I don't have a long (high) antenna.

Sarom

8. អញ្ចឹងមិនអីទេ ថ្ងៃណាលោកទិញខ្សែអង្តែនទៅ ហើយចាំខ្ញុំទៅតម្លើងជូន ។ — No problem there. Some day buy some antenna wire and wait for me to come and put it up for you.

John

9. បាទ ខ្ញុំអរគុណច្រើនណាស់បើបានលោកទៅជួយអញ្ចឹង ។ — (I'd) thank you very much, if you could come and help.

	Sarom	
10.	លោកមានដែលស្តាប់ការផ្សាយខាង ពាណិជ្ជកម្មតាមវិទ្យុទេ?	Have you ever heard the commercials?
	John	
11.	បាទខ្ញុំស្តាប់ម្តងៗដែរ តែជួនកាលខ្ញុំ មិនទាន់ទេ ពីព្រោះគេនិយាយញាប់ ពេក។	I've heard them from time to time, but some times I can't understand because they talk too fast.
	Sarom	
12.	លោកមានទូរទស្សន៍ទេ?	Do you have a T.V.?
	John	
13.	បាទខ្ញុំទើបនឹងទិញមួយពីអាទិត្យ មុន។ គ្រួសារខ្ញុំគេចូលចិត្តមើលល្ខោន ខ្មែរណាស់។	I just bought one last week. My family likes to watch Cambodian theater very much.
	Sarom	
14.	ខ្ញុំចង់ទិញមួយដែរ តែចាំមើល១ ខែ ពីរខែទៀតសិន ចាំមានលុយកាក់ បន្តិច។	I want to buy one but I'm waiting a month or two more until I have a little money.

DRILLS

Drill A. Substitution

1.	វិទ្យុខ្ញុំធំគួរសំដែរហើយអាចចាប់បានប៉ុស្តិ៍ច្រើនដែរ។	My radio is rather large and can get a lot of stations.
2.	វិទ្យុខ្ញុំមានប៉ង់ច្រើនគួរសំដែរហើយអាចចាប់បានប៉ុស្តិ៍ច្រើនដែរ។	My radio has a lot of meter bands and can get a lot of stations.
3.	វិទ្យុខ្ញុំធ្ងន់គួរសំដែរហើយអាចចាប់បានប៉ុស្តិ៍ច្រើនដែរ។	My radio is heavy and can get a lot of stations.
4.	វិទ្យុខ្ញុំមានអង់តែនវែងគួរសំដែរហើយអាចចាប់បានប៉ុស្តិ៍ច្រើនដែរ។	My radio has a long antenna and can get a lot of stations.
5.	វិទ្យុខ្ញុំតូចគួរសំដែរហើយអាចចាប់បានប៉ុស្តិ៍ច្រើនដែរ។	My radio is small and can get a lot of stations.
6.	វិទ្យុខ្ញុំល្អគួរសំដែរហើយអាចចាប់បានប៉ុស្តិ៍ច្រើនដែរ។	My radio is pretty and can get a lot of stations.
7.	វិទ្យុខ្ញុំមានសម្លេងគួរសំដែរហើយអាចចាប់បានប៉ុស្តិ៍ច្រើនដែរ។	My radio has a speaker and can get a lot of stations.
8.	វិទ្យុខ្ញុំឮច្បាស់គួរសំដែរហើយអាចចាប់បានប៉ុស្តិ៍ច្រើនដែរ។	My radio sounds clear and can get a lot of stations.

Drill B. Substitution

1.	ពេលយប់ជ្រៅខ្ញុំតែងតែបើកស្ដាប់ភ្លេងពីអឺរ៉ុប។	Late at night I always listen to music from Europe.
2.	ពេលយប់ជ្រៅខ្ញុំតែងតែបើកស្ដាប់ភ្លេងពីអាមេរិកឡាតាំង។	Late at night I always listen to music from Latin America.
3.	ពេលយប់ជ្រៅខ្ញុំតែងតែបើកស្ដាប់ភ្លេងពីប្រេស៊ីល ឬ គុយបា។	Late at night I always listen to music from Brazil or Cuba.
4.	ពេលយប់ជ្រៅខ្ញុំតែងតែបើកស្ដាប់ភ្លេងពីស្រុកឥណ្ឌា។	Late at night I always listen to music from India.
5.	ពេលយប់ជ្រៅខ្ញុំតែងតែបើកស្ដាប់ភ្លេងពីបរទេស។	Late at night I always listen to music from abroad.
6.	ពេលយប់ជ្រៅខ្ញុំតែងតែបើកសាប់ភ្លេងពីសហរដ្ឋអាមេរិក។	Late at night I always listen to music from the United States.
7.	ពេលយប់ជ្រៅខ្ញុំតែងតែបើកស្ដាប់ភ្លេងពីស្រុកបារាំង។	Late at night I always listen to music from France.

Drill C. Double Substitution

1.	ខ្ញុំមិនសូវស្ដាប់ភ្លេងប៉ុន្មានទេ ខ្ញុំច្រើនតែស្ដាប់ដំណឹង។	I don't listen to music very much; I listen to news for the most part.
2.	ខ្ញុំមិនសូវស្ដាប់វិចារណកថាប៉ុន្មានទេ ខ្ញុំច្រើនតែស្ដាប់វិជ្ជាមេផ្ទះ។	I don't listen to editorials very much; I listen to home economics for the most part.
3.	ខ្ញុំមិនសូវស្ដាប់ពត៌មានប៉ុន្មានទេ ខ្ញុំច្រើនតែមើលកាសែត។	I don't listen to news very much; I read the paper for the most part.
4.	ខ្ញុំមិនសូវស្ដាប់ភ្លេងអឺរ៉ុបប៉ុន្មានទេ ខ្ញុំច្រើនតែស្ដាប់ភ្លេងខ្មែរបុរាណ។	I don't listen to European music very much; I listen to traditional Cambodian music for the most part.
5.	ខ្ញុំមិនសូវស្ដាប់កម្មវិធីជាបារាំងប៉ុន្មានទេ ខ្ញុំច្រើនតែស្ដាប់កម្មវិធីជាអង់គ្លេស។	I don't listen to the French program, very much; I listen to the program in English for the most part.
6.	ខ្ញុំមិនសូវស្ដាប់វិទ្យុប៉ុន្មានទេ ខ្ញុំច្រើនតែមើលសៀវភៅ។	I don't listen to the radio very much; I read books for the most part.
7.	ខ្ញុំមិនសូវស្ដាប់ភ្លេងតាមវិទ្យុប៉ុន្មានទេ ខ្ញុំច្រើនតែមើលទីវី។	I don't listen to the music on the radio very much; I look at TV for the most part.
8.	ខ្ញុំមិនសូវស្ដាប់ប៉ុស្តិ៍បរទេសប៉ុន្មានទេ ខ្ញុំច្រើនតែស្ដាប់ប៉ុស្តិ៍ខ្មែរ។	I don't listen to the foreign stations very much; I listen to Cambodian stations for the most part.

Drill D. Variable Double Substitution

1.	ខ្ញុំទើបតែនឹងទិញបានវិទ្យុមួយ ឥឡូវកំពុងតែរៀបដាក់អង់តែន។	I just bought a radio, and now I'm installing the antenna.
2.	គាត់ទើបតែនឹងទិញបានទីវីមួយ ឥឡូវកំពុងតែរៀបដាក់អង់តែន។	He just bought a TV, and now I'm installing the antenna.
3.	គាត់ទើបតែនឹងទិញបានឡាន១ ឥឡូវកំពុងតែរៀបដាក់វិទ្យុ។	He just bought a car, and now I'm installing the radio.
4.	គាត់ទើបតែនឹងទិញបានផ្ទះមួយ ឥឡូវកំពុងតែរៀបដាក់តេលេហ្វូន។	He just bought a house, and now I'm installing the telephone.
5.	គាត់ទើបតែនឹងទិញបានវិទ្យុ១ ឥឡូវកំពុងតែរៀបដាក់ក្នុងបន្ទប់។	He just bought a radio, and now I'm installing it in the room.
6.	វាទើបតែនឹងទិញបានទូមួយ ឥឡូវកំពុងតែរៀបដាក់ក្នុងបន្ទប់។	He just bought a wardrobe, and now I'm installing it in the room.
7.	វាទើបនឹងទិញបានទូរទស្សន៍១ ឥឡូវកំពុងតែរៀបដាក់ក្នុងបន្ទប់ទទួលភ្ញៀវ។	He just bought a TV, and now I'm installing it in the living room.

Drill E. Multiple Substitution

1.	ខ្ញុំខំស្ដាប់គេនិយាយខ្មែរតាមវិទ្យុតែ ខ្ញុំស្ដាប់មិនសូវទាន់ព្រោះនិយាយញាប់ ពេក។	I try to listen to them speaking Cambodian on the radio, but I still don't understand much because they talk too fast.
2.	ខ្ញុំខំស្ដាប់គេនិយាយចិនតាមតេឡេហ្វូន តែខ្ញុំស្ដាប់មិនសូវទាន់ព្រោះគេនិយាយមិន ច្បាស់។	I try to listen to them speaking Chinese on the telephone, but I still don't understand much because they talk too unclearly.
3.	ខ្ញុំខំស្ដាប់គេនិយាយអង់គ្លេសតាមទីវីតែខ្ញុំ ស្ដាប់មិនសូវទាន់ព្រោះគេនិយាយញាប់។	I try to listen to them speaking English on the TV, but I still don't understand much because they talk too fast.
4.	ខ្ញុំខំស្ដាប់គេនិយាយបារាំងតាមវិទ្យុតែខ្ញុំ ស្ដាប់មិនសូវទាន់ព្រោះឮមិនល្អ។	I try to listen to them speaking French on the radio, but I still don't understand much because I can't hear well.
5.	ខ្ញុំខំស្ដាប់គេនិយាយអេស្ប៉ាញ៉ុលតាមវិទ្ យុតែខ្ញុំស្ដាប់មិនសូវបានព្រោះគេនិយា- យញាប់ណាស់។	I try to listen to them speaking Spanish on the radio, but I still don't understand much because they talk very fast.
6.	ខ្ញុំខំស្ដាប់គេនិយាយយួនតាមខ្សែអាត់ តែខ្ញុំស្ដាប់មិនសូវបានព្រោះគេនិយាយ មិនដូចយួន។	I try to listen to them speaking Vietnamese on the tape, but I still don't understand much because they talk unlike Vietnamese.
7.	ខ្ញុំខំស្ដាប់គេនិយាយខ្មែរតាមទីវីតែខ្ញុំស្ដា- ប់មិនសូវបានព្រោះគេនិយាយពាក្យច្រើន ខ្ញុំមិនយល់។	I try to listen to them speaking Cambodian on the TV, but I still don't understand much because they speak a lot of words I don't understand.
8.	ខ្ញុំខំស្ដាប់គេនិយាយអង់គ្លេសតាមថាសចំ- រៀងតែខ្ញុំស្ដាប់មិនសូវបានព្រោះគេនិយា- យមិនដូចខ្ញុំធ្លាប់ឮ។	I try to listen to them speaking English on records, but I still don't understand much because they speak in a way I'm not used to hearing.

Drill F. Equivalence

MODEL:	គ្រូ: ខ្ញុំស្ដាប់វិទ្យុម្ដងៗដែរកាលណាខ្ញុំ មិនរវល់។	Teacher:	I listen to the radio from time to time when I'm not busy.
	សិស្ស: ជួនកាល បើខ្ញុំមិនរវល់ ខ្ញុំស្ដាប់ វិទ្យុដែរ។	Student:	Sometimes, if I'm not busy, I listen to the radio.

1.	ខ្ញុំមើលទីវីម្ដងៗដែរកាលណាខ្ញុំមិន អស់កំឡាំង។	ជួនកាល បើខ្ញុំមិនអស់កំឡាំង ខ្ញុំមើល ទីវីដែរ។
2.	ខ្ញុំទៅស្ដាប់ភ្លេងម្ដងៗដែរ កាលណាខ្ញុំដឹងថា មានវង់ភ្លេងល្អ។	ជួនកាល បើខ្ញុំដឹងថាមានវង់ភ្លេងល្អ ខ្ញុំ ទៅស្ដាប់ភ្លេងដែរ។

3.	គាត់ឲ្យកូនគាត់ទៅមើលកុនម្ដងៗដែរ កាលណាគាត់អាចទៅផ្ទះបាន។	ជួនកាល បើគាត់អាចទៅផ្ទះបាន គាត់ឲ្យកូនគាត់ទៅមើលកុនដែរ។
4.	វាទៅបណ្ណាល័យម្ដងៗដែរ កាលណាវាត្រូវខ្ចីសៀវភៅ។	ជួនកាល បើវាត្រូវខ្ចីសៀវភៅ វាទៅបណ្ណាល័យដែរ។
5.	ខ្ញុំទៅទាត់បាល់ម្ដងៗដែរ កាលណាខ្ញុំមានកម្លាំង។	ជួនកាល បើខ្ញុំមានកម្លាំង ខ្ញុំទៅទាត់បាល់ដែរ។

Drill G. Transformation

MODEL:	គ្រូៈ វិទ្យុលោកប្រើភ្លើងមែនទេ? (ថ្មពិល)	Teacher: Your radio runs on electricity doesn't it? (batteries)
	សិស្សៈ វិទ្យុលោកប្រើភ្លើងក៏បានថ្មពិលក៏បានមែនទេ?	Student: Your radio uses either electricity or batteries doesn't it?
1.	ទីវីលោកប្រើថ្មពិលមែនទេ? (ភ្លើង)	ទីវីលោកប្រើថ្មពិលក៏បាន ប្រើភ្លើងក៏បានមែនទេ?
2.	ឡានលោកប្រើសាំងធម្មតាមែនទេ? (សាំងល្អបំផុត)	ឡានលោកប្រើសាំងធម្មតាក៏បានសាំងល្អបំផុតក៏បានមែនទេ?
3.	លោកអញ្ជើញទៅឥឡូវបានមែនទេ? (បន្តិចទៀត)	លោកអញ្ជើញទៅឥឡូវក៏បាន បន្តិចទៀតក៏បាន មែនទេ?
4.	លោកបើកបានតែឡានតូចៗមែនទេ? (ឡានធំៗ)	លោកបើកឡានតូចៗក៏បាន ធំៗក៏បាន មែនទេ?
5.	គាត់ចង់ឲ្យលោកទៅឥឡូវមែនទេ? (ថ្ងៃស្អែក)	គាត់ចង់ឲ្យលោកឥឡូវក៏បាន ស្អែកក៏បាន មែនទេ?

Drill H. Expansion

1.	ខ្ញុំមិនបានទិញវិទ្យុទេ។	I didn't buy a radio.
2.	កាលខ្ញុំទៅហុងកុង ខ្ញុំមិនបានទិញវិទ្យុទេ។	When I was in Hong Kong, I didn't buy a radio.
3.	ខែមុន កាលខ្ញុំទៅហុងកុង ខ្ញុំមិនបានទិញវិទ្យុទេ។	Last month when I was in Hong Kong, I didn't buy a radio.
4.	ខែមុនកាលខ្ញុំទៅហុងកុងខ្ញុំមិនបានទិញវិទ្យុទេព្រោះខ្ញុំមានអីវ៉ាន់ច្រើន។	Last month when I was in Hong Kong, I didn't buy a radio because I had a lot of things.
5.	ខែមុនកាលខ្ញុំទៅហុងកុងខ្ញុំមិនបានទិញវិទ្យុទេព្រោះខ្ញុំមានអីវ៉ាន់ឯទៀតច្រើន។	Last month when I was in Hong Kong, I didn't buy a radio because I had a lot of other things.
6.	ខែមុនកាលខ្ញុំទៅហុងកុងខ្ញុំមិនបានទិញវិទ្យុទេព្រោះខ្ញុំមានអីវ៉ាន់ឯទៀតច្រើន ហើយខ្ញុំគិតថា	Last month when I was in Hong Kong, I didn't buy a radio because I had a lot of other things and I thought

7. ខែមុនកាលខ្ញុំនៅហុងកុងខ្ញុំមិនបានទិញវិទ្យុទេ ព្រោះខ្ញុំមានអីវ៉ាន់ឯទៀតច្រើន ហើយគិតថាខ្ញុំអាចទិញវិទ្យុដែលគេធ្វើនៅភ្នំពេញបានថោកជាង។	Last month when I was in Hong Kong, I didn't buy a radio because I had a lot of other things and I thought I could buy a radio made in Phnom Penh cheaper.

Drill I. Reduction

1. ខែមុនកាលខ្ញុំនៅហុងកុងខ្ញុំមិនបានទិញវិទ្យុទេ ព្រោះខ្ញុំមានអីវ៉ាន់ឯទៀតច្រើនហើយខ្ញុំគិតថាខ្ញុំអាចទិញវិទ្យុដែលគេធ្វើនៅភ្នំពេញបានថោកជាង។	Last month when I was in Hong Kong, I didn't buy a radio because I had a lot of other things and I thought I could buy a radio made in Phnom Penh cheaper.
2. ខែមុនកាលខ្ញុំនៅហុងកុងខ្ញុំមិនបានទិញវិទ្យុទេ ព្រោះខ្ញុំមានអីវ៉ាន់ឯទៀតច្រើនហើយខ្ញុំគិតថា	Last month when I was in Hong Kong, I didn't buy a radio because I had a lot of other things and I thought
3. ខែមុនកាលខ្ញុំនៅហុងកុងខ្ញុំមិនបានទិញវិទ្យុទេព្រោះខ្ញុំមានអីវ៉ាន់ឯទៀតច្រើន។	Last month when I was in Hong Kong, I didn't buy a radio because I had a lot of other things.
4. ខែមុនកាលខ្ញុំនៅហុងកុងខ្ញុំមិនបានទិញវិទ្យុទេព្រោះខ្ញុំមានអីវ៉ាន់ច្រើន។	Last month when I was in Hong Kong. I didn't buy a radio because I had a lot of things.
5. ខែមុនកាលខ្ញុំនៅហុងកុងខ្ញុំមិនបានទិញវិទ្យុទេ។	Last month when I was in Hong Kong, I didn't buy a radio.
6. កាលខ្ញុំនៅហុងកុងខ្ញុំមិនបានទិញវិទ្យុទេ។	When I was in Hong Kong, I didn't buy a radio.
7. ខ្ញុំមិនបានទិញវិទ្យុទេ។	I didn't buy a radio.

UNIT 90

NARRATION

1. នៅប្រទេសកម្ពុជាមានកាសែតច្រើនគួរសំដែរ។
2. កាសែតទាំងនោះខ្លះចេញរាល់ថ្ងៃ ខ្លះចេញរាល់អាទិត្យ។
3. គេមានចេញជាភាសាខ្មែរ បារាំង ចិននិងយួន។
4. កាសែតសរសេរជាអង់គ្លេសមិនទាន់មានទេ តែមានទស្សនាវដ្ដីជាភាសាអង់គ្លេសដែរ។
5. កាសែតខ្លះមានច្រើនទំព័រ ខ្លះទៀតមានតិចជាង១០ទំព័រ។
6. គេលក់មិនថ្លៃប៉ុន្មានទេ ពីប្រាំរៀលទៅ១៥រៀលឬ២០រៀល។
7. កាសែតធំជាងគេគឺកាសែតអ្នកជាតិនិយម។
8. នៅក្នុងកាសែតនេះគេនិយាយអំពីសកម្មភាពផ្សេងៗនៅក្នុងស្រុកហើយនិងអំពីវប្បធម៌
និងច្បាប់ទំលាប់ខ្មែរ។
9. គេមានទំព័រវិចារណកថាដែលគេសរសេរជាខ្មែរនិងបារាំង។
10. ទំព័រឯទៀតស្ដីអំពី កសិកម្ម ពាណិជ្ជកម្ម វិទ្យាសាស្ត្រ កីឡានិងរឿងកំសាន្ត។

1. In Cambodia there are rather many newspapers.
2. Of all these papers, some are issued daily, others are issued weekly.
3. They are published in Cambodian, French, Chinese, and Vietnamese.
4. They still don't have newspapers written in English, but there are magazines in English.
5. Some papers have many pages; others don't have more than ten pages.
6. They are sold cheaply, from five riels to 15 or 20 riels.
7. The largest newspaper is Neak Cheat Niyum.
8. In this newspaper they talk about various domestic activities, culture, and Cambodian traditional law.
9. There are editorial pages written in Cambodian and French.
10. Other pages talk about agriculture, commerce, science, sports, and humorous stories.

1. កាសែតអ្នកជាតិនិយមជាកាសែតរបស់រាជការសង្គមរាស្ត្រនិយម។
2. គេលក់កាសែតនេះពាសពេញនៅក្នុងស្រុកហើយនឹងនៅក្រៅស្រុកខ្លះទៀត។
3. ជនបរទេសជាពិសេសអ្នកតំណាងប្រទេសនានាគេទិញកាសែតនេះដើម្បីមើលវិចារណកថា។
4. អ្នកខ្លះចេះមើលខ្មែរ គេទិញយកទៅមើលអំពីសកម្មភាពផ្សេងៗនៅស្រុកខ្មែរ។
5. ជនបរទេសដែលមិនចេះមើលខ្មែរគេអាចទិញកាសែតរេអាលីតេ កាំបូជីយ៉ែនមើល។ កាសែតនេះចេញជាភាសាបារាំងរាល់អាទិត្យ។
6. គេអាចមើលប៊ុលឡេតាំង (ព្រឹត្តិបត្រ) នៃទីភ្នាក់ងារសារពត៌មានខ្មែរទៀត។
7. ប៊ុលឡេតាំងនេះចេញជាភាសាបារាំងរាល់ថ្ងៃពីក្រសួងឃោសនាការជាតិ។
8. ក្នុងប៊ុលឡេតាំងនេះមានដំណឹងសព្វគ្រប់ក្នុងនិងក្រៅប្រទេសហើយមានកម្មវិធីទូរទស្សន៍ផង។
9. កាសែតកម្ពុជាចេញរាល់ថ្ងៃពីក្រសួងឃោសនាការទៀត។
10. កាសែតនេះមានដំណឹងដូចនៅក្នុងប៊ុលឡេតាំងដែរ តែសរសេរជាខ្មែរ។

1. The newspaper Neak Cheat Niyum is the newspaper of the Sangkum government.

2. They sell this newspaper everywhere inside the country and outside the country also.

3. Foreigners, especially the representatives of various countries, buy this paper to read the editorials.

4. Other people who know how to read Cambodian buy it to read about the various activities in Cambodia.

5. Foreigners who do not know how to read Cambodian can buy Realites Cambodgiennes to read. This paper is issued in French every week.

6. They can also read the bulletin of the Agence Khmere Presse.

7. This bulletin is issued daily bv the Cambodian Press Agency.

8. In this bulletin there is all kinds of news, both domestic and foreign; and there is even the television schedule.

9. The newspaper Kampuchea is issued every day from the Ministry of Information.

10. This newspaper contains news just like that in the bulletin but written in Cambodian.

1. ពីដើមនៅតាមស្រុកខេត្តគេមិនសូវនិយមអានកាសែតទេ គេច្រើនតែស្ដាប់ពត៌មានតាមវិទ្យុ។
2. ឥឡូវនេះនៅតាមទីប្រជុំជនគេមានមន្ទីរឃោសនាការ ហើយអ្នកស្រុកអាចទៅមើលកាសែតនិងស្ដាប់វិទ្យុបានតាមចិត្ត។
3. អ្នកនៅស្រុកស្រែចំការមិនសូវទិញកាសែតទេ គេច្រើនទិញវិទ្យុប្រើថ្មពិល។
4. គេអាចទិញវិទ្យុរបៀបនេះបានហើយថោកផង ព្រោះគេមានធ្វើវិទ្យុនិងថ្មពិលនៅភ្នំពេញដែរ។
5. ឥឡូវដំណឹងផ្សេងៗគេដឹងភ្លាមៗ ទោះបីគេនៅតែជនបទក៏ដោយ។
